“តាំងពីដើមដំបូងមក យើងបានទទូចនៅ ក្រុមប្រឹក្សាស្តីពី ភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ ថា តួនាទីបំពេញបន្ថែម (complementarian position) ត្រូវបានចាក់ឫសយ៉ាងរឹងមាំនៅក្នុងសិទ្ធិអំណាច និងភាពគ្រប់គ្រាន់នៃព្រះគម្ពីរ។ នៅទីនេះ លោកអ្នកនឹងរកឃើញចម្លើយចំពោះសំណួរសំខាន់ៗក្នុងទម្រង់សង្ខេបពីគំនិតដ៏ល្អបំផុតរបស់សហគមន៍ផ្សាយដំណឹងល្អចំនួនពីរនាក់។ សូមព្រះប្រើសៀវភៅនេះ ដើម្បីលើកទឹកចិត្តឲ្យមានការស្តាប់បង្គាប់ដ៏ស្មោះអស់ពីដួងចិត្ត  តាមរបៀបដែលព្រះអង្គបានរចនាឡើងយ៉ាងល្អ”។

លោក **Randy Stinson**, Provost and Senior Vice President for Academic Administration, The Southern Baptist Theological Seminary

“ដើម្បីខ្ចីប្រយោគមួយពី លោក ស៊ី.អេស. លូវីស (C. S. Lewis) គាត់ថាមានប្រភេទមួយនៃ “វេទមន្តដ៏ជ្រាលជ្រៅ” អំពីរបៀបដែលព្រះបានបង្កើតបុរស និងស្ត្រី ដែលជាអច្ឆរិយពីបុរាណ ដែលយើងមួយចំនួនក្រោយសម័យទំនើបមិនសូវឲ្យតម្លៃលើ។ តាមរយៈការរៀបចំដ៏ជាក់ស្តែងនៃសំណួរសំខាន់ទាំង៥០ លោកគ្រូ ផាបភ័រ (Piper) និងលោកគ្រូ ហ្គ្រូដឹម (Grudem) បានលើកឡើងពីអត្ថបទមួយទៅអត្ថបទមួយនៅក្នុងព្រះគម្ពីរ ដើម្បីដាស់ស្មារតី និងដួងចិត្តរបស់យើងឲ្យមានភាពស្ញប់ស្ញែងចំពោះអ្វីដែលព្រះអាទិកររបស់យើងបានធ្វើ។ ដំណោះស្រាយចំពោះសំណួរសំខាន់ៗទាំងនោះជុំវិញតួនាទីរបស់យើងនៅក្នុងក្រុមជំនុំ និងនៅផ្ទះ នឹងទាក់ទាញអ្នកអានឲ្យចូលទៅដោយត្រង់ទៅកាន់ព្រះបន្ទូលរបស់ព្រះ ដើម្បីឲ្យបានឃើញថា ពិតដូចជាព្រះបន្ទូលដែលមាននៅទីនោះមែន”។

លោកស្រី **Gloria Furman**, pastor’s wife, Redeemer Church of Dubai; author, The Pastor’s Wife and Missional Motherhood

“ខ្លឹមសារស្នូលនៃសៀវភៅនេះ គឺត្រូវការជាចាំបាច់ និងមានប្រយោជន៍ជាខ្លាំង នៅពេលដែលវាត្រូវបានបោះពុម្ពជាលើកដំបូងជិតមួយសតវត្សមុននេះ។ ក្នុងជំនាន់បច្ចុប្បន្នរបស់យើងនេះមានការភាន់ច្រឡំ និងការបំភ្លៃគួរឲ្យភ្ញាក់ផ្អើលទាក់ទងនឹងយេនឌ័រ និងអាពាហ៍ពិពាហ៍ ហេតុដូច្នេះហើយបានជាយើងត្រូវការសៀវភៅនេះច្រើនជាងពេលណាៗផ្សេងទៀត។ មានតម្រូវការដ៏ចាំបាច់សម្រាប់អ្នកដឹកនាំក្រុមជំនុំផ្សាយដំណឹងល្អ ដើម្បីនិយាយដោយប្រាជ្ញា ឲ្យបានច្បាស់លាស់ និងមិនចុះសម្រុងគ្នាជាមួយនឹងវប្បធម៌នៅជុំវិញ ប៉ុន្តែចុះសម្រុងស្របតាមព្រះគម្ពីរវិញ។ លោកគ្រូ ផាបភ័រ និងលោកគ្រូ ហ្គ្រូដឹម បានផ្ដល់នូវចម្លើយយ៉ាងច្បាស់ៗ ហើយខ្ញុំអធិស្ឋានសូមឲ្យមានការទទួលយកចម្លើយរបស់ពួកគាត់ និងមានការអនុវត្តផងដែរ ដើម្បីឲ្យសិរីល្អរបស់ព្រះត្រូវបានបង្ហាញកាន់តែខ្លាំង តាមរយៈការរចនាដ៏អស្ចារ្យរបស់ទ្រង់សម្រាប់បុរស និងស្ត្រី”។

លោក **Erik Thoennes,** Professor of Biblical and Theological Studies, Chair, Biblical and Theological Studies Theology Department, Talbot School of Theology, Biola University; Pastor, Grace Evangelical Free Church, La Mirada, California

# សំណួរសំខាន់ៗ៥០

## 50 Crucial Questions

*ការពិនិត្យមើលទូទៅលើចំណុចស្នូលអំពីភាពជា*
*បុរស និងស្ត្រី*

JOHN PIPER និង
WAYNE GRUDEM

ផ្លូវពិត

*50 Crucial Questions: An Overview of Central Concerns about Manhood and Wommanhood*

សំណួរសំខាន់ៗ៥០៖ ការពិនិត្យមើលទូទៅលើចំណុចស្នូលអំពីភាពជាបុរស និងស្ត្រី

Copyright © ២០១៦ by The Council on Biblical Manhood and Womanhood
Published by Crossway ១៣០០ Crescent Street, Wheaton, Illinois ៦០១៨៧, U.S.A.

This edition published by arrangement with Crossway.

All rights reserved.

Khmer version ©២០២៦ by Crossway

This edition in Khmer copyright ©២០២៦ by ACTION Cambodia Organization

All rights reserved.

រក្សាសិទ្ធិគ្រប់បែបយ៉ាង ©២០២៦

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ កញ្ញា គឹម បូព្រឹក

ជំនួយការបកប្រែ៖ លោក ឈាង បូរ៉ា

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ហុង សម្កុស, លោក ឡង់ គីមឡុង, លោក ឯក សត្យា, លោក ស៊ូ ទិត្យ, លោក Jeff Lai, លោកស្រី ឡូញ ស្រីរ័ត្ន, លោកស្រី ចារ ប៊ុនរី និងលោកស្រី កែវ សុធា

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វ៉ែល ណាថាន និងលោក វណ្ណដ្ឋា សុតរ៉ាប៊ី

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖ plovpitshop.com

បោះពុម្ពលើកទី១ ចំនួន ៣.០០០ ក្បាល ២០២៦ នៃគ.ស. ISBN ៩-៧៨៩៩២៤-៥៦៦២៤៣

# មាតិកា


បុព្វកថា ........................................................................................ ១៣

សេចក្តីផ្តើម........................................................................................ ១៧

ការជួយបំពេញបន្ថែម ........................................................................... ១៧

**សំណួរសំខាន់ៗ៥០**........................................................................... ២១

១. ហេតុអ្វីរាប់តួនាទីបុរស និងស្ត្រីថាមានសារៈសំខាន់ខ្លាំង? ..............................២១

២. តើលោកគ្រូមានន័យយ៉ាងណាចំពោះឃ្លា «ភាពជាអ្នកដឹកនាំរបស់ស្ត្រីមិនស្របតាមព្រះគម្ពីរនៅក្នុងក្រុមជំនុំ» (នៅក្នុងសំណួរទី១)?....................................... ២២

៣. នៅត្រង់ណានៃព្រះគម្ពីរ ដែលលោកអ្នកទទួលបានគំនិតថា មានតែបុរសៗប៉ុណ្ណោះគួរតែធ្វើជាគ្រូគង្វាល និងគ្រូចាស់ទុំរបស់ក្រុមជំនុំ? ................. ២២

៤. ចុះចំណែកឯអាពាហ៍ពិពាហ៍វិញ? តើលោកគ្រូមានន័យយ៉ាងដូចម្តេចអំពី «គំរូនៃអាពាហ៍ពិពាហ៍នានាដែលមិនបង្ហាញទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំ» (នៅក្នុងសំណួរទី១)? ........................................................................២៣

៥. តើលោកគ្រូមានន័យយ៉ាងដូចម្តេចចំពោះឃ្លា «ការចុះចូល» (នៅក្នុងសំណួរទី៤)? ........................................................................២៣

៦. តើលោកគ្រូមានន័យយ៉ាងណា នៅពេលលោកគ្រូហៅប្តីថាជា «ក្បាល» (នៅក្នុងសំណួរទី៥)? ...........................................................................២៤

៧. តើនៅកន្លែងណានៃព្រះគម្ពីរដែលលោកគ្រូទទួលបានគំនិតថា ប្តីគួរតែជាអ្នកដឹកនាំនៅក្នុងផ្ទះរបស់ផងពួកគេ? ..................................................२៤


50 Crucial Questions.indd 5 7/4/26 2:18 in the afternoon

៨. នៅពេលដែលលោកគ្រូលើកឡើងថា ប្រពន្ធមិនគួរដើរតាមប្ដីរបស់ខ្លួនចូលទៅក្នុងអំពើបាបនោះឡើយ (សំណួរទី៥) តើប្ដីនៅមានអំណាចអ្វីទៀតសល់ទេ? តើអ្នកណាជាអ្នកនិយាយថា ទង្វើអ្វីនៃការដឹកនាំរបស់ប្ដីជាអំពើបាប នៅក្នុងការបង្ហាញអំពីភាពត្រឹមត្រូវរបស់ប្រពន្ធ ដើម្បីឲ្យគាត់អាចបដិសេធមិនធ្វើតាមប្ដី?............................២៥

៩. តើលោកគ្រូមិនគិតថា ការសង្កត់ធ្ងន់ទៅលើភាពដឹកនាំ និងការចុះចូលផ្ដល់អំណាចដល់ការរាតត្បាតនៃការរំលោភបំពានលើប្រពន្ធនោះទេ?............................ ២៧

១០. ប៉ុន្តែ លោកគ្រូមិនជឿលើឃ្លា «ការចុះចូលនឹងគ្នាទៅវិញទៅមក» ដែលសាវ័ក ប៉ុលហាក់បីដូចជាបានបង្រៀននៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ («ការចំណុះនឹងគ្នាទៅវិញទៅមក») ទេឬអី? ..........................................................២៨

១១. ប្រសិនបើពាក្យ «ក្បាល» មានន័យថាជា «ប្រភព» នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២៣ («ប្ដីជាក្បាលនៃប្រពន្ធ») ដូចអ្នកប្រាជ្ញខ្លះបានលើកឡើងដូច្នេះមែន តើឃ្លានោះនឹងមិនបានផ្លាស់ប្ដូរទាំងស្រុងនូវរបៀបនៃការមើលទៅកាន់អត្ថបទព្រះគម្ពីរនេះ និងលុបបំបាត់គំនិតដែលថា ប្ដីជាអ្នកដឹកនាំនៅក្នុងផ្ទះទេឬអី? ...................... ៣០

១២. តើការសង្កត់ធ្ងន់របស់លោកគ្រូទៅលើការដឹកនាំនៅក្នុងក្រុមជំនុំ និងភាពជាអ្នកដឹកនាំ (ក្បាល) នៅក្នុងផ្ទះ ផ្ទុយពីការសង្កត់ធ្ងន់របស់ព្រះគ្រីស្ទនៅក្នុងកណ្ឌគម្ពីរ លូកា ២២:២៦ «ឯអ្នកណាដែលធំជាងគេ ក្នុងពួកអ្នករាល់គ្នា នោះត្រូវប្រព្រឹត្តដូចជាតូចជាងគេវិញ ហើយអ្នកណាដែលនាំមុខគេ នោះដូចជាអ្នកបម្រើដែរ» ទេឬអី? ... ៣៣

១៣. នៅក្នុងសំណួរទី២ និងទី៦ លោកគ្រូបាននិយាយថា ការត្រាស់ហៅមនុស្សម្នាក់មកទទួល «ទំនួលខុសត្រូវចម្បង» សម្រាប់ការដឹកនាំនៅក្នុងក្រុមជំនុំ និងផ្ទះ។ តើលោកគ្រូមានន័យយ៉ាងណាចំពោះពាក្យ «ចម្បង»?.......................................... ៣៤

១៤. ប្រសិនបើប្ដីត្រូវប្រព្រឹត្តនឹងប្រពន្ធរបស់ខ្លួនដូចព្រះគ្រីស្ទប្រព្រឹត្តនឹងក្រុមជំនុំ តើនោះមានន័យថា គាត់គួរតែគ្រប់គ្រងគ្រប់ទាំងរឿងលម្អិតទាំងអស់នៃជីវិតគាត់ ហើយនោះនាងគួរតែសុំការអនុញ្ញាតពីគាត់ជាមុន គ្រប់ទាំងការសម្រេចចិត្តមែនទេ? .............. ៣៤

១៥. តើលោកគ្រូមិនគិតថា អត្ថបទព្រះគម្ពីរទាំងនេះ គឺជាឧទាហរណ៍នៃសេចក្ដីសម្របសម្រួលបណ្ដោះអាសន្នជាមួយនឹងឋានៈបុរសជាធំ ស្របពេលដែលកម្លាំងជំរុញដ៏សំខាន់នៃបទគម្ពីរឆ្ពោះទៅរកកម្រិតនៃភាពខុសគ្នានៃតួនាទី ដោយផ្អែកទៅលើយេនឌ័រទេឬអី?......................................................................... ៣៥

១៦. តើអំណះអំណាងផ្សេងៗមិនបានធ្វើឡើង ដើម្បីការពារការដកស្ត្រីចេញពីការងារជាគ្រូគង្វាលសព្វថ្ងៃស្របគ្នាទៅនឹងអំណះអំណាងដែលគ្រីស្ទបរិស័ទធ្វើឡើង ដើម្បីការពារទាសភាពនៅក្នុងសតវត្សទី១៩ទេឬអី?..................................................៣៧

50 Crucial Questions.indd 6 7/4/26 2:18 in the afternoon

១៧. ដោយសារការបង្រៀនព្រះគម្ពីរសញ្ញាថ្មីអំពីការចុះចូលរបស់ប្រពន្ធនៅក្នុងអាពាហ៍ពិពាហ៍បានរកឃើញនៅក្នុងផ្នែកនៃបទគម្ពីរដែលគេស្គាល់ថាជា «វិន័យគ្រួសារ» (Haustafeln) ដែលត្រូវបានកាន់កាប់មួយផ្នែករប្បធម៌សតវត្សទីមួយ យើងមិនគួរទទួលស្គាល់ថា អ្វីដែលបទគម្ពីរកំពុងបង្រៀនយើងគឺមិនត្រូវអាក់អន់ចិត្តនឹងរប្បធម៌បច្ចុប្បន្នទេ ប៉ុន្តែត្រូវសមនឹងវារហូតដល់ចំណុចមួយ ហើយដូច្នេះតើត្រូវមានឆន្ទៈក្នុងការផ្លាស់ប្តូរទម្លាប់របស់យើងអំពីរបៀបដែលបុរស និងស្ត្រីមានទំនាក់ទំនងជាមួយគ្នាជាជាងកាន់ខ្ជាប់ គំរូបណ្តោះអាសន្ននៃសតវត្សទីមួយ? ............................. ៤០

១៨. តើអ្វីទៅជារបៀបនៃការរំដោះខាងឯរប្បធម៌ ដែលព្រះយេស៊ូវបានប្រព្រឹត្តនឹងមនុស្សស្រី? តើទ្រង់មិនបានចូលទៅក្នុងប្រពៃណីតាមឋានានុក្រមរបស់យើង ហើយបើកផ្លូវឲ្យស្ត្រីចូលទៅក្នុងគ្រប់តួនាទីខាងព័ន្ធកិច្ចទេឬអី?........................................៤២

១៩. តើតួនាទីដ៏សំខាន់ដែលស្ត្រីមានក្នុងកិច្ចបម្រើព័ន្ធកិច្ចជាមួយសាវ័ក ប៉ុល មិនបានបង្ហាញថា ការបង្រៀនរបស់គាត់មិនមានន័យថា ស្ត្រីគួរតែត្រូវបានដកចេញពីកិច្ចបម្រើផ្សាយទេឬអី? .......................................................................... ៤៤

២០. ប៉ុន្តែនាង ព្រីស៊ីល បានបង្រៀនលោក អាប៉ូឡូ មែនឬទេនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ១៨:២៦? ហើយនាងថែមទាំងត្រូវបានគេលើកឈ្មោះឡើងនៅមុខប្តីរបស់នាងគឺលោកអ័រគីឡា។ តើការនេះមិនបង្ហាញថា ការអនុវត្តរបស់ក្រុមជំនុំដំបូងមិនបានដកស្ត្រីចេញពីការិយាល័យនៃការបង្រៀនរបស់ពួកជំនុំទេឬអី? ............................. ៤៦

២១. តើលោកគ្រូចង់និយាយថា វាត្រឹមត្រូវក្នុងការដែលស្ត្រីបង្រៀនបុរសក្នុងកាលៈទេសៈមួយចំនួនមែនទេ?.......................................................................... ៤៨

២២. តើគ្រូគង្វាលមិនអាចអនុញ្ញាតឲ្យស្ត្រីបង្រៀនព្រះគម្ពីរដល់ក្រុមជំនុំ និងបន្ទាប់មកបន្តត្រួតពិនិត្យពេលនាងបង្រៀនបានទេមែនឬ?............................................ ៥០

២៣. តើលោកគ្រូអាចគាំទ្រស្ត្រីឲ្យធ្វើថ្លែងទំនាយក្នុងក្រុមជំនុំ តែមិនពេញចិត្តឲ្យស្ត្រីធ្វើជាគ្រូគង្វាល និងពួកចាស់ទុំបានដោយរបៀបណាទៅ? តើការថ្លែងទំនាយមិនមែនជាចំណុចស្នូលនៃតួនាទីទាំងនោះទេឬអី? ................................................ ៥០

២៤. ដូច្នេះ តើលោកគ្រូកំពុងនិយាយថា លោកគ្រូទទួលយកសេរីភាពរបស់ស្ត្រីក្នុងការថ្លែងទំនាយជាសាធារណៈ ដូចដែលបានពិពណ៌នានៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២:១៧; ២១:៩; និង ១កូរិនថូស ១១:៥ មែនឬ?................................................៥២

២៥. ដោយសារមានសេចក្ដីចែងទុកនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៤ ថា៖ «នៅក្នុងពួកជំនុំត្រូវឲ្យពួកស្រីៗនៅស្ងៀម» នោះវាហាក់បីដូចជាថា គោលជំហររបស់លោកគ្រូមិនស្របតាមព្រះគម្ពីរឡើយ ដោយសារតែកម្រិតនៃការឲ្យស្ត្រីនិយាយស្ដីដែលលោកគ្រូបានផ្ដល់ដល់មនុស្សស្រី។ តើលោកគ្រូពន្យល់ការហាមប្រាមដោយត្រង់ៗនេះចំពោះការនិយាយស្ដីរបស់ស្ត្រីយ៉ាងដូចម្ដេចទៅ? .......................................... ៥៣

២៦. តើការលើកឡើងរបស់សាវ័ក ប៉ុល ដែលថា៖ «គ្មានប្រុស និងស្រីទៀតទេ ពីព្រោះអ្នករាល់គ្នាទាំងអស់រួមមកតែមួយ នៅក្នុងព្រះគ្រីស្ទយេស៊ូវ» (កាឡាទី ៣:២៨) លុបបំបាត់យេនឌ័រថា ជាកត្តាមូលដ្ឋានក្នុងការបែងចែកតួនាទីក្នុងក្រុមជំនុំមែនទេ? ... ៥៥

២៧. តើលោកគ្រូពន្យល់យ៉ាងណាចំពោះការគាំទ្រជាក់ស្ដែងរបស់ព្រះជាម្ចាស់ចំពោះស្ត្រីក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមានតួនាទីទស្សន៍ទាយ ឬជាអ្នកដឹកនាំបាន? .......... ៥៦

២៨. តើលោកគ្រូគិតថា មនុស្សស្រីងាយចាញ់បញ្ឆោតជាងបុរសមែនឬ? ............... ៥៨

២៩. ប៉ុន្តែ ពេលមើលទៅវាហាក់បីដូចជាថាសាវ័ក ប៉ុល ពិតជាបានគិតថា នាង អេវ៉ាងាយនឹងចាញ់បញ្ឆោតជាងលោក អ័ដាម។ តើការនេះមិនធ្វើឲ្យសាវ័ក ប៉ុល ក្លាយជាអ្នកដែលមានបុរេនិច្ឆ័យទេមែនឬ? ..................................................... ៦០

៣០. ប្រសិនបើស្ត្រីមិនមានការអនុញ្ញាតឲ្យបង្រៀនបុរសជាទូទៅ និងជាផ្លូវការទេ ហេតុអ្វីបានជាមានការអនុញ្ញាតឲ្យនាងបង្រៀនក្មេងៗ ដែលជាអ្នកងាយនឹងគ្រាប់តាមអ្នកដទៃ និងទន់ខ្សោយទៅវិញ? .................................................................... ៦១

៣១. តើលោកគ្រូមិនមានកំហុសលើការជ្រើសរើសយកតែន័យត្រង់ៗមួយនេះទេឬអី នៅពេលលោកគ្រូលើកឡើងថា សេចក្ដីបង្គាប់មួយចំនួននៅក្នុងអត្ថបទមួយមានសុពលភាពជាអចិន្ត្រៃយ៍ ហើយសេចក្ដីបង្គាប់ខ្លះទៀតដូចជា «កុំឲ្យក្រេងសក់» ឬ «កុំឲ្យគ្របក្បាល» ថាមានលក្ខខណ្ឌ និងភាពមិនដាច់ខាតតាមវប្បធម៌ក្នុងនោះដែរឬទេ? ..៦២

៣២. ប៉ុន្តែតើសាវ័ក ប៉ុល មិនបានតវ៉ាសុំឲ្យមានការគ្របក្បាលសម្រាប់ស្ត្រីក្នុងការថ្វាយបង្គំដោយអំពាវនាវឲ្យផ្អែកទៅលើលំដាប់លំដោយដែលព្រះបានបង្កើតនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:១៣-១៥ ទេឬអី? ហេតុអ្វីបានជាការគ្របក្បាលមិននៅជាប់រហូតដល់សព្វថ្ងៃនេះ ខណៈពេលដែលការបង្រៀនដែលទាក់ទងទៅនឹងការចុះចូល និងការដឹកនាំនៅជាប់ដរាបដល់សព្វថ្ងៃ? ....................................................... ៦៤

៣៣. តើវាមានភាពស៊ីគ្នាយ៉ាងដូចម្ដេច ខណៈពេលដែលមានការហាមឃាត់ក្នុងការផ្ដល់តួនាទីជាពួកចាស់ទុំលើស្ត្រីៗនៅក្នុងក្រុមជំនុំទាំងឡាយរបស់យើង តែបែរជាបញ្ជូនពួកគេឲ្យចេញទៅក្នុងនាមជាបេសកជន ដើម្បីធ្វើការជាច្រើនដែលបានហាមឃាត់នៅក្រុមជំនុំខ្លួន? ........................................................................... ៦៦

៣៤. តើលោកគ្រូបដិសេធសិទ្ធិស្ត្រីក្នុងការប្រើប្រាស់អំណោយទានដែលព្រះជាម្ចាស់បានប្រទានដល់ពួកគាត់ដែរឬទេ? តើការប្រទានអំណោយទានខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់មិនមែនមានន័យថា ទ្រង់គាំទ្រការប្រើប្រាស់អំណោយទាននោះសម្រាប់ការស្ថាបនាក្រុមជំនុំទេឬអី?....................................................................៧១

៣៥. ប្រសិនបើព្រះជាម្ចាស់បានត្រាស់ហៅស្ត្រីៗឲ្យធ្វើជាគ្រូគង្វាលយ៉ាងពិតប្រាកដមែន នោះតើលោកគ្រូអាចនិយាយថា នាងមិនគួរធ្វើជាគ្រូគង្វាលបានយ៉ាងដូចម្ដេច?. ៧២

៣៦. តើសិទ្ធិអំណាចមានន័យយ៉ាងដូចម្ដេច ពេលលោកគ្រូនិយាយអំពីវាក្នុងទំនាក់ទំនងរវាងផ្ទះ និងក្រុមជំនុំ? .......................................................................៧៣

៣៧. ប្រសិនបើក្រុមជំនុំទទួលយកទម្រង់នៃការគ្រប់គ្រងក្នុងក្រុមជំនុំ ដែលក្រុមជំនុំគឺជាអំណាចខ្ពស់បំផុតនៅក្រោមព្រះគ្រីស្ទ និងព្រះគម្ពីរ ហើយមិនមែនជាពួកអ្នកចាស់ទុំ តើស្ត្រីគួរតែមានការអនុញ្ញាតឲ្យបោះឆ្នោតដែរឬទេ?....................................៧៦

៣៨. នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦:៧ សាវ័ក ប៉ុល បានសរសេរយ៉ាងដូច្នេះថា៖ «សូមជម្រាបសួរអ្នកអាន់ត្រូនីក និងអ្នកយូនាស៍ ជាញាតិខ្ញុំ គឺជាអ្នកជាប់គុកជាមួយនឹងខ្ញុំ ដែលមានកេរ្តិ៍ឈ្មោះក្នុងពួកសាវ័ក ក៏ជឿដល់ព្រះគ្រីស្ទមុនខ្ញុំដែរ»។ តើឈ្មោះ «យូនាស៍» មិនមែនជាមនុស្សស្រីទេឬអី? ហើយតើនាងមិនមែនជាសាវ័កម្នាក់ទេឬអី? ហើយតើមិនមែនមានន័យថា សាវ័ក ប៉ុល សុខចិត្តទទួលស្គាល់ថា ស្ត្រីម្នាក់អាចកាន់តំណែងដែលមានសិទ្ធិអំណាចខ្លាំងជាងបុរស ក្នុងក្រុមជំនុំដំបូងទេឬអី?..................... ៧៧

៣៩. សាវ័ក ប៉ុល ហាក់ដូចជាផ្អែកលើទំនួលខុសត្រូវចម្បងរបស់បុរសក្នុងការដឹកនាំ និងការបង្រៀនអំពីការពិតដែលថា លោក អ័ដាម ត្រូវបានបង្កើតមកមុនគេ គឺមុននាងអេវ៉ា ទៅទៀត (១ធីម៉ូថេ ២:១៣)។ តើការនេះជាអំណះអំណាងមានសុពលភាពយ៉ាងដូចម្ដេច ក្នុងកាលដែលសត្វត្រូវបានបង្កើតឡើងមុនមនុស្ស ប៉ុន្តែមិនមានទំនួលខុសត្រូវចម្បងនៅក្នុងការដឹកនាំគាត់? ......................................................... ៨៣

៤០. តើវាពិតមែនឬទេដែលថា មូលហេតុដែលសាវ័ក ប៉ុល មិនអនុញ្ញាតឲ្យស្ត្រីៗបង្រៀនគឺដោយសារតែស្ត្រីៗមិនបានទទួលការអប់រំខ្ពស់នៅក្នុងសតវត្សរ៍ទី១? ប៉ុន្តែ ហេតុផលនោះមិនត្រូវនឹងបរិបទសព្វថ្ងៃនេះទេ។ តាមពិតទៅ ដោយសារតែស្ត្រីមានការអប់រំខ្ពស់ដូចបុរសសព្វថ្ងៃនេះដែរ តើយើងមិនគួរអនុញ្ញាតឲ្យទាំងស្ត្រី និងបុរសធ្វើជាគ្រូគង្វាលបានទេឬ?......................................................................... ៨៤

៤១. ហេតុអ្វីបានជាលោកគ្រូលើកឡើងពីការស្រឡាញ់ភេទដូចគ្នា នៅពេលពិភាក្សាអំពីភាពខុសគ្នានៃតួនាទីបុរស ហើយនិងស្ត្រីនៅក្នុងផ្ទះ និងក្រុមជំនុំទៅវិញ? (ដូចសំណួរទី១) ក្រុមខាងនិកាយដំណឹងល្អស្ត្រីនិយមភាគច្រើនក៏ប្រឆាំងនឹងការស្រឡាញ់ភេទដូចគ្នាដែរ។........................................................................... ៨៦

៤២. តើលោកគ្រូដឹងដោយរបៀបណាថា ការកាត់ស្រាយបទគម្ពីររបស់លោកគ្រូមិនបានទទួលឥទ្ធិពលច្រើនពីបទពិសោធន៍ និងវប្បធម៌របស់លោកគ្រូ លើសអំពីអ្វីដែលអ្នកនិពន្ធព្រះគម្ពីរមានបំណងពិតប្រាកដនៅក្នុងការសរសេរ? ............................៩២

៤៣. ហេតុអ្វីគេអាចទទួលយកទំនុកចម្រៀង ទំនុកតម្កើងដែលស្ត្រីតែង និងណែនាំសៀវភៅដែលសរសេរឡើងដោយស្ត្រី ប៉ុន្តែមិនអនុញ្ញាតឲ្យពួកគេនិយាយរឿងដូចគ្នានេះជាសាធារណៈទៅវិញ? ........................................................................ ៩៣

៤៤. តើការផ្តល់សិទ្ធិឲ្យស្ត្រីមានមុខងារ និងតួនាទីផ្សេងៗជារឿងយុត្តិធម៌ ដែលសូម្បីតែសង្គមរបស់យើងក៏ទទួលស្គាល់នោះជារឿងធម្មតាឬ? ................................ ៩៥

៤៥. តើវាមិនពិតទេមែនទេដែលថា គេហៅព្រះជាម្ចាស់ថា «អ្នកជំនួយ» របស់យើងជាច្រើនដងនៅក្នុងព្រះគម្ពីរជាមួយនឹងពាក្យដូចគ្នាដែលគេបានប្រើ ដើម្បីពណ៌នាអំពីនាងអេវ៉ា នៅពេលដែលនាងត្រូវបានគេហៅថាជា «អ្នកជំនួយ» ដែលសមស្របសម្រាប់បុរសមែនឬ? តើវាមិនច្រានចោលការយល់ឃើញណាមួយនៃតួនាទីចុះចូលពិសេសសម្រាប់នាង ឬសូម្បីតែធ្វើឲ្យនាងមានសិទ្ធិអំណាចជាងបុរសទេឬអី?.............. ៩៩

៤៦. នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៧:៣-៥ បានចែងដោយត្រង់ៗថា «ត្រូវឲ្យប្តីប្រព្រឹត្តនឹងប្រពន្ធដោយចិត្តសប្បុរស ហើយត្រូវឲ្យប្រពន្ធប្រព្រឹត្តនឹងប្តីក៏ដូច្នោះដែរ ប្រពន្ធមិនមែនជាម្ចាស់លើរូបកាយខ្លួនឯងទេ គឺជាប្តីវិញ ហើយប្តីក៏មិនមែនជាម្ចាស់លើរូបកាយខ្លួនឯងដែរ គឺជាប្រពន្ធវិញ ដូច្នេះ កុំឲ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល ដើម្បីឲ្យបានជាទំនេរនឹងអធិស្ឋាន រួចត្រូវវិលមកនៅជាមួយវិញ ក្រែងអារក្សសាតាំងល្បួងលួងអ្នករាល់គ្នា ដោយមិនចេះអត់ទ្រាំ»។ តើការនេះមិនបង្ហាញថា សិទ្ធិអំណាចឯកតោភាគីពីប្តីខុសទេឬ? ..............................................................១០១

៤៧. ប្រសិនបើលោកគ្រូជឿថា ភាពខុសគ្នានៃតួនាទីរបស់បុរស និងស្ត្រីនៅក្នុងគ្រួសារ និងក្រុមជំនុំត្រូវបានចាក់ឫសទៅតាមលំដាប់លំដោយដែលព្រះបានបង្កើត ហេតុអ្វីបានជាលោកគ្រូមិនទទូចចង់ឲ្យមានការអនុវត្តច្បាប់នោះ នៅគ្រប់ទីកន្លែងក្នុងជីវិតលោកីយ៍ដូចដែលអ្នកនៅក្នុងផ្ទះ និងព្រះវិហារដូច្នេះដែរ? ......................................១០៣

៤៨. តើស្ត្រីដែលជាគ្រីស្ទបរិស័ទនៅលីវអាចចូលទៅក្នុងសេចក្តីអាថ៌កំបាំងនៃព្រះគ្រីស្ទ និងក្រុមជំនុំដោយរបៀបណា បាន ប្រសិនបើនាងមិនធ្លាប់ឆ្លងកាត់អាពាហ៍ពិពាហ៍ផងនោះ? ..............................................................................................១០៥

៤៩. ដោយសារតែអ្នកប្រាជ្ញខាងឯដំណឹងល្អឈានមុខជាច្រើននាក់មិនយល់ស្របចំពោះសំណួរទាំងឡាយអំពីភាពជាបុរស និងភាពជាស្ត្រី នោះតើអ្នកជឿធម្មតាម្នាក់អាចសូម្បីតែសង្ឃឹមថានឹងមានការជឿជាក់យ៉ាងច្បាស់លាស់លើសំណួរទាំងនេះដោយរបៀបណាទៅ? ...................................................................១០៦

៥០. ប្រសិនបើអត្ថបទមួយក្រុមបង្កជម្លោះយ៉ាងក្ដៅគគុក តើវាមិនមែនជាគោលការណ៍ដ៏ល្អ ទេឬនៅក្នុងការកាត់ស្រាយដែលមិនអនុញ្ញាតឲ្យពួកគេមានឥទ្ធិពលយ៉ាងសំខាន់លើ ទស្សនៈរបស់យើងចំពោះភាពជាបុរស និងស្ត្រី? ស្រដៀងគ្នានេះដែរ ដោយសារតែ មានការខ្វែងគំនិតគ្នាយ៉ាងខ្លាំងនៅក្នុងក្រុមជំនុំជុំវិញបញ្ហានៃតួនាទីបុរស និងស្ត្រី តើ យើងមិនគួរចាត់ទុករឿងនេះថា វាមានសារៈសំខាន់តិចក្នុងការកំណត់ស្តង់ដារនៃជំនឿ និងការអនុវត្តរបស់ក្រុមនិកាយ ស្ថាប័ន និងក្រុមជំនុំទេឬ? ........................ ១០៩

សេចក្ដីបន្ថែម ........................................................................... ១១៥

សេចក្ដីថ្លែងការណ៍ទីក្រុងដែនវើរស៍ស្ដីពីភាពជាស្ត្រី និងភាពជាបុរសស្របតាមព្រះគម្ពីរ ១១៥

កំណត់ចំណាំ ........................................................................... ១២១

លិបិក្រមតាមព្រះគម្ពីរ ..................................................................... ១៣៥

# បុព្វកថា

កូនសៀវភៅនេះពីដើមត្រូវបានបោះពុម្ពជា២ជំពូកនៅក្នុងសៀវភៅការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ។ យើងបានធ្វើការកែសម្រួលកូនសៀវភៅនោះរួមគ្នា និងបានសរសេរប៉ុន្មានថែមដែរ រួមទាំងជំពូកនេះផង។

សូម្បីតែនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ក៏ដោយ ក៏យើងកំពុងគ្រវីទង់ជាតិនៃការបង្រៀនអំពីបំពេញបន្ថែមស្របតាមព្រះគម្ពីរ (biblical complem-etarianism ដែលពេលនោះមិនទាន់ហៅថាដូច្នេះនៅឡើយ) ជុំវិញការជំរុញកម្រិតយេនឌ័រដែលកំពុងលេចឡើងនៃអ្វីដែលនៅពេលនោះហៅថា ការផ្សាយដំណឹងល្អបែបស្ត្រីនិយម ឬលទ្ធិសមភាពនិយម។ ក្នុងរយៈពេលជាច្រើនទសវត្សមកហើយ ការឆ្លើយតបទៅនឹងបញ្ហានៃភាពជាបុរស និងភាពជាស្ត្រី មិនមានលក្ខណៈសាមញ្ញ ឬឯកតោភាគីនោះទេ។ វាជាហេតុនាំឲ្យមានសេចក្តីអំណរ និងទុក្ខព្រួយ។

ម៉្យាងវិញទៀត វប្បធម៌របស់យើងជាទូទៅបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សឆ្ងាយពីការយល់ស្របរបស់គ្រីស្ទបរិស័ទលើអ្វីដែលត្រូវ និងខុសក្នុងបញ្ហាសីលធម៌ផ្លូវភេទ។ ចំណុចរំជើបរំជួលបានផ្លាស់ប្តូរពីការដឹកនាំរបស់បុរសទៅជាការស្រឡាញ់ភេទដូចគ្នា។ នេះមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលសម្រាប់ពួកយើងទេ ហើយលោកអ្នកអាចឃើញនូវអ្វីដែលយើងបានឃើញដោយអានសំណួរទី៤១។ ជំហានសីលធម៌ និងជំហានកាត់ស្រាយពីការបដិសេធយេនឌ័រជាកត្តាដែលគូស្វាមីភរិយាធ្វើ ដើម្បីបដិសេធវាជាកត្តាដ៏តូចតាចមួយដែលគូស្វាមីភរិយាទទួលយក។ ប្រសិនបើយេនឌ័រមិនរាប់បញ្ចូលក្នុងអ្វីដែល



50 Crucial Questions.indd 13 7/4/26 2:18 in the afternoon

ប្ដីប្រពន្ធធ្វើទេ នោះយេនឌ័រមិនរាប់បញ្ចូលថាប្ដីប្រពន្ធជានរណាទេ។ នេះហើយគឺជាចំណុចមួយដែលវប្បធម៌របស់យើងមានសព្វថ្ងៃ។

មួយទៀតសោត មានក្រុមជំនុំ និងគ្រីស្ទបរិស័ទមួយចំនួនយកព្រះគម្ពីររបស់ពួកគេយ៉ាងយកចិត្តទុកដាក់គ្រប់គ្រាន់ ដែលថាពួកគេសុខចិត្តដើរចេញពីជំហានយ៉ាងខ្លាំងជាមួយនឹងវប្បធម៌នេះ។ ពួកគេឃើញនៅក្នុងព្រះគម្ពីរអំពីរបៀបថ្មីនៃភាពជាបុរស និងភាពជាស្ត្រី ដែលមិនធ្វើឲ្យការរួមភេទមានភាពស្រពិចស្រពិល ប៉ុន្តែដាក់ភាពខុសគ្នារបស់ពួកគេនៅក្នុងពណ៌ដ៏គួរឲ្យទាក់ទាញវិញ។ ក្រុមជំនុំទាំងនេះមើលឃើញចក្ខុវិស័យដែលបំពេញបន្ថែមជាការផ្ដល់ជីវិតសម្រាប់ទាំងបុរស និងស្ត្រី។ ពួកគេគិតថា នេះជាអ្វីដែលព្រះបានបង្រៀន។ ហើយពួកគេជឿថា ព្រះជាម្ចាស់មានព្រះបញ្ញាញាណ ហើយព្រះអង្គទ្រង់ល្អ។ ព្រះតម្រិះរបស់ទ្រង់ទាក់ទងនឹងរឿងផ្លូវភេទ គឺមានភាពស្រស់ស្អាត និងស្កប់ចិត្តបំផុត។

ចំណុចសំខាន់បំផុត ការគូសបញ្ជាក់អំពីភាពខុសគ្នារវាងបុរស និងស្ត្រីនៅក្នុងសក្ដានុពលនៃអាពាហ៍ពិពាហ៍ធ្វើឲ្យព្រះគ្រីស្ទ និងក្រុមជំនុំរបស់ទ្រង់បង្ហាញដោយភាពច្បាស់លាស់បំផុត។ នៅក្នុងកណ្ឌគម្ពីរ អេភេសូរជំពូក៥ សាវ័ក ប៉ុល បានបង្ហាញអំពីអាពាហ៍ពិពាហ៍របស់បុរស និងស្ត្រីជាឧទាហរណ៍មួយអំពីទំនាក់ទំនងនៃសេចក្ដីសញ្ញារបស់ព្រះគ្រីស្ទជាមួយនឹងកូនក្រមុំរបស់ទ្រង់ គឺក្រុមជំនុំ ។ ស្វាមីត្រូវយកគំរូរបស់ទ្រង់ពីការដឹកនាំ ការការពារ និងការផ្គត់ផ្គង់ដោយមានការលះបង់ ដែលព្រះគ្រីស្ទបានប្រទានមក ហើយប្រពន្ធត្រូវយកគំរូពីការគោរពដ៏ច្បាស់លាស់ និងការចុះចូលដោយរីករាយដែលក្នុងនាមជាមនុស្សប្រោសលោះ ដើម្បីថ្វាយដល់ព្រះគ្រីស្ទ។

ជាមួយគ្នានេះដែរក្នុងទំនាក់ទំនងដែលមានសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅ និងលើកតម្កើងព្រះគ្រីស្ទនេះ ស្វាមី និងប្រពន្ធបង្កើតជាបន្ទាយនៃនគរជំនួសឲ្យមួយនៅក្នុងពិភពលោកនេះ។ នៅក្នុងនគរទាំងនេះ ដែលយើងហៅថាជា គ្រួសារពួកគេមានគោលបំណង ចិញ្ចឹមសិស្សរបស់ព្រះយេស៊ូវដែលមាន



50 Crucial Questions.indd 14 7/4/26 2:18 in the afternoon

ប្រាជ្ញាភាពក្លាហាន និងហ៊ានមានការប្រថុយ។ ហើយពួកគេអធិស្ឋានឲ្យក្រុមគ្រួសាររបស់ពួកគេក្លាយជាទីបន្ទាល់ដ៏មានឥទ្ធិពល (ក្នុងនាមជាអំបិលនៃផែនដី) ក្នុងសង្គមដែលពុកផុយនេះ។

តាំងពីដើមមក ព្រះមានព្រះទ័យឲ្យជីវិតអាពាហ៍ពិពាហ៍គឺជាការលើកតម្កើងភាពស្រស់ស្អាតនៃសេចក្តីសញ្ញារវាងព្រះ និងមនុស្ស។ ទាំងសមភាពនិយម (egalitarianism) និងអ្វីដែលហៅថា "អាពាហ៍ពិពាហ៍អ្នកស្រឡាញ់ភេទដូចគ្នា" មានប្រសិទ្ធភាពចាត់ទុកជាមោឃៈនូវរឿងប្រៀបប្រដូចអាពាហ៍ពិពាហ៍របស់ព្រះគ្រីស្ទ និងក្រុមជំនុំ។ វាគួរឲ្យរីករាយណាស់ដែលឃើញថា មានគ្រីស្ទបរិស័ទវ័យក្មេងប៉ុន្មាននាក់ដែលយល់ពីសារៈសំខាន់ខាងទ្រឹស្តីនៃអាពាហ៍ពិពាហ៍ ហើយជ្រើសរើសទទួលយកការយល់ឃើញក្នុងព្រះគម្ពីរនៃការបំពេញបន្ថែម (complementarity) រស់នៅក្នុងក្រុមជំនុំដែលរីកចម្រើន និងផ្តោតលើការចេញទៅធ្វើ បេសកកម្ម។

នៅពេលដែលមនុស្សម្នាក់ចាប់ផ្តើមទទួលយកចក្ខុវិស័យនេះយ៉ាងម៉ឺងម៉ាត់ នោះសំណួរនៃការបកស្រាយព្រះគម្ពីរ និងការអនុវត្តជាក់ស្តែងនឹងកើនឡើងជាមិនខាន។

នោះហើយជាមូលហេតុដែលយើងនិពន្ធសៀវភៅនេះឡើង។ យើងជឿថា សំណួរទាំង៥០នេះ មានភាពពាក់ព័ន្ធទៅនឹងសព្វថ្ងៃនេះដែរ។ សំណួរខ្លះទៀត មានភាពពាក់ព័ន្ធកាន់តែខ្លាំង។ ហើយយើងជឿថា ប្រសិនបើលោកអ្នកធ្វើតាមហេតុផលក្នុងព្រះគម្ពីរអំពីសំណួរទាំងនេះ នោះលោកអ្នកប្រហែលជាអាចឆ្លើយតបចំពោះអ្នកដទៃដែលកើតឡើងដោយធ្វើតាមគន្លងស្រដៀងគ្នានោះដែរ។

លើសពីនោះទៅទៀត យើងគិតថាបញ្ហានៃភាពជាបុរស និងស្ត្រីគឺជារឿងសំខាន់។ ហើយដូចដែលយើងបាននិយាយនៅក្នុងជំពូកដែលយើងបានសរសេរកាលពី២៥ឆ្នាំមុន គោលបំណង និងការអធិស្ឋានរបស់យើង គឺដើម្បីជាការល្អដល់ក្រុមជំនុំ ដល់បេសកកម្មជាសកល និងសម្រាប់ជាសិរីល្អនៃព្រះ។



50 Crucial Questions.indd 15 7/4/26 2:18 in the afternoon

# សេចក្ដីផ្ដើម

## *ការជួយបំពេញបន្ថែម*

បញ្ហាដែលយើងប្រឈមក្នុងសៀវភៅនេះ គឺរបៀបដែលបុរស និងស្ត្រីគួរមានទំនាក់ទំនងគ្នាស្របតាមព្រះគម្ពីរ។ យើងមានការព្រួយបារម្ភ ជាពិសេសអំពីរបៀបដែលពួកគេមានទំនាក់ទំនងនៅក្នុងផ្ទះ និងនៅឯក្រុមជំនុំ។ ជំហរដែលយើងទទួលយកបញ្ជាក់ពីភាពខុសប្លែកគ្នារវាងបុរស និងស្ត្រីដែលជួយបំពេញបន្ថែមគ្នា ហើយបង្ហាញអំពីផលប៉ះពាល់នៃភាពខុសគ្នាទាំងនោះចំពោះវិធីដែលបុរស និងស្ត្រីទាក់ទងគ្នាទៅវិញទៅមកតាមរបៀបដែលបំពេញគ្នាបានល្អបំផុត។

យើងកំពុងការពារនូវអ្វីដែលលោក ឡារី ក្រែប (Larry Crabb) ហៅថា “ការរីករាយនឹងភាពខុសប្លែកគ្នា” ពោលគឺ “ភេទមានភាពខុសប្លែកគ្នានៅក្នុងអ្វីដែលពួកគេជាមូលដ្ឋានដែលត្រូវបានរចនាឡើងដើម្បីផ្ដល់ឲ្យ និងអ្វីដែលនាំឲ្យពួកគេមានសេចក្ដីរីករាយបំផុតក្នុងទំនាក់ទំនងនោះ។ នៅកម្រិតដ៏ជ្រាលជ្រៅបំផុត បុរសបម្រើស្ត្រី មានលក្ខណៈខុសគ្នាពីស្ត្រីបម្រើបុរស”។[1]

យើងគាំទ្រលោក ឆក់ ខលសុន (Chuck Colson) នៅពេលដែលគាត់សោកស្ដាយចំពោះទំនោរនៃការបំផ្លាញ ដោយការលាយបញ្ចូលគ្នារវាងយេនឌ័រនៅក្នុងវប្បធម៌របស់យើង។ យើងឈរជាមួយនឹងគាត់ ពេលដែល

១ លោក ឡារី ខ្រាប បុរសនិងស្ត្រី ការរីករាយនឹងភាពខុសប្លែកគ្នា (ហ្វ្រែន រ៉ាភីតស៍ អិមអាយ៖ ហ្សូនឌីវ៉ាន់ ឆ្នាំ១៩៩១) ទំព័រ១៧៤។



50 Crucial Questions.indd 17 7/4/26 2:18 in the afternoon

គាត់និយាយថា «ព្រះបានបង្កើតមនុស្សពីរប្រភេទខុសពីគ្នា បុរស និងស្ត្រី និងភាពជាប្រុស និងភាពជាស្រី—មានតួនាទី និងសមត្ថភាពខុសគ្នាសម្រាប់ការផ្សព្វផ្សាយ និងបំប៉នពូជសាសន៍»។ យើងយល់ស្របថា «វារំលោភលើការពិតដែលជាមូលដ្ឋាននៃការបង្កើត» នៅពេលដែលអ្នកយកព័ត៌មានស្រីម្នាក់បានទាមទារចូលបន្ទប់ផ្លាស់សំលៀកបំពាក់បុរស នៅពេលដែលបុរសស្រឡាញ់ភេទដូចគ្នាយកទារកមកចិញ្ចឹម និងប្រើអាវទ្រនាប់សម្រាប់បំបៅដោះ ពេលដែលឆ្មាំពន្ធនាគារជាស្ត្រីធ្វើការឆែកឆេររាងកាយអ្នកទោសប្រុស ហើយនៅពេលដែលតារារ៉ុកដ៏ល្បីផ្លាស់ប្តូរផ្លូវភេទ។[២]

នេះជាមូលហេតុដែលយើងហៅខ្លួនយើងថាជាអ្នកបំពេញបន្ថែម (complementarians)។ ទស្សនវិស័យរបស់យើងអំពីភាពជាបុរស និងភាពជាស្ត្រីមានឥទ្ធិពលដោយចំណង់ចំណូលចិត្តចំពោះការពិត—ការពិតដ៏ស្រស់បំព្រងនៃភាពខុសគ្នាបំពេញបន្ថែម ដែលព្រះបានរចនាឡើងសម្រាប់សេចក្តីអំណររបស់យើងនៅដើមដំបូង នៅពេលដែលព្រះបានបង្កើតពួកយើងជាបុរស និងស្ត្រីដោយមានភាពស្មើគ្នាក្នុងរូបអង្គទ្រង់។

ប្រសិនបើពាក្យមួយត្រូវតែប្រើ ដើម្បីពណ៌នាអំពីគោលជំហររបស់យើង នោះយើងនឹងប្រើពាក្យថាអ្នកបំពេញបន្ថែម ពីព្រោះវាបានបង្ហាញទាំងភាពស្មើគ្នា និងអត្ថប្រយោជន៍នៃភាពខុសគ្នារវាងបុរស និងស្ត្រីផងដែរ។ យើងមិនសប្បាយចិត្តនឹងពាក្យថាប្រពៃណីនិយម (traditionalist) ទេ ព្រោះវាបង្កប់នូវឆន្ទៈមិនចង់ឲ្យព្រះគម្ពីរមានការប្រកួតប្រជែងនឹងគំរូនៃអាកប្បកិរិយាបែបប្រពៃណី ហើយយើងពិតជាបដិសេធពាក្យថា ឋានានុក្រមនិយម (hierachicalist) ព្រោះវាសង្កត់ធ្ងន់លើអំណាចដែលមានរចនាសម្ព័ន្ធខ្លាំងពេក ខណៈពេលដែលមិនផ្តល់យោបល់អំពីភាពស្មើគ្នា ឬភាពស្រស់ស្អាតនៃការពឹងពាក់គ្នាទៅវិញទៅមកឡើយ។

---

២ លោក ឆាលស៍ ដាប់បលយូ.ខូលសុន «តើការច្របល់ភេទឲ្យបញ្ចូលគ្នានាំឲ្យមានអ្វីកើតឡើង? ពិភពលោក ៥ (ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៩១), ទំព័រ១១។



50 Crucial Questions.indd 18 7/4/26 2:18 in the afternoon

មានការនិពន្ធសៀវភៅជាច្រើនលើបញ្ហានេះ រួមទាំងការស្ដារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្រប តាមព្រះគម្ពីររបស់យើងផ្ទាល់។[៣] ប៉ុន្តែមនុស្សភាគច្រើនមិនមាន ពេលអានសៀវភៅជាច្រើនលើបញ្ហាសំខាន់ៗនីមួយៗនៃជីវិតសម័យទំនើបនោះទេ។ ជារឿយៗ អ្វីដែលយើងត្រូវការគឺចម្លើយសង្ខេបចំពោះសំណួរជាក់លាក់ណាមួយ។ នេះហើយគឺជាអ្វីដែលសៀវភៅនេះមាន។

៣ សូមមើលបន្ថែមលោក Wayne Grudem, *Evangelical Feminism and Biblical Truth: An Analysis of Over 100 Disputed Questions* (Sisters, OR: Multnomah, ឆ្នាំ២០០៤; Wheaton, IL: Crossway, ឆ្នាំ២០១២); Wayne Grudem, *Evangelical Feminism: A New Path to Liberalism?* (Wheaton, IL: Crossway, ឆ្នាំ២០០៦); និងលោក John Piper, *What's the Difference? Manhood and Womanhood Defined According to the Bible* (Wheaton, IL: Crossway, ឆ្នាំ១៩៩០)។

# សំណួរសំខាន់ៗ៥០

## សំណួរទី១
## ហេតុអ្វីរាប់តួនាទីបុរស និងស្ត្រីថាមានសារៈសំខាន់ខ្លាំង?

យើងមិនគ្រាន់តែមានការព្រួយបារម្ភចំពោះអាកប្បកិរិយានៃតួនាទីរបស់បុរស និងស្ត្រីទេ ប៉ុន្តែក៏ទៅលើលក្ខណៈមូលដ្ឋាននៃភាពជាបុរស និងភាពជាស្ត្រីផ្ទាល់ផងដែរ។ សេចក្ដីពិត និងការបញ្ជាក់យ៉ាងច្បាស់នៃព្រះគម្ពីរនៅក្នុងបញ្ហានេះ គឺមានសារៈសំខាន់ណាស់ ដោយសារតែកំហុស និងការយល់ច្រឡំទៅលើអត្តសញ្ញាណភេទបាននាំឲ្យមាន (១) គំរូអាពាហ៍ពិពាហ៍ដែលមិនបានបង្ហាញទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំ[៤] (អេភេសូរ ៥:៣១-៣២) (២) ការអនុវត្តភាពជាឪពុកម្ដាយដែលមិនបានបង្ហាត់បង្រៀនក្មេងប្រុសៗឲ្យមានលក្ខណៈជាបុរស ឬក្មេងស្រីៗឲ្យមានលក្ខណៈជាស្ត្រី (៣) ទំនោរនៃការស្រឡាញ់ភេទដូចគ្នា និងការព្យាយាមបង្ហាញពីភាពត្រឹមត្រូវនៃសម្ព័ន្ធភាពនៃការស្រឡាញ់ភេទដូចគ្នា (សូមមើលសំណួរ៤១) និង (៤) គំរូនៃភាពជាអ្នកដឹកនាំរបស់ស្ត្រីមិនស្របតាមព្រះគម្ពីរនៅក្នុងក្រុមជំនុំដែលឆ្លុះបញ្ចាំង និងបង្កើនការយល់ច្រឡំទៅលើអត្ថន័យពិតនៃភាពជាបុរស និងភាពជាស្ត្រី។

អំណោយទានរបស់ព្រះជាម្ចាស់ចំពោះការបំពេញឲ្យគ្នាទៅវិញទៅមកនៃភាពជាបុរស និងភាពជាស្ត្រី គឺជាអ្វីដែលត្រូវបានលើកតម្កើងឡើងតាំងពីដើមដំបូង (លោកុប្បត្តិ ២:២៣)។ វាមានតម្លៃលើសពីការស្មាន។ ប៉ុន្តែសព្វថ្ងៃ

៤ នេះរាប់បញ្ចូលទាំងគំរូដែលកើតចេញពីការព្រងើយកន្តើយ និងការបំពានដោយទាំងប្ដី និងប្រពន្ធ។ ដូចដែលសេចក្ដីថ្លែងការណ៍នៃទីក្រុងដែនវើរស៍បានថ្លែងថា៖ «នៅក្នុងផ្ទះ សេចក្ដីស្រឡាញ់ ការដឹកនាំដ៏បន្ទាបខ្លួនរបស់ប្ដីមានទំនោរជំនួសឲ្យការត្រួតត្រា ឬអសកម្ម។ ការចុះចូលដោយដ៏ឆ្លាតវៃ មានឆន្ទៈរបស់ប្រពន្ធមានទំនោរជំនួសឲ្យការដណ្ដើមយកអំណាច ឬបម្រើ»។ គោលបំណងរបស់យើង គឺធ្វើការចេញពីភាគីទាំងសងខាង ដើម្បីលើកកម្ពស់ទំនាក់ទំនងដែលព្រះគ្រីស្ទពិតជាគាប់ព្រះទ័យឲ្យយើងមានចំពោះក្រុមជំនុំ។



50 Crucial Questions.indd 21 7/4/26 2:18 in the afternoon

នេះ វាត្រូវបានឲ្យតម្លៃតិចតួច និងកំពុងតែត្រូវបានរលាយបាត់ពីសង្គមដ៏ទាន់សម័យខ្លាំងនេះ។ យើងជឿថា អ្វីដែលជាប់ពាក់ព័ន្ធទៅនឹងចំណងមេត្រីភាពផ្លូវភេទរបស់មនុស្ស គឺមានភាពស្មុគស្មាញនៅក្នុងជីវិត ដូចដែលព្រះជាម្ចាស់សព្វព្រះទ័យឲ្យមានភាពបរិសុទ្ធសម្រាប់រាស្ត្រទ្រង់ និងសម្រាប់បេសកកម្មសង្គ្រោះរបស់ពួកគេទៅកាន់លោកីយ៍។ (សូមមើល "ហេតុផល" នៅក្នុង The Danvers Statement នៅខាងក្រោយសៀវភៅនេះ)។

## សំណួរទី២

## តើលោកគ្រូមានន័យយ៉ាងណាចំពោះឃ្លា «ភាពជាអ្នកដឹកនាំរបស់ស្ត្រីមិនស្របតាមព្រះគម្ពីរនៅក្នុងក្រុមជំនុំ» (នៅក្នុងសំណួរទី១)?

យើងត្រូវចុះចូលក្រោមការបង្រៀនរបស់ព្រះគម្ពីរថា មានតែបុរសប៉ុណ្ណោះគួរតែធ្វើជាគ្រូគង្វាល និងជាចាស់ទុំនៅក្រុមជំនុំបាន។ ដែលនោះគឺថា បុរសៗគួរតែកាន់ទំនួលខុសត្រូវចម្បងសម្រាប់ភាពជាអ្នកដឹកនាំ និងការបង្រៀនដូចជាព្រះគ្រីស្ទនៅក្នុងក្រុមជំនុំ។ ដូច្នេះ យើងជឿថា វាមិនស្របតាមព្រះគម្ពីរនោះទេ ហើយជាការជះឥទ្ធិពលប៉ះពាល់ដល់ស្ត្រីក្នុងការទទួល/ដើរក្នុងតួនាទីនេះ។ (សូមមើលសំណួរទី១៣)។

## សំណួរទី៣

## នៅត្រង់ណានៃព្រះគម្ពីរ ដែលលោកអ្នកទទួលបានគំនិតថា មានតែបុរសៗប៉ុណ្ណោះគួរតែធ្វើជាគ្រូគង្វាល និងគ្រូចាស់ទុំរបស់ក្រុមជំនុំ?

អត្ថបទព្រះគម្ពីរដែលបង្ហាញយ៉ាងច្បាស់លាស់ទាក់ទងនឹងការដឹកនាំរបស់បុរសនៅក្នុងក្រុមជំនុំផ្ទាល់គឺ នៅកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១១-១៥; ១កូរិនថូស ១១:២-១៦; ១៤:៣៤-៣៦។ សំណួរទី៥ សំណួរទី៦ និងសំណួរទី៩ នៃសៀវភៅ ការស្តារឡើងវិញនូវភាពជាបុរស និងស្ត្រីស្របតាមព្រះគម្ពីរ ("Recovering Biblical Manhood and Womanhood") មានការបង្ហាញយ៉ាងលម្អិតស្តីពីការកាត់ស្រាយ និងផ្តល់នូវចម្លើយស្របតាមព្រះគម្ពីរដែល



50 Crucial Questions.indd 22 7/4/26 2:18 in the afternoon

គាំទ្រថា ហេតុអ្វីយើងជឿអត្ថបទព្រះគម្ពីរ ទាំងនេះផ្តល់នូវការប្រកាន់ខ្ជាប់នូវការញែកជាបរិសុទ្ធចំពោះភាពជាចាស់ទុំរបស់បុរសៗដែលពេញខាងព្រលឹងវិញ្ញាណ។ លើសជាងនេះទៅទៀត ទំនាក់ទំនងនៅក្នុងព្រះគម្ពីររវាងក្រុមគ្រួសារ និងក្រុមជំនុំបង្ហាញយ៉ាងច្បាស់ថា ភាពជាអ្នកដឹកនាំរបស់ស្វាមីនៅឯផ្ទះ បញ្ជាក់ពីភាពជាអ្នកដឹកនាំចម្បងខាងវិញ្ញាណរបស់បុរសនៅក្នុងក្រុមជំនុំផងដែរ។

## សំណួរទី៤
## ចុះចំណែកឯអាពាហ៍ពិពាហ៍វិញ? តើលោកគ្រូមានន័យយ៉ាងដូចម្តេចអំពី «គំរូនៃអាពាហ៍ពិពាហ៍នានាដែលមិនបង្ហាញទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំ» (នៅក្នុងសំណួរទី១)?

យើងជឿជាក់ថាព្រះគម្ពីរបង្រៀនថា ព្រះជាម្ចាស់មានព្រះទ័យចង់ឲ្យទំនាក់ទំនងរវាងប្តី និងប្រពន្ធ បង្ហាញអំពីទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំរបស់ទ្រង់។ ប្តីត្រូវយកគំរូតាមសេចក្តីស្រឡាញ់ និងការដឹកនាំដែលមានការលះបង់ដូចជាព្រះគ្រីស្ទ ហើយប្រពន្ធត្រូវយកគំរូតាមការចុះចូលដោយរីករាយដែលបានផ្តល់ឲ្យដោយឥតគិតថ្លៃពីក្រុមជំនុំ។[៥]

## សំណួរទី៥
## តើលោកគ្រូមានន័យយ៉ាងដូចម្តេចចំពោះឃ្លា «ការចុះចូល» (នៅក្នុងសំណួរទី៤)?

ការចុះចូលសំដៅទៅលើការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះប្រពន្ធ ដើម្បីនឹងផ្តល់កិត្តិយស និងបញ្ជាក់អំពីភាពជាអ្នកដឹកនាំរបស់ប្តី និងជួយបំពេញវាតាមរយៈអំណោយទានរបស់នាង។ វាមិនមែនជាការដាច់ខាតត្រូវតែចុះចាញ់ចំពោះរាល់ក្តីបំណងរបស់នាងនោះទេ។ ផ្ទុយទៅវិញ យើងនិយាយអំពីឆន្ទៈរបស់នាងក្នុងការធ្វើតាមការណែនាំរបស់ប្តី និងឆន្ទៈរបស់នាងក្នុងការធ្វើតាម

៥ សម្រាប់ព័ត៍មានបន្ថែម សូមមើលជំពូក១៣នៅក្នុងសៀវភៅ ការស្តារឡើងវិញនូវភាពជាបុរស និងស្ត្រីស្របតាមព្រះគម្ពីរ (“Recovering Biblical Manhood and Womanhood”)។



50 Crucial Questions.indd 23 7/4/26 2:18 in the afternoon

ការដឹកនាំរបស់គាត់។ សិទ្ធិអំណាចទាំងស្រុងរបស់នាង គឺស្ថិតនៅក្នុងព្រះគ្រីស្ទមិនមែននៅក្នុងប្ដីរបស់នាងនោះទេ។ នាងចុះចូល “ដោយសេចក្ដីកោតខ្លាចដល់ព្រះគ្រីស្ទ” (អេភេសូរ ៥:២១)។ សិទ្ធិអំណាចធំរបស់ប្ដីនាងនឹងត្រូវមានគណនេយ្យភាពចំពោះព្រះគ្រីស្ទ។ នាងមិនគួរធ្វើតាមប្ដីនៅក្នុងអំពើបាបឡើយ។ ផ្ទុយទៅវិញ នាងប្រហែលជាត្រូវឈរជាមួយនឹងព្រះគ្រីស្ទ នៅពេលប្រឆាំងទាស់នឹងឆន្ទៈនៃអំពើបាបរបស់ប្ដីនាង (ឧ. ១ពេត្រុស ៣:១ នាងមិនត្រូវចុះចូលចំពោះភាពគ្មានសេចក្ដីជំនឿរបស់ប្ដីឡើយ) នាងនៅតែអាចមានវិញ្ញាណនៃការចុះចូល—បំណងចិត្តក្នុងការចុះចូល។ នាងអាចបង្ហាញដោយឥរិយាបថ និងអាកប្បកិរិយារបស់នាងថា នាងមិនចូលចិត្តតតាំងនឹងបំណងចិត្តរបស់គាត់ ហើយថានាងប្រាថ្នាចង់ឲ្យគាត់លះបង់អំពើបាប ហើយដឹកនាំដោយសុចរិតភាព ដើម្បីឲ្យទំនោរចិត្តរបស់នាងផ្ដល់កិត្តិយសឲ្យគាត់ជាអ្នកនាំមុខ អាចបង្កើតភាពសុខដុមរមនាជាថ្មី។

## សំណួរទី៦
## តើលោកគ្រូមានន័យយ៉ាងណា នៅពេលលោកគ្រូហៅប្ដីថាជា «ក្បាល» (នៅក្នុងសំណួរទី៥)?

នៅក្នុងគ្រួសារ ភាពជាអ្នកដឹកនាំស្របតាមព្រះគម្ពីរ សំដៅទៅលើការត្រាស់ហៅពីព្រះជាម្ចាស់សម្រាប់ប្ដី ក្នុងការមានទំនួលខុសត្រូវចម្បងក្នុងការដឹកនាំការការពារ និងការផ្គត់ផ្គង់ដូចជាព្រះគ្រីស្ទ។ (សូមមើលសំណួរទី១៣ ចំពោះអត្ថន័យនៃពាក្យ “ចម្បង”)។

## សំណួរទី៧
## តើនៅកន្លែងណានៃព្រះគម្ពីរដែលលោកគ្រូទទួលបានគំនិតថា ប្ដីគួរតែជាអ្នកដឹកនាំនៅក្នុងផ្ទះរបស់ផងពួកគេ?

កណ្ឌគម្ពីរដែលបង្ហាញយ៉ាងច្បាស់ជាងគេបំផុតទាក់ទងនឹងការដឹកនាំ និងការចុះចូលនៅក្នុងចំណងអាពាហ៍ពិពាហ៍ គឺនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ



50 Crucial Questions.indd 24 7/4/26 2:18 in the afternoon

ជំពូក១-៣; អេភេសូរ ៥:២១-៣៣; កូឡូស ៣:១៨-១៩; ១ធីម៉ូថេ ៣:២, ៤, ១២; ទីតុស ២:៥ និង ១ពេត្រុស ៣:១-៧។ ទស្សនៈនៃការបង្រៀនរបស់អត្ថបទក្នុងកណ្ឌគម្ពីរទាំងនេះ គឺជារូបភាពនៃការដឹកនាំរបស់បុរស ដែលជ្រួតជ្រាបទូទៅអាចជាការដែលព្រះគម្ពីរបានពណ៌នាអំពីជីវិតគ្រួសារ ដែលអាចជាការឆ្លុះបញ្ចាំងមិនគ្រាន់តែបាតុភូតវប្បធម៌មួយកន្លងផុតទៅជាងរាប់ពាន់ឆ្នាំតែប៉ុណ្ណោះទេ។ ប៉ុន្តែ ជាការតាក់តែងដើមរបស់ព្រះជាម្ចាស់ ទោះបីជាអំពើបាបបានបង្ខូចវាក៏ដោយ។

## សំណួរទី៨

## នៅពេលដែលលោកគ្រូលើកឡើងថា ប្រពន្ធមិនគួរដើរតាមប្ដីរបស់ខ្លួនចូលទៅក្នុងអំពើបាបនោះឡើយ (សំណួរទី៥) តើប្ដីនៅមានអំណាចអ្វីទៀតសល់ទេ? តើអ្នកណាជាអ្នកនិយាយថា ទង្វើអ្វីនៃការដឹកនាំរបស់ប្ដីជាអំពើបាប នៅក្នុងការបង្ហាញអំពីភាពត្រឹមត្រូវរបស់ប្រពន្ធ ដើម្បីឲ្យគាត់អាចបដិសេធមិនធ្វើតាមប្ដី?

យើងមិនអះអាងថា យើងកំពុងរស់នៅក្នុងភាពមិនច្បាស់លាស់នោះទេ ព្រោះពេលខ្លះមនុស្សប្រឈមមុខនឹងការសម្រេចចិត្តដ៏លំបាកនៅក្នុងស្ថានភាពស្មុគស្មាញមួយចំនួន។ យើងក៏មិននិយាយបានដែរថា ការដឹកនាំ/ភាពជាអ្នកនាំមុខមានតាំងនៅក្នុងការណែនាំជាស៊ើសម្រាប់ប្រពន្ធដែរ។ ភាពជាអ្នកដឹកនាំ មិនមានន័យដូចគ្នាទៅនឹងការសម្រេចចិត្តដោយឯកតោភាគីនោះទេ។ តាមពិតទៅ នៅក្នុងចំណងអាពាហ៍ពិពាហ៍ដ៏ល្អមួយ ភាពជាអ្នកដឹកនាំតាំងនៅជាចម្បងក្នុងការទទួលខុសត្រូវនៅក្នុងការបង្កើតគំរូនៃអន្តរកម្ម ដែលផ្តល់កិត្តិយសដល់ប្ដី និងប្រពន្ធ (និងកូន) ដូចជាឃ្លាំងនៃការរក្សាទុកប្រាជ្ញាផ្សេងៗសម្រាប់ជីវិតគ្រួសារ។ ភាពជាអ្នកដឹកនាំមានទំនួលខុសត្រូវចម្បងសម្រាប់ការកែច្នៃ និងការរៀបចំផែនការខាងសីលធម៌នៅក្នុងផ្ទះ ប៉ុន្តែការអភិវឌ្ឍន៍នៃការកែច្នៃ និងរៀបចំផែនការនោះនឹងធ្វើរួមជាមួយនឹងប្រពន្ធ (ដែលនាងប្រហែលជាឆ្លាតជាង និងមានប្រាជ្ញាជាង)។ គ្មានអ្វីមួយត្រូវបានចាត់ទុក

ថា ឥតប្រយោជន៍ដោយភាពមិនច្បាស់លាស់ មួយចំនួននៅក្នុងស្ថានភាពលំបាកៗ និងករណីផ្សេងៗដែលប្ដី និងប្រពន្ធមិនយល់ស្របលើអ្វីដែលជំរុញឲ្យមានភាពស្មោះត្រង់ចំពោះព្រះគ្រីស្ទឡើយ។

រចនាសម្ព័ន្ធដឹកនាំរបស់ប្រទេសជាតិ ក្រុមជំនុំ និងគ្រួសារមិនអាចក្លាយទៅជាអសារឥតការបានទេ ទោះបើព្រះគ្រីស្ទមានអំណាចទាំងស្រុងលើការដឹកនាំបុគ្គលម្នាក់ៗក៏ដោយ។ ព្រះគម្ពីរសញ្ញាថ្មីបានបង្គាប់យើងឲ្យចុះចូលនឹងអ្នកដឹកនាំក្រុមជំនុំ (ហេព្រើរ ១៣:១៧) គឺមិនមែនជាការអសារឥតការនោះទេ ទោះបីជាព្រះគម្ពីរបានប្រាប់ថានឹងមានពួកចាស់ទុំនឹងក្រោកឡើងអធិប្បាយសេចក្ដីខុសឆ្គងក៏ដោយ (កិច្ចការ ២០:៣០) ហើយថានៅពេលដែលពួកគេធ្វើដូច្នេះ នោះពួកគេគួរតែត្រូវផ្ចាញ់ផ្ចាលនៅមុខមនុស្សទាំងអស់ជាជាងការធ្វើតាម (១ធីម៉ូថេ ៥:២០)។ សេចក្ដីបង្គាប់ឲ្យចុះចូលចំពោះអាជ្ញាធរ (រ៉ូម ១៣:១) ក៏មិនមែនគ្មានន័យនោះដែរ ទោះបីជាមានការជំទាស់ដោយបញ្ញាចិត្តក៏ដោយ (កិច្ចការ ៥:២៩)។ នេះក៏មិនមែនជាលក្ខណៈពិតនៃភាពជាអ្នកដឹកនាំដ៏ទន់ភ្លន់ រឹងមាំរបស់បុរសនៅឯផ្ទះត្រូវបានចាត់ទុកជាមោឃៈដោយសារតែនៅទីបំផុតប្រពន្ធរបស់គាត់ត្រូវតែចុះចូលនឹងអំណាចរបស់ព្រះគ្រីស្ទ មិនមែនគាត់នោះទេ។ ក្នុងករណីដែលការដឹកនាំរបស់គាត់បរាជ័យនៅក្នុងការទទួលបានការឆ្លើយតបដោយរីករាយរបស់នាង គាត់ត្រូវតែទុកចិត្តលើព្រះគុណនៃព្រះ ហើយស្វែងរកផ្លូវនៃប្រាជ្ញាស្របតាមព្រះគម្ពីរ តាមរយៈការអធិស្ឋាន និងការទូន្មាន។ គ្មាននរណាម្នាក់ក្នុងចំណោមពួកយើងអាចគេចផុតពីភាពមិនច្បាស់លាស់នៃជីវិតពិតនោះទេ (ទោះបើពេលខ្លះ វាជាការឈឺចាប់ដ៏ពិបាកទ្រាំ)។



50 Crucial Questions.indd 26 7/4/26 2:18 in the afternoon

## សំណួរទី៩
## តើលោកគ្រូមិនគិតថា ការសង្កត់ធ្ងន់ទៅលើភាពដឹកនាំ និងការចុះចូល ផ្តល់អំណាចដល់ការរាតត្បាតនៃការរំលោភបំពានលើប្រពន្ធនោះទេ?

ទេ! ទី១ យើងសង្កត់ធ្ងន់ទៅលើការដឹកនាំដែលយកគំរូតាមព្រះគ្រីស្ទ ការដឹកនាំដែលលះបង់ «ឯពួកប្រុសៗ នោះក៏ត្រូវនៅជាមួយនឹងប្រពន្ធដោយប្រាជ្ញាដែរ ដូចនឹងគ្រឿងភាជនៈដែលខ្សោយជាង គឺជាមនុស្សស្រី ព្រមទាំងរាប់អាននាង ទុកដូចជាអ្នកគ្រងព្រះគុណនៃជីវិត ទុកជាមរដកជាមួយគ្នា...» (១ពេត្រុស ៣:៧) ហើយស្របពេលជាមួយគ្នានោះ យើងសង្កត់ធ្ងន់លើការចុះចូលដោយយកចិត្តទុកដាក់ ដែលមិនបានធ្វើឲ្យបុរសៗជាប្តីក្លាយជាចៅហ្វាយនាយដាច់មុខនោះទេ (សូមមើលសំណួរទី៥)។ ទី២ យើងជឿថា ការរំលោភបំពានសិទ្ធិលើប្រពន្ធ និងការរំលោភបំពានសិទ្ធិលើប្តី មានឫសគល់យ៉ាងជ្រៅមកពីការបរាជ័យនៃភាពជាឪពុកម្តាយនៅក្នុងការផ្ទេរដល់កូនប្រុសស្រីរបស់ខ្លួននូវអត្ថន័យនៃភាពជាបុរស និងភាពជាស្ត្រីពិតប្រាកដ។ សេចក្តីភាន់ច្រឡំ និងភាពច្របូកច្របល់នៃអត្តសញ្ញាណភេទ ជារឿយៗលេចឡើងនូវអាកប្បកិរិយាផ្សេងៗដែលបង្កឲ្យមានហានិភ័យ។ ដំណោះស្រាយ គឺមិនមែន ដើម្បីកាត់បន្ថយភាពខុសគ្នាខាងភេទ (ដែលនឹងផ្ទុះឡើងនៅពេលក្រោយនៅក្នុងលក្ខណៈគម្រាមកំហែងនោះទេ) ប៉ុន្តែដើម្បីបង្រៀនក្រុមគ្រួសារនីមួយៗ និងក្រុមជំនុំអំពីលក្ខណៈនៃភាពជាបុរស និងភាពជាស្ត្រីពិតប្រាកដនឹងបង្ហាញនូវគំរូនៅក្នុងតួនាទីដែលពេញដោយសេចក្តីស្រឡាញ់ និងបំពេញគ្នាទៅវិញទៅមកនៅក្នុងចំណងអាពាហ៍ពិពាហ៍។



50 Crucial Questions.indd 27 7/4/26 2:18 in the afternoon

## សំណួរទី១០
## ប៉ុន្តែ លោកគ្រូមិនជឿលើឃ្លា «ការចុះចូលនឹងគ្នាទៅវិញទៅមក» ដែលសាវ័ក ប៉ុល ហាក់បីដូចជាបានបង្រៀននៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ («ការចំណុះនឹងគ្នាទៅវិញទៅមក») ទេឬអី?

អ្វីៗគ្រប់យ៉ាង អាស្រ័យទៅលើអ្វីដែលលោកអ្នកចង់សំដៅទៅលើឃ្លា "ការចុះចូលគ្នាទៅវិញទៅមក"។ ពួកយើងខ្លះបានដាក់សម្ពាធលើការព្រមព្រៀងគ្នានៅត្រង់ចំណុចនេះច្រើនជាងអ្វីៗផ្សេង។[៦]

---

៦ ទស្សនៈពីរនៃកណ្ឌគម្ពីរ អេភេសូរ ៥:២១ គឺស៊ីគ្នានឹងទស្សនៈនៃសៀវភៅនេះ។ ទស្សនៈមួយគឺ ខគម្ពីរបង្រៀន «ការចុះចូលគ្នាទៅវិញទៅមក» របស់គ្រីស្ទបរិស័ទទាំងអស់ចំពោះគ្នាទៅវិញទៅមក ហើយខ២២-៣៣ បង្រៀនប្រភេទនៃការចុះចូលជាក់លាក់។ ការកាត់ស្រាយនេះ គឺស្របនឹងការបង្រៀនខាងក្រមសីលធម៌ទូទៅនៃបទគម្ពីរ ព្រោះវាត្រឹមត្រូវក្នុងការនិយាយថា យើងគួរតែ «ចុះចូលគ្នាទៅវិញទៅមក» ក្នុងន័យនៃការប្រព្រឹត្តដោយក្តីស្រឡាញ់ ការគិតគូរ និងការលះបង់ចំពោះគ្នាទៅវិញទៅមក។

ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃកិច្ចព្រមព្រៀងក្នុងចំណោមអ្នកបំពេញគ្នាទៅវិញទៅមក (ដូចដែលបានលើកជាឧទាហរណ៍ នៅក្នុងភាគដែលបានកែសម្រួលដែលធំជាងនេះរបស់យើងនៅក្នុងសៀវភៅ ការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ) មានកន្លែងសម្រាប់ការកាត់ស្រាយមួយផ្សេងទៀតនៃកណ្ឌគម្ពីរ អេភេសូរ ៥:២១ ខគម្ពីរនោះមិនបានបង្រៀនអំពី «ការចុះចូលគ្នាទៅវិញទៅមក» ទាល់តែសោះ ប៉ុន្តែបង្រៀនថា យើងទាំងអស់គ្នាគួរតែចុះចូលនឹងអ្នកដែលព្រះជាម្ចាស់បានដាក់ឲ្យមានអំណាចលើយើងដូចជាប្តី ឪពុកម្តាយ ឬនិយោជក (៥:២២; ៦:១, ៥)។ កណ្ឌគម្ពីរ អេភេសូរ ៥:២១ នឹងត្រូវបានកាត់ស្រាយថា៖ «ការចុះចូលនឹងគ្នាទៅវិញទៅមក (នោះគឺ អ្នកផ្សេងទៀត) ដោយការកោតខ្លាចដល់ព្រះគ្រីស្ទ»។

អំណះអំណាងចម្បងសម្រាប់ទិដ្ឋភាពជំនួសនេះ គឺពាក្យក្រិក អ៊ីប៉ូតាសូ (hypotasso «ចុះចូល»។ ទោះបីជាមនុស្សជាច្រើនបានអះអាងថា ពាក្យនេះអាចមានន័យថា «មានគំនិត និងចេះគិតគូរ ប្រព្រឹត្តដោយសេចក្តីស្រឡាញ់» (ចំពោះអ្នកដទៃ) វាជាការសង្ស័យដែលអ្នកនិយាយភាសាក្រិកនៅសតវត្សរ៍ទី១នឹងយល់វាតាមរបៀបនោះ ដ្បិតពាក្យនេះតែងតែបង្កប់ន័យទំនាក់ទំនងនៃការចុះចូលចំពោះសិទ្ធិអំណាច។ ពាក្យនេះត្រូវបានប្រើនៅកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីអំពីការចុះចូលរបស់ព្រះយេស៊ូវចំពោះសិទ្ធិអំណាចរបស់ឪពុកម្តាយខាងសាច់ឈាមរបស់ទ្រង់ (លូកា ២:៥១) អំពីពួកអារក្សដែលចុះចូលនឹងពួកសាវ័ក (លូកា ១០:១៧—ច្បាស់ណាស់ថា អត្ថន័យ «ចេះគិតគូរ និងប្រព្រឹត្តដោយសេចក្តីស្រឡាញ់» មិនសមនឹងនៅទីនេះទេ) អំពីប្រជារាស្ត្រដែលចុះចូលនឹងអំណាចរបស់រដ្ឋាភិបាល (រ៉ូម ១៣:១, ៥; ទីតុស ៣:១; ១ពេត្រុស ២:១៣) អំពីចក្រវាឡដែលចុះចូលនឹងព្រះគ្រីស្ទ (១កូរិនថូស ១៥:២៧; អេភេសូរ ១:២២) អំពីអំណាចខាងឯវិញ្ញាណដែលមើលមិនឃើញចុះចូលនៅក្រោមអំណាចរបស់ព្រះគ្រីស្ទ (១ពេត្រុស ៣:២២) អំពីព្រះគ្រីស្ទដែលចុះចូលនឹងព្រះវរបិតា (១កូរិនថូស ១៥:២៨) អំពីសមាជិកក្រុមជំនុំដែលចុះចូលនឹងថ្នាក់ដឹកនាំក្រុមជំនុំ (១កូរិនថូស ១៦:១៥-១៦ [ជាមួយ ១ក្លេមិន ៤២:៤ (១Clement ៤២:៤)]; ១ពេត្រុស ៥:៥) អំពីប្រពន្ធដែលចុះចូលនឹងប្តី (កូឡូស ៣:១៨; ទីតុស ២:៥; ១ពេត្រុស. ៣:៥; អេភេសូរ ៥:២២, ២៤) អំពីក្រុមជំនុំចុះចូលនឹងព្រះគ្រីស្ទ (អេភេសូរ ៥:២៤) អំពីអ្នកបម្រើដែលចុះចូលនឹងចៅហ្វាយរបស់ពួកគេ (ទីតុស ២:៩; ១ពេត្រុស ២:១៨) និងអំពីគ្រីស្ទបរិស័ទដែលចុះចូលនឹងព្រះជាម្ចាស់ (ហេព្រើរ ១២:៩; យ៉ាកុប ៤:៧)។ គ្មានទំនាក់ទំនងណាមួយក្នុងចំណោមទំនាក់ទំនងទាំងនេះត្រូវបានបញ្ច្រាសត្រឡប់មកវិញឡើយ។ នោះគឺ ស្វាមីមិនដែលប្រាប់ឲ្យចុះចូលនឹងភរិយា រដ្ឋាភិបាលមិនដែលប្រាប់ឲ្យចុះចូលចំពោះប្រជាពលរដ្ឋ ចៅហ្វាយមិនដែលប្រាប់ឲ្យចុះចូលចំពោះបាវបម្រើ ពួកសាវ័កមិនដែលប្រាប់ឲ្យចុះចូលចំពោះពួកអារក្ស ។ល។ និងការស្តាប់បង្គាប់របស់ទាហានក្នុងជួរកងទ័ពចំពោះអ្នកដែលមានឋានៈខ្ពង់ខ្ពស់ សូមមើល យ៉ូសែបផាស (Josephus) សង្គ្រាមជនជាតិយូដា (Jewish War) ២.៥៦៦, ៥៧៨; នៅក្នុងកណ្ឌ ១ក្លេមិន ៣៧:២ (១Clement ៣៧:២) អំពីគុណកិរិយា និងលោក ហេនរី ចច លីដឌែល (Henry George Liddell) និងលោក រ៉ូប៊ឺត ស្កត (Robert Scott), វចនានុក្រមក្រិក-អង់គ្លេស (A Greek-English Lexicon) លោកគ្រូ ហេនរី ស្ទើត ចូនស៍ (Henry Stuart Jones) និងលោក រូឌ័រិក ម៉ាកខិនហ្ស៊ី (Roderick McKenzie, suppl. E. A. Barber, et al. [Oxford: Clarendon, ឆ្នាំ១៩៦៨], ទំព័រ១៨៩៧, ដែលបានផ្តល់អត្ថន័យទៅលើពាក្យ អ៊ីប៉ូតាសូ (hypotasso [កម្មវាចកៈ] ដែលមានន័យថា «ឲ្យស្តាប់បង្គាប់»)។ ន័យរបស់ពាក្យនេះមិនមានន័យ «ទៅវិញទៅមក» នោះទេ វាតែងតែមានទិសដៅតែមួយជាមួយភស្តុតាងនៃការចុះចូលចំពោះអ្នកមានសិទ្ធិអំណាច។ ដូច្នេះ យើងអាចនឹងសួរថា ហេតុអ្វីបាន



50 Crucial Questions.indd 28 7/4/26 2:18 in the afternoon

ប៉ុន្តែ ទោះបីជាសាវ័ក ប៉ុល ចង់សំដៅដល់ការព្រមព្រៀងគ្នាពេញលេញ (ប្រពន្ធចុះចូលនឹងប្តី ហើយប្តីចុះចូលនឹងប្រពន្ធ) ក្តី នេះមិនមានន័យថា ប្តី និងប្រពន្ធគួរចុះចូលគ្នាទៅវិញទៅមក ក្នុងរបៀបដូចគ្នានោះទេ។ ចំណុចសំខាន់នោះគឺត្រូវចងចាំថា បទគម្ពីរនេះសំដៅដល់ទំនាក់ទំនងរវាងប្តី និងប្រពន្ធត្រូវធ្វើឡើងតាមគំរូនៃទំនាក់ទំនងរវាងព្រះគ្រីស្ទ និងក្រុមជំនុំ។ តើព្រះគ្រីស្ទ និងក្រុមជំនុំចុះចូលនឹងគ្នាទៅវិញទៅមកដែរឬទេ? ទេ! មិនចុះចូលគ្នាទៅវិញទៅមកទេ ប្រសិនបើការចុះចូលនោះសំដៅទៅលើព្រះគ្រីស្ទចុះចូលចំពោះអំណាចរបស់ក្រុមជំនុំ។ ប៉ុន្តែ ព្រះគ្រីស្ទ និងក្រុមជំនុំចុះចូលគ្នាទៅវិញទៅមក ប្រសិនបើការចុះចូលនោះ សំដៅទៅលើព្រះគ្រីស្ទបានដាក់អង្គទ្រង់ទៅនឹងការរងទុក្ខ និងសេចក្តីស្លាប់ ដើម្បីជាប្រយោជន៍ដល់ក្រុមជំនុំ។ ទោះបីជាយ៉ាងណាក៏ដោយ នោះមិនមែនជារបៀបដែលពួកជំនុំចុះចូលចំពោះ

---

ជាយើងគួរកំណត់អត្ថន័យមួយទៅលើពាក្យ អ៊ីប៉ូតាសសូ នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ តែមិនមែនយកកន្លែងណាផ្សេងដូច្នេះ?

ដូច្នេះហើយ វាហាក់ដូចជាការយល់ច្រឡំពីកណ្ឌគម្ពីរ អេភេសូរ៥:២១ ដើម្បីនិយាយថាវាបង្កប់ន័យចុះចូលទៅវិញទៅមក សូម្បីតែនៅកណ្ឌគម្ពីរ អេភេសូរ ៥:២២-២៤ ក៏យើងឃើញថា ប្រពន្ធមិនត្រូវចុះចូលចំពោះមនុស្សគ្រប់គ្នា ឬប្តីទាំងអស់នោះឡើយ ប៉ុន្តែត្រូវចុះចូលចំពោះ «ប្តីរបស់ខ្លួន»—«ការចុះចូល» ដែលសាវ័ក ប៉ុល មានក្នុងចិត្តមិនមែនជាការគិតទូទៅចំពោះអ្នកដទៃទេ ប៉ុន្តែជាការចុះចូលជាក់លាក់ចំពោះសិទ្ធិអំណាចខ្ពស់ជាង។ ប៉ុន្តែ តើកិរិយាសព្ទចុះចូលនៅក្នុងខ២២ (មិនថាដោយប្រយោល ឬច្បាស់លាស់) មិនគួរទទួលយកន័យដូចគ្នាដែលវាធ្វើនៅក្នុងខ២១ ទេឬអី?

ការបកស្រាយការចុះចូលចំពោះគ្នាទៅវិញទៅមកគឺជារឿងធម្មតាណាស់ ពីព្រោះអ្នកបកប្រែសន្មតថា សព្វនាមក្រិក «អិលលាលូស៍» (allelous ដែលមានន័យថា «មួយផ្សេងទៀត») ត្រូវតែទៅវិញទៅមកទាំងស្រុង—ពោលគឺវាត្រូវតែមានន័យថា «មនុស្សគ្រប់គ្នាចំពោះមនុស្សគ្រប់គ្នា»។ មានអត្ថបទជាច្រើនដែលពាក្យ អិលលាលូស៍ មានន័យថា «អ្នកគ្រប់គ្នាចំពោះមនុស្សគ្រប់គ្នា» ប៉ុន្តែនោះមិនមែនជាករណីនៅក្នុងការប្រើប្រាស់របស់វាទាំងអស់នោះទេ ហើយវាពិតជាមិនចាំបាច់ទទួលយកអត្ថន័យនោះដែរ។ ផ្ទុយទៅវិញ វាច្រើនតែមានន័យថា «ដល់អ្នកខ្លះទៀត»។ ជាឧទាហរណ៍នៅក្នុងកណ្ឌគម្ពីរ វិវរណៈ ៦:៤ បានចែងថា «ដូច្នេះមនុស្សត្រូវសម្លាប់គ្នា» មានន័យថា «ដូច្នេះអ្នកខ្លះនឹងសម្លាប់អ្នកដទៃ» (មិនមែន «ដូច្នេះមនុស្សគ្រប់គ្នានឹងសម្លាប់មនុស្សគ្រប់គ្នា» ឬ «ដូច្នេះថាមនុស្សទាំងនោះ ការត្រូវបានសម្លាប់នឹងសម្លាប់គ្នាទៅវិញទៅមក អ្នកដែលកំពុងតែសម្លាប់ពួកគេ» ដែលមិនសមហេតុផល) នៅកណ្ឌគម្ពីរ កាឡាទី ៦:២ «ចូរយកអាសាគ្នាទៅវិញទៅមក» មានន័យថា មិនមែន «អ្នករាល់គ្នាត្រូវដោះបន្ទុកជាមួយនឹងអ្នកដទៃ» ទេ។ ប៉ុន្តែ «អ្នកខ្លះដែលមានសមត្ថភាពច្រើនគួរជួយទទួលបន្ទុកអ្នកដទៃដែលមិនសូវមានសមត្ថភាព»។ ហើយនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:៣៣ «ដូច្នេះ បងប្អូនអើយ កាលណាប្រជុំគ្នា ដើម្បីនឹងបរិភោគនោះត្រូវបង្អង់ចាំគ្នាផង» នេះមានន័យថា «អ្នកណាដែលត្រៀមខ្លួនពីព្រលឹម ត្រូវរង់ចាំអ្នកឯទៀតដែលយឺត» (លូកា ២:១៥; ១២:១; ២៤:៣២—នៅមានឧទាហរណ៍ជាច្រើនដែលយើងមិនទាន់បានចំរាស់ពាក្យនេះទាំងស្រុង)។ ដូចគ្នានេះដែរនៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ ទាំងបរិបទខាងក្រោម និងអត្ថន័យនៃពាក្យអ៊ីប៉ូតាសសូ តម្រូវឲ្យពាក្យ អិលលាលូស៍ នៅទីនេះមានន័យថា «ខ្លះចំពោះអ្នកផ្សេងទៀត» ដូច្នេះ ខគម្ពីរអាចត្រូវបានកាត់ស្រាយថា «អ្នកដែលស្ថិតនៅក្រោមអំណាចគួរតែចុះចូលនឹងអ្នកដទៃក្នុងចំណោមអ្នកដែលមានអំណាចលើពួកគេ»។

ដូច្នេះ យោងទៅតាមការបកស្រាយនេះ (ទីពីរ) វាហាក់ដូចជាល្អបំផុតក្នុងការនិយាយថានៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ សាវ័ក ប៉ុល កំពុងបញ្ជាមិនឲ្យត្រឹមតែ «ចុះចូលគ្នាទៅវិញទៅមក» ប៉ុន្តែក៏ត្រូវចុះចូលចំពោះសិទ្ធិអំណាចដែលសមស្របផងដែរ។



50 Crucial Questions.indd 29 7/4/26 2:18 in the afternoon

ព្រះគ្រីស្ទទេ។ ក្រុមជំនុំចុះចូលចំពោះព្រះគ្រីស្ទ ដោយបញ្ជាក់អំពីសិទ្ធិអំណាច ហើយធ្វើតាមការដឹកនាំរបស់ទ្រង់។ ដូច្នេះ ការចុះចូលគ្នាទៅវិញទៅមកមិនមែនមានន័យថា ចុះចូលគ្នាទៅវិញទៅមកក្នុងសណ្ឋានដូចគ្នានោះទេ។ ការចុះចូលគ្នាទៅវិញទៅមកនោះ មិនធ្វើឲ្យការដឹកនាំរបស់ព្រះគ្រីស្ទលើក្រុមជំនុំមានភាពអន់ខ្សោយ ហើយក៏មិនគួរធ្វើឲ្យមានការសម្របសម្រួលដល់ការដឹកនាំរបស់ប្តីលើប្រពន្ធរបស់គាត់ផងដែរ។ (សម្រាប់របៀបនានាដែលបទគម្ពីរបានដាក់លក្ខខណ្ឌលើការអនុវត្តភាពជាអ្នកដឹកនាំ សូមមើលសំណួរទី៣៦)។

## សំណួរទី១១
## ប្រសិនបើពាក្យ «ក្បាល» មានន័យថាជា «ប្រភព» នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២៣ («ប្តីជាក្បាលនៃប្រពន្ធ») ដូចអ្នកប្រាជ្ញខ្លះបានលើកឡើងដូច្នេះមែន តើឃ្លានោះនឹងមិនបានផ្លាស់ប្តូរទាំងស្រុងនូវរបៀបនៃការមើលទៅកាន់អត្ថបទព្រះគម្ពីរនេះ និងលុបបំបាត់គំនិតដែលថា ប្តីជាអ្នកដឹកនាំនៅក្នុងផ្ទះទេឬអី?

ទេ! យើងមិនជឿថា នោះជាបរិបទនោះទេ ប៉ុន្តែមុននឹងយើងដោះស្រាយជាមួយនឹងលទ្ធភាពនៃសម្មតិកម្មនេះ យើងគួរតែនិយាយថា អត្ថន័យពាក្យ "ប្រភព" នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២៣ គឺមិនទំនងទាល់តែសោះ។ អ្នកប្រាជ្ញនឹងចង់បានការប្រព្រឹត្តចំពោះគ្នាយ៉ាងទូលំទូលាយនៃពាក្យនេះនៅក្នុងសៀវភៅ ការស្តារឡើងវិញនូវភាពជាបុរស និងស្ត្រីស្របតាមព្រះគម្ពីរ និងសៀវភៅ ការផ្សាយដំណឹងល្អខាងឯស្ត្រីនិយម និងសេចក្តីពិតស្របតាមព្រះគម្ពីរ។[៧] ប៉ុន្តែ តាមការពិត មនុស្សទូទៅនឹងទាញយកការសន្និដ្ឋានរបស់ពួកគេដោយផ្អែកលើអ្វីដែលសមហេតុផលនៅទីនេះនៅក្នុងកណ្ឌគម្ពីរអេភេសូរ។ ៥ខ២៣ គឺជាមូលដ្ឋាន ឬអំណះអំណាងសម្រាប់ខ២២ ដូច្នេះវាចាប់ផ្តើមដោយពាក្យថា ដ្បិតៈ "ស្ត្រីរាល់គ្នាអើយ ចូរឲ្យចុះចូលចំពោះប្តីខ្លួន ដូចជាចុះចូល

៧ លោក Wayne Grudem, *Evangelical Feminism and Biblical Truth*, ទំព័រ៥៤៤-៥៩៩។



50 Crucial Questions.indd 30 7/4/26 2:18 in the afternoon

នឹងព្រះអម្ចាស់ដែរ ដ្បិតប្ដីជាក្បាលនៃប្រពន្ធ»។ នៅពេលដែលការដឹកនាំរបស់ប្ដីត្រូវបានផ្ដល់ជាមូលដ្ឋានសម្រាប់ការចុះចូលរបស់ប្រពន្ធ ការយល់ដឹងពីធម្មតាបំផុតគឺថា ការដឹកនាំបង្ហាញពីប្រភេទនៃភាពជាអ្នកដឹកនាំ។

ម្យ៉ាងវិញទៀតសាវ័ក ប៉ុល មានរូបភាពក្នុងគំនិតគាត់រួចជាស្រេចទៅហើយ នៅពេលគាត់និយាយថា ប្ដីជាក្បាលនៃប្រពន្ធ។ ពាក្យ ក្បាល មិនជាប់ក្នុងលំហរង់ចាំអត្ថន័យណាមួយត្រូវបានចាត់ឲ្យបំពេញវានោះទេ។ សាវ័ក ប៉ុល និយាយថា «ដ្បិតប្ដីជាក្បាលនៃប្រពន្ធ ដូចជាព្រះគ្រីស្ទទ្រង់ជាសិរសានៃពួកជំនុំដែរ ក៏ជាព្រះអង្គសង្គ្រោះដល់រូបកាយផង» (អេភេសូរ ៥:២៣)។ រូបភាពនៅក្នុងគំនិតរបស់សាវ័ក ប៉ុល គឺជារូបកាយដែលមានក្បាល។ ការនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវានាំទៅរកការរួបរួមជា «សាច់តែមួយ» នៃប្ដីប្រពន្ធនៅក្នុងខគម្ពីរខាងក្រោម។ ក្បាល និងខ្លួនរបស់វាគឺជា «សាច់តែមួយ»។ ដូច្នេះ សាវ័ក ប៉ុល បន្តមានប្រសាសន៍នៅក្នុង ខ២៨-៣០ ថា «ត្រូវឲ្យប្ដីស្រឡាញ់ប្រពន្ធបែបយ៉ាងនោះឯង គឺដូចជាស្រឡាញ់រូបកាយរបស់ខ្លួនដែរ អ្នកណាដែលស្រឡាញ់ប្រពន្ធខ្លួន នោះក៏ឈ្មោះថា ស្រឡាញ់ដល់ខ្លួនឯងហើយ ដ្បិតមិនដែលមានអ្នកណាស្អប់រូបសាច់ខ្លួនឯងឡើយ គឺគេតែងចិញ្ចឹមហើយថ្នាក់ថ្នមវិញ ដូចជាព្រះអម្ចាស់ដល់ពួកជំនុំដែរ ដ្បិតយើងរាល់គ្នាជាអវយវៈរបស់រូបអង្គ និងសាច់ឆ្អឹងទ្រង់»។ សាវ័ក ប៉ុល កាន់តាមរូបព្រះគ្រីស្ទជាព្រះសិរសា និងរូបកាយ ដែលជាពួកជំនុំរបស់ទ្រង់។ ព្រះគ្រីស្ទចិញ្ចឹម និងស្រឡាញ់ក្រុមជំនុំ ដោយសារយើងជាអវយវៈនៃរូបកាយទ្រង់។ ដូច្នេះ ប្ដីប្រៀបបាននឹងក្បាលរបស់ប្រពន្ធ កាលណាចិញ្ចឹមបីបាច់ថែរក្សានាង នោះពិតជាចិញ្ចឹម និងថ្នមខ្លួនឯងដូចជាក្បាលដែលជា «សាច់តែមួយ» ជាមួយនឹងរូបកាយនេះ។

យើងឃើញថា វាសំខាន់ណាស់ ដែលនៅក្នុង អក្សរសិល្ប៍ក្រិកបុរាណទាំងអស់ មនុស្សម្នាក់ត្រូវបានគេហៅថា «ក្បាល» (ភាសាក្រិក «កែបហ្វាល់ឡេ» kephalē) របស់បុគ្គលម្នាក់ផ្សេងទៀត ឬក្រុមមួយក្នុង

ឧទាហរណ៍ជាងសែសិប ហើយក្នុងករណីនីមួយៗ បុគ្គលដែលត្រូវបានគេហៅថាជា “ក្បាល” មានតួនាទីនៃសិទ្ធិអំណាចលើអ្នកដទៃ ឬលើក្រុមនោះ។ គ្មានឧទាហរណ៍ណាដែលបុគ្គលដែលគេហៅថាជា “ក្បាល” ឬក៏ “ប្រភព” នៃបុគ្គល ឬក៏ក្រុមណានោះទេ។ ដូច្នេះ អត្ថន័យនេះនៅតែមានការសង្ស័យយ៉ាងខ្លាំង ដោយគ្មានឧទាហរណ៍ច្បាស់លាស់ ដើម្បីគាំទ្រវានោះទេ។

ប៉ុន្តែ បើទោះជាពាក្យ “ក្បាល” មានន័យថា “ប្រភព” ក្នុងកណ្ឌគម្ពីរអេភេសូរ ៥:២៣ ក៏ដោយ តើប្ដីជាប្រភពនៃអ្វី? តើរូបកាយទទួលបានអ្វីពីក្បាល? វាទទួលបានអាហារូបត្ថម្ភ (ដែលបានរៀបរាប់នៅក្នុងខ២៩)។ ហើយយើងអាចយល់បានថា ដោយសារមាត់នៅជាប់ជាមួយនឹងក្បាល និងដោយសារអាហារបំប៉នមកតាមមាត់ដល់រាងកាយ។ ប៉ុន្តែ នោះមិនមែនរាងកាយទាំងអស់ទទួលបានពីក្បាលទេ។ វាទទួលបានការណែនាំព្រោះភ្នែកស្ថិតនៅជាប់ជាមួយក្បាល។ ហើយវាទទួលបានការដាស់តឿនឲ្យប្រុងប្រយ័ត្ន និងការការពារ ព្រោះត្រចៀកនៅជាប់នឹងក្បាល។ ហើយវាទទួលបានការដឹកនាំ និងការគ្រប់គ្រង ព្រោះតែខួរក្បាលនៅក្នុងក្បាល។

ម្យ៉ាងវិញទៀត ប្រសិនបើប្ដីដែលជាក្បាល គឺជាសាច់ឈាមតែមួយជាមួយនឹងប្រពន្ធដែលជារូបកាយរបស់គាត់ ហើយប្រសិនបើគាត់ជាប្រភពនៃការណែនាំ អាហារូបត្ថម្ភ និងការប្រុងប្រយ័ត្ន នោះការសន្និដ្ឋានតាមធម្មជាតិគឺប្ដីដែលជាក្បាលមានទំនួលខុសត្រូវចម្បងសម្រាប់ភាពជាអ្នកដឹកនាំ ការផ្គត់ផ្គង់ និងការការពារ។ ដូច្នេះ ទោះបីជាអ្នកផ្ដល់អត្ថន័យឲ្យ “ក្បាល” ថាជា “ប្រភព” ក៏ដោយ ក៏ការបកស្រាយធម្មតាបំផុតនៃខគម្ពីរទាំងនេះគឺថា ប្ដីត្រូវបានត្រាស់ហៅដោយព្រះជាម្ចាស់ឲ្យទទួលខុសត្រូវចម្បងសម្រាប់ការដឹកនាំ ការការពារ និងការផ្គត់ផ្គង់នៅក្នុងផ្ទះ ហើយប្រពន្ធត្រូវបានត្រាស់ហៅឲ្យគោរព និងបញ្ជាក់ពីការដឹកនាំរបស់ប្ដីដូចជាព្រះគ្រីស្ទ និងជួយឲ្យប្ដីធ្វើទៅតាមអំណោយរបស់ពួកគេ។[៨]

---

៨ សូមមើលការស្រាវជ្រាវដែលបានចុះនៅក្នុងកំណត់ចំណាំមុន។



50 Crucial Questions.indd 32 7/4/26 2:18 in the afternoon

## សំណួរទី១២
## តើការសង្កត់ធ្ងន់របស់លោកគ្រូទៅលើការដឹកនាំនៅក្នុងក្រុមជំនុំ និងភាពជាអ្នកដឹកនាំ (ក្បាល) នៅក្នុងផ្ទះ ផ្ទុយពីការសង្កត់ធ្ងន់របស់ព្រះគ្រីស្ទនៅក្នុងកណ្ឌគម្ពីរ លូកា ២២:២៦ «ឯអ្នកណាដែលធំជាងគេ ក្នុងពួកអ្នករាល់គ្នា នោះត្រូវប្រព្រឹត្តដូចជាតូចជាងគេវិញ ហើយអ្នកណាដែលនាំមុខគេ នោះដូចជាអ្នកបម្រើដែរ» ទេឬអី?

ទេ! យើងកំពុងព្យាយាមបែងចែងរឿងទាំងពីរនេះយ៉ាងជាក់លាក់នៅក្នុងតុល្យភាពព្រះគម្ពីរ ពោលគឺ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកបម្រើ។ វានឹងផ្ទុយទៅនឹងព្រះគ្រីស្ទ ប្រសិនបើយើងនិយាយថា ភាពជាអ្នកបម្រើលុបចោលការដឹកនាំ។ ព្រះយេស៊ូវមិនលុបបំបាត់ចោលភាពជាអ្នកដឹកនាំទេ ទ្រង់កំពុងកំណត់វា។ ពាក្យដែលទ្រង់ប្រើសម្រាប់ "អ្នកនាំមុខ" នៅក្នុងកណ្ឌគម្ពីរ លូកា ២២:២៦ ត្រូវបានប្រើនៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១៣:១៧ ដែលនិយាយថា៖ "ចូរស្ដាប់តាម ហើយចុះចូលនឹងពួកអ្នកដែលនាំមុខអ្នករាល់គ្នាចុះ ដើម្បីឲ្យអ្នកទាំងនោះបានថែរក្សាព្រលឹងអ្នករាល់គ្នាដោយអំណរ...ពីព្រោះអ្នកទាំងនោះថែរក្សា ហាក់ដូចជានឹងត្រូវរាប់រៀបទូលដល់ទ្រង់វិញ"។ អ្នកដឹកនាំ ("អ្នកនាំមុខ") ត្រូវធ្វើជាអ្នកបម្រើដែលមានការលះបង់ ដើម្បីថែរក្សាព្រលឹងវិញ្ញាណរបស់មនុស្ស។ ប៉ុន្តែ នេះមិនបានធ្វើឲ្យពួកគេក្លាយជាអ្នកដឹកនាំតូចទាបនោះទេ ដូចយើងឃើញនៅក្នុងពាក្យគោរព និងចុះចូល។ ព្រះយេស៊ូវមិនមែនជាអ្នកដឹកនាំដែលតូចទាបនោះទេ ពេលទ្រង់លុតជង្គង់លាងជើងជាពេលទ្រង់ប្រទានឲ្យពួកគេនូវបេសកកម្មដ៏អស្ចារ្យ។

## សំណួរទី១៣
## នៅក្នុងសំណួរទី២ និងទី៦ លោកគ្រូបាននិយាយថា ការត្រាស់ហៅមនុស្សម្នាក់មកទទួល «ទំនួលខុសត្រូវចម្បង» សម្រាប់ការដឹកនាំនៅក្នុងក្រុមជំនុំ និងផ្ទះ។ តើលោកគ្រូមានន័យយ៉ាងណាចំពោះពាក្យ «ចម្បង»?

យើងចង់មានន័យថា មានកម្រិត និងប្រភេទនៃភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី ដែលជាញឹកញាប់ស្ត្រីអាចមានទំនួលខុសត្រូវលើបាន។ មានប្រភេទនៃការបង្រៀន ការចាត់ចែង ការបម្រើព័ន្ធកិច្ច ការមានឥទ្ធិពល និងការផ្ដួចផ្ដើមគំនិត ដែលប្រពន្ធគួរតែទទួលរ៉ាប់រងនៅផ្ទះ និងស្ត្រីគួរតែរ៉ាប់រងនៅក្រុមជំនុំ។ ភាពដឹកនាំរបស់បុរសនៅផ្ទះ និងភាពជាចាស់ទុំរបស់បុរសនៅក្នុងក្រុមជំនុំមានន័យថា បុរសមានទំនួលខុសត្រូវលើគំរូនៃជីវិត សូម្បីតែភាពជាអ្នកនាំមុខមិនបានរៀបរាប់លម្អិតថា អ្នកណាធ្វើសកម្មភាពអ្វីឲ្យច្បាស់លាស់ក៏ដោយ។ ដូច្នេះ បន្ទាប់ពីការធ្លាក់ក្នុងអំពើបាបរបស់មនុស្សជាតិ ព្រះជាម្ចាស់បានហៅលោក អ័ដាម មកទទួលខុសត្រូវជាមុន (លោកុប្បត្តិ ៣:៩) មិនមែនដោយសារស្ត្រីមិនមានទំនួលខុសត្រូវចំពោះអំពើបាបនោះទេ ប៉ុន្តែដោយសារបុរសមានទំនួលខុសត្រូវចម្បង ចំពោះជីវិតនៅក្នុងសួនច្បារ—រួមទាំងអំពើបាប។

## សំណួរទី១៤
## ប្រសិនបើប្ដីត្រូវប្រព្រឹត្តនឹងប្រពន្ធរបស់ខ្លួនដូចព្រះគ្រីស្ទប្រព្រឹត្តនឹងក្រុមជំនុំ តើនោះមានន័យថា គាត់គួរតែគ្រប់គ្រងគ្រប់ទាំងរឿងលម្អិតទាំងអស់នៃជីវិតគាត់ ហើយនោះនាងគួរតែសុំការអនុញ្ញាតពីគាត់ជាមុន គ្រប់ទាំងការសម្រេចចិត្តមែនទេ?

ទេ! យើងប្រហែលជាមិនសង្កត់លើភាពស្រដៀងគ្នារវាងព្រះគ្រីស្ទ និងប្ដីរហូតនោះទេ។ មិនដូចព្រះគ្រីស្ទទេ ប្ដីទាំងអស់សុទ្ធតែមានបាប។ ពួកគេមានកម្រិត ហើយក៏មិនមានប្រាជ្ញាញាណពេញលេញនោះដែរ។ មិនត្រឹមតែប៉ុណ្ណឹងទេ ប៉ុន្តែក៏មិនដូចព្រះគ្រីស្ទនោះដែរ ប្ដីរៀបចំកូនក្រមុំមិនមែនត្រឹមសម្រាប់ខ្លួនគាត់

តែប៉ុណ្ណោះទេ តែក៏សម្រាប់ម្នាក់ទៀតដែរ ពោលគឺព្រះគ្រីស្ទ។ គាត់មិនគ្រាន់តែប្រព្រឹត្តដូចជាព្រះគ្រីស្ទទេ ប៉ុន្តែគាត់ក៏ប្រព្រឹត្តសម្រាប់ព្រះគ្រីស្ទដែរ។ នៅពេលនេះ គាត់មិនត្រូវធ្វើជាព្រះគ្រីស្ទចំពោះប្រពន្ធរបស់គាត់ឡើយ ក្រែងគាត់ជាអ្នកក្បត់ចំពោះព្រះគ្រីស្ទវិញ។ គាត់ត្រូវតែដឹកនាំតាមរបៀបដែលប្រពន្ធរបស់គាត់ត្រូវបានលើកទឹកចិត្តឲ្យពឹងផ្អែកលើព្រះគ្រីស្ទ មិនមែនពឹងផ្អែកលើខ្លួនគាត់នោះឡើយ។

ជាក់ស្តែង នោះមិនគួរឲ្យមានការត្រួតត្រាបែបមើលងាយ និងការត្រួតពិនិត្យយ៉ាងលម្អិត។ សូម្បីតែពេលធ្វើដូចជាព្រះគ្រីស្ទ ក៏ប្តីត្រូវចាំថា ព្រះគ្រីស្ទដឹកនាំក្រុមជំនុំមិនមែនក្នុងនាមជាកូនស្រីរបស់ទ្រង់នោះទេ តែជាភរិយារបស់ទ្រង់វិញ។ ទ្រង់កំពុងរៀបចំនាងឲ្យធ្វើជា "អ្នកស្នងមរដក" មិនមែនជាស្រីបម្រើទេ (រ៉ូម ៨:១៧)។ ភាពជាអ្នកដឹកនាំប្រភេទណាក៏ដោយ ដែលក្នុងនាមជាអ្នកដឹកនាំ (ក្បាល) ដែលដូចព្រះគ្រីស្ទ មានទំនោរក្នុងការចិញ្ចឹមបីបាច់ភរិយា ភាពមិនពេញវ័យផ្ទាល់ខ្លួន ឬភាពទន់ខ្សោយខាងវិញ្ញាណ ឬការខ្វះទំនុកចិត្ត តាមរយៈការគ្រប់គ្រងហួសហេតុ ការគ្រប់គ្រងដោយរើសអើង ឬការត្រួតត្រាដោយសង្កត់សង្កិន បានខកខានចំណុចនៃភាពស្រដៀងគ្នានៅក្នុងកណ្ឌគម្ពីរអេភេសូរជំពូក៥។ ព្រះគ្រីស្ទមិនបង្កើតឲ្យមានប្រពន្ធប្រភេទនេះឡើងនោះទេ។

## សំណួរទី១៥
## តើលោកគ្រូមិនគិតថា អត្ថបទព្រះគម្ពីរទាំងនេះ គឺជាឧទាហរណ៍នៃសេចក្តីសម្របសម្រួលបណ្តោះអាសន្នជាមួយនឹងឋានៈបុរសជាធំ ស្របពេលដែលកម្លាំងជំរុញដ៏សំខាន់នៃបទគម្ពីរឆ្ពោះទៅរកកម្រិតនៃភាពខុសគ្នានៃតួនាទី ដោយផ្អែកទៅលើយេនឌ័រទេឬអី?

យើងទទួលស្គាល់ថា ពេលខ្លះបទគម្ពីរផ្តល់ការណែនាំចំពោះស្ថានភាពទំនាក់ទំនងដែលមិនសមស្រប ដោយមិនអនុញ្ញាតឲ្យពួកគេធ្វើជាគំរូអចិន្ត្រៃយ៍។ ជាឧទាហរណ៍៖ ព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកផារិស៊ីថា "លោក ម៉ូសេ



50 Crucial Questions.indd 35 7/4/26 2:18 in the afternoon

អនុញ្ញាតឲ្យអ្នករាល់គ្នាលែងប្រពន្ធទៅ គឺដោយព្រោះតែចិត្តអ្នករាល់គ្នារឹងរបឹងប៉ុណ្ណោះ តែពីដើមមកមិនមែនដូច្នោះទេ» (ម៉ាថាយ ១៩:៨)។ ឧទាហរណ៍មួយទៀតគឺបទបញ្ញត្តិអំពីរបៀបដែលទាសករជាគ្រីស្ទបរិស័ទទាក់ទងជាមួយចៅហ្វាយរបស់ពួកគេ ទោះជាសាវ័ក ប៉ុល ចង់ឲ្យអ្នកបម្រើគ្រប់រូបដែលម្ចាស់របស់គាត់ទទួល «តែមិនមែនដូចជាបាវបម្រើទៀតឡើយ គឺលើសជាងបាវបម្រើទៅទៀត ទុកដូចជាប្អូនស្ងួនភ្ងាវិញ» (ភីលេម៉ូន ១:១៦)។

ប៉ុន្តែ យើងមិនបានដាក់ការចូលចិត្តភាពជាអ្នកដឹកនាំរបស់ប្ដី ឬភាពជាចាស់ទុំរបស់បុរសៗដែលព្រះជាម្ចាស់បានរចនាឡើងទៅនឹងចំណាត់ថ្នាក់ដូចគ្នានឹងការលែងលះ និងទាសភាពនោះទេ។ ហេតុផលដែលយើងមិនធ្វើបែបនេះ មានបីចំណុចនេះ៖

១. ភាពជាមនុស្សប្រុស និងស្រីជាមួយនឹងភាពខុសគ្នានៃតួនាទីដែលត្រូវគ្នាមួយចំនួន មានការចាក់ឫសនៅក្នុងកិច្ចការបង្កើតរបស់ព្រះជាម្ចាស់ (លោកុប្បត្តិ១ និង២) មុនពេលការបង្ខូចទ្រង់ទ្រាយ ដោយអំពើបាបនៃស្ថានភាពបច្ចុប្បន្នត្រូវបានបង្កើតឡើង (លោកុប្បត្តិ ៣)។ អំណះអំណាងនេះគឺដូចគ្នាដែរ យើងជឿថា ស្ត្រីដែលផ្សាយដំណឹងល្អ និងបម្រើ ដើម្បីការពារអាពាហ៍ពិពាហ៍ភេទដូចគ្នាទាស់ប្រឆាំងនឹងអំណះអំណាង (ដែលរីករាលដាលកាន់តែខ្លាំងឡើង) ដែលថា «ការរុញច្រាននៃកម្រិត» នៃព្រះគម្ពីរនាំឲ្យមានការចងសម្ព័ន្ធភាពស្រឡាញ់ភេទដូចគ្នា។ ពួកគេនឹងនិយាយថា៖ «ទេ ពីព្រោះការរុញច្រានកម្រិតនៃព្រះគម្ពីរមិនមែនមានន័យថានឹងរុះរើលក្ខណៈលំដាប់លំដោយនៃធម្មជាតិដែលព្រះជាម្ចាស់បានបង្កើតឡើងឡើយ»។ នោះជាអំណះអំណាងមូលដ្ឋានរបស់យើងផងដែរ។
២. ការជំរុញការប្រោសលោះនៃព្រះគម្ពីរមិនមានគោលបំណងលុបបំបាត់ការដឹកនាំ និងការចុះចូលនោះទេ ប៉ុន្តែដើម្បីស្តារពួកវាឡើងវិញនូវគោលបំណងដើមរបស់ពួកវាតាមលំដាប់លំដោយដែលបានបង្កើត។
៣. ព្រះគម្ពីរគ្មានការចោទប្រកាន់អំពីភាពជាអ្នកដឹកនាំប្រកបដោយសេចក្ដីស្រឡាញ់ ហើយមិនលើកទឹកចិត្តឲ្យបោះបង់វាចោលឡើយ។ ដូច្នេះ វា



50 Crucial Questions.indd 36 7/4/26 2:18 in the afternoon

ជារឿងខុសឆ្គងក្នុងការបង្ហាញថា ព្រះគម្ពីរមានភាពស្មើគ្នាដ៏លើសលប់ជាមួយនឹងអត្ថបទបែបពួយុកោដែលទាក់ទងតាមបរិបទមួយចំនួន។ ការរុញច្រានភាពផ្ទុយគ្នានៃបទគម្ពីរជាធម្មតាមិនមានឡើយ។ វាហាក់ដូចជាមាននៅពេលដែលគោលបំណងនៃបទគម្ពីរ ដើម្បីលោះការដឹកនាំ និងការចុះចូលត្រូវបានបង្ហាញថាជាការធ្វើឲ្យខូចដល់វា។ (សូមមើលសំណួរទី៥០ សម្រាប់ឧទាហរណ៍នៃកំហុសនៃការកាត់ស្រាយលើខគម្ពីរនេះ)។

## សំណួរទី១៦
## តើអំណះអំណាងផ្សេងៗមិនបានធ្វើឡើង ដើម្បីការពារការដកស្ត្រីចេញពីការងារជាគ្រូគង្វាលសព្វថ្ងៃស្របគ្នាទៅនឹងអំណះអំណាងដែលគ្រីស្ទបរិស័ទធ្វើឡើង ដើម្បីការពារទាសភាពនៅក្នុងសតវត្សទី១៩ទេឬអី?

សូមមើលសំណួរទី១៥សម្រាប់ការចាប់ផ្តើមសំណួររបស់យើងចំពោះបញ្ហានៃសំណួរនេះ។ ដើម្បីនិយាយឲ្យកាន់តែស៊ីជម្រៅ ការរក្សាចំណងអាពាហ៍ពិពាហ៍មិនសមស្របជាមួយនឹងការរក្សាទាសភាពទេ។ ការកើតមានឡើងនៃភាពជាបាវបម្រើ គឺមិនស្ថិតនៅក្នុងការបង្កើតក្រឹត្យវិន័យណាមួយនោះទេ ប៉ុន្តែគឺជាការកើតមានឡើងនៃចំណងអាពាហ៍ពិពាហ៍វិញ។ ពាក្យទូន្មានរបស់សាវ័ក ប៉ុល អំពីលក្ខណៈដែលពួកបាវបម្រើ និងពួកចៅហ្វាយគួរតែមានទំនាក់ទំនងរវាងគ្នានឹងគ្នាមិនបានសន្មតថា ជាការល្អចំពោះការតាំងឡើងនៃទាសភាពនោះទេ។ ផ្ទុយទៅវិញ គ្រាប់ពូជសម្រាប់ការរម្លាយទាសភាពត្រូវបានសាបព្រោះនៅក្នុងកណ្ឌគម្ពីរ ភីលេម៉ូន ១:១៦ («តែមិនមែនដូចជាបាវបម្រើទៀតឡើយ គឺលើសជាងបាវបម្រើទៅទៀតទុកដូចជាប្អូនស្ងួនភ្ញាវិញ»)។ កណ្ឌគម្ពីរ អេភេសូរ ៦:៩ [«ចៅហ្វាយរាល់គ្នាអើយ…ទាំងលែងគំហកកំហែង (ចំពោះបាវបម្រើរបស់អ្នក)»] កណ្ឌគម្ពីរ កូឡុស ៤:១ («ពួកចៅហ្វាយរាល់គ្នាអើយ ចូរបើកឲ្យដល់អ្នកបម្រើរបស់អ្នកតាមត្រឹមត្រូវ ហើយទៀងត្រង់ចុះ») និងកណ្ឌគម្ពីរ ១ធីម៉ូថេ ៦:១-២ (ចៅហ្វាយ និងបាវបម្រើគឺជា «បងប្អូន»)។ នៅពេលដែលគ្រាប់ពូជនៃសមភាពទាំងនេះត្រូវបានចេញផ្កាពេញលេញ ការតាំង

ឡើងនៃទាសភាពនឹងត្រូវបានបញ្ឈប់។ តាមពិតទៅ នៅពេលដែលយើងបានយល់បានត្រឹមត្រូវអំពីកណ្ឌគម្ពីរ ១ធីម៉ូថេ ១:១០ នៅក្នុងការរាយនាម “អ្នកត្រូវបានគេយកធ្វើជាបាវបម្រើ” ក្នុងចំណោមបញ្ជីមនុស្សដែល “មនុស្សទមិឡល្មើស និងមនុស្សដែលមានបាប” (៩)។

ប៉ុន្តែ សេចក្តីទូន្មានរបស់សាវ័ក ប៉ុល អំពីលក្ខណៈដែលប្តីប្រពន្ធគួរតែមានទំនាក់ទំនងចំពោះគ្នាទៅវិញទៅមកក្នុងអាពាហ៍ពិពាហ៍សន្មតបានថា ជាការល្អចំពោះការតាំងឡើងនៃចំណងអាពាហ៍ពិពាហ៍—ហើយមិនត្រឹមតែជាការល្អប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាមូលដ្ឋានគ្រឹះស្របតាមបំណងព្រះហឫទ័យរបស់ព្រះអាទិករតាំងពីដើមដំបូងមកផងដែរ (អេភេសូរ ៥:៣១-៣២)។ លើសពីនេះទៅទៀត សាវ័ក ប៉ុល បានកំណត់មូលដ្ឋានគ្រឹះនៃអាពាហ៍ពិពាហ៍ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងការបង្កើតតាមលក្ខណៈដែលបង្ហាញថា ក្រឹត្យវិន័យរបស់ទ្រង់សម្រាប់អាពាហ៍ពិពាហ៍ក៏ស្របទៅតាមលំដាប់លំដោយនៃការបង្កើតផងដែរ។ សាវ័ក ប៉ុល បានដកស្រង់ព្រះបន្ទូលពីកណ្ឌគម្ពីរ លោកុប្បត្តិ ២:២៤ “ហើយអ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ” ហើយគាត់ពន្យល់ថា៖ “តែខ្ញុំនិយាយខាងឯព្រះគ្រីស្ទ និងពួកជំនុំវិញ”។ តាមរយៈ “អាថ៌កំបាំង” នេះ គាត់បានគូសវាសគំរូនៃទំនាក់ទំនងរវាងប្តីជាក្បាល (ជារូបតំណាងនៃព្រះគ្រីស្ទ) និងថាប្រពន្ធជារូបកាយ ឬសាច់ឈាមរបស់គាត់ (ជារូបភាពនៃក្រុមជំនុំ) និងទទួលបានភាពសមស្របនៃការដឹកនាំរបស់ប្តី និងការចុះចូលរបស់ប្រពន្ធ។ ដូច្នេះ ក្រឹត្យវិន័យរបស់សាវ័កប៉ុល ទាក់ទងនឹងអាពាហ៍ពិពាហ៍ គឺដូចជាមានឫសគល់នៃលំដាប់លំដោយនៃការបង្កើតដូចជាការតាំងឡើងផ្ទាល់ដែរ។ នេះមិនមែនជាសេចក្តីពិតនៃភាពជាបាវបម្រើនោះទេ។ ហេតុដូច្នេះហើយ ខណៈពេលដែលម្ចាស់បាវបម្រើមួយចំនួននៅសតវត្សទី១៩បានទទួលស្គាល់ថា ពីការជជែកអះអាងតាមរបៀបដែលស្របនឹងការការពាររបស់យើងអំពីតួនាទីផ្សេងគ្នានៅក្នុងអាពាហ៍ពិពាហ៍គឺមានលក្ខណៈមិនស៊ីជម្រៅ និងមានលក្ខណៈនាំឲ្យមានការយល់ខុស។ ពួក



50 Crucial Questions.indd 38 7/4/26 2:18 in the afternoon

អ្នកដែលព្យាយាមការពារភាពជាបាវបម្រើពីព្រះគម្ពីរច្បាស់ជាខុសក្នុងការកាត់ស្រាយរបស់ពួកគេ ហើយបានវង្វេងជាមួយនឹងការរ៉េកញ៉ែកទាំងនោះហើយ។

លោកស្រី ម៉ារី ស្ទីវ៉ត វ៉ាន់ លីវិន (Mary Stewart Van Leeuwen) បានចង្អុលបង្ហាញអំពីកណ្ឌគម្ពីរ ១ធីម៉ូថេ ៦:១-៦ យោងទៅតាមអ្នកគាំទ្រឲ្យមានទាសភាពនៅសតវត្សទី១៩ ដែលជាគ្រីស្ទបរិស័ទ «ទោះបីជាការតាំងឡើងនៃទាសភាពមិនបានឆ្លុះបញ្ចាំងពីការបង្កបង្កើតដំបូងក្តី...លក្ខណៈដែលសាវ័ក ប៉ុល បានពឹងផ្អែកលើការបើកសម្តែងពីព្រះយេស៊ូវផ្ទាល់មានន័យថា នរណាម្នាក់ដែលមានបំណងចង់លុបបំបាត់ភាពជាបាវបម្រើ (ឬសូម្បីតែការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់បាវបម្រើ) កំពុងប្រឆាំងនឹងបញ្ញត្តិព្រះគម្ពីរសម្រាប់សង្គម ដែលមិនចេះចប់»។[៩] ទាក់ទងនឹងការរ៉េកញ៉ែកនេះ សាវ័ក ប៉ុល បានឆ្លើយតបចំពោះការអះអាងនេះដោយប្រើការបង្រៀនរបស់ព្រះយេស៊ូវដែលមិនឲ្យ «រក្សា» ការតាំងឡើងនៃភាពជាបាវបម្រើនោះទេ ប៉ុន្តែដើម្បីគ្រប់គ្រងអាកប្បកិរិយារបស់បាវបម្រើ និងចៅហ្វាយនាយដែលជាគ្រីស្ទបរិស័ទនៅក្នុងស្ថាប័នមួយដែលមានរួចមកហើយ នៅក្នុងផ្នែកមួយដោយសារអំពើបាប។ អ្វីដែលព្រះយេស៊ូវគាំទ្រ គឺសេរីភាពនៅខាងក្នុង និងសេចក្តីស្រឡាញ់ដែលមានឆន្ទៈក្នុងការបម្រើបន្ថែមទៀត ទោះជាការទាមទារមិនយុត្តិធម៌ក្តី (ម៉ាថាយ ៥:៤១)។ ហេតុនេះ ជារឿងខុសឆ្គងដែលនិយាយថា ព្រះបន្ទូលរបស់ព្រះយេស៊ូវផ្តល់មូលដ្ឋានគ្រឹះមួយសម្រាប់ទាសភាពតាមរបៀបដែលការបង្កើតផ្តល់មូលដ្ឋានគ្រឹះសម្រាប់អាពាហ៍ពិពាហ៍។ ព្រះយេស៊ូវមិនបានផ្តល់មូលដ្ឋានគ្រឹះណាមួយសម្រាប់ទាសភាពនោះទេ ប៉ុន្តែការបង្កើតផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់អាពាហ៍ពិពាហ៍ និងសម្រាប់តួនាទីដែលជួយបំពេញដល់គ្នាទៅវិញទៅមករបស់ប្តីប្រពន្ធ។

ចុងក្រោយ ប្រសិនបើអស់អ្នកដែលសួរសំណួរនេះមានការព្រួយបារម្ភ

៩ . លោកស្រី Mary Stewart Van Leeuwen, *Gender and Grace: Love, Work, and Parenting in a Changing World* (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៩០), ទំព័រ២៣៨។



50 Crucial Questions.indd 39 7/4/26 2:18 in the afternoon

ដើម្បីនឹងជៀសវាងការធ្វើខុសរបស់ពួកគ្រីស្ទបរិស័ទដែលមានទំនោរការពារទាសភាពនិយម យើងត្រូវចងចាំពីលទ្ធភាពពិតប្រាកដដែលថា វាមិនមែនជាក្រុមដែលគាំទ្រថា បុរស និងស្ត្រីបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមកទេ ប៉ុន្តែជាក្រុមដែលគាំទ្របុរស និងស្ត្រីមានភាពស្មើគ្នាវិញទេតើ។ សព្វថ្ងៃនេះ ចំណុចនេះស្រដៀងនឹងអ្នកការពារទាសភាពនៅសតវត្សទី១៩ នៅក្នុងលក្ខណៈដ៏សំខាន់បំផុត៖ ការប្រើអំណះអំណាងចេញពីព្រះគម្ពីរ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃការអនុលោមជាបណ្តោះអាសន្នទៅនឹងសម្ពាធដ៏ខ្លាំងមួយចំនួននៅក្នុងសង្គមនេះ (សម្រាប់ជាប្រយោជន៍ភាពជាបាវបម្រើនៅក្នុងពេលនោះ និងស្ត្រីនិយមបច្ចុប្បន្ននេះ)។

## សំណួរទី១៧

**ដោយសារការបង្រៀនព្រះគម្ពីរសញ្ញាថ្មីអំពីការចុះចូលរបស់ប្រពន្ធនៅក្នុងអាពាហ៍ពិពាហ៍បានរកឃើញនៅក្នុងផ្នែកនៃបទគម្ពីរដែលគេស្គាល់ថាជា «វិន័យគ្រួសារ» (Haustafeln) ដែលត្រូវបានកាន់កាប់មួយផ្នែករប្បធម៌សតវត្សទីមួយ យើងមិនគួរទទួលស្គាល់ថា អ្វីដែលបទគម្ពីរកំពុងបង្រៀនយើងគឺមិនត្រូវអាក់អន់ចិត្តនឹងរប្បធម៌បច្ចុប្បន្នទេ ប៉ុន្តែត្រូវសមនឹងវារហូតដល់ចំណុចមួយ ហើយដូច្នេះតើត្រូវមានឆន្ទៈក្នុងការផ្លាស់ប្តូរទម្លាប់របស់យើងអំពីរបៀបដែលបុរស និងស្ត្រីមានទំនាក់ទំនងជាមួយគ្នាជាជាងកាន់ខ្ជាប់ គំរូបណ្តោះអាសន្ននៃសតវត្សទីមួយ?**

នេះគឺជាទម្រង់ដ៏ស្មុគស្មាញជាងមុននៃប្រភេទសំណួរដែលបានសួររួចហើយនៅក្នុងសំណួរទី១៥ និង១៦។ មានមតិយោបល់បន្ថែមមួយចំនួនទៀតដែលអាចមានប្រយោជន៍ដល់យើង។ ទីមួយ តាមរយៈការពន្យល់ពាក្យ "វិន័យគ្រួសារ" សំដៅនៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២២-៦:៩; កូឡុស ៣:១៨-៤:១ ហើយន័យតិចជាងនេះបន្តិច ១ពេត្រុស ២:១៣-៣:៧ ខគម្ពីរដែលរួមមានការណែនាំសម្រាប់សមាជិកគ្រួសារជាគូរៗ៖ ប្រពន្ធ និងប្តី កូន និងឪពុកម្តាយ និងទាសករ និងចៅហ្វាយនាយ។



50 Crucial Questions.indd 40 7/4/26 2:18 in the afternoon

បញ្ហាដំបូងជាមួយនឹងអំណះអំណាងនេះគឺថា ភាពស្រដៀងគ្នាទៅនឹង "វិន័យគ្រួសារ" ទាំងនេះនៅជុំវិញពិភពលោក គឺមិនដូចគ្នានឹងអ្វីដែលយើងមាននៅក្នុងគម្ពីរសញ្ញាថ្មីទេ។ វាមិនមែនទាល់តែសោះ ដែលថាសាវ័ក ប៉ុល គ្រាន់តែយកខ្លឹមសារ ឬទម្រង់ពីវប្បធម៌របស់គាត់មកនិយាយ។ ទាំងពីរមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពី "ភាពស្របគ្នា" ដែលមិនមែនជាព្រះគម្ពីរអ្វីដែលយើងស្គាល់។[១០]

បញ្ហាទីពីរនៃអំណះអំណាងនេះគឺថា វាពង្រីកអតិបរមានូវអ្វីដែលចៃដន្យ (រឿងតិចតួចនៃការបង្រៀនរបស់សាវ័ក ប៉ុល មានដូចគ្នាទៅនឹងពិភពនៅជុំវិញ) និងកាត់បន្ថយអ្វីដែលសំខាន់ទាំងស្រុង (ធម្មជាតិ និងមូលដ្ឋានគ្រឹះនៃអ្វីដែលសាវ័ក ប៉ុល បានបង្រៀនអំពីអាពាហ៍ពិពាហ៍នៅក្នុង "វិន័យគ្រួសារ")។ យើងបានបង្ហាញនៅក្នុងសំណួរទី១៥ និង១៦ ថាសាវ័ក ប៉ុល ស្ទើរតែមិនផ្លះបញ្ចាំងក្នុងការនិយាយរឿងខ្លះដែលមានលក្ខណៈស្រពិចស្រពិលទៅនឹងវប្បធម៌ជុំវិញនោះ។ គាត់ផ្អែកលើការបង្រៀនរបស់គាត់អំពីភាពជាអ្នកដឹកនាំលើលក្ខណៈនៃទំនាក់ទំនងរបស់ព្រះគ្រីស្ទចំពោះក្រុមជំនុំ ដែលគាត់មើលឃើញថាជា "អាថ៌កំបាំង" បានបង្ហាញនៅក្នុងកណ្ឌគម្ពីរ លោកុប្បត្តិ ២:២៤ ហើយដូច្នេះនៅក្នុងការបង្កើតខ្លួនវាផ្ទាល់។

យើងគិតថា វាមិនផ្តល់កិត្តិយសដល់សេចក្តីសច្ចធម៌របស់សាវ័ក ប៉ុល ឬការដែលព្រះបានបណ្តាលឲ្យតែងព្រះគម្ពីរ ដើម្បីអះអាងថាសាវ័ក ប៉ុល បាន

១០ នៅពេលយើងសរសេរសំណេរនេះដំបូងសម្រាប់ការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ *(Recovering Biblical Manhood and Womanhood)* សំណេរជាភាសាអង់គ្លេសដកស្រង់មកច្រើនបំផុតចំពោះសំណួរនេះគឺនិក្ខេបបទដោយ៖ លោក J. E. Crouch, *The Origin and Intention of the Colossian Haustafel, Forschungen zur Religion und Literatur des Alten und Neuen Testaments 109* (Göttingen: Vandenhoeck und Ruprecht, 1972)។ ឧទាហរណ៍នៃការបកប្រែជាក់ស្តែងដែលស្របគ្នាទៅជាភាសាអង់គ្លេសអាចអាននៅក្នុងសំណេរនេះ។ សម្រាប់ការស្រាវជ្រាវបន្ថែមនាពេលថ្មីៗជាភាសាអង់គ្លេសលើប្រធានបទនេះ សូមមើលការនិពន្ធរបស់លោក James P. Hering, *The Colossian and Ephesian Haustafeln in Theological Context: An Analysis of Their Origins, Relationship, and Message,* American University Studies, ser. ៧, Theology and Religion 260 (New York: P. Lang, ឆ្នាំ២០០៧); លោក M. Y. McDonald, "Reading the New Testament Household Codes in Light of New Research on Children and Childhood in the Roman World," Studies in Religion ៤១, លេខ៣ (ឆ្នាំ២០១២), ទំព័រ៣៧៦-៨៧។

ប្រើអំណះអំណាងនៃការដាស់តឿនរបស់គាត់គឺត្រូវបានមានការចាក់ឫសតាមលំដាប់លំដោយនៃការបង្កើត និងក្នុងកិច្ចការរបស់ព្រះគ្រីស្ទ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃភាពបណ្ដោះអាសន្ននៃវប្បធម៌គាត់ទេ។ វាទំនងជាច្រើនជាងនេះទៅទៀត ដែលជម្រៅខាងទ្រឹស្ដី និងការបំផុសគំនិតដ៏ទេវភាពរបស់លោកបាននាំឲ្យគាត់មិនត្រឹមតែមានការរើសអើងយ៉ាងខ្លាំងនៅក្នុងអ្វីដែលគាត់បានកាន់កាប់ពីពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញអំពីភាពត្រឹមត្រូវនៃក្រមសីលធម៌របស់គាត់ជាមួយនឹងការបង្កើតតែក្នុងកន្លែងដែលពួកគេមានសុពលភាពប៉ុណ្ណោះ។ ដូច្នេះហើយ បានជាយើងជឿថាមានហេតុផលដ៏ល្អ ដើម្បីបញ្ជាក់ការអនុវត្តដ៏យូរអង្វែងនៃគំរូរបស់សាវ័ក ប៉ុល សម្រាប់ជីវិតអាពាហ៍ពិពាហ៍៖ សូមឲ្យមនុស្សប្រុស ដែលជាអ្នកដឹកនាំគ្រួសារស្រឡាញ់ និងដឹកនាំព្រះគ្រីស្ទបានស្រឡាញ់ និងដឹកនាំដល់ក្រុមជំនុំ ហើយឲ្យប្រពន្ធគាំទ្រការដឹកនាំដែលពេញដោយសេចក្ដីស្រឡាញ់នោះ ខណៈពេលដែលក្រុមជំនុំថ្វាយព្រះកិត្តិយសដល់ព្រះគ្រីស្ទចុះ។

## សំណួរទី១៨

## តើអ្វីទៅជារបៀបនៃការរំដោះខាងឯវប្បធម៌ ដែលព្រះយេស៊ូវបានប្រព្រឹត្តនឹងមនុស្សស្រី? តើទ្រង់មិនបានចូលទៅក្នុងប្រពៃណីតាមឋានានុក្រមរបស់យើង ហើយបើកផ្លូវឲ្យស្ត្រីចូលទៅក្នុងគ្រប់តួនាទីខាងព័ន្ធកិច្ចទេឬអី?

យើងជឿថា ព័ន្ធកិច្ចបម្រើរបស់ព្រះយេស៊ូវជាប់ទាក់ទងខុសប្លែកពីរបៀបដែលបុរស និងស្ត្រីមានបាប ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក។ ជាញយដង មានភស្តុតាងដែលបង្ហាញពីការយកព្រះទ័យទុកដាក់របស់ព្រះជាម្ចាស់ចំពោះស្ត្រី៖ «ឯស្ត្រីនេះជាពូជលោក អ័ប្រាហាំ ដែលអារក្សសាតាំងបានចងគាត់១៨ឆ្នាំមកហើយ ដូច្នេះតើមិនគួរនឹងស្រាយឲ្យរួចពីចំណងនេះ នៅថ្ងៃឈប់សម្រាកដែរទេឬអី» (លូកា ១៣:១៦)។ អ្វីៗដែលព្រះយេស៊ូវបានបង្រៀន និងបានធ្វើ គឺជាការវាយប្រហារដល់សេចក្ដីអំនួត ដែលធ្វើឲ្យបុរស និងស្ត្រីបន្ទុះ



50 Crucial Questions.indd 42 7/4/26 2:18 in the afternoon

បង្គាប់គ្នាទៅវិញទៅមក។ គ្រប់អ្វីៗដែលព្រះយេស៊ូវបានបង្រៀន និងបានធ្វើ គឺជាការត្រាស់ហៅឲ្យបន្ទាបខ្លួន និងឲ្យមានសេចក្ដីស្រឡាញ់ ដែលអាចកម្ចាត់ការលើកតម្កើងខ្លួនឯងចេញពីការដឹកនាំ ហើយឲ្យមានភាពជាអ្នកបម្រើដែលចុះចូល។ ព្រះទ្រង់បានចាត់ទុកការដែលក្រឡេកឃើញស្ត្រី ហើយមានតម្រេកសម្រើបចង់បាននោះឈ្មោះថា បានប្រព្រឹត្តសេចក្ដីកំផិតនឹងនាងនោះនៅក្នុងចិត្តខ្លួនហើយ ព្រមទាំងព្រមានថា នឹងត្រូវបោះទៅក្នុងស្ថាននរក (ម៉ាថាយ ៥:២៨-២៩)។ ព្រះអង្គបានថ្កោលទោសចំពោះការបោះបង់ចោលស្ត្រីដោយការលែងលះ (ម៉ាថាយ ១៩:៨-៩)។ ព្រះអង្គមានបន្ទូលប្រាប់យើងថា នៅថ្ងៃជំនុំជម្រះ នោះមនុស្សលោកនឹងត្រូវរៀបរាប់ប្រាប់ពីអស់ទាំងហេតុនៃពាក្យឥតប្រយោជន៍ ដែលគេបាននិយាយ (ម៉ាថាយ ១២:៣៦)។ ព្រះអង្គបានបង្គាប់ឲ្យយើងធ្វើអស់ទាំងការអ្វី ដែលយើងរាល់គ្នាចង់ឲ្យមនុស្សលោកប្រព្រឹត្តនឹងខ្លួន នោះត្រូវឲ្យយើងប្រព្រឹត្តនឹងគេដូច្នោះដែរ (ម៉ាថាយ ៧:១២)។ ព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកសម្ដេចសង្ឃដែលគ្មានសេចក្ដីមេត្តាថា៖ «…ពួកស្រីសំផឹងគេចូលទៅក្នុងនគរព្រះមុនអ្នករាល់គ្នា» (ម៉ាថាយ ២១:៣១)។ ស្ត្រីៗបានអមដំណើរទ្រង់ ទ្រង់បានបង្រៀនដល់ស្ត្រី ហើយស្ត្រីបានធ្វើទីបន្ទាល់អំពីការមានព្រះជន្មឡើងវិញរបស់ទ្រង់។ យើងអាចអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូវ ទោះសេចក្ដីទាំងនោះបានប្រឆាំងនឹងរាល់ទំនៀមទម្លាប់សង្គមដែលបន្ទាប ឬបំពានលើបុរស និងស្ត្រីក្ដី «តើហេតុអ្វីបានជាធ្វើខុសនឹងបញ្ញត្តិព្រះ ដោយកាន់តាមទំនៀមទម្លាប់បុរាណរបស់អ្នករាល់គ្នាដូច្នេះដែរ» (ម៉ាថាយ ១៥:៣)។

ប៉ុន្ដែ តើនៅកន្លែងណាដែលព្រះយេស៊ូវមានព្រះបន្ទូល ឬរិះគន់អំពីលំដាប់លំដោយនៃការបង្កើតដែលបុរសមានទំនួលខុសត្រូវចម្បងក្នុងការដឹកនាំ ការពារ និងផ្គត់ផ្គង់? គ្មានកន្លែងណាដែលព្រះអង្គបានសួរអំពីលំដាប់លំដោយដ៏ល្អឡើយ។ វាមិនសមហេតុផលទាល់តែសោះ ដែលព្រះយេស៊ូវត្រូវត្រឡប់មកប្រឆាំងនឹងការដឹកនាំដោយសេចក្ដីស្រឡាញ់របស់ស្វាមី ឬជាចាស់ទុំខាងឯព្រលឹងវិញ្ញាណ ដោយសារតែស្ត្រីបានបម្រើ បាន

រៀន ហើយបានប្រាប់អំពីការរស់ឡើងវិញ របស់ព្រះយេស៊ូវទៅពួកសិស្សនោះ។ យើងនឹងមិនវែកញែកដោយគ្រាន់តែព្រះយេស៊ូវបានជ្រើសរើសបុរសដប់ពីរនាក់ឲ្យធ្វើជាសាវ័កដ៏មានអំណាចរបស់ទ្រង់ នោះព្រះយេស៊ូវច្បាស់ជាសព្វព្រះទ័យនឹងភាពចាស់ទុំនៃពួកបុរសតែនៅក្នុងក្រុមជំនុំនោះឡើយ។ ប៉ុន្តែការវែកញែកនេះយ៉ាងហោចណាស់អាចយកជាការបានដូចជាការវែកញែកផ្សេងទៀត ដែលព្រះយេស៊ូវបានធ្វើ មានន័យថា ទ្រង់នឹងប្រឆាំងនឹងភាពចាស់ទុំរបស់បុរសទាំងអស់ ឬការដឹកនាំរបស់ប្ដី។ កិច្ចខិតខំប្រឹងប្រែងនៅក្នុងការបង្ហាញថា ការបម្រើព័ន្ធកិច្ចរបស់ព្រះយេស៊ូវ គឺជាផ្នែកមួយដ៏សំខាន់នៃការជំរុញស្របតាមព្រះគម្ពីរប្រឆាំងនឹងតួនាទី ដោយផ្អែកលើយេនឌ័រអាចត្រូវបានទ្រទ្រង់ដោយការសន្និដ្ឋាន (ជាជាងការបង្ហាញ) ថា ទ្រង់ចង់ចាត់ទុកជាមោឃៈ ចំពោះភាពជាអ្នកដឹកនាំ និងការចុះចូលជាជាងកែតម្រូវពួកគេវិញ។ អ្វីដែលច្បាស់នោះគឺថា ព្រះយេស៊ូវបានលុបបំបាត់ភាពជាអ្នកដឹកនាំនៃសេចក្ដីអំនួត ភាពភ័យខ្លាច និងការលើកតម្កើងខ្លួនឯង ហើយថាទ្រង់ក៏បានលើកតម្កើងស្ត្រីជាបុគ្គលដែលស័ក្តិសមនឹងការគោរពដ៏ខ្ពង់ខ្ពស់ក្រោមការគ្រប់គ្រងរបស់ព្រះជាម្ចាស់។

## សំណួរទី១៩
## តើតួនាទីដ៏សំខាន់ដែលស្ត្រីមានក្នុងកិច្ចបម្រើព័ន្ធកិច្ចជាមួយសាវ័ក ប៉ុល មិនបានបង្ហាញថា ការបង្រៀនរបស់គាត់មិនមានន័យថា ស្ត្រីគួរតែត្រូវបានដកចេញពីកិច្ចបម្រើផ្សាយទេឬអី?

បាទ! បានបង្ហាញ ប៉ុន្តែបញ្ហាគឺមិនមែនថា ស្ត្រីគួរត្រូវបានគេដកចេញពីព័ន្ធកិច្ច ឬអត់នោះទេ។ យើងមិនត្រូវដកពួកគាត់ចេញទេ។ មានការបម្រើព័ន្ធកិច្ចរាប់រយបើកចំហសម្រាប់បុរស និងស្ត្រី។ យើងត្រូវសួរសំណួររបស់យើងដោយប្រុងប្រយ័ត្ន។ បើមិនដូច្នេះទេ នោះយើងអាចនឹងបិទបាំងសេចក្ដីពិតពីដើមដំបូង។

បញ្ហានៅត្រង់ថា តើមានស្ត្រីណាម្នាក់បានបម្រើជាមួយនឹងសាវ័ក ប៉ុល



50 Crucial Questions.indd 44 7/4/26 2:18 in the afternoon

នៅក្នុងព័ន្ធកិច្ចបានបំពេញតួនាទី ដែលមិនសមស្រប ហើយបានដាក់ដែនកំណត់លើភាពចាស់ទុំរបស់បុរសទេ? យើងជឿថាចម្លើយចំពោះសំណួរនេះ គឺគ្មានទេ។ លោក ធម ឆ្រេនើ (Tom Schreine) បានដោះស្រាយនឹងបញ្ហានេះកាន់តែពេញលេញនៅក្នុងសំណួរទី១១នៅក្នុងសៀវភៅ ការស្តារឡើងវិញនូវភាពជាបុរស និងស្ត្រីស្របតាមព្រះគម្ពីរ។ ប៉ុន្តែ យើងប្រហែលជាអាចលើកឧទាហរណ៍អំពីស្ត្រីសំខាន់ៗពីរនាក់ នៅក្នុងព័ន្ធកិច្ចរបស់សាវ័ក ប៉ុល បាន។

សាវ័ក ប៉ុល មានប្រសាសន៍ថា នាង អើរ៉ូឌា និងនាង ស៊ុនទីច «ដែលបានតតាំងជាមួយនឹងខ្ញុំ ក្នុងដំណឹងល្អផង ហើយនិងអ្នក ក្លេមេន និងគូកនខ្ញុំឯទៀត» (ភីលីព ៤:២-៣)។ មានកិត្តិយសដ៏អស្ចារ្យនៅក្នុងការដាក់នាង អើរ៉ូឌា និងនាង ស៊ុនទីច ឲ្យនៅទីនេះសម្រាប់ការបម្រើព័ន្ធកិច្ច។ ប៉ុន្តែ គ្មានមូលដ្ឋានអ្វីសម្រាប់ការបញ្ជាក់ពីលក្ខណៈនៃព័ន្ធកិច្ចបម្រើរបស់ពួកគេ ដែលផ្ទុយទៅនឹងការកំណត់ដែលសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២ នោះឡើយ។ មានអ្នកខ្លះអាចនឹងប្រើការសន្មតផ្ទុយគ្នានេះ ដើម្បីប្រឆាំងនឹងដែនកំណត់ទាំងនេះ។ ច្បាស់ណាស់សាវ័ក ប៉ុល បានលើកឡើងថា ទាំង «ពួកត្រួតត្រា» និង «ពួកអ្នកជំនួយ» ដែលបានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ភីលីព ១:១ គឺជាគូកនឯទៀតៗរបស់គាត់នៅពេលដែលគាត់នៅទីនោះ។ ហើយនោះមានន័យថា បុគ្គលម្នាក់អាចជា «គូកនឯទៀត» ជាសាវ័ក ប៉ុល ដោយមិនចាំបាច់មានអំណាចលើបុរស។ (យើងកាត់ស្រាយចេញពីកណ្ឌគម្ពីរ ១ធីម៉ូថេ ៣:២ និង ៥:១៧ អ្វីដែលសម្គាល់ថា ពួកចាស់ទុំនិងពួកអ្នកជំនួយខុសពីគ្នា គឺទំនួលខុសត្រូវក្នុងការបង្រៀន និងការគ្រប់គ្រងជាទំនួលខុសត្រូវរបស់ពួកចាស់ទុំ ហើយមិនមែនជារបស់ពួកអ្នកជំនួយនោះទេ)។

សាវ័ក ប៉ុល បានសរសើរនាង ភីបេ ក្នុងនាមជា «អ្នកបម្រើ» ឬ «អ្នកជំនួយ» នៃក្រុមជំនុំនៅក្រុងកេងគ្រា ដូចដែលគាត់បានលើកឡើងថា៖ ដ្បិត



50 Crucial Questions.indd 45 7/4/26 2:18 in the afternoon

នាង “បានជួយគេជាច្រើន ព្រមទាំងខ្ញុំផង” (រ៉ូម ១៦:១-២)។ អ្នកខ្លះបានព្យាយាមប្រកែកថា ពាក្យជាភាសាក្រិកនៅក្រោយពាក្យ “អ្នកជំនួយ” ពិតជាមានន័យថា “អ្នកដឹកនាំ”។[១១] នេះគួរឲ្យសង្ស័យ ដ្បិតវាពិបាកនៅក្នុងការស្រមៃនៅក្នុងន័យណាមួយ ជាអ្វីដែលសាវ័ក ប៉ុល ចង់មានន័យដោយការលើកឡើងថា នាង ភីបេ បានក្លាយជាអ្នកដឹកនាំរបស់គាត់។ ជាការពិតណាស់ គាត់អាចមានន័យថា នាងគឺជាអ្នកដឹកនាំដ៏មានឥទ្ធិពលម្នាក់ដែលបានផ្ដល់ទីស្នាក់អាស្រ័យសម្រាប់គាត់ និងក្រុមរបស់គាត់ ឬថានាងបានប្រើឥទ្ធិពលក្នុងសហគមន៍របស់នាងសម្រាប់ប្រយោជន៍ដំណឹងល្អ និងជាពិសេសសម្រាប់សាវ័ក ប៉ុល។ នាងជាមនុស្សសំខាន់ម្នាក់ ហើយមានតួនាទីសំខាន់ក្នុងការបម្រើព័ន្ធកិច្ច។ ប៉ុន្តែ ដើម្បីទាញយកអ្វីមួយពីពាក្យដែលផ្ទុយនឹងការយល់ដឹងរបស់យើងអំពីកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២ ដែលគេមុខជាសន្និដ្ឋានថា នាង ភីបេ បានប្រើសិទ្ធិអំណាចលើមនុស្សប្រុស។ ជាក់ស្ដែង បទគម្ពីរមិនបានបង្ហាញបែបនោះទេ។

## សំណួរទី២០
## ប៉ុន្តែនាង ព្រីស៊ីល បានបង្រៀនលោក អាប៉ូឡូ មែនឬទេនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ១៨:២៦? ហើយនាងថែមទាំងត្រូវបានគេលើកឈ្មោះឡើងនៅមុខប្ដីរបស់នាងគឺលោក អ័រគីឡា។ តើការនេះមិនបង្ហាញថា ការអនុវត្តរបស់ក្រុមជំនុំដំបូងមិនបានដកស្ត្រីចេញពីការិយាល័យនៃការបង្រៀនរបស់ពួកជំនុំទេឬអី?

យើងទទួលស្គាល់ដោយរីករាយថា នាង ព្រីស៊ីល ជាគូកនបម្រើព័ន្ធកិច្ចជាមួយសាវ័ក ប៉ុល នៅក្នុងព្រះគ្រីស្ទ! (រ៉ូម ១៦:៣) នាង និងប្ដីមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងក្រុមជំនុំនៅក្រុងកូរិនថូស (១កូរិនថូស ១៦:១៩) ក៏ដូចជានៅក្រុងអេភេសូរផងដែរ។ យើងអាចគិតអំពីស្ត្រីជាច្រើននៅក្រុមជំនុំរបស់យើងសព្វថ្ងៃ

១១ ពាក្យជាភាសាក្រិក «ប្រូសស្តេតធីស» (prostatis) មិនមែនមានន័យថា «អ្នកដឹកនាំ» នោះទេ ប៉ុន្តែមានន័យថា «អ្នកជំនួយ»។ នៅក្នុងព្រះគម្ពីរវាមាននៅទីនេះប៉ុណ្ណោះ។



50 Crucial Questions.indd 46 7/4/26 2:18 in the afternoon

ដូចជានាង ព្រីស៊ីល។ គ្មានអ្វីនៅក្នុងការយល់ដឹងរបស់យើងអំពីព្រះគម្ពីរដែលថា នៅពេលប្ដីប្រពន្ធទៅជួបអ្នកមិនជឿ (ឬអ្នកជឿដែលមានការភាន់ច្រឡំ—ឬអ្នកក្រៅ) ត្រូវឲ្យប្រពន្ធនៅស្ងៀមនោះទេ។ វាងាយស្រួលសម្រាប់យើងក្នុងការស្រមៃពីភាពស្វាហាប់នៅក្នុងការពិភាក្សាបែបនេះ ដែលនាង ព្រីស៊ីល ចូលរួមចំណែកក្នុងការពន្យល់ និងការបង្ហាញអំពីពិធីបុណ្យជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវ និងកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធ។ ភាពស្វាហាប់នេះមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីមនុស្សទូទៅ ដែលជាការបង្រៀនប្រកបដោយអំណាចនៃព្រះគម្ពីរដល់ក្រុមជំនុំដែលសាវ័ក ប៉ុល បានហាមប្រាមស្ត្រីនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២។

តើអ្វីទៅជាការស័ក្ដិសមសម្រាប់បុរស និងស្ត្រីនៅក្នុងស្ថានភាពបែបនេះ? យើងមិនចង់ធ្វើឲ្យវាសាមញ្ញពេក ឬចេញបញ្ជីបទបញ្ញត្តិសិប្បនិម្មិតលើអ្វីដែលស្ត្រី និងបុរសអាចនិយាយ និងធ្វើបាននោះឡើយ។ ផ្ទុយទៅវិញ ករណីបែបនេះទាមទារឲ្យយកចិត្តទុកដាក់ខ្ពស់ និងមានការប្រុងប្រយ័ត្នចំពោះកម្លាំងផ្ទាល់ខ្លួន ដែលគោរពដល់ការដឹកនាំរបស់លោក អ័គីឡា ដោយមិនលុបបំបាត់ប្រាជ្ញា និងការយល់ដឹងរបស់នាង ព្រីស៊ីល ឡើយ។ មិនមានអ្វីនៅក្នុងអត្ថបទគម្ពីរនេះ ដែលមិនអាចពន្យល់បានដោយការយល់ដឹងអំពីអ្វីដែលបានកើតឡើងនោះទេ។

យើងមិនអះអាងថា យើងអាចដឹងអំពីចិត្តគំនិត និងរបៀបដែលនាង ព្រីស៊ីល លោក អ័គីឡា និងលោក អប៉ូឡូស មានទំនាក់ទំនងជាក់ស្ដែងចំពោះគ្នានោះទេ។ យើងគ្រាន់តែអះអាងថា ការកសាងទំនាក់ទំនង ភាពជាស្ត្រីនិយមមិនមានការធានាលើសពីទំនាក់ទំនងរបស់យើងទេ។ សិទ្ធិរបស់នាង ព្រីស៊ីល ក្នុងការកាន់អំណាចលើកិច្ចការបង្រៀន ដែលមិនអាចបង្កើតឡើងនៅក្នុងព្រឹត្តិការណ៍មួយដែលយើងដឹងតិចតួចនោះឡើយ។ វាគ្រាន់តែជាការសន្និដ្ឋាន ដើម្បីណែនាំថាសេចក្ដីបង្គាប់ចំពោះឈ្មោះរបស់ពួកគេបង្ហាញពីការដឹកនាំរបស់នាង ព្រីស៊ីល។ លោក លូកា ប្រហែលជាចង់លើកកិត្តិយស



50 Crucial Questions.indd 47 7/4/26 2:18 in the afternoon

ជាងមុនដល់ស្ត្រីដោយដាក់ឈ្មោះនាងជាមុន (១ពេត្រុស ៣:៧) ឬប្រហែលជាមានហេតុផលផ្សេងទៀតដែលយើងមិនដឹង។ ដោយនិយាយថា៖ នាងព្រីស៊ីល បង្ហាញពីការបង្រៀនប្រកបដោយអំណាចរបស់ស្ត្រីនៅក្នុងព្រះគម្ពីរសញ្ញាថ្មី គឺជាប្រភេទនៃការសន្និដ្ឋានមិនច្បាស់លាស់ និងគ្មានការធានា ដែលត្រូវបានធ្វើឡើងម្តងហើយម្តងទៀតដោយពួកនិកាយដំណឹងល្អស្ត្រីនិយម ដែលគាំទ្រថា បុរស និងស្ត្រីមានភាពស្មើគ្នា ហើយបន្ទាប់មកហៅថា ការរុញច្រានព្រះគម្ពីរដ៏សំខាន់ប្រឆាំងនឹងភាពខុសគ្នានៃតួនាទីផ្អែកលើភេទ។ ប៉ុន្តែការសន្និដ្ឋានមិនត្រឹមត្រូវជាច្រើនមិនធ្វើឲ្យមានការរុញច្រានដ៏សំខាន់នោះទេ។

## សំណួរទី២១
## តើលោកគ្រូចង់និយាយថា វាត្រឹមត្រូវក្នុងការដែលស្ត្រីបង្រៀនបុរសក្នុងកាលៈទេសៈមួយចំនួនមែនទេ?

នៅពេលដែលសាវ័ក ប៉ុល លើកឡើងនៅកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២ ថា៖ «ខ្ញុំមិនបើកឲ្យស្ត្រីណាបង្រៀន ឬឲ្យមានអំណាចលើបុរសទេ ត្រូវឲ្យគេនៅដោយស្រគត់ស្រគំចុះ»។ យើងមិនយល់ថា គាត់ហាមឃាត់ដាច់ខាតចំពោះការបង្រៀនទាំងអស់ដោយស្ត្រីនោះទេ។ នៅកន្លែងផ្សេងទៀត សាវ័ក ប៉ុល ណែនាំពួកស្ត្រីចាស់ៗឲ្យ «ត្រូវខំបង្រៀនសេចក្តីត្រឹមត្រូវវិញ ដើម្បីនឹងបង្ហាត់ដល់ពួកស្ត្រីក្មេងៗ» (ទីតុស ២:៣-៤) ហើយគាត់សរសើរការបង្រៀនដែលអ្នកស្រី អើនីស និងលោកយាយ ឡូអ៊ីស ចំពោះលោក ធីម៉ូថេ ដែលជាកូន និងជាចៅប្រុសដ៏គួរឲ្យគោរពរបស់ពួកគាត់ (២ធីម៉ូថេ ១:៥; ៣:១៤)។ កណ្ឌគម្ពីរ សុភាសិត សរសើរប្រពន្ធគ្រប់លក្ខណ៍ «នាងពោលដោយប្រាជ្ញា ហើយនៅអណ្តាតនាងមានសេចក្តីសប្បុរស» (សុភាសិត ៣១:២៦)។ សាវ័ក ប៉ុល គាំទ្រស្ត្រីដែលអធិស្ឋាន ឬអធិប្បាយព្រះបន្ទូលនៅក្នុងក្រុមជំនុំ (១កូរិនថូស ១១:៥) ហើយនិយាយថា៖ បុរស «រៀន» ដោយការថ្លែងព្រះបន្ទូលបែបនេះ (១កូរិនថូស ១៤:៣១) ហើយថាសមាជិក (ដោយសន្មតបានថាបុរស និងស្ត្រី) គួរតែជា «ការបង្រៀន ហើយទូន្មានគ្នា ដោយប្រាជ្ញាគ្រប់យ៉ាង ដោយនូវ



50 Crucial Questions.indd 48 7/4/26 2:18 in the afternoon

ទំនុកតម្កើង ទំនុកបរិសុទ្ធ និងចម្រៀងខាងឯវិញ្ញាណ ទាំងច្រៀងក្នុងចិត្តថ្វាយព្រះ ដោយព្រះគុណ» (កូឡូស ៣:១៦)។ ប្រាកដណាស់ បន្ទាប់មកមាននាងព្រីស៊ីល នៅជាមួយលោក អ័គីឡា បានជួយកែតម្រូវលោក អ័ប៉ុឡូស (កិច្ចការ ១៨:២៦)។

វាជាការគិតដោយបំពានដែលយល់ថាសាវ័ក ប៉ុល មានគ្រប់ទម្រង់នៃការបង្រៀននៅក្នុងគំនិត នៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២។ ការបង្រៀន និងការរៀន គឺជាពាក្យទូលំទូលាយណាស់ ដែលវាមិនអាចទៅរួចនោះទេ ដែលស្ត្រីមិនបង្រៀនបុរស ហើយថាបុរសមិនរៀនពីស្ត្រីក្នុងន័យណាមួយនោះ។ ជាក់ស្តែង សូម្បីតែអ្វីដែលជាលក្ខណៈនៃធម្មជាតិក៏អាចនឹងបង្រៀនយើងបានដែរ (១កូរិនថូស ១១:១៤) ហើយការបង្រៀនពីដើមល្វា (ម៉ាថាយ ២៤:៣២) និងការបង្រៀនពីការរងទុក្ខលំបាក (ហេព្រើរ ៥:៨) ហើយការបង្រៀនពីអាកប្បកិរិយារបស់មនុស្ស (១កូរិនថូស ៤:៦; ១ពេត្រុស ៣:១)។

ប្រសិនបើសាវ័ក ប៉ុល មិនមានការយល់ឃើញពីទម្រង់នៃការបង្រៀន និងការរៀនដែលអាចយល់បានក្នុងគំនិត តើគាត់ចង់មានន័យយ៉ាងណា? ទី១៖ វាជួយឲ្យយើងស្គាល់បរិបទ គឺក្រុមជំនុំបានប្រជុំគ្នា ដើម្បីអធិស្ឋាន និងបង្រៀន (១ធីម៉ូថេ ២:៨-១០; ៣:១៥)។ ទី២៖ តម្រុយដ៏ល្អបំផុត គឺប្រហែលជាការភ្ជាប់គ្នានៃ «ការបង្រៀន» ជាមួយ «ការប្រើប្រាស់សិទ្ធិអំណាចលើបុរស»។ យើងអាចនិយាយបានថា ការបង្រៀនមិនសមរម្យសម្រាប់ស្ត្រី គឺជាការបង្រៀននៅក្នុងបរិបទបង្រៀនបុរស ឬរបៀបដែលបង្អាប់ដល់ការត្រាស់ហៅបុរសឲ្យទទួលខុសត្រូវចម្បងសម្រាប់ការបង្រៀន និងការដឹកនាំ។ ទំនួលខុសត្រូវចម្បងនេះគឺត្រូវបំពេញដោយគ្រូគង្វាល ឬពួកចាស់ទុំ។ ហេតុដូច្នេះហើយបានជាយើងគិតថា ជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលមានតែបុរសប៉ុណ្ណោះ ដែលមានទំនួលខុសត្រូវសម្រាប់កិច្ចការទាំងនេះ។



50 Crucial Questions.indd 49 7/4/26 2:18 in the afternoon

## សំណួរទី២២
## តើគ្រូគង្វាលមិនអាចអនុញ្ញាតឲ្យស្ត្រីបង្រៀនព្រះគម្ពីរដល់ក្រុមជំនុំ និងបន្ទាប់មកបន្តត្រួតពិនិត្យពេលនាងបង្រៀនបានទេមែនឬ?

វាជារឿងត្រឹមត្រូវសម្រាប់ព័ន្ធកិច្ចបង្រៀនទាំងអស់របស់ក្រុមជំនុំក្នុងការទទួលបានការអនុញ្ញាត ឬទទួលស្គាល់ពីអ្នកធានាខុសត្រូវ និងអ្នកគ្រប់គ្រង (ឧ. ពួកចាស់ទុំ) របស់ក្រុមជំនុំ។ ទោះជាយ៉ាងណា វាអាចជារឿងខុសឆ្គងសម្រាប់ការដឹកនាំក្រុមជំនុំនៅក្នុងការប្រើប្រាស់សិទ្ធអំណាចរបស់ខ្លួន ដើម្បីអនុញ្ញាតឲ្យស្ត្រីធ្វើការបង្រៀនដល់ក្រុមចាស់ទុំក្នុងក្រុមជំនុំ ទោះបើនាងមិនត្រូវបានទទួលមុខតំណែង ឬចាត់តាំងច្បាស់លាស់ក្តី។ ម្យ៉ាងវិញទៀត ដើម្បីធ្វើការបញ្ជាក់ដោយស្របតាមព្រះគម្ពីរដល់ស្ត្រីដែលកំពុងបង្រៀន ពួកគេគួរតែមានលក្ខណៈពីរប្រភេទនេះ គួរតែត្រូវបានបំពេញ។ បុគ្គលនោះ គឺត្រូវមានការយល់ស្របពីអ្នកគ្រប់គ្រងខាងឯវិញ្ញាណនៃក្រុមជំនុំ (ពោលគឺ ពួកចាស់ទុំ)។ មួយវិញទៀត គឺដើម្បីជៀសវាង និងការបង្រៀនណាដែលដាក់ស្ត្រីឲ្យបំពេញតួនាទីជាអ្នកគង្វាលខាងឯវិញ្ញាណលើក្រុមបុរសៗ ឬជៀសវាងការបង្រៀនណាដែលមានលក្ខណៈស៊ីជម្រៅខ្លាំង ដែលប៉ះពាល់ដល់បញ្ញាចិត្តរបស់បុរសលើមូលដ្ឋាននៃសិទ្ធិអំណាចរបស់ព្រះជាម្ចាស់។ សកម្មភាពទាំងនេះនឹងបំពានលើអ្វីដែលសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២។ គ្រូគង្វាលមិនមានសិទ្ធិក្នុងការធ្វើអ្វីមួយដែលព្រះគម្ពីរបានហាមប្រាមឡើយ ដ្បិតគ្រូគង្វាលមិនមានអំណាចខ្ពស់ជាងព្រះបន្ទូលផ្ទាល់ទេ។

## សំណួរទី២៣
## តើលោកគ្រូអាចគាំទ្រស្ត្រីឲ្យធ្វើថ្លែងទំនាយក្នុងក្រុមជំនុំ តែមិនពេញចិត្តឲ្យស្ត្រីធ្វើជាគ្រូគង្វាល និងពួកចាស់ទុំបានដោយរបៀបណាទៅ? តើការថ្លែងទំនាយមិនមែនជាចំណុចស្នូលនៃតួនាទីទាំងនោះទេឬអី?

ទេ! ការគ្រប់គ្រង និងបង្រៀនគឺជាតួនាទីចម្បងរបស់គ្រូគង្វាល ឬពួកចាស់ទុំ (១ធីម៉ូថេ ៥:១៧)។ បញ្ជីលក្ខណសម្បត្តិរបស់ពួកចាស់ទុំមិនបានរម្លឹកអំពី



50 Crucial Questions.indd 50 7/4/26 2:18 in the afternoon

អំណោយទាននៃការថ្លែងទំនាយក្នុងនោះទេ ប៉ុន្តែបានរម្លឹកអំពីសមត្ថភាពនៃការបង្រៀន (១ធីម៉ូថេ ៣:២)។ នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៤:១១ ពួកហោរាមានលក្ខណៈខុសពីគ្រូគង្វាល-គ្រូបង្រៀន។ ទោះបើបុរសរៀនបានអំពីការអធិប្បាយព្រះបន្ទូលដែលស្ត្រីបានអធិប្បាយក្តី ក៏សាវ័ក ប៉ុល បានបង្ហាញអំពីលក្ខណៈខុសគ្នារវាងអំណោយទាននៃការថ្លែងទំនាយ និងអំណោយទាននៃការបង្រៀន (រ៉ូម ១២:៦-៧; ១កូរិនថូស ១២:២៨)។ គ្មានកន្លែងណាដែលស្ត្រីត្រូវបានហាមឃាត់មិនឲ្យថ្លែងសេចក្តីទំនាយនោះទេ។ សាវ័ក ប៉ុល គ្រាន់តែធ្វើការដាក់កម្រិតអាកប្បកិរិយាដែលពួកគេថ្លែងទំនាយ ដើម្បីកុំឲ្យខូចគោលការណ៍នៃភាពជាអ្នកដឹកនាំខាងព្រលឹងវិញ្ញាណរបស់បុរស (១កូរិនថូស ១១:៥-១០)។

ការថ្លែងទំនាយក្នុងការថ្វាយបង្គំរបស់ក្រុមជំនុំដំបូងមិនមែនជាប្រភេទនៃការបង្គាប់បញ្ជា ការបើកសម្តែងដែលមិនចេះខុស ពាក់ព័ន្ធជាមួយការថ្លែងសេចក្តីទំនាយផ្សេងៗជាលាយលក្ខណ៍អក្សរនៃគម្ពីរសញ្ញាចាស់នោះទេ។[១២] វាជារបាយការណ៍មួយស្តែងចេញពីនៅក្នុងពាក្យសម្តីរបស់មនុស្ស ដែលផ្អែកលើការបើកសម្តែងផ្ទាល់ខ្លួន កើតឡើងដោយឯកឯងបណ្តាលពីព្រះវិញ្ញាណបរិសុទ្ធ (១កូរិនថូស ១៤:៣០) ក្នុងគោលបំណងនៃការលើកទឹកចិត្ត ការលួងលោម ការជឿជាក់ និងការណែនាំ (១កូរិនថូស ១៤:៣, ២៤-២៥; កិច្ចការ ២១:៤; ១៦:៦-១០)។ វាមិនចាំបាច់រួចផុតពីការលាយឡំនៃកំហុសរបស់មនុស្សទេ ដូច្នេះហើយទើបតម្រូវឲ្យមានការវាយតម្លៃ (១ថែស្សាឡូនីច ៥:២០-២១; ១កូរិនថូស ១៤:២៩) ដោយផ្អែកលើមូលដ្ឋាននៃការបង្រៀន (ស្របតាមព្រះគម្ពីរ) របស់ក្រុមសាវ័ក (១កូរិនថូស ១៤:៣៦-៣៨;

---

១២ អ្នកចូលរួមខ្លះមិនគាំទ្រចំពោះទស្សនៈទំនាយនៃកណ្ឌសញ្ញាថ្មីទៅលើការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ (“Recovering Biblical Manhood and Womanhood”)។ ពួកគេនឹងនិយាយថា អំណោយទាននៃព្រះគម្ពីរសញ្ញាថ្មីនៃការទស្សន៍ទាយមិនបន្តដល់ថ្ងៃនេះទេ ព្រោះវាជាផ្នែកមួយនៃពេលវេលាបើកសម្តែងដ៏ពិសេសនៅក្នុងប្រវត្តិសាស្ត្រ ហើយមានពាក្យដែលមានសិទ្ធិអំណាចដែលមិនអាចកាត់ថ្លៃបានរបស់ព្រះជាម្ចាស់។ ពួកគេនឹងនិយាយថា ស្ត្រីអាចទាយក្នុងន័យនេះ ប៉ុន្តែមិនអាចបង្រៀនបានទេ ពីព្រោះមានសិទ្ធិអំណាចភ្ជាប់ពាក្យដោយឡែកពីគេ មិនមែនសំដៅលើបុគ្គល ឬការបង្ហាញដូចដែលវាធ្វើនៅក្នុងការបង្រៀននោះទេ។



50 Crucial Questions.indd 51 7/4/26 2:18 in the afternoon

២ថែស្សាឡូនីច ២:១-៣)។ ការថ្លែងសេចក្តីទំនាយនៅក្នុងក្រុមជំនុំដំបូងមិនមានលក្ខណៈដូចគ្នានឹងការអធិប្បាយ ឬការកាត់ស្រាយបទគម្ពីរនាសព្វថ្ងៃនេះទេ។ ទាំងស្ត្រី និងបុរសអាចក្រោកឡើងបាន ហើយ "អធិប្បាយ/ថ្លែងសេចក្តីទំនាយ"—ពោល គឺចែករំលែកអ្វីដែលពួកគេជឿថា ព្រះបាននាំមកក្នុងគំនិត ដើម្បីផលប្រយោជន៍ដល់ក្រុមជំនុំ។ ប៉ុន្តែ ការសាកល្បងជាសាធារណៈនូវពាក្យទាំងនេះ និងព័ន្ធកិច្ចបង្រៀនព្រះគម្ពីរជាទៀងទាត់ គឺជាការទទួលខុសត្រូវរបស់អ្នកចាស់ទុំ/គ្រូបង្រៀន។ តួនាទីចុងក្រោយនេះ គឺជាតួនាទីដែលសាវ៉ក ប៉ុល បានប្រគល់ឲ្យបុរសតែប៉ុណ្ណោះ ។[១៣]

## សំណួរទី២៤
## ដូច្នេះ តើលោកគ្រូកំពុងនិយាយថា លោកគ្រូទទួលយកសេរីភាពរបស់ស្ត្រីក្នុងការថ្លែងទំនាយជាសាធារណៈ ដូចដែលបានពិពណ៌នានៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២:១៧; ២១:៩; និង ១កូរិនថូស ១១:៥ មែនឬ?

បាទ។[១៤]

១៣ ការយល់ដឹងចំពោះទំនាយនៅក្នុងកណ្ឌគម្ពីរសញ្ញាថ្មីនេះ គឺបានអភិវឌ្ឍ និងការពារនៅក្នុងសៀវភៅរបស់លោក វ៉េន ហ្គ្រូដឹម (Wayne Grudem), «អំណោយទាននេះការទស្សន៍ទាយនៅក្នុងកណ្ឌគម្ពីរសញ្ញាថ្មី និងបច្ចុប្បន្ន» (*The Gift of Prophecy in the New Testament and Today* Wheaton, IL: Crossway, ឆ្នាំ១៩៨៨); លោក Graham Houston, *Prophecy: A Gift for Today?* (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៩); លោក ឌី.អេ ខាសុន D. A. Carson, *Showing the Spirit: A Theological Exposition of ១ Corinthians ១២–១៤* (Grand Rapids, MI: Baker, ឆ្នាំ១៩៨៧)។ ទស្សនៈនៃទំនាយក្នុងព្រះគម្ពីរសញ្ញាថ្មីនេះ គឺជាទស្សនៈមួយដែលប្រកាន់យកដោយអ្នកនិពន្ធទាំងឡាយនៅក្នុងសៀវភៅនេះ «ការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ» *(Recovering Biblical Manhood and Womanhood)* ប៉ុន្តែអ្នកចូលរួមខ្លះនៅក្នុងសៀវភៅនេះប្រកាន់យកនូវទស្សនៈខុសគ្នា។

១៤ សូមមើលកំណត់ចំណាំ១១ និង១២។



50 Crucial Questions.indd 52 7/4/26 2:18 in the afternoon

## សំណួរទី២៥
## ដោយសារមានសេចក្តីចែងទុកនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៤ ថា៖ «នៅក្នុងពួកជំនុំត្រូវឲ្យពួកស្រីៗនៅស្ងៀម» នោះវាហាក់បីដូចជាថា គោលជំហររបស់លោកគ្រូមិនស្របតាមព្រះគម្ពីរឡើយ ដោយសារតែកម្រិតនៃការឲ្យស្ត្រីនិយាយស្តីដែលលោកគ្រូបានផ្តល់ដល់មនុស្សស្រី។ តើលោកគ្រូពន្យល់ការហាមប្រាមដោយត្រង់ៗនេះចំពោះការនិយាយស្តីរបស់ស្ត្រីយ៉ាងដូចម្តេចទៅ?

មូលហេតុដែលយើងជឿថាសាវ័ក ប៉ុល មិនមានន័យថា ស្ត្រីត្រូវនៅស្ងៀមស្ងាត់ទាំងស្រុងនៅក្នុងក្រុមជំនុំគឺដោយសារនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:៥ សាវ័ក ប៉ុល បានអនុញ្ញាតឲ្យស្ត្រីអធិស្ឋាន និងថ្លែងព្រះបន្ទូល («អធិប្បាយ») នៅក្នុងក្រុមជំនុំ៖ «ឯស្ត្រីណាដែលអធិស្ឋាន ឬអធិប្បាយ ដោយមានក្បាលទទេនោះឈ្មោះថាធ្វើបង្អាប់ដល់ក្បាលខ្លួនវិញ»។ ប៉ុន្តែ អាចនឹងមានអ្នកខ្លះសួរថា៖ «ហេតុអ្វីបានជាលោកគ្រូសម្រេចឲ្យកណ្ឌគម្ពីរ ១កូរិនថូស ១១:៥ កំណត់អត្ថន័យលើកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៤ ជាជាងឲ្យកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៤ កំណត់អត្ថន័យលើកណ្ឌគម្ពីរ ១កូរិនថូស ១១:៥ ទៅវិញដូច្នេះ?»

ដើម្បីចាប់ផ្តើមឆ្លើយសំណួរ យើងគួរកត់សម្គាល់ទាំងពីរកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៥ និង១កូរិនថូស ១១:៦ សាវ័ក ប៉ុល មានការព្រួយបារម្ភអំពីអ្វីដែល «គួរឲ្យអាម៉ាស់» ឬ «គួរឲ្យអាប់យស» សម្រាប់ស្ត្រី (ពាក្យជាភាសាក្រិកនៅក្នុងខទាំងពីរគឺ «អៃស៍ខ្រន» (aischron) ដែលនៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានបង្ហាញតែនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស)។ ចំណុចគឺមិនបានថា ស្ត្រីមិនមានសមត្ថភាព ឬភាពឆ្លាតវៃ ឬមិនមានប្រាជ្ញា ឬមិនបង្រៀនល្អនោះទេ តែបញ្ហាគឺទាក់ទងទៅនឹងការដែលពួកគេមានទំនាក់ទំនងនឹងបុរសនៅក្នុងក្រុមជំនុំវិញទេ។ នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៥ សាវ័ក ប៉ុល បាននិយាយអំពីការចុះចូល ហើយនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:៣ គាត់និយាយថាបុរសជាក្បាល។ ដូច្នេះ បញ្ហានៃភាពអាម៉ាស់ គឺជាឫសគល់នៃបញ្ហានៃការ

ធ្វើអ្វីមួយដែលបង្អាប់តួនាទីរបស់បុរសជាអ្នកដឹកនាំក្រុមជំនុំ។ ប្រសិនបើការនិយាយទាំងអស់មានភាពអាម៉ាស់តាមរបៀបនេះ នោះសាវ័ក ប៉ុល មិនអាចអត់ឱនដល់ការអធិស្ឋាន និងការអធិប្បាយរបស់ស្ត្រីដូចដែលគាត់បានធ្វើនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:៥៖ ប្រាកដណាស់ ភាពអាម៉ាស់ គឺជាបញ្ហា។ ប៉ុន្តែ សាវ័ក ប៉ុល បង្ហាញអំពីអ្វីដែលជាបញ្ហានៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:៥-១៦៖ គឺមិនមែនជាការដែលស្ត្រីអធិស្ឋាន និងអធិប្បាយព្រះបន្ទូលនៅទីសាធារណៈទេ ប៉ុន្តែជារបៀបដែលពួកគេកំពុងធ្វើវានោះវិញ។ នោះគឺថា តើពួកគេកំពុងធ្វើវាដោយការស្លៀកពាក់ និងអាកប្បកិរិយា បញ្ជាក់អំពីការដឹកនាំរបស់បុរសដែលត្រូវបានត្រាស់ហៅឲ្យដឹកនាំក្រុមជំនុំដែរឬក៏អត់?

យើងក្រឡេកទៅមើលបរិបទនៃកណ្ឌគម្ពីរ ១កូរិនថូស ១៤:៣៣-៣៦ ដើម្បីស្វែងរកតម្រុយស្រដៀងគ្នាសម្រាប់ប្រភេទនៃការនិយាយដែលសាវ័ក ប៉ុល ប្រហែលជាមាននៅក្នុងគំនិត នៅពេលគាត់និយាយថា វា “គួរឲ្យអាម៉ាស់” ចំពោះស្ត្រីក្នុងការនិយាយ។ សូមកត់សម្គាល់ម្តងទៀតថា បញ្ហាមិនទាក់ទងទៅនឹងសមត្ថភាព ឬប្រាជ្ញារបស់ស្ត្រីក្នុងការនិយាយដោយឆ្លាតវៃនោះទេ ប៉ុន្តែរបៀបដែលស្ត្រីប្រាស្រ័យទាក់ទងនឹងបុរស (“ហ៊ូបពូតាសីនធូសិន” (hypotassesthōsan) — “ចូរឲ្យពួកគេចុះចូល”)។ ប្រភេទនៃទំនាក់ទំនងមួយចំនួនគឺកំពុងកើតឡើងដែលសាវ័ក ប៉ុល យល់ថា ប៉ះពាល់ការត្រាស់ហៅបុរសដែលជាអ្នកដឹកនាំចម្បងនៃក្រុមជំនុំ។ សាវ័ក ប៉ុល ប្រហែលជាយល់ថា មិនសមរម្យនោះទេ ដែលឲ្យស្ត្រីធ្វើនូវមុខងារនោះ ដូច្នេះគឺនៅក្នុងសកម្មភាពនៃការវិនិច្ឆ័យជាសាធារណៈលើការថ្លែងសេចក្តីទំនាយផ្សេងៗ ដែលលោកឲ្យពួកគេនៅស្ងៀម។[១៥] ម្យ៉ាងវិញទៀត នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ជំពូក១១ និងកណ្ឌគម្ពីរ ១កូរិនថូស ជំពូក១៤៖ សាវ័ក ប៉ុល កំពុងអំពាវនាវ មិនមែនឲ្យមានភាពស្ងៀមស្ងាត់ទាំងស្រុងពីស្ត្រីនោះទេ ប៉ុន្តែឲ្យមានប្រភេទនៃការចូលរួម

---

១៥ សូមមើលការនិពន្ធរបស់លោក Wayne Grudem, “Prophecy, Yes, but Teaching, No: Paul’s Consistent Affirmation of Women’s Participation without Governing Authority,” Journal of the Evangelical Theological Society ៣០, no. ១ (ខែមិនា ឆ្នាំ១៩៨៧), ទំព័រ១១-២៣។



50 Crucial Questions.indd 54 7/4/26 2:18 in the afternoon

ដែលបង្ហាញអំពីភាពរីករាយរបស់ពួកគេចំពោះភាពជាអ្នកដឹកនាំរបស់បុរស ដែលព្រះជាម្ចាស់បានត្រាស់ហៅឲ្យធ្វើជាអ្នកមើលថែរក្សា និងជាអ្នកគ្រប់គ្រងក្រុមជំនុំ។

## សំណួរទី២៦

### តើការលើកឡើងរបស់សាវ័ក ប៉ុល ដែលថា៖ «គ្មានប្រុស និងស្រីទៀតទេ ពីព្រោះអ្នករាល់គ្នាទាំងអស់រួមមកតែមួយ នៅក្នុងព្រះគ្រីស្ទយេស៊ូវ» (កាឡាទី ៣:២៨) លុបបំបាត់យេនឌ័រថា ជាកត្តាមូលដ្ឋានក្នុងការបែងចែកតួនាទីក្នុងក្រុមជំនុំមែនទេ?

ទេ! និកាយជំណឹងល្អភាគច្រើនយល់ស្របថា បទគម្ពីរនេះមិនមែនគាំទ្រការស្រឡាញ់ភេទដូចគ្នាទេ។ ម្យ៉ាងវិញទៀត យើងភាគច្រើនមិនបានកាត់ស្រាយឃ្លាដែលសាវ័ក ប៉ុល សរសេរថា "គ្មានប្រុស និងស្រីទៀតទេ" ឲ្យមានន័យលើសពីអ្វីដែលយើងដឹងពីព្រះគម្ពីរទេ ដែលគាត់បានបញ្ជាក់នៅក្នុងខផ្សេងៗនោះទេ។ ឧទាហរណ៍៖ យោងតាមកណ្ឌគម្ពីរ រ៉ូម ១:២៤-៣២ យើងដឹងថាសាវ័ក ប៉ុល មិនមែនចង់សំដៅលើការបង្រៀននៅក្នុងកណ្ឌគម្ពីរ កាឡាទី ៣:២៨ ដើម្បីបង្វែចសេចក្តីបង្គាប់អំពីភាពខុសប្លែកនៃតួនាទីរបស់មនុស្សប្រុស និងមនុស្សស្រីផ្នែកទំនាក់ទំនងផ្លូវភេទនោះទេ។

បរិបទនៃកណ្ឌគម្ពីរ កាឡាទី ៣:២៨ បង្ហាញឲ្យយើងឃើញយ៉ាងជាក់ច្បាស់នូវអត្ថន័យដែលថា បុរស និងស្ត្រីមានភាពស្មើគ្នានៅក្នុងព្រះគ្រីស្ទ។ ពួកគេបានរាប់ជាសុចរិតដោយអាងសេចក្តីជំនឿ (ខ២៤) នោះយើងមិនមែននៅក្រោមអំណាចនៃក្រឹត្យវិន័យនោះទៀតទេ (ខ២៥) ដ្បិតអ្នករាល់គ្នាសុទ្ធតែជាកូនព្រះ (ខ២៦) ប្រដាប់ដោយព្រះគ្រីស្ទ (២៧) ជារបស់ផងព្រះគ្រីស្ទ (២៩) និងជាពូជរបស់លោក អ័ប្រាហាំ ហើយក៏ជាអ្នកគ្រងមរដកតាមសេចក្តីសន្យា (២៩)។

ព្រះពរចុងក្រោយនេះមានសារៈសំខាន់យ៉ាងពិសេស ពោលគឺភាពស្មើគ្នារបស់ស្ត្រីក្នុងការក្លាយជាអ្នកគ្រងមរតកនៃសេចក្តីសន្យារបស់ព្រះជាម្ចាស់ជា



50 Crucial Questions.indd 55 7/4/26 2:18 in the afternoon

មួយបុរសៗដែរ។ នៅក្នុងកណ្ឌគម្ពីរ ១ពេត្រុស ៣:១-៧ ព្រះពរនៃការក្លាយជាអ្នកគ្រងមរតករួមគ្នាក្នុង «ព្រះគុណនៃជីវិត» (ខ៧) ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការដាស់តឿនចំពោះស្ត្រីឲ្យចុះចូលចំពោះប្ដីរបស់ខ្លួន (ខ១) និងសម្រាប់ប្ដី ត្រូវប្រព្រឹត្តចំពោះប្រពន្ធដោយប្រាជ្ញា «ដូចនឹងគ្រឿងភាជនៈដែលខ្សោយជាង» (ខ៧)។ ម្យ៉ាងទៀតសាវ័ក ពេត្រុស មិនយល់ថា ការទាស់ទែងគ្នារវាងគោលការណ៍គ្មានប្រុស គ្មានស្រីទៀតទេទាក់ទងនឹងការគ្រងមរតករបស់យើង ហើយនិងគោលការណ៍ដឹកនាំដោយចុះចូលទាក់ទងនឹងតួនាទីរបស់យើង។ កណ្ឌគម្ពីរ កាឡាទី ៣:២៨ មិនបានលុបបំបាត់តួនាទីនៃផ្នែកផ្លូវភេទដែលព្រះជាម្ចាស់បានបង្កើតឡើងឡើយ ហើយព្រះគ្រីស្ទបានប្រោសលោះនោះដែរ។

ជាចុងក្រោយ វាជារឿងសំខាន់ក្នុងការយកចិត្តទុកដាក់លើអ្វីដែលសាវ័ក ប៉ុល បានលើកឡើងនៅក្នុងកណ្ឌគម្ពីរ កាឡាទី ៣:២៨។ គាត់មិនបានលើកឡើងថា៖ «អ្នកទាំងអស់គ្នាគឺដូចគ្នា នៅក្នុងព្រះគ្រីស្ទយេស៊ូវ» ប៉ុន្តែ «អ្នករាល់គ្នាទាំងអស់រួមមកតែមួយ នៅក្នុងព្រះគ្រីស្ទយេស៊ូវ»។ គាត់កំពុងសង្កត់ធ្ងន់លើការរួបរួមរបស់ពួកគេក្នុងព្រះគ្រីស្ទ មិនមែនអំពីភាពដូចគ្នារបស់ពួកគេទេ។

## សំណួរទី២៧
## តើលោកគ្រូពន្យល់យ៉ាងណាចំពោះការគាំទ្រជាក់ស្ដែងរបស់ព្រះជាម្ចាស់ចំពោះស្ត្រីក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលមានតួនាទីទស្សន៍ទាយ ឬជាអ្នកដឹកនាំបាន?

ជាដំបូង ចូរយើងចាំថា ព្រះជាម្ចាស់គ្មានព្រះទ័យទាស់ប្រឆាំងចំពោះការបើកសម្ដែងបំណងព្រះទ័យរបស់ទ្រង់ចំពោះស្ត្រីនោះទេ។ ទ្រង់ក៏មិនបានប្រកាសថា ពួកគេជាអ្នកនាំសារដែលមិនគួរឲ្យទុកចិត្តនោះដែរ។ ភាពខុសគ្នានៃតួនាទីសម្រាប់បុរស និងស្ត្រីនៅក្នុងកិច្ចការបម្រើព័ន្ធកិច្ច គឺមិនមែនមកពីស្ត្រីអសមត្ថភាពក្នុងការទទួល ឬបង្ហាញសេចក្ដីពិតនោះទេ ប៉ុន្តែជាទំនួលខុសត្រូវចម្បងរបស់បុរសចំពោះសេចក្ដីបង្គាប់របស់ព្រះនៅក្នុងការដឹកនាំ និង



50 Crucial Questions.indd 56 7/4/26 2:18 in the afternoon

ការបង្រៀន។ គ្មានអ្វីដែលចម្លែកនៅក្នុងករណីស្ត្រីដែលចេះថ្លែងទំនាយ និងដឹកនាំនោះទេ។ ផ្ទុយទៅវិញ មានការចង្អុលបង្ហាញនៅក្នុងករណីនីមួយៗ ដែលស្ត្រីបានគាំទ្រ និងផ្តល់កិត្តិយសដល់ការដឹកនាំធម្មតារបស់បុរស ឬបានចោទប្រកាន់អំពីការបរាជ័យរបស់បុរសក្នុងការដឹកនាំរបស់បុរសវិញទេតើ។

ឧទាហរណ៍៖ ហោរា ម៉ារាម តាមដែលយើងដឹងជាអ្នកប្រកាសទំនាយ បានផ្តោតការយកចិត្តទុកដាក់លើកិច្ចការបម្រើរបស់នាងទៅលើស្ត្រីនៃជនជាតិអ៊ីស្រាអែល (និក្ខមនំ ១៥:២០)។ នាង ដេបូរ៉ា ជាហោរា ជាចៅហ្វាយ និងជាម្តាយនៃសាសន៍អ៊ីស្រាអែល (ពួកចៅហ្វាយ ៤:៤; ៥:៧) ដូចទៅនឹងនាង យ៉ាអែល (ពួកចៅហ្វាយ ៥:២៤-២៧) ជាអ្នកចោទប្រកាន់ដែលកំពុងមានជីវិតនៃភាពទន់ខ្សោយរបស់លោក បារ៉ាក និងបុរសដទៃទៀតក្នុងប្រទេសអ៊ីស្រាអែល ដែលគួរតែជាអ្នកដឹកនាំដ៏ក្លាហានជាងនាង (ពួកចៅហ្វាយ ៤:៩)។ (អំឡុងពេលនៃពួកចៅហ្វាយគ្រប់គ្រង គឺជាមូលដ្ឋានគ្រឹះដ៏មិនច្បាស់លាស់មួយសម្រាប់ការកសាងចក្ខុវិស័យនៃឧត្តមភាពដ៏ល្អឥតខ្ចោះរបស់ព្រះជាម្ចាស់សម្រាប់ការដឹកនាំ។ នៅសម័យនោះ ព្រះជាម្ចាស់មិនមានព្រះទ័យទាស់នឹងការនាំយកនូវស្ថានភាពនៃកិច្ចការណាមួយ ដែលមិនអនុលោមតាមឆន្ទៈដែលបានបើកសម្តែងឲ្យឃើញ ដើម្បីសម្រេចបាននូវគោលបំណងដ៏ឈ្លាសវៃមួយចំនួន [សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ចៅហ្វាយ ១៤:៤])។

ស្រដៀងគ្នានេះដែរ ហោរា ហ៊ុលដា ដែលជាស្ត្រីម្នាក់ក៏បានអនុវត្តអំណោយទាននៃការថ្លែងទំនាយរបស់គាត់ ដែលនោះមិនមែនព័ន្ធកិច្ចនៅការប្រកាសផ្សព្វផ្សាយជាសាធារណៈនោះទេ ប៉ុន្តែតាមរយៈការពិគ្រោះជាលក្ខណៈឯកជន (២ពង្សាវតារក្សត្រ ២២:១៤-២០)។ ហើយហោរា អាណា ជាព្យាការីនៅដើមព្រះគម្ពីរសញ្ញាថ្មី បានប្រើប្រាស់ការរស់នៅប្រចាំថ្ងៃរបស់នាងដោយការតមអាហារ និងការអធិស្ឋាននៅក្នុងព្រះវិហារ (លូកា ២:៣៦-៣៧)។

យើងត្រូវតែចងចាំផងដែរថា ការផ្តល់អំណាច ឬការបើកបង្ហាញរបស់



50 Crucial Questions.indd 57 7/4/26 2:18 in the afternoon

ព្រះជាម្ចាស់ដល់មនុស្សណាម្នាក់ មិនមែនជាសញ្ញាច្បាស់លាស់ដែលថា បុគ្គលនេះគឺជាគំរូដ៏ល្អសម្រាប់យើងក្នុងការធ្វើតាមគ្រប់ចំណុចទាំងអស់នោះទេ។ ឧទាហរណ៍៖ នេះជាភស្តុតាងដ៏ពិត មានមនុស្សមួយចំនួនដែលព្រះបានប្រទានពរនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺអ្នកមានប្រពន្ធច្រើន (ឧ. លោកអ័ប្រាហាំ និងស្តេច ដាវីឌ)។ ទោះបីជាមានអំណោយទាននៃការទាយក៏មិនមែនជាភស្តុតាងនៃការស្តាប់បង្គាប់ និងការគាំទ្របុគ្គលម្នាក់ដោយព្រះជាម្ចាស់ដែរ។ ការនេះស្តាប់ទៅហាក់បីដូចជាចម្លែក ប៉ុន្តែកណ្ឌគម្ពីរ ១សាំយូអែល ១៩:២៣-២៤; ម៉ាថាយ ៧:២២ និង ១កូរិនថូស ១៣:២ បង្ហាញថា ការនេះគឺដូច្នេះ។ ជាងនេះទៅទៀត ជាមួយនឹងស្ត្រីម្នាក់ៗដែលបានសំដៅទៅដល់ខាងលើ យើងមានឧទាហរណ៍នៃការលេចចេញជារូបរាងដ៏គួរឲ្យទាក់ទាញនៅកន្លែងកើតហេតុ មិនមែនជាការដាក់ឲ្យកាន់តំណែងជាសង្ឃ (អ្នកដឹកនាំ) ធម្មតាតាមព្រះគម្ពីរសញ្ញាចាស់ ដែលជាទំនួលខុសត្រូវរបស់បុរសនោះទេ។

## សំណួរទី២៨
## តើលោកគ្រូគិតថា មនុស្សស្រីងាយចាញ់បញ្ឆោតជាងបុរសមែនឬ?

កណ្ឌគម្ពីរ ១ធីម៉ូថេ ២:១៤ បានចែងថា៖ «ហើយមិនមែនលោក អ័ដាម ដែលចាញ់បញ្ឆោតទេ គឺជាស្ត្រីវិញទេតើ ដែលចាញ់បញ្ឆោតនោះ ព្រមទាំងរំលងច្បាប់ផង»។ សាវ័ក ប៉ុល បានលើកឡើងថា នេះជាមូលហេតុមួយដែលគាត់មិនអនុញ្ញាតឲ្យស្ត្រី «បង្រៀន ឬឲ្យមានអំណាចលើបុរស» (ខ១២)។ យោងតាមប្រវត្តិសាស្ត្រ ការលើកឡើងនេះជាធម្មតាគេយល់ថា ជាទូទៅស្ត្រីមានការងាយក្នុងការជឿគេ ឬអាចងាយក្នុងការចាញ់បញ្ឆោតគេជាងបុរស ដូច្នេះហើយបានជាពួកគេមិនសូវសមរម្យនៅក្នុងការមើលការខុសត្រូវលើគោលលទ្ធិរបស់ក្រុមជំនុំឡើយ។

លក្ខណៈនៃការកាត់ស្រាយត្រឹមត្រូវ (សូមមើលសំណួរទី២៩)។ ទោះយ៉ាងណាក៏ដោយ ក៏យើងចាប់អារម្មណ៍នឹងការយល់ដឹងមួយទៀតអំពីអំណះអំណាងរបស់សាវ័ក ប៉ុល យើងគិតថា គោលដៅចម្បងរបស់សាតាំង



50 Crucial Questions.indd 58 7/4/26 2:18 in the afternoon

មិនមែនជាលក្ខណៈងាយចាញ់បញ្ឆោតខុសធម្មតារបស់នាង អេវ៉ា ទេ (ប្រសិនបើវាជាលក្ខណៈពិតរបស់នាង) ប៉ុន្តែផ្ទុយទៅវិញ ជាការដឹកនាំរបស់លោក អ័ដាម ជាអ្នកដែលត្រូវបានតែងតាំងដោយព្រះជាម្ចាស់ឲ្យទទួលខុសត្រូវចំពោះជីវិតនៃសួនច្បារវិញទេតើ។ ភាពប៉ិនប្រសប់របស់សាតាំងគឺថា វាដឹងពីលំដាប់លំដោយនៃការបង្កើត ដែលព្រះជាម្ចាស់បានចាត់តាំងសម្រាប់ជាប្រយោជន៍ដល់គ្រួសារ និងសាតាំងបានបំពានដោយមានចេតនាមិនខ្វល់ចំពោះបុរស ហើយចាប់អារម្មណ៍តែនឹងការល្បួងលស្ត្រីវិញ។ សាតាំងបានឲ្យនាងកាន់តំណែងជាអ្នកនាំពាក្យ អ្នកដឹកនាំ និងអ្នកការពារ។ នៅខណៈនោះទាំងបុរស និងស្ត្រីបានបាត់បង់ភាពស្អាតស្អំរបស់ពួកគេ ហើយបានដាក់ឲ្យខ្លួនរបស់ពួកគេធ្លាក់ទៅក្នុងគំរូនៃការទំនាក់ទំនងដែលមានហានិភ័យ ជាលទ្ធផលមានរហូតមកដល់សព្វថ្ងៃនេះ ។

ប្រសិនបើនេះជាការយល់ដឹងត្រឹមត្រូវ នោះអ្វីដែលសាវ័ក ប៉ុល ចង់មានន័យនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១៤ គឺៈ «ហើយមិនមែនលោក អ័ដាម ដែលចាញ់បញ្ឆោតទេ (ពោល គឺលោក អ័ដាម មិនត្រូវបានចូលទៅជិតដោយមេបោកបញ្ឆោត ហើយមិនបានបន្តទាក់ទងដោយផ្ទាល់ជាមួយមេបោកបញ្ឆោតនោះឡើយ) គឺជាស្ត្រីវិញទេតើ ដែលចាញ់បញ្ឆោតនោះ និងបានក្លាយជាអ្នករំលងច្បាប់ (នោះគឺនាងជាអ្នកដែលមានទំនាក់ទំនងជាមួយនឹងមេបោកបញ្ឆោត ហើយត្រូវបានដឹកនាំតាមរយៈទំនាក់ទំនងផ្ទាល់របស់នាងជាមួយនឹងគាត់ទៅជាការបោកបញ្ឆោត និងការរំលងច្បាប់)។ នៅក្នុងករណីនេះ ចំណុចសំខាន់គឺមិនមែនថា បុរសមិនអាចនឹងចាញ់បញ្ឆោតបាន ឬថាស្ត្រីងាយចាញ់បញ្ឆោតជាងនោះទេ ប៉ុន្តែនៅពេលដែលពួកគេមិនស្តាប់បង្គាប់តាមការដឹកនាំរបស់ព្រះជាម្ចាស់ វានាំមកនូវការខូចខាត និងការបំផ្លាញ។ ទាំងបុរស និងស្ត្រី គឺងាយរងគ្រោះចំពោះកំហុស និងអំពើបាបដូចគ្នា នៅពេលដែលពួកគេបោះបង់ចោលលំដាប់លំដោយនៃការបង្កើតសេចក្តីបង្គាប់ដែលព្រះជាម្ចាស់មាន។



50 Crucial Questions.indd 59 7/4/26 2:18 in the afternoon

## សំណួរទី២៩
## ប៉ុន្តែ ពេលមើលទៅវាហាក់បីដូចជាថាសាវ័ក ប៉ុល ពិតជាបានគិតថា នាង អេវ៉ា ងាយនឹងចាញ់បញ្ឆោតជាងលោក អ័ដាម។ តើការនេះមិនធ្វើឲ្យសាវ័ក ប៉ុល ក្លាយជាអ្នកដែលមានបុរេនិច្ឆ័យទេមែនឬ?

ទេ នៅពេលដែលនរណាម្នាក់សួរថា តើស្ត្រីខ្សោយជាងបុរស ឆ្លាតជាងបុរស ងាយភ័យខ្លាចជាងបុរស ឬអ្វីមួយនោះ។ វិធីល្អបំផុតនៅក្នុងការឆ្លើយគឺប្រហែលជាថា៖ ស្ត្រីខ្សោយជាងត្រង់ចំណុចខ្លះ ហើយបុរសខ្សោយជាងនៅត្រង់ចំណុចផ្សេង។ ស្ត្រីឆ្លាតជាងបុរសនៅក្នុងចំណុចមួយចំនួន ហើយបុរសឆ្លាតជាងនៅក្នុងរបៀបផ្សេងទៀត ស្ត្រីងាយភ័យខ្លាចក្នុងកាលៈទេសៈខ្លះ ហើយបុរសងាយភ័យខ្លាចនៅក្នុងកាលៈទេសៈផ្សេងទៀត។ វាមានគ្រោះថ្នាក់ក្នុងការវាយតម្លៃលើភាពអវិជ្ជមានលើអ្វីដែលគេហៅថា ភាពទន់ខ្សោយដែលយើងម្នាក់ៗមាន។ ព្រះជាម្ចាស់មានបំណងព្រះទ័យចង់ឲ្យ «ភាពទន់ខ្សោយ» ទាំងអស់ដែលជាលក្ខណៈរបស់បុរស ដើម្បីរំលេចឡើង និងបញ្ជាក់ពីភាពខ្លាំងរបស់ស្ត្រី។ ហើយព្រះជាម្ចាស់មានបំណងព្រះទ័យចំពោះ «ភាពទន់ខ្សោយ» ទាំងអស់ដែលជាលក្ខណៈរបស់ស្ត្រី ដើម្បីរំលេចឡើង និងបញ្ជាក់ពីភាពខ្លាំងរបស់បុរស។

បើទោះជាកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១៤ មានន័យថា នៅក្នុងកាលៈទេសៈមួយចំនួន ស្ត្រីមានលក្ខណៈងាយរងគ្រោះជាងដូចជាក្នុងការចាញ់បញ្ឆោតក៏ដោយ ក៏ការនោះនឹងមិនកំណត់ពីភាពស្មើគ្នា ឬតម្លៃនៃភាពជាបុរស និងភាពជាស្ត្រីឡើយ។ ការអួតខ្លួនចំពោះភេទណាមួយថា ពូកែជាង គឺជាភាពល្ងង់ខ្លៅ។ នៅពេលព្រះជាម្ចាស់បានបង្កើតយើងមកជាបុរស និងស្ត្រី នោះយើងមានភាពខុសគ្នាច្រើនរាប់រយរបៀប។ ការបានបង្កើតឲ្យមានភាពស្មើៗគ្នានៅក្នុងរូបអង្គទ្រង់យ៉ាងហោចណាស់នេះមានន័យថា៖ ជាក់ស្តែង ទាំងភេទប្រុសនិងភេទស្រីមាននូវចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗគ្នា ប៉ុន្តែគុណតម្លៃរួមនោះគឺ ទាំងពីរភេទត្រូវបានបង្កើតមកឲ្យមានតុល្យភាព ហើយឲ្យបំពេញ



50 Crucial Questions.indd 60 7/4/26 2:18 in the afternoon

បន្ថែមដល់គ្នា។ ហើយនៅពេលដែលលោកអ្នកយកកាឡោននៃភេទទាំងពីរហើយដាក់ពីលើគ្នា នោះហើយជាព្រះទ័យរបស់ព្រះជាម្ចាស់ចង់ឲ្យពួកគេក្លាយជាការបំពេញបន្ថែមដ៏ល្អឥតខ្ចោះដល់គ្នាទៅវិញទៅមក។

## សំណួរទី៣០
## ប្រសិនបើស្ត្រីមិនមានការអនុញ្ញាតឲ្យបង្រៀនបុរសជាទូទៅ និងជាផ្លូវការទេ ហេតុអ្វីបានជាមានការអនុញ្ញាតឲ្យនាងបង្រៀនក្មេងៗដែលជាអ្នកងាយនឹងត្រាប់តាមអ្នកដទៃ និងទន់ខ្សោយទៅវិញ?

សំណួរនេះសន្មតអ្វីមួយដែលយើងមិនជឿតាម។ ដូចដែលយើងបានសំដៅនៅក្នុងសំណួរទី២១ យើងមិនសង់និមិត្តរបស់យើងលើការសន្មតថា ព្រះគម្ពីរបានកំណត់តួនាទីសម្រាប់ស្ត្រីៗ ដោយសារពួកគេគ្មានសមត្ថភាពខាងគោលលទ្ធិ ឬខាងសីលធម៌នោះទេ។ ភាពខុសគ្នានៃតួនាទីសម្រាប់បុរស និងស្ត្រីនៅក្នុងការបម្រើព័ន្ធកិច្ច គឺមិនមានឫសគល់ពាក់ព័ន្ធទៅនឹងសមត្ថភាពណាមួយដែលរំពឹងទុកនោះទេ ប៉ុន្តែមាននៅក្នុងសេចក្តីបង្គាប់ដែលព្រះជាម្ចាស់បានបង្កើតមកសម្រាប់ភាពជាបុរស និងភាពជាស្ត្រីវិញ។ ដោយសារក្មេងប្រុសតូចៗមិនផ្សារភ្ជាប់ទំនាក់ទំនងនឹងគ្រូបង្រៀនស្ត្រីរបស់ពួកគេ ដូចលក្ខណៈដែលបុរសពេញវ័យមានការផ្សារភ្ជាប់នឹងស្ត្រី នោះភាពជាអ្នកដឹកនាំដែលមានលក្ខណៈរឹងមាំតែងតាំងដោយព្រះជាម្ចាស់ផ្ទាល់មិនធ្វើឲ្យរងរបួសទេ។ (ទោះជាយ៉ាងនេះក្តី កម្លាំងចលកររឹងមាំនៃការផ្សារភ្ជាប់នោះនឹងរងរបួស ប្រសិនបើគំរូនៃការដំណើរការ និងការបង្រៀននៅក្នុងក្រុមជំនុំរបស់យើងមានការបង្ហាញថា ការបង្រៀនព្រះគម្ពីរគឺគ្រាន់តែជាកិច្ចការរបស់ស្ត្រីប៉ុណ្ណោះ ហើយមិនមែនជាទំនួលខុសត្រូវចម្បងរបស់ឪពុក និងបុរសខាងព្រះវិញ្ញាណនៃក្រុមជំនុំ)។



50 Crucial Questions.indd 61 7/4/26 2:18 in the afternoon

## សំណួរទី៣១
## តើលោកគ្រូមិនមានកំហុសលើការជ្រើសរើសយកតែន័យត្រង់ៗមួយនេះទេឬអី នៅពេលលោកគ្រូលើកឡើងថា សេចក្តីបង្គាប់មួយចំនួននៅក្នុងអត្ថបទមួយមានសុពលភាពជាអចិន្ត្រៃយ៍ ហើយសេចក្តីបង្គាប់ខ្លះទៀតដូចជា «កុំឲ្យក្រងសក់» ឬ «កុំឲ្យគ្របក្បាល» ថាមានលក្ខខណ្ឌ និងភាពមិនដាច់ខាតតាមវប្បធម៌ក្នុងនោះដែរឬទេ?

គ្រប់ទាំងជីវិត និងភាសា គឺសុទ្ធតែមានលក្ខខណ្ឌវប្បធម៌។ យើងចែករំលែកវាជាមួយអ្នកកាត់ស្រាយព្រះបន្ទូលទាំងអស់អំពីការលំបាកនៃការប្រឈមក្នុងការយល់ដឹងអំពីលក្ខណៈនៃការបង្រៀនពីព្រះគម្ពីរ ព្រះជាម្ចាស់ ដំណឹងល្អ ឬការបង្កើត ដូចដែលព្រះជាម្ចាស់បានមានបន្ទូលបង្គាប់។ យើងនឹងសិក្សាអំពីរឿងទាំងនេះ ដូចដែលយើងឃើញនៅពាសពេញព្រះគម្ពីរ។

ផ្ទុយទៅវិញ ដើម្បីបង្ហាញថា ទម្រង់ជាក់លាក់ណាមួយនៃសេចក្តីបង្គាប់នានាត្រូវបានកំណត់នៅក្នុងស្ថានភាព ឬវប្បធម៌ណាមួយ (១) យើងស្វែងរកតម្រុយនៅក្នុងបរិបទនេះគឺដូច្នេះមែន (២) យើងប្រៀបធៀបការជាប់ទាក់ទងផ្សេងទៀតនៃកណ្ឌគម្ពីរទៅនឹងប្រធានបទដូចគ្នា ដើម្បីមើលថាយើងកំពុងដោះស្រាយជាមួយការអនុវត្តដែលមានដែនកំណត់ ឬជាមួយនឹងការនៅជាប់នឹងសេចក្តីតម្រូវការ ហើយ (៣) យើងព្យាយាមបង្ហាញថា វប្បធម៌ជាក់លាក់នៃសេចក្តីបង្គាប់ គឺមិនមានឫសគល់នៅក្នុងលក្ខណៈរបស់ព្រះជាម្ចាស់ ដំណឹងល្អ ឬលំដាប់លំដោយនៃការបង្កើតទេ។ នៅក្នុងបរិបទនៃការបង្រៀនរបស់សាវ័ក ប៉ុល និងសាវ័ក ពេត្រុស អំពីលក្ខណៈដែលបុរស និងស្ត្រីមានទំនាក់ទំនងនៅក្នុងក្រុមជំនុំ និងនៅផ្ទះ គឺមិនមែនមានតែការណែនាំត្រឹមតែអំពីការចុះចូល និងការដឹកនាំ ប៉ុន្តែក៏មានលក្ខណៈនៃការតុបតែងខ្លួនរបស់ស្ត្រីផងដែរ។ មានខគម្ពីរជាប់ទាក់ទងគ្នានៅក្នុងការកាត់ស្រាយដោយត្រង់ៗរបស់យើង៖

ឯពួកស្រីៗ នោះខ្ញុំក៏ចង់ឲ្យគេតែងខ្លួនតាមបែបគួរសម ឲ្យចេះអៀនខ្លួន ហើយដឹងប្រមាណខ្លួន មិនមែនជាអ្នកតែងខ្លួន ដោយក្រងសក់ ឬពាក់មាស



50 Crucial Questions.indd 62 7/4/26 2:18 in the afternoon

កែវមុក្តា ឬសំលៀកបំពាក់យ៉ាងថ្លៃពេកនោះឡើយ តែឲ្យសំណាំនឹងពួកស្ត្រី ដែលរាប់ខ្លួនជាអ្នកកោតខ្លាចដល់ព្រះ គឺដោយការប្រព្រឹត្តល្អវិញ (១ធីម៉ូថេ ២:៩-១០)។

ទាំងតែងខ្លួនមិនមែនដោយបែបខាងក្រៅ ដូចជាក្រងសក់ ពាក់មាស ឬសំលៀកបំពាក់ផ្សេងៗឡើយ គឺតែងចំពោះមនុស្សលាក់កំបាំងក្នុងចិត្តវិញ ដោយគ្រឿងដ៏មិនចេះពុករលួយ (ឧ. គ្រឿងអលង្ការ) របស់វិញ្ញាណសំឡូត ហើយរម្យទម នោះឯងជាសេចក្តីដែលមានតម្លៃវិសេសនៅចំពោះព្រះ (១ពេត្រុស ៣:៣-៥)។

វាអាចនឹងខុសនៅក្នុងការនិយាយថា សេចក្តីបង្គាប់ទាំងនោះមិនជាប់ទាក់ទងគ្នានៅបច្ចុប្បន្ននេះ។ ការបង្រៀនដ៏ជាក់លាក់មួយនៅក្នុងពួកគេ គឺជាការផ្តោតសំខាន់នៃការខិតខំប្រឹងប្រែងនៅក្នុងការតុបតែង គួរតែលើ “ការប្រព្រឹត្តល្អ” និងលើ “មនុស្សលាក់កំបាំងក្នុងចិត្តវិញ” ជាជាងលើអ្វីដែលនៅខាងក្រៅដូចជា សំលៀកបំពាក់ ក្រងសក់ និងគ្រឿងអលង្ការ។ ទាំងមិនមានហេតុផលណាមួយ ដើម្បីទុកជាមោឃៈនូវពាក្យបញ្ជាទូទៅឲ្យមានលក្ខណៈសមរម្យ និងសមហេតុសមផល ឬការព្រមានប្រឆាំងនឹងការបង្អួតមាសប្រាក់។ មានសំណួរតែមួយគត់៖ តើការក្រងសក់ ពាក់មាសប្រាក់ និងគជ់ គឺជាអំពើបាបនៅពេលនោះ និងពេលបច្ចុប្បន្ននេះឬក៏អត់?

មានការបញ្ជាក់យ៉ាងច្បាស់មួយអំពីបរិបទនេះថា ដែលមិនមែនជាចំណុចសំខាន់នោះទេ។ សាវ័ក ពេត្រុស និយាយថា៖ “ទាំងតែងខ្លួនមិនមែនដោយបែបខាងក្រៅ...សំលៀកបំពាក់ផ្សេងៗឡើយ”។ ភាសាក្រិកមិននិយាយថា សំលៀកបំពាក់ “យ៉ាងថ្លៃពេក” (ព្រះគម្ពីរបរិសុទ្ធ បកប្រែឆ្នាំ១៩៥៤) ប៉ុន្តែគ្រាន់តែប្រើ “ស្លៀកសំលៀកបំពាក់” ពោលគឺ “សំលៀកបំពាក់ដែលអ្នកពាក់” ឬ “ការស្លៀកសំលៀកបំពាក់”។ ឥឡូវយើងដឹងថា សាវ័ក ពេត្រុស មិនបានថ្កោលទោសចំពោះការប្រើប្រាស់សំលៀកបំពាក់ទេ។ គាត់កំពុងថ្កោលទោសចំពោះការប្រើប្រាស់សំលៀកបំពាក់ខុស។ ដូច្នេះ ការនេះបង្ហាញថា រឿង



50 Crucial Questions.indd 63 7/4/26 2:18 in the afternoon

ដដែលនេះអាចនិយាយបានអំពីមាស និងការក្រងសក់ដែរ។ ចំណុចសំខាន់គឺមិនមែនដើម្បីព្រមានប្រឆាំងនឹងអ្វីដែលអាក្រក់នៅខាងក្នុងនោះទេ ប៉ុន្តែដើម្បីព្រមានប្រឆាំងនឹងការប្រើប្រាស់វាខុស ដែលជាការបង្ហាញពីការលើកតម្កើងខ្លួនឯង ឬការគិតតាមលោកីយ៍វិញ។ បន្ថែមទៀត ពាក្យបញ្ជាដែលទាក់ទងនឹងការដឹកនាំ និងការចុះចូលមានឫសគល់តាមលំដាប់លំដោយនៃការបង្កើតមក (១ធីម៉ូថេ ២:១៣-១៤) ខណៈដែលមិនមានលក្ខណៈជាក់លាក់នៃបែបគួរសម។ នេះជាមូលហេតុដែលយើងទូលអង្វរសម្រាប់អ្នកគ្មានកំហុសចំពោះការចោទប្រកាន់ពីការជ្រើសរើសអ្នកអក្សរសាស្ត្រនិយម។

## សំណួរទី៣២
## ប៉ុន្តែតើសាវ័ក ប៉ុល មិនបានតវ៉ាសុំឲ្យមានការគ្របក្បាលសម្រាប់ស្ត្រីក្នុងការថ្វាយបង្គំ ដោយអំពាវនាវឲ្យផ្អែកទៅលើលំដាប់លំដោយដែលព្រះបានបង្កើតនៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:១៣-១៥ ទេឬអី? ហេតុអ្វីបានជាការគ្របក្បាលមិននៅជាប់រហូតដល់សព្វថ្ងៃនេះ ខណៈពេលដែលការបង្រៀនដែលទាក់ទងទៅនឹងការចុះចូល និងការដឹកនាំនៅជាប់ដរាបដល់សព្វថ្ងៃ?

សំណួរសំខាន់នៅត្រង់នេះគឺថា តើសាវ័ក ប៉ុល កំពុងនិយាយថា ការបង្កើតកំពុងចង្អុលបង្ហាញការពាក់អ្វីលើក្បាល ឬការបង្កើតនោះបានចង្អុលបង្ហាញដែលយើងបានប្រើការបញ្ជាក់យ៉ាងត្រឹមត្រូវតាមវប្បធម៌នៃភាពជាបុរស និងភាពជាស្ត្រី ដែលទើបតែបានកើតឡើងពីការគ្របក្បាលរបស់ស្ត្រីនៅក្នុងបរិបទនោះមែនឬ? យើងគិតថា អ្វីដែលកើតឡើងបន្ទាប់នោះគឺជាអ្វីដែលអ្នកនិពន្ធកំពុងតែលើកឡើង។ ខគម្ពីរគន្លឹះគឺ៖ “ចូរពិចារណាក្នុងខ្លួនអ្នករាល់គ្នាមើល តើគួរគប្បីឲ្យស្ត្រីអធិស្ឋានដល់ព្រះ ដោយឥតមានពាក់អីលើក្បាលឬទេ? តើធម្មតាលោកមិនបង្រៀនអ្នករាល់គ្នាទេឬអីថា បើបុរសទុកសក់វែងនោះជាការបង្អាប់ដល់ខ្លួន តែបើស្ត្រីទុកសក់វែង នោះឯងជាសេចក្តីលម្អដល់នាងវិញ ដ្បិតសក់វែងនោះ ទ្រង់បានប្រទានមកនាង ទុកជាប្រដាប់សម្រាប់



50 Crucial Questions.indd 64 7/4/26 2:18 in the afternoon

ទទូរ» (១កូរិនថូស ១១:១៣-១៥)។

តើអ្វីទៅជាលក្ខណៈនៃការបង្រៀនដែលថា ការទុកសក់វែងធ្វើឲ្យជាការបង្អាប់ដល់បុរស ហើយប្រទានមកស្ត្រីសម្រាប់ទទូរដោយរបៀបណា? លក្ខណៈធម្មជាតិមិនបានផ្តល់មកស្ត្រីឲ្យមានសក់ច្រើនជាងបុរសនោះទេ។ តាមពិតទៅ ប្រសិនបើយើងអនុវត្តតាមគោលការណ៍ធម្មជាតិរបស់ខ្លួន នោះបុរសនឹងមានសក់ច្រើនជាងស្ត្រី ព្រោះវានឹងគ្របមុខ និងក្បាលរបស់ពួកគេផងដែរ។ ត្រូវតែមានវិធីមួយទៀត ដែលលក្ខណៈធម្មជាតិបង្រៀនលើប្រធានបទនេះ! យើងជឿថា ទំនៀមទម្លាប់ និងធម្មជាតិរួមផ្សំគ្នានៅក្នុងការបង្រៀននេះ។ ម្យ៉ាងវិញទៀត ទំនៀមទម្លាប់កំណត់ថា តើការរៀបចំសក់បែបណា ជាទូទៅមានលក្ខណៈជាបុរស ឬជាស្ត្រី។ ម្យ៉ាងវិញទៀត លក្ខណៈធម្មជាតិកំណត់ថា បុរសមានអារម្មណ៍ថាអាម៉ាស់ នៅពេលដែលពួកគេពាក់និមិត្តសញ្ញានៃភាពជាស្ត្រី។ យើងអាចមានអារម្មណ៍អំពីការដឹងពីការបង្ខំនៃរឿងនេះ ដោយសួរបុរសនៅក្នុងក្រុមជំនុំរបស់យើងថា៖ «តើធម្មជាតិមិនបង្រៀនអ្នកមិនឲ្យស្លៀករ៉ូបទៅព្រះវិហារទេឬអី? ការបង្រៀនពីធម្មជាតិ គឺជាទំនោរនៃលក្ខណៈពីកំណើតរបស់មនុស្សប្រុស និងមនុស្សស្រីឲ្យមានអារម្មណ៍ថាអាម៉ាស់ នៅពេលដែលពួកគេបោះបង់ចោលនូវនិមិត្តសញ្ញាវប្បធម៌ ដែលបានបង្កើតឡើងនៃភាពជាបុរស ឬភាពជាស្ត្រី។ ធម្មជាតិមិនបានបង្រៀនអំពីអ្វីដែលនិមិត្តសញ្ញាគួរតែមានលក្ខណៈដូចម្តេចនោះទេ។

នៅពេលដែលសាវ័ក ប៉ុល បានលើកឡើងថា សក់របស់ស្ត្រី «បានប្រទានមកនាង ទុកជាប្រដាប់សម្រាប់ទទូរ» (ខ១៥) គាត់មានន័យថា លក្ខណៈធម្មជាតិបានផ្តល់សក់ឲ្យស្ត្រី និងទំនោរក្នុងការធ្វើតាមទំនៀមទម្លាប់ទូទៅនៃការបង្ហាញភាពជាស្ត្រីរបស់នាង ដែលក្នុងករណីនេះរួមបញ្ចូលការទុកសក់នាងដុះវែង ហើយទុកវាជាប្រដាប់សម្រាប់ទទូរក្បាល។ ដូច្នេះ គំនិតសំខាន់របស់សាវ័ក ប៉ុល នៅក្នុងព្រះគម្ពីរនេះគឺថា ទំនាក់ទំនងនៃភាពជាបុរស និងភាពជាស្ត្រីដែលត្រូវបានចាក់ឫសតាមលំដាប់លំដោយនៃការបង្កើតមក



50 Crucial Questions.indd 65 7/4/26 2:18 in the afternoon

(១កូរិនថូស ១១:៧-៩) គួរតែរកការបញ្ជាក់ដែលសមរម្យសម្រាប់វប្បធម៌នៅពេលថ្វាយបង្គំ។ ធម្មជាតិបង្រៀនរឿងនេះដោយផ្តល់ឲ្យបុរស និងស្ត្រីនូវទំនោរចិត្តយ៉ាងជ្រាលជ្រៅ និងខុសគ្នាអំពីការប្រើប្រាស់និមិត្តសញ្ញានៃភាពជាបុរស និងភាពជាស្ត្រី។

## សំណួរទី៣៣

## តើវាមានភាពស៊ីគ្នាយ៉ាងដូចម្តេច ខណៈពេលដែលមានការហាមឃាត់ក្នុងការផ្តល់តួនាទីជាពួកចាស់ទុំលើស្ត្រីៗនៅក្នុងក្រុមជំនុំទាំងឡាយរបស់យើង តែបែរជាបញ្ជូនពួកគេឲ្យចេញទៅក្នុងនាមជាបេសកជន ដើម្បីធ្វើការជាច្រើនដែលបានហាមឃាត់នៅក្រុមជំនុំខ្លួន?

យើងឈរដោយស្ញប់ស្ញែងនៅក្នុងសេចក្តីជំនឿ សេចក្តីស្រឡាញ់ សេចក្តីក្លាហាន និងការលះបង់ដែលបានជំរុញស្ត្រីៗដែលនៅលីវ និងរៀបការរួចរាប់ពាន់នាក់ឲ្យចូលរួមក្នុងបេសកកម្ម។ នេះជារឿងដែលបានប្រាប់ដោយលោកស្រី រស់ ថាក់ឃើ (Ruth Tucker) ក្នុងសៀវភៅអ្នកការពារមហាបេសកកម្មៈ "ដំណើររឿងរបស់ស្ត្រីៗនៅក្នុងបេសកកម្មសម័យទំនើប" (*Guardians of the Great Commission*: *The Story of Women in Modern Missions*)[១៦] នេះគឺរឿងដ៏អស្ចារ្យណាស់។ ការអធិស្ឋានរបស់យើងគឺថា វានឹងជំរុញស្ត្រីៗ—និងបុរសៗរាប់ពាន់នាក់ទៀត!—ក្នុងការថ្វាយខ្លួនពួកគាត់ទៅក្នុងកិច្ចការដ៏អស្ចារ្យនៃការផ្សាយដំណឹងល្អសកល។

តើការនេះមិនស្របគ្នានឹងយើងទេឬ? តើវាជាការពិតមែនដែរឬទេ ដែលថាយើងកំពុងបញ្ជូនស្ត្រីជាបេសកជនឲ្យធ្វើនូវអ្វីដែលត្រូវ "បានហាមឃាត់" នៅក្នុងក្រុមជំនុំនៅក្នុងស្រុក? បើដូច្នេះមែន វាគឺជាការពិតដ៏គួរឲ្យកត់សម្គាល់មួយ ដែលស្ត្រីភាគច្រើនដែលបានក្លាយជាបេសកជនជាច្រើនសតវត្សមកនេះ ហើយក៏បានគាំទ្រទំនួលខុសត្រូវរបស់បុរសក្នុងភាពជាអ្នកដឹកនាំតាមរបៀប

១៦ លោកស្រី Ruth Tucker, *Guardians of the Great Commission: The Story of Women in Modern Missions* (Grand Rapids, MI: Zondervan, ឆ្នាំ១៩៨៨)។



50 Crucial Questions.indd 66 7/4/26 2:18 in the afternoon

ដែលយើងធ្វើដែរ។[១៧] ហើយបុរសដែលបានជ្រើសរើស និងការពារស្ត្រីយ៉ាងខ្លាំងក្លាបំផុតសម្រាប់បេសកកម្មបានធ្វើដូច្នេះ គឺមិនមែនដោយសារតែពួកគេមិនយល់ស្របនឹងនិមិត្តរបស់យើងអំពីភាពជាបុរស និងភាពជាស្ត្រីនោះទេ ប៉ុន្តែគឺដោយសារតែពួកគេបានឃើញការងារគ្មានព្រំដែនក្នុងការផ្សាយដំណឹងល្អ—ការងារមួយចំនួនដែលស្ត្រីអាចធ្វើបានល្អប្រសើរជាងបុរសទៅទៀត។

ជាឧទាហរណ៍៖ លោកគ្រូ ហ័ដសុន ថេល័រ បានឃើញថា ពេលដែលអ្នកផ្សាយដំណឹងល្អជនជាតិចិនរៀនជាមួយ «បងប្អូនស្រីៗដែលជាបេសកជន» ជាជាងរៀនជាមួយបេសកជនដែលជាបុរសជនជាតិអឺរ៉ុប «[នោះ] ការងារទាំងអស់ទាក់ទងនឹងការបង្រៀន និងការអធិប្បាយ ហើយការតំណាងឲ្យបេសកកម្មដល់មនុស្សខាងក្រៅស្រុកលែងមានការពឹងផ្អែកលើគាត់។ គេបានរាប់គាត់ថាជាប្រមុខបេសកកម្ម ហើយត្រូវតែធ្វើសកម្មភាពដោយឯករាជ្យ»។[១៨] ភាពមិនសមហេតុសមផលនៃកម្លាំងជាបេសកជននៃភាពកម្សោយ គេក៏ទទួលស្គាល់ថា ជាភាពខ្លាំងម្តងហើយម្តងទៀត។ អ្នកគ្រូ ម៉ារី ស្លីសស័រ (Mary Slessor) ក្នុងការបង្ហាញភាពខ្លាំងដែលមិនគួរឲ្យជឿលើបានក៏ប្រកែកថា នាងគួរតែទទួលបានការអនុញ្ញាតឲ្យទៅតែម្នាក់ឯងទៅកាន់ទឹកដី ដែលគេមិនទាន់បានទៅដល់នៅក្នុងទ្វីបអាហ្រ្វិក ពីព្រោះ «ក្នុងនាមជាស្ត្រី នោះនាងនឹងមិនមានការគម្រាមកំហែងដល់កុលសម្ព័ន្ធដើមតិចជាងបេសកជនជាបុរស ដូច្នេះនាងនឹងមានសុវត្ថិភាពជាង»។[១៩]

ឧទាហរណ៍មួយទៀត គឺលោកគ្រូ អេ.ជេ ហ្គ័រដុន (A. J. Gordon) ដែលជាគ្រូគង្វាលនៅបូស្តុន (Boston) ជាបេសកជន ជាអ្នកធ្វើការរដ្ឋ និងជាស្ថាបនិក (ក្នុងឆ្នាំ១៨៨៩) នៃវិទ្យាស្ថានបណ្តុះបណ្តាលបេសកជនបូស្តុន (Boston Missionary Training Institute) ដែលក្រោយមកនឹង

១៧ ក្នុងសៀវភៅដូចគ្នា ទំព័រ៣៨។

១៨ ក្នុងសៀវភៅដូចគ្នា ទំព័រ៤៧។

១៩ ក្នុងសៀវភៅដូចគ្នា ទំព័រ៨៣។



50 Crucial Questions.indd 67 7/4/26 2:18 in the afternoon

បង្កើតបានទាំងមហាវិទ្យាល័យហ្គ័រដុន (Gordon College) និងសាលាព្រះគម្ពីរ ហ្គ័រដុន-ខនវែល (Gordon and Gordon-Conwell Theological Seminary)។ លោកគ្រូបានលើកកម្ពស់យ៉ាងខ្លាំងដល់ស្ត្រីក្នុងការធ្វើបេសកកម្ម ដោយអំពាវនាវជាពិសេសដល់កូនស្រីដែលបានថ្លែងទំនាយនៅក្នុងកណ្ឌគម្ពីរ កិច្ចការ ២:១៧។ ប៉ុន្តែ សម្រាប់ភាពរីករាយទាំងអស់របស់គាត់ក្នុងការការបម្រើដ៏ធំបំផុតរបស់ស្ត្រីក្នុងបេសកកម្ម លោកក៏បានមើលឃើញទស្សនៈមួយដូចយើងដែរនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២៖

> ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំទទួលស្គាល់ថា ការហាមឃាត់នេះគឺប្រឆាំងនឹងការបង្រៀនជាសាធារណៈ។ តើវាអាចមានន័យយ៉ាងដូចម្តេច? ការបង្រៀន និងការគ្រប់គ្រងគឺជាមុខងារពិសេសរបស់ពួកចាស់ទុំ។ គ្រូបង្រៀន និងគ្រូគង្វាលដែលមានឈ្មោះនៅក្នុងអំណោយទាននៃក្រុមជំនុំ (អេភេសូរ ៤:១១) លោក ហ្គ័រដុន ក៏បានចាត់ទុកថាដូចគ្នា ហើយជាទូទៅគ្រូគង្វាលក៏ត្រូវបានចាត់ទុកថា ដូចគ្នាបេះបិទជាមួយគ្រូត្រួតត្រាដែរ។ តាមពិតទៅ គ្មានឧទាហរណ៍ណាមួយនៅក្នុងព្រះគម្ពីរសញ្ញាថ្មីអំពីស្ត្រីដែលត្រូវបានតែងតាំងឡើងឲ្យគ្រប់គ្រងលើក្រុមជំនុំ ជាអ្នកត្រួតត្រា និងជាគ្រូបង្រៀននោះទេ។ ការខ្វះគំរូបែបនេះនឹងនាំយើងឲ្យបដិសេធការតែងតាំងស្ត្រីធ្វើជាអ្នកគ្រូគង្វាលនៃក្រុមជំនុំគ្រីស្ទបរិស័ទ។ ប៉ុន្តែ ប្រសិនបើព្រះអម្ចាស់បានកំណត់ដែនកំណត់នេះ នោះយើងជឿថាវាមានមូលដ្ឋានមិនមែននៅលើទីតាំងដែលមិនសូវពេញចិត្តរបស់នាងនៅក្នុងឯកសិទ្ធិនៃព្រះគុណនោះទេ តែនៅក្នុងឧបសគ្គចំពោះការបម្រើបែបនេះ ដែលមាននៅក្នុងលក្ខណៈខ្លួនឯងវិញ។[៧០]

យើងទទួលស្គាល់ថា មានភាពមិនច្បាស់លាស់ក្នុងការអនុវត្តការណែនាំរបស់សាវ័ក ប៉ុល ស្តីអំពីក្រុមជំនុំដែលបានបង្កើតឡើង ចំពោះក្រុមជំនុំដែលកំពុងតែរីកចម្រើនឡើង។ យើងទទួលស្គាល់ថា ពិតជាមានភាពមិនច្បាស់លាស់មែនក្នុងការបំបែកការទូន្មានប្រភេទដូចជានាង ព្រីស៊ីល ពីតួនាទីនៃ

៧០ . លោក A. J. Gordon, "The Ministry of Women," Gordon Conwell Monograph ៦១ (South Hamilton, MA: Gordon Conwell Theological Seminary, n.d.), ១០។ បានបោះពុម្ពផ្សាយដំបូងនៅក្នុង Missionary Review of the World, n.s., ៨, លេខ ១២ (ខែធ្នូ ឆ្នាំ១៨៩៤)។



50 Crucial Questions.indd 68 7/4/26 2:18 in the afternoon

ការបង្រៀនជាផ្លូវការនៃកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២។ យើងអាចស្រមៃថា ខ្លួនយើងកំពុងតស៊ូ ដើម្បីភាពស្មោះត្រង់ក្នុងព្រះគម្ពីរ និងវប្បធម៌ ដូចដែលលោក ហ៉ាដសុន ថេល័រ បានមានការតស៊ូនៅក្នុងសំបុត្រមួយផ្ញើទៅកញ្ញា ហ្វូលឌីង (Miss Fauld-ing) នៅឆ្នាំ១៨៦៨៖

> ខ្ញុំមិនដឹងថា ពេលណាខ្ញុំអាចនឹងត្រឡប់មកវិញបានទេ ហើយកិច្ចការក្នុងក្រុមជំនុំមិនអាចរង់ចាំខ្ញុំឡើយ។ ប្អូនស្រីមិនអាចធ្វើជាគ្រូគង្វាលបានទេ ប៉ុន្តែប្អូនស្រីត្រូវតែជួយលោកគ្រូ (ហ្វាង) ឡែតជុន (Wang Laedjun) ដើម្បីធ្វើកិច្ចការទទួលនរណាម្នាក់ចូលក្រុមជំនុំ ក៏ដូចជាកាត់នរណាម្នាក់ចេញពីក្រុមជំនុំ តាមដែលប្អូនស្រីអាចធ្វើបាន។ ប្អូនស្រីអាចនិយាយជាលក្ខណៈឯកជនជាមួយបេក្ខជន ព្រមទាំងអាចចូលរួមក្នុងការប្រជុំនៅក្រុមជំនុំ ហើយប្អូនស្រីថែមទាំងអាចសួរសំណួរដែលត្រូវសួរដល់អស់អ្នកណាដែលចង់ទទួលពិធីបុណ្យជ្រមុជទឹកតាមរយៈអ្នកដទៃទៀតផង។ បន្ទាប់មក ក្រោយពីប្រជុំរួចប្អូនស្រីអាចនិយាយជាលក្ខណៈឯកជនជាមួយលោកគ្រូ ឡែតជុន អំពីរឿងរ៉ាវរបស់ពួកគេ ហើយផ្តល់យោបល់ អ្នកណាដែលប្អូនស្រីគិតថា គាត់អាចនឹងទទួលធ្វើបុណ្យជ្រមុជទឹកឲ្យបាននៅពេលដែលជួបពួកគេលើកក្រោយ។ ដូច្នេះ គាត់ប្រហែលជាទទួលបានជំនួយដែលគាត់ត្រូវការ ហើយនិងមិនមាននរណាម្នាក់អាចចាត់ទុកថា វាជារឿងមិនសមរម្យនោះទេ។[២១]

យើងមិនចង់បង្អាក់បុព្វហេតុដ៏អស្ចារ្យនៃការផ្សាយដំណឹងល្អជាសកលដោយការឆ្ងល់ថា តើតួនាទីមួយណាក្នុងចំណោមតួនាទីរាប់រយសម្រាប់បេសកជន អាចទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងតួនាទីជាគ្រូគង្វាល/ពួកចាស់ទុំបានទេ ឬថាមិនសមរម្យសម្រាប់ស្ត្រីនោះទេ។ ច្បាស់ណាស់ សម្រាប់យើង ស្ត្រីគឺជាអ្នកធ្វើការរួមគ្នានៅក្នុងដំណឹងល្អ ហើយគួរតែព្យាយាមបម្រើនៅក្បែរមនុស្សប្រុស (ភីលីព ៤:៣; រ៉ូម ១៦:៣, ១២)។ ហើយសម្រាប់ជាប្រយោជន៍

២១ . លោកបណ្ឌិត និងលោកស្រី Howard Taylor, *Hudson Taylor and the China Inland Mission: The Growth of a Work of God* (London: The Religious Tract Society, ឆ្នាំ១៩៤០), ទំព័រ៣៩៧-៩៨។



50 Crucial Questions.indd 69 7/4/26 2:18 in the afternoon

នៃការបញ្ចប់មហាបេសកកម្មនៅសម័យរបស់យើង នោះយើងសុខចិត្តប្រថុយប្រថាននឹងការចាត់តាំងតួនាទីដែលមិនសូវសមរម្យមួយចំនួន។

យើងសង្ឃឹមថា យើងនឹងមិនបញ្ជូនបុរស ឬស្ត្រីឲ្យទៅធ្វើអ្វីដែលយើងហាមឃាត់នៅផ្ទះទេ។ យើងមិនបានចាត់ស្ត្រីឲ្យទៅធ្វើជាគ្រូគង្វាល ឬពួកចាស់ទុំរបស់ក្រុមជំនុំទេ។ ហើយភាគច្រើន ក៏គ្មានអ្នកផ្សាយដំណឹងល្អ ឬអ្នកដាំក្រុមជំនុំជាស្ត្រីណាព្យាយាមចង់មានតួនាទីនេះសម្រាប់ខ្លួនគេនោះដែរ។ យើងមិនបានគិតថា ស្ត្រីមិនអាចប្រាប់ដំណើររឿងនៃដំណឹងល្អ ហើយនាំទាំងបុរសៗ និងស្ត្រីៗឲ្យទទួលជឿលើព្រះគ្រីស្ទនោះទេ។ យើងមិនបានគិតថា ព្រះជាម្ចាស់ហាមឃាត់ស្ត្រីឲ្យធ្វើការក្នុងចំណោមស្ត្រីដែលបាត់បង់រាប់លាននាក់នៅលើពិភពលោកនោះដែរ ដែលយោងទៅតាមលោកស្រី រស់ ថាក់យើ "គឺជាយុត្តិកម្មដ៏សំខាន់នៃចលនាបេសកកម្មរបស់ស្ត្រី" ។[៧២] ទោះបីមានស្ត្រីដែលប្រកាន់ភ្ជាប់លើទស្សនៈដែលមានកំហិតជាងយើង ក៏ការពិតដែលថា ជាងពីរភាគបី (២/៣) នៃមនុស្សបាត់បង់នៅលើពិភពលោកនេះ គឺជាស្ត្រី និងកុមារ មានន័យថា មានឱកាសកាន់តែច្រើនទៀតក្នុងការផ្សាយដំណឹងល្អ និងការបង្រៀន ទាន់នៅមានលទ្ធភាពនៅអាចផ្សាយដំណឹងល្អបាន។

បំណងប្រាថ្នារបស់យើង គឺមិនមែនដើម្បីក្លាយជាការត្រួតត្រាលើកន្លែងដែលស្ត្រីបម្រើទេ។ បំណងប្រាថ្នារបស់យើង គឺពួតដៃជាមួយរាស្ត្រទាំងអស់របស់ព្រះជាម្ចាស់នៅក្នុងរបៀបព្រះជាម្ចាស់ ដើម្បី "ថ្លែងប្រាប់ពីសិរីល្អទ្រង់នៅកណ្ដាលអស់ទាំងសាសន៍" (ទំនុកតម្កើង ៩៦:៣)។

៧២ លោកស្រី Tucker, *Guardians of the Great Commission*, ទំព័រ១១៧។



50 Crucial Questions.indd 70 7/4/26 2:18 in the afternoon

## សំណួរទី៣៤
## តើលោកគ្រូបដិសេធសិទ្ធិស្ត្រីក្នុងការប្រើប្រាស់អំណោយទានដែលព្រះជាម្ចាស់បានប្រទានដល់ពួកគាត់ដែរឬទេ? តើការប្រទានអំណោយទានខាងឯវិញ្ញាណរបស់ព្រះជាម្ចាស់មិនមែនមានន័យថា ទ្រង់គាំទ្រការប្រើប្រាស់អំណោយទាននោះសម្រាប់ការស្ថាបនាក្រុមជំនុំទេឬអី?

ការមានអំណោយទានខាងឯវិញ្ញាណ មិនមែនជាការអនុញ្ញាតឲ្យយើងប្រើវាតាមតែយើងចង់នោះទេ។ លោក ចន វ៉ាយធ៍ (John White) បានសរសេរយ៉ាងត្រឹមត្រូវថា «មនុស្សមួយចំនួនជឿថា វាមិនអាចទៅរួចទេ ដែលអំណាចនៃព្រះវិញ្ញាណបរិសុទ្ធអាចមានលទ្ធផលមិនបរិសុទ្ធនៅក្នុងជីវិតរបស់មនុស្សម្នាក់ៗ។ ប៉ុន្តែ វាអាចទៅរួចបានមែន»។[៧៣] អំណោយទានខាងឯវិញ្ញាណមិនត្រឹមតែបានប្រទានដោយព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះទេ ពួកគេបានគ្រប់គ្រងដោយព្រះគម្ពីរបរិសុទ្ធផងដែរ។ ច្បាស់ណាស់ ចេញពីកណ្ឌគម្ពីរ ១កូរិនថូស៖ មានមនុស្សដែលមានអំណោយទានក្នុងការនិយាយភាសាដទៃត្រូវបានប្រាប់កុំឲ្យប្រើវានៅទីសាធារណៈ នៅពេលដែលគ្មាននរណាមានអំណោយទាននៅក្នុងការបកប្រែ ហើយប្រាប់អ្នកអធិប្បាយឲ្យបញ្ឈប់ការថ្លែងទំនាយ នៅពេលដែលមានអ្នកណាផ្សេងមានការបើកសម្តែងពីព្រះ (១កូរិនថូស ១៤:២៨-៣០)។ យើងមិនបដិសេធសិទ្ធិស្ត្រីនៅក្នុងការប្រើអំណោយទានដែលព្រះជាម្ចាស់បានប្រទានដល់ពួកគេឡើយ។ ប្រសិនបើពួកគេមានអំណោយទាននៅក្នុងការបង្រៀន ឬការគ្រប់គ្រង ឬការផ្សាយដំណឹងល្អ នោះព្រះជាម្ចាស់ពិតជាសព្វព្រះទ័យឲ្យពួកគេប្រើអំណោយទាំងនោះ ហើយទ្រង់នឹងទទួលបានព្រះកិត្តិយស ចំពោះការប្តេជ្ញាចិត្តនៅក្នុងការប្រើប្រាស់អំណោយទានទាំងនោះតាមការណែនាំដែលមាននៅក្នុងព្រះគម្ពីរជាមិនខាន។

---

៧៣ លោក John White, *When the Spirit Comes with Power: Signs and Wonders among God's People* (Downers Grove,w IL: InterVarsity Press, ឆ្នាំ១៩៨៨), ទំព័រ១២៨។



50 Crucial Questions.indd 71 7/4/26 2:18 in the afternoon

## សំណួរទី៣៥
## ប្រសិនបើព្រះជាម្ចាស់បានត្រាស់ហៅស្ត្រីៗឲ្យធ្វើជាគ្រូគង្វាលយ៉ាងពិតប្រាកដមែន នោះតើលោកគ្រូអាចនិយាយថា នាងមិនគួរធ្វើជាគ្រូគង្វាលបានយ៉ាងដូចម្ដេច?

យើងមិនជឿថា ព្រះជាម្ចាស់ពិតជាត្រាស់ហៅស្ត្រីឲ្យធ្វើជាគ្រូគង្វាលនោះឡើយ។ យើងនិយាយនេះមិនមែនដោយសារតែយើងអាចយល់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់នរណាម្នាក់អស់នោះទេ ប៉ុន្តែដោយសារតែយើងជឿថា បទពិសោធន៍ផ្ទាល់ខ្លួនត្រូវតែវាយតម្លៃជាលក្ខណៈទូទៅដោយពឹងលើព្រះបន្ទូលរបស់ព្រះ គឺព្រះគម្ពីរ។ បើព្រះគម្ពីរបង្រៀនថា ព្រះសព្វព្រះហឫទ័យឲ្យតែបុរសប៉ុណ្ណោះ ដែលទទួលខុសត្រូវចំពោះការបង្រៀនជាចម្បង និងទំនួលខុសត្រូវក្នុងការគ្រប់គ្រងជាគ្រូគង្វាល នោះតាមន័យធៀបព្រះគម្ពីរក៏បង្រៀនថា ព្រះជាម្ចាស់មិនបានត្រាស់ហៅស្ត្រីឲ្យធ្វើជាគ្រូគង្វាលនោះទេ។ ក្រុមជំនុំដំបូងបានដឹងតាំងពីសម័យដើមថា អារម្មណ៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ចំពោះការដឹកនាំពីព្រះជាម្ចាស់ មិនមែនជាលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ដោយខ្លួនឯងផ្ទាល់សម្រាប់ការយល់ដឹងអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់នោះទេ។ ប្រាកដណាស់ ព្រះទ្រង់បានចាត់អ្នកបម្រើដែលបានជ្រើសរើស (រ៉ូម ១០:១៥) ប៉ុន្តែ ព្រះជាម្ចាស់ក៏បានព្រមានប្រឆាំងនឹងអ្នកដែលគិតថា ពួកគេត្រូវបានគេត្រាស់ហៅ ហើយក៏មិនត្រូវបានហៅផងដែរ៖ «អញមិនបានចាត់គេ ឬបង្គាប់គេឡើយ» (យេរេមា ២៣:៣២)។

ប្រហែលអ្វីដែលស្ត្រីជាគ្រីស្ទបរិស័ទស្មោះត្រង់ខ្លះយល់ថា ជាការត្រាស់ហៅពីព្រះជាម្ចាស់ឲ្យធ្វើជាគ្រូគង្វាល គឺពិតជាការត្រាស់ហៅនៅក្នុងការបម្រើព័ន្ធកិច្ចមែន ប៉ុន្តែមិនមែនធ្វើជាគ្រូគង្វាលទេ។ ជាញឹកញយ នៅពេលនរណាម្នាក់ទទួលបានការត្រាស់ហៅយ៉ាងខ្លាំងពីព្រះជាម្ចាស់នៅក្នុងការបម្រើកើតមានលើគ្រីស្ទបរិស័ទ ដែលព្រះវិញ្ញាណបរិសុទ្ធមិនបានបញ្ជាក់អំពីផ្លូវនៃការបម្រើដ៏ច្បាស់លាស់។ ត្រង់ចំណុចនេះ យើងមិនគួរតែមើលត្រឹមតែអំណោយ



50 Crucial Questions.indd 72 7/4/26 2:18 in the afternoon

ទានរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមើលការបង្រៀនពីព្រះគម្ពីរទាក់ទងនឹងអ្វីដែលជាភាពសមរម្យសម្រាប់យើងជាបុរស និងស្ត្រីផងដែរ។

## សំណួរទី៣៦
## តើសិទ្ធិអំណាចមានន័យយ៉ាងដូចម្ដេច ពេលលោកគ្រូនិយាយអំពីវាក្នុងទំនាក់ទំនងរវាងផ្ទះ និងក្រុមជំនុំ?

សំណួរនេះគឺជាសំណួរសំខាន់ ពីព្រោះព្រះគម្ពីរសញ្ញាថ្មីបានបង្ហាញថា ទំនាក់ទំនងមូលដ្ឋាននៃជីវិតសមស្របគ្នានៅក្នុងលក្ខខណ្ឌសិទ្ធិអំណាច និងការប្រព្រឹត្តតាម។ ឧទាហរណ៍៖ ទំនាក់ទំនងរវាងឪពុកម្ដាយ និងកូនៗ ដំណើរការដោយឈរលើមូលដ្ឋាននៃសិទ្ធិអំណាចរបស់ឪពុកម្ដាយនៅក្នុងតម្រូវការនៃការស្ដាប់បង្គាប់ (អេភេសូរ ៦:១-២)។រដ្ឋាភិបាលស៊ីវិលក៏មានសិទ្ធិអំណាចក្នុងការបង្កើតច្បាប់ ដែលគ្រប់គ្រងលើអាកប្បកិរិយារបស់ប្រជាពលរដ្ឋ (រ៉ូម ១៣:១-៧; ទីតុស ៣:១; ១ពេត្រុស ២:១៣-១៧)។ ស្ថាប័នសង្គមភាគច្រើនមានរចនាសម្ព័ន្ធ ដែលផ្ដល់សិទ្ធិអំណាចខ្លះៗដោយផ្ទាល់ដល់អ្នកដទៃក្នុងការដឹកនាំពួកគាត់។ ផ្នែកយោធា និងជំនួញភាគច្រើនគិតនៅក្នុងគំនិតរួចរាល់ហើយ (ម៉ាថាយ ៨:៩; ១ពេត្រុស ២:១៨-២០)។

ស្របពេលដែលក្រុមជំនុំមានមនុស្សដែលជាសង្ឃនៃអ្នកជឿ នោះក្រុមជំនុំក៏ត្រូវមានការគ្រប់គ្រង នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដោយអ្នកដឹកនាំដែលមានចិត្តជាអ្នកបម្រើ ដែលយើងត្រូវដើរតាម (១ថែស្សាឡូនីច ៥:១២; ហេព្រើរ ១៣:៧, ១៧; ១ធីម៉ូថេ ៣:៥; ៥:១៧)។ នៅក្នុងជីវិតអាពាហ៍ពិពាហ៍ ព្រះអង្គបានត្រាស់ហៅប្រពន្ធឲ្យចុះចូលចំពោះការដឹកនាំ ដែលមានការលះបង់របស់ប្ដី (អេភេសូរ ៥:២២-៣៣; កូឡូស ៣:១៨-១៩; ១ពេត្រុស ៣:១-៧)។ ជាចុងក្រោយ ប្រភពនៃសិទ្ធអំណាចនេះគឺជាសិទ្ធិអំណាចដាច់ខាតរបស់ព្រះជាម្ចាស់។

អ្វីដែលកាន់តែច្បាស់លាស់នៅពេលយើងព្យាយាមផ្ដល់និយមន័យចំពោះសិទ្ធិអំណាចនេះគឺថា មានទម្រង់ផ្លាស់ប្ដូរពីទំនាក់ទំនងមួយទៅទំនាក់ទំនង

មួយផ្សេងទៀត។ យើងនឹងកំណត់លើនិយមន័យនៃពាក្យ "សិទ្ធិអំណាច" ជាទូទៅមានន័យថាជា ក្រោមបង្គាប់ (ម៉ាថាយ ៨:៩) និងស្តាប់បង្គាប់ (ម៉ាកុស ១:២៧; ១កូរិនថូស ៧:៣៧) និងអំណាច (ឬក៏ការទទួលខុសត្រូវ) (២កូរិនថូស ១០:៨; ១៣:១០) ដើម្បីផ្តល់ការដឹកនាំ (ឬក៏ការណែនាំ) ទៅអ្នកដទៃ។ ការនេះអនុវត្តយ៉ាងគ្រប់លក្ខណ៍ចំពោះព្រះជាម្ចាស់នៅក្នុងទំនាក់ទំនងទាំងអស់របស់ទ្រង់។ ប៉ុន្តែ វាមានការអនុវត្តតាមក្នុងវិធីខុសគ្នាៗខ្លាំងចំពោះទំនាក់ទំនងផ្សេងៗ របស់មនុស្សយើង។

ឧទាហរណ៍៖ ទាក់ទងនឹងអំណាចនៃការដឹកនាំអ្នកដទៃ រដ្ឋមានដាវ (រ៉ូម ១៣:៤) ឪពុកម្តាយទទួលបានរំពាត់ (សុភាសិត ១៣:២៤) អ្នករកស៊ីអាចបញ្ជាប់បុគ្គលិកបាន (លូកា ១៦:២) ហើយពួកចាស់ទុំក៏អាចដោះស្រាយជាមួយក្រុមជំនុំ ដោយកាត់ការសមាជិកណាម្នាក់ចេញពីក្រុមជំនុំបានដែរ (ម៉ាថាយ ១៨:១៧; ១កូរិនថូស ៥:១-៨)។ ដូចគ្នានេះដែរ វិសាលភាពនៃសិទ្ធិនៃការដឹកនាំអ្នកដទៃក៏មានការប្រែប្រួលទៅតាមទំនាក់ទំនងនីមួយៗ។ ឧទាហរណ៍៖ ឪពុកម្តាយមានសិទ្ធិចូលរួមដោយផ្ទាល់នៅក្នុងរឿងលម្អិតនៃជីវិតរបស់កូនតូចៗរបស់ពួកគេ ដោយបង្រៀនពួកគេឲ្យចេះកាន់តែគួរសមឲ្យបានត្រឹមត្រូវ ហើយអង្គុយឲ្យបានត្រង់ខ្លួន។ ប៉ុន្តែ រដ្ឋាភិបាល និងក្រុមជំនុំនឹងមិនអាចមានសិទ្ធិទូលំទូលាយបែបនេះបានឡើយ។

សម្រាប់គ្រីស្ទបរិស័ទ សិទ្ធិ និងអំណាចថយចុះ ហើយការទទួលខុសត្រូវក្នុងការគ្រប់គ្រងកើនឡើង។ ដូចដែលព្រះយេស៊ូវបានមានបន្ទូលទៅកាន់ពួកសិស្សទ្រង់ថា៖ "អ្នករាល់គ្នាដឹងថា ពួកចៅហ្វាយនៃសាសន៍ដទៃតែងគ្រប់គ្រងលើសាសន៍របស់ខ្លួន ហើយពួកអ្នកធំក៏មានអំណាចលើគេដែរ ប៉ុន្តែមិនត្រូវឲ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ គឺអ្នកណាក្នុងពួកអ្នករាល់គ្នា ដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបម្រើដល់អ្នករាល់គ្នាវិញ" (ម៉ាថាយ ២០:២៥-២៦)។ អ្នកមានសិទ្ធិអំណាចក្លាយជាបន្ទុកដែលត្រូវទទួលខុសត្រូវ មិនមែនជាសិទ្ធិនៅក្នុងការទាមទារការគ្រប់គ្រងទៀតទេ។ វាជាកាតព្វកិច្ចដ៏ពិសិដ្ឋ



50 Crucial Questions.indd 74 7/4/26 2:18 in the afternoon

មួយក្នុងការលះបង់ ដើម្បីប្រយោជន៍អ្នកដទៃ។ ការកាត់កាល់សមាជិកក្រុមជំនុំចេញពីសមាជិកភាព គឺជាការកែប្រែចុងក្រោយដ៏ឈឺចាប់មួយ។ កុមារដែលឪពុកម្តាយប្រៀនប្រដៅ ដោយវាយក៏ត្រូវបានបង្កប់ដោយក្តីស្រឡាញ់ដែរ។ ចៅហ្វាយបង្ហាញក្តីមេត្តា។ ប៉ុន្តែ ទាំងអស់នោះគ្មានការលុបចោលនូវរចនាសម្ព័ន្ធអាជ្ញាធរទេ។ ផ្ទុយទៅវិញ វាប្រែក្លាយទៅជាទំនួលខុសត្រូវដោយក្តីស្រឡាញ់ស្វែងរកសិទ្ធិ និងអំណាចហួសពីសិទ្ធិវិញ។

ការផ្លាស់ប្តូរអំណាច គឺល្អពេញលេញបំផុតក្នុងជីវិតអាពាហ៍ពិពាហ៍។ នេះហើយជាមូលហេតុដែលយើងចូលចិត្តនិយាយអំពីសិទ្ធិអំណាចក្នុងលក្ខខណ្ឌនៃការណែនាំ និងការដឹកនាំ។ ព្រះគម្ពីរមិនអនុញ្ញាតឲ្យប្តីប្រើអំណាចដោយវាយដំប្រពន្ធ ដើម្បីនាំឲ្យប្រពន្ធឲ្យចុះចូលនោះឡើយ។ នៅពេលដែលកណ្ឌគម្ពីរ អេភេសូរ ៥:២៥-២៧ បង្ហាញថា ព្រះគ្រីស្ទនាំកូនក្រមុំរបស់ទ្រង់ទៅកាន់សេចក្តីបរិសុទ្ធ ខគម្ពីរនោះបានបង្ហាញថា ទ្រង់បានរងទុក្ខសម្រាប់នាង (ក្រុមជំនុំ) មិនមែនធ្វើឲ្យនាងរងទុក្ខសម្រាប់ទ្រង់ឡើយ។ សិទ្ធិអំណាចរបស់ស្វាមីគឺជាទំនួលខុសត្រូវដែលព្រះជាម្ចាស់បានប្រទានមក ក្នុងការដឹកនាំប្រពន្ធដោយមានការបន្ទាបខ្លួន មិនមែនជាសិទ្ធិពីធម្មជាតិ ដើម្បីអួតអាងនោះទេ។

យ៉ាងហោចណាស់ មានរឿងបីយ៉ាងដែលរារាំងប្តីពីការប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ (ភាពជាអ្នកដឹកនាំ!) ក្នុងការបង្ហាញថា គាត់ត្រឹមត្រូវនៅពេលដែលគាត់ប្រើអំពើហិង្សា៖ (១) ភាពស្និទ្ធស្នាល និងការរួបរួមតែមួយគត់ដែលបង្កប់ន័យនៅក្នុងឃ្លាថា “សាច់តែមួយ”—“ដ្បិតមិនដែលមានអ្នកណាស្អប់រូបសាច់ខ្លួនឯងឡើយ គឺគេតែងចិញ្ចឹម ហើយថ្នាក់ថ្នមវិញ ដូចជាព្រះអម្ចាស់ដល់ពួកជំនុំដែរ” (អេភេសូរ ៥:២៩–៣១); (២) កិត្តិយសពិសេសដែលបានបញ្ជាឲ្យធ្វើនៅក្នុងកណ្ឌគម្ពីរ ១ពេត្រុស ៣:៧ សម្រាប់ស្វាមីក្នុងការចាត់ទុកប្រពន្ធរបស់គាត់ជាអ្នកទទួលមរតករួមនៃព្រះគុណសម្រាប់ជីវិត។ និង (៣) គោលបំណង ដើម្បីបណ្តុះភាពចាស់ទុំរួមគ្នានៅក្នុងព្រះគ្រីស្ទ មិនមែនជាការពឹងផ្អែកបែបជាកូនក្មេងនោះទេ។



50 Crucial Questions.indd 75 7/4/26 2:18 in the afternoon

ដូច្នេះ ជាទូទៅសិទ្ធិអំណាចគឺជាការនៅក្រោមបង្គាប់ និងស្តាប់បង្គាប់អំណាច និងជាទំនួលខុសត្រូវ ដើម្បីដឹកនាំអ្នកដទៃ។ ប៉ុន្តែ ទម្រង់ និងតុល្យភាពនៃធាតុទាំងនេះនឹងមានការប្រែប្រួលនៅក្នុងទំនាក់ទំនងផ្សេងគ្នានៃជីវិត អាស្រ័យទៅតាមការបង្រៀននៃបទគម្ពីរ។

## សំណួរទី៣៧
## ប្រសិនបើក្រុមជំនុំទទួលយកទម្រង់នៃការគ្រប់គ្រងក្នុងក្រុមជំនុំ ដែលក្រុមជំនុំគឺជាអំណាចខ្ពស់បំផុតនៅក្រោមព្រះគ្រីស្ទ និងព្រះគម្ពីរ ហើយមិនមែនជាពួកអ្នកចាស់ទុំ តើស្ត្រីគួរតែមានការអនុញ្ញាតឲ្យបោះឆ្នោតដែរឬទេ?

បាទ ស្ត្រីមានសិទ្ធិអនុញ្ញាត។ កណ្ឌគម្ពីរ កិច្ចការ ១៥:២២ បានចែងថា៖ «នោះពួកសាវ័ក និងពួកចាស់ទុំ ព្រមទាំងពួកជំនុំគ្រប់គ្នាក៏យល់ព្រមថា គួរនឹងរើសយកអ្នកខ្លះក្នុងពួកគេ ជាពួកអ្នកមុខក្នុងពួកជំនុំ ដើម្បីនឹងចាត់ឲ្យទៅឯអាន់ទីយ៉ូក»។ នេះហាក់ដូចជាការបង្ហាញនូវភាពជាសមស្របតាមព្រះគម្ពីរសម្រាប់អ្នកជឿទាំងអស់គ្នា (១ពេត្រុស ២:៩; វិវរណៈ ១:៦; ៥:១០; ម៉ាថាយ ១៨:១៧)។ មូលហេតុដែលយើងគិតថា វាមិនស្របនឹងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២ គឺត្រង់ថា សិទ្ធិអំណាចនៃក្រុមជំនុំ មិនដូចគ្នាទៅនឹងសិទ្ធិអំណាចរបស់បុគ្គលនីមួយៗនៅក្នុងក្រុមជំនុំនោះទេ។ ពេលយើងលើកឡើងថា សមាជិកនៅក្នុងក្រុមជំនុំមានសិទ្ធិអំណាច យើងមិនមែនមានន័យថា បុរស និងស្ត្រីម្នាក់ៗមានសិទ្ធិអំណាចនោះទេ។ ដូច្នេះ យេនឌ័រ ជាផ្នែកមួយនៃភាពជាបុគ្គលម្នាក់ៗ គឺមិនសំខាន់ទេក្នុងទិដ្ឋភាពនៃការសម្រេចចិត្តរួមក្នុងក្រុមជំនុំ។

## សំណួរទី៣៨
**នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦:៧ សាវ័ក ប៉ុល បានសរសេរយ៉ាងដូច្នេះថា៖ «សូមជម្រាបសួរអ្នកអាន់ត្រូនីក និងអ្នកយូនាស៍ ជាញាតិខ្ញុំ គឺជាអ្នកជាប់គុកជាមួយនឹងខ្ញុំ ដែលមានកេរ្តិ៍ឈ្មោះក្នុងពួកសាវ័ក ក៏ជឿដល់ព្រះគ្រីស្ទមុនខ្ញុំដែរ»។ តើឈ្មោះ «យូនាស៍» មិនមែនជាមនុស្សស្រីទេឬអី? ហើយតើនាងមិនមែនជាសាវ័កម្នាក់ទេឬអី? ហើយតើមិនមែនមានន័យថា សាវ័ក ប៉ុល សុខចិត្តទទួលស្គាល់ថា ស្ត្រីម្នាក់អាចកាន់តំណែងដែលមានសិទ្ធិអំណាចខ្លាំងជាងបុរស ក្នុងក្រុមជំនុំដំបូងទេឬអី?**

យើងសូមឆ្លើយសំណួរទាំងបីនៅពេលតែមួយនេះ៖

(១) តើនាង យូនា (ស៍) គឺជាមនុស្សស្រីមែនទេ? យើងមិនអាចដឹងបានទេ។ មិនមានភស្តុតាង ដែលមិនអាចយកជាការបានទេ ហើយការបកប្រែខ្លះទៀតប្រើឈ្មោះ យូនា (ជាឈ្មោះមនុស្សស្រី) និងឈ្មោះ យូនាស៍ ផ្សេងទៀត (ថាជាឈ្មោះមនុស្សប្រុស)។ យើងបានស្វែងរកទាំងស្រុងនូវសំណេរជាភាសាក្រិកទាំងអស់ពីអ្នកនិពន្ធជនជាតិក្រិកឈ្មោះ ហូមើរ (Homer សតវត្សទីប្រាំបួនមុនគ.ស?) រហូតមកដល់សតវត្សទី៥នៃគ.ស។ ឥឡូវនេះមានកម្មវិធីឌីជីថលដែលអាចស្វែងរកបានតាមរយៈកម្មវិធី Thesaurus Linguae Graecae[២៤] ដែលរួមមានអ្នកនិពន្ធចំនួន ២.៨៨៩នាក់ និងស្នាដៃចំនួន ៨.២០៣។ យើងបានស្វែងរកគ្រប់ទម្រង់នៃឈ្មោះ អ៊ីអូនា (Iounia-) ដូច្នេះ យើងនឹងលើកយកករណីដែលអាចកើតមានទាំងអស់មក។ (យើងមិនបានស្វែងរកការបំបែកជាសព្វនាមបុរិសៈ បុរសទីមួយ អ៊ីអូនីវ (Iouniou) ដែលអាចបំបែកមែកធាងមកពីសព្វនាមបុរិសៈ អូនីអើស (Iounias) ទេពីព្រោះមិនមានវិធីដើម្បីប្រាប់ថា តើពាក្យ អ៊ីអូនីវ (Iouniou) អាចក្លាយមកពីឈ្មោះរបស់បុរសផ្សេងទៀត អ៊ីអូនីអើស (Iounios) (បញ្ចប់ដោយ -os ជាជាង -as) ដែលនឹងធ្វើឲ្យទម្រង់កម្មសិទ្ធិទាំងនេះគ្មានប្រយោជន៍ក្នុងការបង្កើត

២៤ . *Thesaurus Linguae Graecae* (Irvine: University of California at Irvine, ឆ្នាំ១៩៨៧), Pilot CD-ROM #C.



50 Crucial Questions.indd 77 7/4/26 2:18 in the afternoon

ឈ្មោះបុរស Iounias នៅកណ្ឌគម្ពីរ រ៉ូម ១៦:៧)។

ការស្វែងរកតាមកុំព្យូទ័ររបស់យើងបង្ហាញឲ្យមានករណីចំនួនបី លើសពីឈ្មោះមួយដែលនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦:៧៖

ក. លោក ផ្លូតាចឆ៍ (Plutarch ប្រហែលឆ្នាំ ៥០-១២០ នៃគ.ស) នៅក្នុង "ជីវិតរបស់លោក ម៉ាឃើស ប្រូធីស" (Life of Marcus Brutus) បានសរសេរអំពីភាពតានតឹងរវាងលោក ប្រូធីស និងលោក សេសៀស (Cassius)៖ "...ទោះបីជាពួកគេមានទំនាក់ទំនងគ្នាក្នុងគ្រួសារក៏ដោយ ក៏លោក សេសៀស បានរៀបការជាមួយលោកស្រី យូនា ជាប្អូនស្រីរបស់លោក ប្រូធីស ដែរ។ [Iounia gar adelphe Broutou sunoikei Kassios]"[២៥]។

ខ. លោក អេពីផានើស (Epiphanius ឆ្នាំ ៣១៥-៤០៣ នៃគ.ស) ដែលជាសម្តេចសង្ឃរបស់ទីក្រុង សាលាមីសនៃប្រទេសស៊ីប បានសរសេរ "បញ្ជីសរុបខ្លឹមសាររបស់ពួកសាវ័ក" (Index of Disciples) ដែលក្នុងនោះគាត់រួមបញ្ចូលប្រយោគនេះផងដែរថា៖ "អ៊ីអូនាស ដែលសាវ័ក ប៉ុល បានលើកឡើងនោះបានក្លាយជាសម្តេចសង្ឃក្រុងអាប៉ាមៀនៃប្រទេសស៊ីរី។[២៦] នៅក្នុងភាសាក្រិកឃ្លា "របស់អ្នកណា" គឺជាសព្វនាមដែលទាក់ទងនឹងបុរស (hou) ហើយបង្ហាញថា លោក អេពីផានើស គិតថា យូនាស (Iounias) គឺជាមនុស្សប្រុស។

គ. លោក ចន គ្រីសូស្ដូម (John Chrysostom ឆ្នាំ ៣៤៧-៤០៧ នៃគ.ស.) នៅក្នុងការអធិប្បាយអំពីកណ្ឌគម្ពីរ រ៉ូម ១៦:៧ បានមានប្រសាសន៍ដោយសំដៅទៅលើនាង យូនា (ស៍) ថា៖ "អូ! តើការលះបង់របស់ស្ត្រីនេះអស្ចារ្យប៉ុណ្ណា ដែលត្រូវរាប់ថានាងសមនឹងការហៅថាជា (សាវ័ក!)"។[២៧]

---

២៥ លោក Plutarch's *Lives of Illustrious Men*, បកប្រែដោយ៖ លោក John Dryden (New York: John Wurtele Lovell, n.d.), ៣:៣៩៥។

២៦ Index Discipulorum ១២៥។ ទំព័រ១៩-២០។

២៧ លោក John Chrysostom, *Homilies on the Epistle of St. Paul the Apostle to the Romans 31.7*, នៅក្នុង A Select Library of the Nicene and Post-Nicene Fathers of the Christian Church, កែសម្រួលដោយ៖ លោក Philip Schaff, ភាគទី១, លេខ១១ (Grand Rapids, MI: Eerdmans, ឆ្នាំ១៩៥៦), ទំព័រ៥៥៥។



50 Crucial Questions.indd 78 7/4/26 2:18 in the afternoon

អ្វីដែលយើងនឹងរៀនពីការប្រើប្រាស់ទាំងបីនេះ គឺថា យូនា (ស៍) ["Junia (s)"] បានប្រើជាឈ្មោះរបស់មនុស្សស្រីនៅអំឡុងពេលនៃព្រះគម្ពីរសញ្ញាថ្មីរបស់លោក ផ្លូតាចឆ៍។ អ្នកស្ថាបនិកក្រុមជំនុំដំបូងបានបែងចែកយ៉ាងច្បាស់ថាតើសាវ័ក ប៉ុល កំពុងប្រើឈ្មោះ យូនា (ស៍) តាមរបៀបនោះឬអត់ លោក អេពីផានើស បានសន្មតថា គឺជាមនុស្សប្រុស ចំណែកឯលោក គ្រីសូស្តូម សន្មតថា គឺជាមនុស្សស្រី។ ប្រហែលជាមានការសង្កត់ធ្ងន់នៅក្នុងអត្ថបទដ៏ចំណាស់បំផុតនៅក្នុងកណ្ឌគម្ពីរ រ៉ូម មានច្រើនជាងនេះដែលនិយាយពីសេចក្តីអធិប្បាយរបស់លោក អេពីផានើស ដោយសារគាត់ហាក់បីដូចជាដឹងព័ត៌មានជាក់លាក់បន្ថែមទៀតអំពី យូនា (ស៍) (នៅពេលដែលគាត់បានក្លាយជាសម្តេចសង្ឃរបស់ក្រុង អាប៉ាមៀ) ខណៈពេលដែលលោក គ្រីសូស្តូម មិនបានផ្តល់ព័ត៌មានច្រើនជាងអ្វីដែលគាត់អាចសន្និដ្ឋានពីកណ្ឌគម្ពីរ រ៉ូម ១៦:៧ (ទោះជាយ៉ាងណា លោក អេពីផានីស បានផ្តល់ព័ត៌មានមិនត្រឹមត្រូវអំពីនាងព្រីស៊ីល (Prisca)។[២៨]

ទោះបីជាយ៉ាងណាក៏ដោយ ប្រហែលជាសំខាន់ជាងនេះទៅទៀត គឺជាសម្រង់សម្តីជាភាសាឡាតាំងរបស់លោក អ័រីហ្គិន (Origen នៅឆ្នាំ ២៥២ នៃគ.ស) នៅក្នុងអត្ថបទអត្ថាធិប្បាយដ៏ចំណាស់បំផុតនៅក្នុងកណ្ឌគម្ពីររ៉ូម។ គាត់លើកឡើងថា សាវ័ក ប៉ុល សំដៅទៅលើ «អ្នកអាន់ត្រូនីក និងអ្នកយូនាស៍ និងអ្នកហេរ៉ូឌាន ដែលគាត់ហៅពួកគេទាំងអស់គ្នាថា សាច់ញាតិ និងពួកអ្នកជាប់ឃុំ» [Andronicus, et Junias, et Herodion, quos omnes et cognatos suos, et concaptivos appellat]»។[២៩] ឈ្មោះ យូនាស៍ នៅ

២៨ យើងមានការងឿងឆ្ងល់អំពីការពិតដែលថា នៅក្នុងបរិបទដែលជិតស្តីពីការដកស្រង់របស់ យូនាស ក្រុងអេភេសូរ ក៏កំណត់ថា ព្រីស៊ីលឡា (Prisca) ដែលត្រូវបានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦:៣ ជាបុរស ទោះជាយើងដឹងពីគម្ពីរសញ្ញាថ្មីថា នាងជាស្ត្រីក៏ដោយ។

២៩ លោក Origen, *Commentaria in Epistolam B. Pauli ad Romanos, in Origenis: Opera Omnia,* លេខ១៤នៃ Patrologia Graeca, បានកែសម្រួលដោយ។ លោកJ. P. Migne, col. ១២៨៩។ សំណេរនេះត្រូវបានរក្សាទុកដោយការបកប្រែជាភាសាឡាតាំងដោយ៖ លោក Rufinus (ប្រហែលឆ្នាំ៣៤៥-៤១០ ក្រោយ គ.ស)។



50 Crucial Questions.indd 79 7/4/26 2:18 in the afternoon

ទីនេះ គឺជាឯកវចនៈនៃភេទប្រុសក្នុងភាសាឡាតាំង—ប្រសិនបើការបកប្រែពីបុរាណនេះអាចទុកចិត្តបាន—នោះលោក អ៊ីហ្គិន (ដែលជាអ្នកប្រាជ្ញបុរាណដ៏ប៉ិនប្រសប់បំផុតរបស់ពិភពលោកគិតថា យូនាស៍ គឺជាបុរស។ គួបផ្សំនឹងការដកស្រង់សម្ដីមួយចំនួនរបស់លោក អេភីផានើស ការដកស្រង់នេះណែនាំអំពីមាត្រដ្ឋាននៃភស្ដុតាងបុរាណ ដើម្បីជាការគាំទ្រទស្សនៈនេះ។

ឈ្មោះរបស់មនុស្សប្រុសបានបញ្ចប់ដោយ -as គឺមិនជារឿងមិនធម្មតានោះទេ សូម្បីតែនៅក្នុងព្រះគម្ពីរសញ្ញាថ្មី៖ លោក អនទ្រេ (Andreas, ម៉ាថាយ ១០:២) ហោរា អេលីយ៉ា (Elias, ម៉ាថាយ ១១:១៤) អេសាយ (Esias, យ៉ូហាន ១:២៣), លោក សាការី (Zacharias, លូកា ១:៥)។ លោក អេ. ធី. រ៉ូប៊ឺតសុន (A. T. Robertson) បង្ហាញថា ឈ្មោះជាច្រើនដែលបញ្ចប់ដោយ -as គឺជាទម្រង់ខ្លីសម្រាប់ទម្រង់ច្បាស់លាស់នៃភេទប្រុស (បុំលិង្គ masculine forms)។[៣០] ឧទាហរណ៍ដ៏ច្បាស់លាស់បំផុតនៅក្នុងគម្ពីរសញ្ញាថ្មីគឺ ស៊ីឡាស (កិច្ចការ ១៥:២២) មកពី ស៊ីលវ៉ាន (១ថែស្សាឡូនីច ១:១; ១ពេត្រុស ៥:១២)។

ដូច្នេះ គ្មានការអះអាងឲ្យច្បាស់លាស់អំពីចំណុចសំខាន់ចេញពីទម្រង់នៃឈ្មោះនោះឡើយ។ វាអាចជាមនុស្សស្រី ឬវាអាចជាមនុស្សប្រុស។ ប្រាកដណាស់! គ្មាននរណាម្នាក់អាចអះអាងថា យូនា គឺជាឈ្មោះទូទៅរបស់មនុស្សស្រីនៅក្នុងពិភពលោក ដែលនិយាយភាសាក្រិក ដោយសារតែយើងអាចសម្គាល់បានត្រឹមតែឧទាហរណ៍ដែលបានបង្ហាញទាំងបីនេះ ដែលមាននៅក្នុងអក្សរសាស្ត្រក្រិកបុរាណ។[៣១] លើសជាងនេះទៅទៀត ចំណុចដែលអ្នក អាន់ត្រូនីក និងអ្នក យូនា (ស៍) ដូចជានាង ព្រីស៊ីល និងលោក អ័គី

៣០ លោក A. T. Robertson, *A Grammar of the Greek New Testament in the Light of Historical Research* (New York: Hodder and Stoughton, ឆ្នាំ១៩១៤), ទំព័រ១៧១-៧៣។

៣១ បើទោះបីជា យូនាស ជាឈ្មោះធម្មតារបស់ស្ត្រីជាភាសាឡាតាំង ហើយនោះត្រូវបានបញ្ចុះបញ្ចូល ដោយការបកប្រែមួយចំនួនចំពោះការបកប្រែឈ្មោះថា យូនាស៍។



50 Crucial Questions.indd 80 7/4/26 2:18 in the afternoon

ឡា (រ៉ូម ១៦:៣) ត្រូវបានលើកឡើងមកជាគូមិនតម្រូវថា ពួកគេជាប្តីប្រពន្ធ ពីព្រោះនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦:១២ ស្ត្រីពីរនាក់ត្រូវបានជម្រាបសួររួមគ្នាជាគូ៖ «សូមជំរាបសួរនាង ទ្រីភេន និងនាង ទ្រីផូស ដែលធ្វើការក្នុងព្រះអម្ចាស់ ជាអ្នកស្ងួនភ្ងា ដែលធ្វើការនឿយហត់ជាច្រើនក្នុងព្រះអម្ចាស់»។ លោក អាន់ត្រូនីក និងនាង យូនា (ស៍) អាចត្រូវបានសំដៅថា ជាឈ្មោះមនុស្សប្រុសពីរនាក់ ដោយសារតែនាង ទ្រីភេន និងនាង ទ្រីផូស ត្រូវសំដៅថាជាមនុស្សស្រីពីរនាក់។

២) តើនាង យូនា (ស៍) ជាសាវ័កម្នាក់មែនទេ? នេះហាក់បីដូចជាមិនទំនងទាល់តែសោះ។ តាមក្បួនវេយ្យាករណ៍ ឃ្លាដែលបានបកប្រែថា៖ «អ្នកទាំងពីរជាសាវ័ក*ដែលគេគោរពរាប់អានខ្លាំងណាស់» នៅក្នុងព្រះគម្ពីរគ្រីស្ទបរិស័ទខ្មែរអាចមានន័យថា ពួកសាវ័កបានគោរពរាប់អានលោក អាន់ត្រូនីក និងនាង យូនា (ស៍) យ៉ាងខ្លាំង (ដូច្នេះ ការបកប្រែរបស់ព្រះគម្ពីរឆ្នាំ១៩៥៤ «ដែលមានកេរ្តិ៍ឈ្មោះក្នុងពួកសាវ័ក» នោះទំនងជាងគេបំផុត បើយោងតាមការសិក្សាវេយ្យាករណ៍)។[៣២] ដូច្នេះ ពួកគេផ្ទាល់មិនមែនជាសាវ័កឡើយ។ ម៉្យាងវិញទៀត ដោយសារលោក អាន់ត្រូនីក និងនាង យូនា (ស៍) ក្លាយជាគ្រីស្ទបរិស័ទ មុនដែលសាវ័ក ប៉ុល នោះទំនងជាមានន័យថា ពួកគេធ្វើការបម្រើអស់រយៈពេលយូរ (មុននឹងបានជួបសាវ័ក ប៉ុល) គឺជាអ្វីដែលសាវ័ក ប៉ុល ពិតជាចង់មានន័យនៅក្នុងចិត្តនៅពេលដែលគាត់លើកឡើងថា៖ «ដែលមានកេរ្តិ៍ឈ្មោះក្នុងពួកសាវ័ក»។ ពួកគេប្រហែលជាមានកេរ្តិ៍ឈ្មោះយ៉ាងល្អ មុនពេលដែលសាវ័ក ប៉ុល បានប្រែចិត្តទទួលជឿ។

---

៣២ សំណង់ប្រយោគនៅក្នុងភាសាក្រិកប្រើគុណនាម episēmos («មានកេរ្តិ៍ឈ្មោះ») ជាមួយនឹងកន្សោមសម្រាប់ «ពួកសាវ័ក» នៅក្នុងករណីកម្មបទមិនផ្ទាល់។ តាមរយៈការស្រាវជ្រាវយ៉ាងទូលំទូលាយនៅក្នុងការសរសេរជាភាសាក្រិកដ៏អស្ចារ្យលោក ម៉ៃខល ប្យូរើ (Michael Burer) បានបង្ហាញថា ការសង់ប្រយោគនេះស្ទើរតែតែងតែមានន័យថា «មានកេរ្តិ៍ឈ្មោះ» (នៅពេលដែលមនុស្សត្រូវបានគេដាក់ឈ្មោះនៅក្នុងករណីកម្មបទមិនផ្ទាល់) ចំណែកឯការនិយាយថានរណាម្នាក់ដែល «មានកេរ្តិ៍ឈ្មោះក្នុងចំណោម» ក្រុមមួយ (ជាកម្មសិទ្ធិនៅក្នុងក្រុម) អ្នកនិពន្ធជនជាតិក្រិកបានប្រើករណីជាប់ទំនាក់ទំនងជាប្រចាំ។ សូមមើលលោក ម៉ៃខល ប្យូរើ, "Ἐπίσημοι ἐν τοῖς ἀποστόλοις នៅក្នុងកណ្ឌគម្ពីររ៉ូម ១៦:៧ មានន័យថា «ដែលមានកេរ្តិ៍ឈ្មោះក្នុងពួកសាវ័ក៖ ការការពារបន្ថែម និងភស្តុតាងថ្មី» ទិនានុប្បវត្តិនៃសមាគមទេវសាស្ត្រផ្សាយដំណឹងល្អ ('Well Known to the Apostles': Further Defense and New Evidence," JETS ៥៨), លេខ៤ (ឆ្នាំ២០១៥), ទំព័រ៧៣១-៥៥។



50 Crucial Questions.indd 81 7/4/26 2:18 in the afternoon

៣) តើនាង យូនា (ស៍) មានមុខតំណែងដែលមានអំណាចខ្លាំងនៅក្នុងក្រុមជំនុំដំបូងដែរឬទេ? ប្រហែលជាគ្មានទេ។ ពាក្យ «សាវ័ក» ត្រូវបានប្រើសម្រាប់អ្នកបម្រើព្រះគ្រីស្ទនៅកម្រិតខុសគ្នានៃសិទ្ធិអំណាចនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ កណ្ឌគម្ពីរ វិវរណៈ ២១:១៤ សំដៅទៅលើ «ពួកសាវ័ករបស់ពួកកូនចៀមទាំង១២នាក់» (ធៀបនឹងកណ្ឌគម្ពីរ ម៉ាថាយ ១៩:២៨; កិច្ចការ ១:១៥-២៦)។ សាវ័កទាំងដប់ពីរបានដើរតួនាទីយ៉ាងពិសេសនៅក្នុងការធ្វើជាទីបន្ទាល់ពីការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ សាវ័ក ប៉ុល បានរាប់ខ្លួនលោកថា នៅក្នុងចំណោមក្រុមដ៏មានអភ័យឯកសិទ្ធិ ដោយការទទួចចង់ឃើញ និងចង់ទទួលបានការត្រាស់ហៅពីព្រះគ្រីស្ទ ដែលមានព្រះជន្មរស់ឡើងវិញ (១កូរិនថូស ៩:១-២; កាឡាទី ១:១, ១២)។ ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការយល់ពីខាងក្នុងជម្រៅចិត្តដ៏ពិសេសនេះ គឺដៃគូបម្រើព័ន្ធកិច្ចរបស់សាវ័ក ប៉ុល គឺលោក បាណាបាស (កិច្ចការ ១៤:១៤) និងលោក ស៊ីលវ៉ាន និងលោក ធីម៉ូថេ (១ថែស្សាឡូនីច ២:៦) ព្រមទាំង លោក យ៉ាកុប ជាប្អូនរបស់ព្រះយេស៊ូវ (កាឡាទី ១:១៩) ហើយប្រហែលជាមានអ្នកខ្លះទៀត (១កូរិនថូស ១៥:៧)។

ចុងក្រោយ ពាក្យថា «សាវ័ក» (ជាភាសាក្រិក «អាផូស្តូលូស» apostolos) ត្រូវបានប្រើយ៉ាងទូលំទូលាយនៅក្នុងន័យថា «អ្នកនាំសារ» ឧទាហរណ៍ លោក អេប៉ាប្រូឌីត នៅក្នុងកណ្ឌគម្ពីរ ភីលីព ២:២៥ ហើយ «អ្នកនាំសារនៃក្រុមជំនុំ» មួយចំនួន នៅក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៨:២៣។ ដូច្នេះ ទោះបីជាលោក អាន់ត្រូនីក និងយូនា (ស៍) គឺ «ពួកសាវ័ក» ក្នុងន័យខ្លះរបស់ពាក្យ «ពួកគេ» ប្រហែលជាស្ថិតនៅក្នុងក្រុមទីបីនេះ ដែលបម្រើនៅក្នុងប្រភេទនៃព័ន្ធកិច្ចដំណឹងល្អបែបធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត។ ប្រសិនបើ យូនា (ស៍) គឺជាមនុស្សស្រី នេះហាក់បីដូចជាត្រូវដាក់គាត់ចូលទៅនឹងក្រុមជាមួយនឹងនាង ព្រីស៊ីល ដែលនាង ហើយប្ដីនាងយ៉ាងហោចណាស់បានរួមដំណើរតិចតួចដែរជាមួយនឹងសាវ័ក ប៉ុល (កិច្ចការ ១៨:១៨)។ ព័ន្ធកិច្ចនេះនឹងមាន



50 Crucial Questions.indd 82 7/4/26 2:18 in the afternoon

សារៈសំខាន់ ប៉ុន្តែមិនចាំបាច់ក្នុងសណ្ឋានដែលមានអំណាចគ្រប់គ្រងនៃក្រុមជំនុំដែលមានលក្ខណៈដូចជា សាវ័ក ប៉ុល នោះទេ (២កូរិនថូស ១០:៨; ១៣:១០)។

## សំណួរទី៣៩

## សាវ័ក ប៉ុល ហាក់ដូចជាផ្អែកលើទំនួលខុសត្រូវចម្បងរបស់បុរសក្នុងការដឹកនាំ និងការបង្រៀនអំពីការពិតដែលថា លោក អ័ដាម ត្រូវបានបង្កើតមកមុនគេ គឺមុននាង អេវ៉ា ទៅទៀត (១ធីម៉ូថេ ២:១៣)។ តើការនេះជាអំណះអំណាងមានសុពលភាពយ៉ាងដូចម្តេច ក្នុងកាលដែលសត្វត្រូវបានបង្កើតឡើងមុនមនុស្ស ប៉ុន្តែមិនមានទំនួលខុសត្រូវចម្បងនៅក្នុងការដឹកនាំគាត់?

បរិបទមូលដ្ឋានសម្រាប់អំណះអំណាងនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិ គឺជាការសន្មតពេញមួយកណ្ឌដែលថា «កូនច្បង» នៅក្នុងគ្រួសារមនុស្សមានសិទ្ធិពិសេស និងមានទំនួលខុសត្រូវក្នុងភាពជាអ្នកដឹកនាំនៅក្នុងគ្រួសារ។ នៅពេលដែលជនជាតិហេព្រើរបានផ្តល់ទំនួលខុសត្រូវពិសេសមួយដល់ «កូនច្បង» ពួកគេមិនយល់ទេថា ការទទួលខុសត្រូវនេះនឹងត្រូវបានទុកជាមោឃៈ ប្រសិនបើឪពុកមានគោក្របីមុនពេលគាត់មានកូនប្រុសៗ។ ម្យ៉ាងវិញទៀត នៅពេលលោក ម៉ូសេ សរសេររឿងនេះចុះ គាត់បានដឹងហើយថា អ្នកអានដំបូងរបស់គាត់នឹងមិនយកឲ្យសត្វ និងមនុស្សមកបូកឡុកគ្នា ជាបេក្ខភាពស្មើគ្នាសម្រាប់ទំនួលខុសត្រូវនៃ «កូនច្បង» នោះទេ។ ហើយយើងក៏មិនគួរធ្វើដូច្នោះដែរ។

នៅពេលដែលការព្រួយបារម្ភស្តីពីអាទិភាពនៃសត្វលោកត្រូវដាក់ដោយឡែកហើយ សំណួរក្រុមស្រ្តីនិយមដែលជឿលើដំណឹងល្អត្រូវតែមានជាលក្ខខណ្ឌជាមួយនឹងសំណួរថា ហេតុអ្វីបានជាព្រះជាម្ចាស់ជ្រើសរើសបង្កើតបុរសមុនស្ត្រី តាមលំដាប់លំដោយនេះទៅវិញ។ វានឹងមិនគ្រប់គ្រាន់ទេក្នុងការនិយាយថា «លំដាប់លំដោយនេះមិនចាំបាច់មានន័យថា ជាមួយនឹង



50 Crucial Questions.indd 83 7/4/26 2:18 in the afternoon

អាទិភាពនៃភាពជាអ្នកដឹកនាំនោះទេ»។ សំណួរដែលយើងនៅអាចលើកមក សួរគឺថា «តើលំដាប់នេះមានន័យយ៉ាងដូចម្តេច?» ហេតុអ្វីបានជាព្រះជាម្ចាស់មិនបានបង្កើតមនុស្សចេញពីធូលីដីក្នុងពេលតែមួយ? នៅក្នុងបរិបទនៃទ្រនិចចង្អុលអត្ថបទ (textual pointers) ទាំងអស់ដែលបានប្រមូលផ្តុំដោយលោក រ៉េយ៍ អតឡុនដ៍ ជេអ៊ែ (Ray Ortlund Jr.) នៅក្នុងអត្ថបទមួយរបស់គាត់ស្តីពីកណ្ឌលោកុប្បត្តិជំពូក១-៣ នៅក្នុងសៀវភៅ «ការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ» យើងគិតថា ការជាប់ពាក់ព័ន្ធដ៏សាមញ្ញបំផុតនៃការសម្រេចចិត្តរបស់ព្រះអង្គក្នុងការបង្កើតលោក អ័ដាម មុននាង អេវ៉ា គឺដោយសារ លោក អ័ដាម ទទួលបានការត្រាស់ហៅឲ្យទទួលខុសត្រូវក្នុងការដឹកនាំ។ ការពិតនោះក៏បានបញ្ជាក់ដោយព្រះគម្ពីរសញ្ញាថ្មី នៅពេលដែលសាវ័ក ប៉ុល លើកឡើងថា «ព្រះបានបង្កើតលោក អ័ដាម ជាមុនរួចបង្កើតនាង អេវ៉ា តាមក្រោយ» (១ធីម៉ូថេ ២:១៣) គឺគាត់បានធ្វើបែបនោះដើម្បីទាញសេចក្តីសន្និដ្ឋានអំពីភាពជាអ្នកដឹកនាំរបស់បុរសនៅក្នុងក្រុមជំនុំ។

## សំណួរទី៤០
## តើវាពិតមែនឬទេដែលថា មូលហេតុដែលសាវ័ក ប៉ុល មិនអនុញ្ញាតឲ្យស្ត្រីៗបង្រៀន គឺដោយសារតែស្ត្រីៗមិនបានទទួលការអប់រំខ្ពស់នៅក្នុងសតវត្សរ៍ទី១? ប៉ុន្តែ ហេតុផលនោះមិនត្រូវនឹងបរិបទសព្វថ្ងៃនេះទេ។ តាមពិតទៅ ដោយសារតែស្ត្រីមានការអប់រំខ្ពស់ដូចបុរសសព្វថ្ងៃនេះដែរ តើយើងមិនគួរអនុញ្ញាតឲ្យទាំងស្ត្រី និងបុរសធ្វើជាគ្រូគង្វាលបានទេឬ?

អំណះអំណាងនេះមិនត្រូវគ្នានឹងទិន្នន័យនៅក្នុងអត្ថបទព្រះគម្ពីរក្រោមហេតុផលយ៉ាងហោចណាស់បីយ៉ាង៖ ទីមួយ សាវ័ក ប៉ុល មិនបានលើកឡើងអំពីការខ្វះការអប់រំជាហេតុផលសម្រាប់ការនិយាយថា ស្ត្រីមិនអាច «បង្រៀន ឬឲ្យមានសិទ្ធិអំណាចលើបុរស» ទេ (១ធីម៉ូថេ ២:១២) ប៉ុន្តែគាត់ចង្អុលបង្ហាញត្រឡប់ទៅការបង្កើតវិញ (១ធីម៉ូថេ ២:១៣-១៤)។ ការបង្កើតការរៀកញ្ញែកលើ

ហេតុផលដែលសាវ័ក ប៉ុល មិនបានផ្តល់ឲ្យជាជាងហេតុផលដែលគាត់បានផ្តល់ឲ្យជារឿងដែលគ្រោះថ្នាក់ណាស់។

ទីពីរ ការបណ្តុះបណ្តាលជាផ្លូវការនៅក្នុងព្រះគម្ពីរមិនតម្រូវសម្រាប់ការដឹកនាំក្រុមជំនុំនៅក្នុង កណ្ឌគម្ពីរសញ្ញាថ្មីទេ សូម្បីតែសាវ័កមួយចំនួនក៏មិនបានទទួលការបណ្តុះបណ្តាលព្រះគម្ពីរជាផ្លូវការដែរ (កិច្ចការ ៤:១៣) ខណៈពេលដែលជំនាញនៃអក្ខរកម្មជាមូលដ្ឋាន ហើយដូច្នេះសមត្ថភាពក្នុងការអាននិងសិក្សាព្រះគម្ពីរអាចធ្វើទៅបានសម្រាប់ទាំងបុរស និងស្ត្រីដូចគ្នា (កំណត់ចំណាំ កិច្ចការ ១៨:២៦; រ៉ូម ១៦:១; ១ធីម៉ូថេ ២:១១; ទីតុស ២:៣-៤)។ សិលាចារឹកផាភីរើស បានបង្ហាញថា៖ «ចំណេះដឹងអក្សរសាស្ត្រយ៉ាងទូលំទូលាយ» ក្នុងចំណោមស្ត្រីដែលនិយាយភាសាក្រិកនៅក្នុងប្រទេសអេហ្ស៊ីប ហើយនិងនៅក្នុងសង្គមចក្រភពរ៉ូម «ស្ត្រីជាច្រើនបានទទួលការអប់រំ និងមានប្រាជ្ញា»។[៣៣]

ទីបី ប្រសិនបើមានស្ត្រីណាម្នាក់នៅក្នុងក្រុមជំនុំគម្ពីរសញ្ញាថ្មីបានទទួលការអប់រំខ្ពស់ នោះជានាង ព្រីស៊ីល ប៉ុន្តែសាវ័ក ប៉ុល កំពុងសរសេរនៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២ ទៅកាន់ក្រុងអេភេសូរ (១ធីម៉ូថេ ១:៣) ដែលជាក្រុមជំនុំរបស់នាង ព្រីស៊ីល និងលោក អ័គីឡា។ នៅឆ្នាំ៥០ នៃគ.ស. សាវ័ក ប៉ុល បានស្នាក់នៅផ្ទះនាង ព្រីស៊ីល និងលោក អ័គីឡា នៅក្រុងកូរិនថូសអស់រយៈពេលដប់ប្រាំបីខែ (កិច្ចការ ១៨:២, ១១) បន្ទាប់មក ពួកគេបានទៅជាមួយសាវ័ក ប៉ុល ទៅក្រុងអេភេសូរនៅឆ្នាំ៥១ នៃគ.ស (កិច្ចការ ១៨:១៨-១៩, ២១)។ សូម្បីតែនៅពេលនោះ នាង ព្រីស៊ីល បានស្គាល់ព្រះគម្ពីរគ្រប់គ្រាន់ ដើម្បីជួយណែនាំដល់លោក អ័ប៉ុឡូស (កិច្ចការ ១៨:២៦) រួចហើយ។ បន្ទាប់មក នាងប្រហែលជាបានរៀនពីសាវ័ក ប៉ុល ផ្ទាល់រយៈពេលបីឆ្នាំទៀត ពេលដែលគាត់ស្នាក់នៅក្រុងអេភេសូរបង្រៀន «ពីគ្រប់ទាំងគំនិតរបស់ព្រះ»

---

៣៣ លោក N. G. L. Hammond និងលោក H. H. Scullard, eds., *Oxford Classical Dictionary*, បានកែសម្រួលជាលើកទី២ (Oxford: Clarendon, ឆ្នាំ១៩៧០), ទំព័រ១១៣៩។



50 Crucial Questions.indd 85 7/4/26 2:18 in the afternoon

(កិច្ចការ ២០:២៧; ប្រៀបធៀបនឹង ៣១; ១កូរិនថូស ១៦:១៩) ហើយគ្មានអ្វីគួរឲ្យសង្ស័យទេ ព្រោះមានស្ត្រីជាច្រើននៅក្រុងអេភេសូរបានធ្វើតាមគំរូរបស់នាង ហើយក៏បានរៀនពីសាវ័ក ប៉ុល ផងដែរ។ លោក អ័គីឡា និងនាង ព្រីស៊ីល បានចេញទៅទីក្រុងរ៉ូមនៅពេលក្រោយមក (រ៉ូម ១៦:៣) ប្រហែលឆ្នាំ៥៨ នៃគ.ស ប៉ុន្តែជាក់ស្តែងបានវិលត្រឡប់មកវិញ ដ្បិតពួកគេនៅក្រុងអេភេសូរម្តងទៀតមុនសាវ័ក ប៉ុល បានស្លាប់ (២ធីម៉ូថេ ៤:១៩) ប្រហែលឆ្នាំ ៦៧ នៃគ.ស។ ដូច្នេះ ទំនងជាពួកគេបានត្រឡប់មកក្រុងអេភេសូរវិញនៅឆ្នាំ៦៥ នៃគ.ស នៅពេលដែលសាវ័ក ប៉ុល បានសរសេរកណ្ឌគម្ពីរ ១ធីម៉ូថេ (ការបៀតបៀនគ្រីស្ទបរិស័ទបានចាប់ផ្តើមនៅទីក្រុងរ៉ូមនៅក្នុងឆ្នាំ៦៤ នៃគ.ស.)។ ប៉ុន្តែ សូម្បីតែនាង ព្រីស៊ីល ដែលមានការអប់រំខ្ពស់ និងស្ត្រីដែលមានការអប់រំខ្ពស់ផ្សេងទៀតនៅក្នុងក្រុងអេភេសូរ ក៏មិនត្រូវបានអនុញ្ញាតឲ្យបង្រៀនបុរសនៅទីសាធារណៈក្នុងក្រុមជំនុំនោះដែរ៖ សំបុត្រផ្ញើមកកាន់ក្រុងអេភេសូរ សាវ័ក ប៉ុល បានលើកឡើងថា “ខ្ញុំមិនបើកឲ្យស្ត្រីណាបង្រៀន ឬឲ្យមានអំណាចលើបុរសទេ” (១ធីម៉ូថេ ២:១២)។ មូលហេតុ គឺមិនមែនជាការខ្វះការអប់រំនោះទេ ប៉ុន្តែជាលំដាប់លំដោយនៃការបង្កើតរបស់ព្រះជាម្ចាស់។

## សំណួរទី៤១

## ហេតុអ្វីបានជាលោកគ្រូលើកឡើងពីការស្រឡាញ់ភេទដូចគ្នា នៅពេលពិភាក្សាអំពីភាពខុសគ្នានៃតួនាទីបុរស ហើយនិងស្ត្រីនៅក្នុងផ្ទះ និងក្រុមជំនុំទៅវិញ? (ដូចសំណួរទី១) ក្រុមខាងនិកាយដំណឹងល្អស្ត្រីនិយមភាគច្រើនក៏ប្រឆាំងនឹងការស្រឡាញ់ភេទដូចគ្នាដែរ។

យើងលើកឡើងពីការស្រឡាញ់ភេទដូចគ្នានេះ ដោយសារតែយើងជឿថា តាមរយៈការកាត់បន្ថយភាពខុសគ្នានៃតួនាទីភេទ ពួកអ្នកស្ត្រីនិយមរួមចំណែកធ្វើឲ្យមានការភាន់ច្រឡំនៃអត្តសញ្ញាណភេទ ជាពិសេសនៅជំនាន់ទីពីរ និងទីបីដែលបង្កឲ្យការស្រឡាញ់ភេទដូចគ្នាមានកាន់តែច្រើននៅក្នុងសង្គម។ ក្រុមខាងនិកាយដំណឹងល្អមួយចំនួនដែលធ្លាប់មិនយល់ស្របចំពោះការស្រឡាញ់



50 Crucial Questions.indd 86 7/4/26 2:18 in the afternoon

ភេទដូចគ្នា ត្រូវបានគាំពារដោយអំណះអំណាងបែបពួកអ្នកស្ត្រីនិយមរបស់ពួកគេចំពោះការយល់ស្របនៃសម្ព័ន្ធភាពនៃការស្រឡាញ់ភេទដូចគ្នាដ៏ស្មោះត្រង់។ ជាឧទាហរណ៍៖ លោក ជើរែល ហ្សិបផាដ (Gerald Sheppard) សាស្ត្រាចារ្យផ្នែកព្រះគម្ពីរសញ្ញាចាស់នៃមហាវិទ្យាល័យអេម៉ាញូអែលនៅសាកលវិទ្យាល័យតូរ៉ូនតូ (Old Testament Literature at Emmanuel College in the University of Toronto) បានបណ្ដុះបណ្ដាលក្នុងប្រពៃណីខាងនិកាយដំណឹងល្អបែបអភិរក្សនិយម ហើយបានចូលរួមសិក្ខាសាលាព្រះគម្ពីរនៃនិកាយដំណឹងល្អ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ លោកបានប្រកែកចំពោះការតែងតាំងស្ត្រីឲ្យធ្វើជាគ្រូគង្វាល។ គាត់ក៏បានបន្តនិយាយទៀតថា៖ «ចំពោះបញ្ហាដែលកាន់តែចម្រូងចម្រាស វត្តមានរបស់គ្រីស្ទបរិស័ទប្រុសស្រឡាញ់ប្រុស និងស្រីស្រឡាញ់ស្រី ហើយនិងអ្នកបម្រើព្រះនៅក្នុងក្រុមជំនុំរបស់យើង សម្រាប់ខ្ញុំ គឺជាបញ្ហាស្រដៀងគ្នា....ខ្ញុំជឿថា ដំណឹងល្អ—ដូចដែលក្រុមនិកាយដំណឹងល្អ (Evangelicals Concerned) ទទួលស្គាល់—គួរតែនាំយើងយ៉ាងហោចណាស់ទៅរកការបញ្ជាក់អំពីភាពជាដៃគូរបស់បុរស និងស្រីស្រឡាញ់ភេទដូចគ្នា ដែលគ្រប់គ្រងដោយក្រមសីលធម៌នៃព្រះគម្ពីរ ស្រដៀងនឹងអ្វីដែលទំនាក់ទំនងផ្លូវភេទរបស់អ្នកស្រឡាញ់ភេទផ្ទុយគ្នា»។[៣៤]

ឧទាហរណ៍មួយផ្សេងទៀត គឺលោកស្រី ខារិន ជ.ធ័ជេសសិន (Karen J. Torjesen) ដែលបានប្រកែកថា ការដកឋានានុក្រមចេញពីទំនាក់ទំនងផ្លូវភេទប្រហែលជាមានន័យថា ភាពសំខាន់បំផុតរបស់អាពាហ៍ពិពាហ៍ភេទផ្ទុយគ្នានឹងមានដូចតទៅ៖

> វាហាក់ដូចជាថាការបង្រៀនរបស់សាវ័ក ប៉ុល ស្ដីពីបញ្ហាភេទ គឺទាក់ទងនឹងឋានានុក្រមបែបទេវវិទ្យា។ បើអញ្ចឹងមែន នោះបញ្ហាទេវវិទ្យាស្ដីពីស្រី

៣៤ លោក Gerald Sheppard, "A Response to Ray Anderson," TSF Bulletin៩, លេខ៤ (ខែមិនា–ឧសភា ឆ្នាំ១៩៨៦), ទំព័រ២១។



50 Crucial Questions.indd 87 7/4/26 2:18 in the afternoon

ស្រឡាញ់ស្រី និងប្រុសស្រឡាញ់ប្រុស គឺជាប់ទាក់ទងគ្នាមិនអាចកាត់ផ្តាច់បានឡើយ។ យើងត្រូវដោះស្រាយលទ្ធភាពដែលថា ការរើកញែករបស់យើងលើការប្រើប្រាស់ភេទរបស់មនុស្សជាតិឲ្យបានសមរម្យ អាចជាការបញ្ហាដែលកើតចេញពីតម្រូវការក្នុងការធ្វើឲ្យរចនាសម្ព័ន្ធសង្គមបែបប្រពៃណីដែលកំណត់ឲ្យបុរស និងស្ត្រីមានមុខងារជាក់លាក់ និងមិនស្មើភាពគ្នា។ តើវាអាចទៅរួចទេដែលថា ការបន្តបញ្ជាក់ពីភាពសំខាន់នៃអាពាហ៍ពិពាហ៍ភេទផ្ទុយគ្នា អាចជាការបញ្ជាក់ពីភាពចាំបាច់សម្រាប់ភេទទាំងពីរ ដើម្បីរក្សាទំនាក់ទំនងតាមលំដាប់លំដោយនោះ? តើការគម្រាមកំហែងចំពោះ «ភាពបរិសុទ្ធនៃអាពាហ៍ពិពាហ៍» ពិតជាគម្រាមកំហែងដល់ឋានានុក្រមមែនឬទេ? តើនោះជាអ្វីដែលធ្វើឲ្យទំនាក់ទំនងភេទដូចគ្នារងការគម្រាមកំហែងខ្លាំងពេកដែរឬទេ?[៣៥]

នៅឆ្នាំ១៩៨៦ កិច្ចប្រជុំខាងស្ត្រីនិយមនៃនិកាយដំណឹង [ក្រុមស្ត្រីដែលជឿថាព្រះគម្ពីរគាំទ្របុរស និងស្ត្រីមានតួនាទីស្មើគ្នា (The Evangelical Women's Caucus)] បានបង្កឲ្យមានការបាក់បែកអំពីរឿង តើគួរតែមាន «ការទទួលស្គាល់វត្តមានរបស់ស្រីដែលស្រឡាញ់ភេទដូចគ្នានៅក្នុង អ៊ី.ដាប់បលយូ.ស៊ី.អាយ EWCI» ឬយ៉ាងណា។[៣៦] យើងសប្បាយចិត្តនៅពេលដែលក្រុមស្ត្រីដែលជឿថា ព្រះគម្ពីរគាំទ្របុរស និងស្ត្រីមានតួនាទីស្មើគ្នាជាច្រើនមិនបានគាំទ្រចំពោះការស្រឡាញ់ភេទដូចគ្នានេះ។ ប៉ុន្តែ អ្វីដែលមានសារៈសំខាន់នោះគឺថា របៀបអ្នកជឿបែបស្ត្រីនិយមនៃនិកាយដំណឹងល្អមួយចំនួនបានចាត់ទុកការគាំទ្រនោះថាជា «ជំហាននៃភាពពេញវ័យនៅក្នុងស្ថាប័ន» (ឧទាហរណ៍ លោកស្រី ណានស៊ី ហាតឌែសស៊ី (Nancy Hardesty) និង លោកស្រី វីជីនៀ ម៉ូលឡិនឃត (Virginia Mollenkott)។ ម្យ៉ាងទៀត ពួកគេចាត់ទុកការដើរឆ្ងាយពីភាពខុសគ្នានៃតួនាទីដែលមានមូលដ្ឋាន

៣៥ លោកស្រី Karen J. Torjesen, "Sexuality, Hierarchy and Evangelicalism," TSF Bulletin ១០, លេខ៤ (ខែមីនា-មេសា ឆ្នាំ១៩៨៧), ទំព័រ២៦-២៧។

៣៦ "Gay Rights Resolution Divides Membership of Evangelical Woman's Caucus," Christianity Today (ថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៨៦), ទំព័រ៤០-៤៣។



50 Crucial Questions.indd 88 7/4/26 2:18 in the afternoon

នៅក្នុងលំដាប់ដែលបានបង្កើតដោយធម្មជាតិថា ជាការនាំដោយជៀសមិនរួចឈានដល់ការដួលរលំនៃការស្រឡាញ់ភេទផ្ទុយគ្នាដែលត្រឹមត្រូវធម្មតា។ វាហាក់ដូចជាថាស្ត្រីនិយមដំណឹងល្អ ដែលមិនគាំទ្រការដែលបុរស និងស្ត្រីមានតួនាទីស្មើគ្នាដែលមិនទទួលយកការស្រឡាញ់ភេទដូចគ្នា នោះវានឹងកាន់តែពិបាកក្នុងការគេចចេញពីហេតុផលនេះ។

លោក ប៉ូល ជីវេត (Paul Jewett) ក៏ដូចគ្នាដែរ ក៏ហាក់ដូចជាបង្ហាញពីការផ្លាស់ប្តូរពីភាពជាស្ត្រីនិយមស្របតាមព្រះគម្ពីរទៅរកការយល់ព្រមលើការបង្ហាញមួយចំនួននៃការស្រឡាញ់ភេទដូចគ្នា។ ការការពារតួនាទីនៃភាពស្មើគ្នារវាងបុរសស្ត្រីដែលបុរសដើរតួជាបុរសផង និងស្ត្រីផង (Man as male and Female) ក្នុងឆ្នាំ១៩៧៥ គាត់បាននិយាយថា គាត់មិនប្រាកដថា «តើវាមានន័យយ៉ាងណាក្នុងការក្លាយជាបុរសខុសពីស្ត្រី ឬស្ត្រីខុសពីបុរសនោះទេ»។[៣៧] ការនោះហាក់ដូចជាពួកយើងរារាំងចំពោះភាពសំខាន់នៃភេទផ្ទុយគ្នានេះ។ នៅក្នុងឆ្នាំ១៩៨៣ គាត់បានពិនិត្យឡើងវិញនូវការការពារជាប្រវត្តិសាស្ត្រនៃការស្រឡាញ់ភេទដូចគ្នាដោយលោក ចន បសស្វែល (John Boswell) ដែលបានប្រកែកថា អត្ថន័យរបស់សាវ័ក ប៉ុល នៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:២៦-២៧ ថាជារឿងតែមួយគត់ដែលត្រូវថ្កោលទោស គឺអាកប្បកិរិយាស្រឡាញ់ភេទដូចគ្នាដោយអ្នកស្រឡាញ់ភេទផ្ទុយគ្នា មិនមែនដោយអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រព្រឹត្តតាម «លក្ខណៈធម្មជាតិរបស់ពួកគេនោះទេ»។ លោក ប៉ូល ជីវេត បានបដិសេធការបកស្រាយនេះដោយលើកឡើងថា «សម្រាប់ [សាវ័ក ប៉ុល] «ធម្មជាតិ» ដែលប្រឆាំងនឹងការស្រឡាញ់ ភេទដូចគ្នាមិនមែនជាលក្ខណៈបុគ្គលរបស់គាត់នោះទេ ប៉ុន្តែជាធម្មជាតិទូទៅរបស់មនុស្សដែលគាត់មានរួមគ្នាក្នុងនាមជាមនុស្សម្នាក់»។[៣៨]

---

៣៧ លោក Paul Jewett, *Man as Male and Female: A Study in Sexual Relationships from a Theological Point of View* (Grand Rapids, MI: Eerdmans, ឆ្នាំ១៩៧៥), ១៧៨។

៣៨ លោក Paul Jewett, "An Overlooked Study: John Boswell on Homosexuality," Reformed Journal ៣៣ លេខ១ (ខែមករា ឆ្នាំ១៩៨៣), ទំព័រ១៧។



50 Crucial Questions.indd 89 7/4/26 2:18 in the afternoon

នេះពិតជាគួរឲ្យពេញចិត្ត ប៉ុន្តែវាហាក់ដូចជាចម្លែកម្តងទៀតសម្រាប់ពួកយើង ដែលគាត់បាននិយាយថាអាកប្បកិរិយាស្រឡាញ់ភេទដូចគ្នា គឺជាអំពើបាបប្រឆាំងទាស់នឹង «លក្ខណៈធម្មជាតិពីកំណើតរបស់មនុស្សទូទៅ» ជាជាងលក្ខណៈនៃភាពជាបុរស ឬជាស្ត្រី។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៨៥ លោក ជីវេត ហាក់ដូចជាបានបោះបង់ចោលការបកស្រាយស្របតាមព្រះគម្ពីរសម្រាប់ការស្រឡាញ់ភេទផ្ទុយគ្នានៅក្នុងការពិនិត្យឡើងវិញនៃសៀវភៅរបស់លោក រ៉ូប៊ីន ស្រ្កូចស៍ (Robin Scroggs) «ព្រះគម្ពីរសញ្ញាថ្មី និងការស្រឡាញ់ភេទដូចគ្នា» (The New Testament and Homosexuality)។ លោក រ៉ូប៊ីន បានលើកជាអំណះអំណាងថា ខគម្ពីរដែលទាក់ទងនឹងអាកប្បកិរិយាស្រឡាញ់ភេទដូចគ្នានៅក្នុងព្រះគម្ពីរសញ្ញាថ្មី «មិនពាក់ព័ន្ធនឹងមិនផ្តល់ជំនួយក្នុងការជជែកវែកញែកដ៏ក្តៅគគុកនាពេលបច្ចុប្បន្ននេះទេ» ពីព្រោះខគម្ពីរទាំងនោះមិនបានសំដៅទៅលើការស្រឡាញ់ភេទដូចគ្នាថាជា «ការបញ្ច្រាស» ដែលជាការតម្រង់ទិសតាមធម្មជាតិ ប៉ុន្តែ «ការបង្វែរ»[៣៩] ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។ លោក ជីវេត បានឆ្លើយតបថា «ប្រសិនបើនេះជាអត្ថន័យនៃប្រភពដើម—ហើយអ្នកប្រាជ្ញមានសមត្ថភាព អំណះអំណាងគឺប្រយ័ត្ន ដូច្នេះហើយការសន្និដ្ឋានគឺគួរឲ្យជឿទុកចិត្តលើបាន—បន្ទាប់មកអ្វីដែលព្រះគម្ពីរសញ្ញាថ្មីប្រឆាំងនឹងគឺខុសគ្នាយ៉ាងខ្លាំងពីទំនោរស្រឡាញ់ភេទដូចគ្នា ដែលមនុស្សមួយចំនួនមានតាំងពីសម័យដំបូងដើមរបស់ពួកគេ»។[៤០] ថ្មីៗនេះ ពួកអ្នកជឿថា ព្រះគម្ពីរគាំទ្របុរស និងស្ត្រីមានតួនាទីស្មើគ្នាលេចធ្លោមួយចំនួនបានបញ្ចេញសម្លេងគាំទ្រទំនាក់ទំនងស្នេហាភេទដូចគ្នា រួមមាន

---

៣៩ លោកស្រី Robin Scroggs, *The New Testament and Homosexuality: Contextual Backgrounds for Contemporary Debate* (Philadelphia: Fortress, ឆ្នាំ១៩៨៣), ទំព័រ១២៩។

៤០ លោក Paul Jewett, review of *The New Testament and Homosexuality: Contextual Backgrounds for Contemporary Debate,* ដោយៈ លោកស្រី Robin Scroggs, Interpretation ៣៩, លេខ២ (ខែមេសា ឆ្នាំ១៩៨៥), ទំព័រ២១០។



50 Crucial Questions.indd 90 7/4/26 2:18 in the afternoon

លោក ជីម វ៉លលីស (Jim Wallis) លោក អ៊ែនថូនី ខេមប៉ូឡូ (Anthony Campolo) និងលោក ដេវីត និហ្វ (David Neff)។[៩១]

ប៉ុន្តែ សូម្បីតែអ្នកជឿបែបស្ត្រីនិយមនៃនិកាយដំណឹងល្អនៅតែបន្តយល់ស្របជាមួយយើងដែលថា បទគម្ពីរចាត់ទុកការស្រឡាញ់ភេទដូចគ្នាជាអំពើបាប ក៏ប្រឈមមុខនឹងគ្រោះថ្នាក់ពិតប្រាកដនៃការបែងចែកតួនាទីយេនឌ័រដល់កូនៗរបស់ពួកគេផងដែរ។ តើការបញ្ជាក់យ៉ាងម៉ឺងម៉ាត់ និងប្រកបដោយក្តីស្រឡាញ់ចំពោះភាពជាបុរសរបស់កូនប្រុស ឬភាពជាស្ត្រីរបស់កូនស្រី អាចត្រូវបានបណ្តុះនៅក្នុងបរិយាកាសនៃការបដិសេធភាពខុសៗគ្នានៃតួនាទីរវាងភាពជាបុរស និងភាពជាស្ត្រីរាល់ពេល ឬកាត់បន្ថយយ៉ាងដូចម្តេច? ប្រសិនបើភាពខុសគ្នានៃតួនាទីសំខាន់តែមួយគត់ គឺផ្អែកលើសមត្ថភាព ហើយមិនមានឫសគល់នៅក្នុងធម្មជាតិ តើឪពុកម្តាយត្រូវធ្វើដូចម្តេច ដើម្បីរៀបចំអត្តសញ្ញាណភេទរបស់កូនៗពួកគេ? ប្រសិនបើពួកគេនិយាយថា ពួកគេនឹងមិនធ្វើអ្វីសោះ នោះបើយោងទៅតាមសុភវិនិច្ឆ័យ និងការសិក្សាចិត្តសាស្ត្រជាច្រើនប្រាប់យើងថា កុមារនឹងមានការយល់ច្រឡំថា ពួកគេជានរណា ដូច្នេះហើយទំនងជានឹងវិវត្តន៍ទៅរកការស្រឡាញ់ភេទដូចគ្នានៅពេលណាមួយ។

សម្រាប់ពួកយើង វាកាន់តែច្បាស់ និងកាន់តែឈឺចាប់ខ្លាំង ដែលភាពជាស្ត្រីនិយមស្របតាមព្រះគម្ពីរ គឺជាដៃគូដែលមិនចង់បានក្នុងការដោះស្រាយនូវភាពជាបុរស និងភាពជាស្ត្រីដែលបំពេញបន្ថែម ដែលផ្តល់មូលដ្ឋានគ្រឹះមិនត្រឹមតែសម្រាប់អាពាហ៍ពិពាហ៍តាមបែបព្រះគម្ពីរ និងលំដាប់លំដោយនៃក្រុមជំនុំតាមបែបព្រះគម្ពីរប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ភេទផ្ទុយគ្នាផងដែរ។

---

៩១ សម្រាប់លោក Jim Wallis, សូមមើល Leigh Jones, "Jim Wallis Announces Support for Same-Sex Marriage," World, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣, http://www.worldmag.com/2013/04
\/jim_wallis_announces_support_for_same_sex_marriage. For Tony Cam- polo and David Neff, see Warren Cole Smith, "Jockeying for Position on Same-Sex Marriage," World, June ១០, ២០១៥, http://www.worldmag.com
/២០១៥/០៦/jockeying_for_position_on_same_sex_marriage.



50 Crucial Questions.indd 91 7/4/26 2:18 in the afternoon

## សំណួរទី៤២
## តើលោកគ្រូដឹងដោយរបៀបណាថា ការកាត់ស្រាយបទគម្ពីររបស់លោកគ្រូមិនបានទទួលឥទ្ធិពលច្រើនពីបទពិសោធន៍ និងវប្បធម៌របស់លោកគ្រូ លើសអំពីអ្វីដែលអ្នកនិពន្ធព្រះគម្ពីរមានបំណងពិតប្រាកដនៅក្នុងការសរសេរ?

យើងដឹងយ៉ាងច្បាស់អំពីភាពខុសឆ្គងរបស់យើង។ យើងមានអារម្មណ៍ថា មានសម្ពាធពីវប្បធម៌ ទំនៀមទម្លាប់ និងទំនោរផ្ទាល់ខ្លួន ក៏ដូចជាព្រួញបោកបញ្ឆោតរបស់អារក្ស។ យើងមានទំនោរផ្ទាល់ខ្លួនរបស់យើង ហើយគ្មានការសង្ស័យណាមួយត្រូវបានជះឥទ្ធិពល ដោយកត្តាលក្ខណៈធម្មជាតិពីកំណើត និងបរិស្ថានទាំងអស់នៃអតីតកាល និងបច្ចុប្បន្នកាលរបស់យើង ហើយយើងសង្ឃឹមថា យើងមិនខ្ពស់ជាងការកែតម្រូវនោះទេ។ ប៉ុន្តែ យើងយកចិត្តទុកដាក់ថា វិធានការមួយចំនួននៃសេរីភាពពីភាពមិនខុសឆ្គងគឺមិនអាចទៅរួចនោះទេ ពីព្រោះព្រះគម្ពីរបានលើកទឹកចិត្តយើងកុំឲ្យត្រាប់តាមសម័យនេះឡើយ ចូរឲ្យអ្នករាល់គ្នាបានផ្លាស់ប្រែវិញ (រ៉ូម ១២:១-២)។

វាពិបាកនិយាយណាស់ ថាតើពួកអ្នកស្រ្តីនិយមត្រូវទទួលឥទ្ធិពលកាន់តែច្រើនពីសម្ពាធវប្បធម៌ដ៏ធំសម្បើមនៃការសន្មតសមភាពសហសម័យ ឬយើងត្រូវបានរងឥទ្ធិពលកាន់តែច្រើនឡើង ដោយសតវត្សរ៍នៃសិទ្ធិប្តីជាធំនិយម និងដោយការជំរុញបែបបុរសនិយមផ្ទាល់របស់យើង។ វាមានផលល្អតិចតួចណាស់ដល់ពួកយើងក្នុងការវាយប្រហារគ្នាទៅវិញទៅមក ដោយផ្អែកលើការទទួលឥទ្ធិពលដោយមិនដឹងខ្លួនពីផ្នែកខ្លះៗទាំងនេះ។ វាច្បាស់ណាស់ថាតាមរយៈអក្សរសិល្ប៍នេះ វាធ្វើឲ្យយើងទាំងអស់គ្នាមានការសង្ស័យ។

ទោះជាយ៉ាងណាក៏ដោយ ទំនុកចិត្តចំពោះការជឿជាក់របស់យើងផ្អែកទៅលើទិដ្ឋភាពទាំងប្រាំនៃការប្រដេញតាមសេចក្តីពិត៖ (១) យើងពិនិត្យមើលការជំរុញរបស់យើងយ៉ាងទៀងទាត់ ហើយយើងសម្អាតអ្វីៗទាំងអស់ដែលនឹងធ្វើឲ្យខូចដល់ការយល់ឃើញពិតប្រាកដទៅលើសេចក្តីពិត។ (២)



50 Crucial Questions.indd 92 7/4/26 2:18 in the afternoon

យើងអធិស្ឋានសុំឲ្យព្រះជាម្ចាស់ប្រទាននូវការបន្ទាបខ្លួន ការបង្រៀន មានប្រាជ្ញា ចំណេះដឹង យុត្តិធម៌ និងភាពស្មោះត្រង់ដល់យើង។ (៣) យើងខិតខំប្រឹងប្រែង ដើម្បីដាក់ចិត្តរបស់យើងទៅនឹងភាពជាក់ស្តែងនៃវេយ្យាករណ៍ និងប្រវត្តិសាស្ត្រដែលមិនផ្លាស់ប្តូរ ហើយមិនអាចបត់បែនបាននៃអត្ថបទព្រះគម្ពីរជាភាសាក្រិក និងហេព្រើរ ដោយប្រើវិធីសាស្ត្រសិក្សាដ៏ល្អបំផុត ដើម្បីចូលទៅដល់គោលបំណងរបស់អ្នកនិពន្ធព្រះគម្ពីរតាមតែអាចធ្វើទៅបាន។ (៤) យើងប្រៀបធៀបសេចក្តីសន្និដ្ឋានរបស់យើងជាមួយនឹងប្រវត្តិនៃការវិភាគក្នុងការកាត់ស្រាយអត្ថបទព្រះគម្ពីរ ដើម្បីបង្ហាញពីទស្សនៈដើមដែលជឿមកដល់បច្ចុប្បន្ន ឬភាពស្រពេចស្រពិលខាងវប្បធម៌។ និង (៥) យើងសាកល្បងការសន្និដ្ឋានរបស់យើងនៅក្នុងពិភពពិតនៃព័ន្ធកិច្ចនាសម័យបច្ចុប្បន្ន ហើយស្វែងរកដំបូន្មានពីអ្នកចាស់ទុំ និងអ្នកគោរពកោតខ្លាចព្រះជាម្ចាស់។ ដោយមានទំនុកចិត្តទាំងបន្ទាបខ្លួនថា យើងកំពុងប្រព្រឹត្តនឹងបទគម្ពីរដោយយកចិត្តទុកដាក់នោះ យើងដាក់និមិត្តរបស់យើងនៅចំពោះមុខសាធារណជន ដើម្បីឲ្យមនុស្សទាំងអស់មើលឃើញ និងធ្វើការជជែកពិភាក្សាក្នុងវេទិកាសាធារណៈ។

## សំណួរទី៤៣
## ហេតុអ្វីគេអាចទទួលយកទំនុកចម្រៀង ទំនុកតម្កើងដែលស្ត្រីតែង និងណែនាំសៀវភៅដែលសរសេរឡើងដោយស្ត្រី ប៉ុន្តែមិនអនុញ្ញាតឲ្យពួកគេនិយាយរឿងដូចគ្នានេះជាសាធារណៈទៅវិញ?

យើងមិននិយាយថា មនុស្សស្រីមិនអាចនិយាយរឿងដូចគ្នានេះ ជាសាធារណៈបាននោះទេ។ នៅពេលសាវ័ក ប៉ុល មានប្រសាសន៍ថា “តែចូរឲ្យបានពេញជាព្រះវិញ្ញាណវិញ ហើយនិយាយគ្នាទៅវិញទៅមក ដោយបទទំនុកតម្កើង ទំនុកបរិសុទ្ធ នឹងចំរៀងខាងឯវិញ្ញាណ ទាំងច្រៀង ហើយសរសើរដល់ព្រះអម្ចាស់ដោយចិត្ត” (អេភេសូរ ៥:១៨-១៩) យើងស្រមៃថា ស្ត្រីក្នុងក្រុមជំនុំកំពុងសូត្រ ឬច្រៀងសម្រាប់ក្រុមជំនុំនូវអ្វីដែលព្រះបានប្រទានដល់ពួកគេ (ប្រហែលជាក្នុងករណីខ្លះជា “ទំនាយ” ដូចដែលបានលើកឡើងនៅ



50 Crucial Questions.indd 93 7/4/26 2:18 in the afternoon

ក្នុងកណ្ឌគម្ពីរ ១កូរិនថូស ១១:៥)។ លើសជាងនេះទៅទៀត យើងរីករាយនឹងការពិតដែលជៀសមិនរួច ដែលបុរស ក៏ដូចជាស្ត្រីនឹងបានរៀនសូត្រ ហើយត្រូវបានបង្កើតឡើង និងទទួលបានការលើកទឹកចិត្តដោយកិច្ចការនៃព័ន្ធកិច្ចខាងការតែងនិពន្ធនេះ។

ជាការពិតណាស់ យើងមិនបានច្រានចោលព័ន្ធកិច្ចទាំងតូចទាំងធំ ឬទូទាំងពិភពលោក ដែលស្ត្រីបង្រៀនស្ត្រីផ្សេងទៀតនោះទេ។ សំណួរគោលសម្រាប់យើងគឺថា តើស្ត្រីគួរតែបំពេញតួនាទីជាផ្នែកមួយនៃការដឹកនាំការបង្រៀនជាមូលដ្ឋាន (ឧទាហរណ៍៖ ភាពជាអ្នកចាស់ទុំ) ក្នុងការប្រកបរវាងស្ត្រី និងបុរសដែរឬយ៉ាងណា ហើយចំពោះយើងវាហាក់ដូចជាថា ការបង្រៀនជាសាធារណៈពីក្រុមជំនុំពីបទគម្ពីរក៏ធ្វើដូច្នោះដែរ។ ផ្ទុយទៅវិញ ពេលនរណាម្នាក់អានសៀវភៅដែលសរសេរដោយស្ត្រី (សូម្បីតែការអធិប្បាយព្រះគម្ពីរដែល «បង្រៀន» បទគម្ពីរ) ទំនងជាសំដៅដល់ការសន្ទនាស្ងាត់ៗរវាងលោកអាប៉ូឡូស នាងព្រីស៊ីល និងលោក អ័គីឡា ក្នុងកណ្ឌគម្ពីរ កិច្ចការ ១៨:២៦ (សូមមើល សំណួរទី២០) ជាងការបង្រៀនជាសាធារណៈនៅក្នុងក្រុមជំនុំដែលសាវ័ក ប៉ុល ហាមឃាត់នៅក្នុងកណ្ឌគម្ពីរ ១ធីម៉ូថេ ២:១២ ទៅទៀត។ យើងក៏ទទួលស្គាល់ផងដែរនូវភាពមិនច្បាស់លាស់ដែលពាក់ព័ន្ធនឹងការធ្វើឲ្យមានភាពខុសគ្នាប្រកបដោយភាពឈ្លាសវៃ និងប្រកបដោយការគិតពិចារណា រវាងប្រភេទនៃការនិយាយជាសាធារណៈដែលសមរម្យ និងមិនសមរម្យ។ ការរំពឹងទុករបស់យើងមិនមែនថា យើងទាំងអស់គ្នានឹងទៅដល់កន្លែងណាដែលគួរគូសបន្ទាត់បញ្ចប់នេះទេ ប៉ុន្តែយើងអាចមក ដើម្បីបញ្ជាក់រួមគ្នានូវគោលការណ៍ជាមូលដ្ឋានរួមមួយជាមួយនឹងគ្នាបាន។ ការអនុវត្តការស្តាប់បង្គាប់តាមសេចក្តីបង្រៀនប្រកបដោយសីលធម៌នាបច្ចុប្បន្ន (ឧ. ការបង្រៀនរបស់ព្រះយេស៊ូវអំពីភាពក្រីក្រ ទ្រព្យសម្បត្តិ កំហឹង ការអភ័យទោស សេចក្តីយុត្តិធម៌ និងការមិនសងសឹក) តែងតែមានជម្រើសដ៏លំបាក។

## សំណួរទី៤៤
## តើការផ្តល់សិទ្ធិឲ្យស្ត្រីមានមុខងារ និងតួនាទីផ្សេងៗជារឿងយុត្តិធម៌ ដែលសូម្បីតែសង្គមរបស់យើងក៏ទទួលស្គាល់នោះជារឿងធម្មតាឬ?

យើងដឹងហើយថា សំណួរនេះកំពុងត្រូវគេចោទសួរកាន់តែខ្លាំងឡើងក្នុងន័យយុត្តិធម៌។ ឧទាហរណ៍ លោក នីកូឡាស វ៉ុលធើស្តហ្វ (Nicholas Wolterstorff) មានប្រសាសន៍ថា៖ «សំណួរដែលស្ត្រីក្នុងក្រុមជំនុំលើកឡើង គឺជាសំណួរពាក់ព័ន្ធនឹងភាពស្មើគ្នា....ស្ត្រីៗមិនមែនសុំអំណោយសប្បុរសធម៌ពីយើងជាបុរសៗនោះទេ។ ពួកគេកំពុងសួរទៅកាន់ក្រុមជំនុំ—ក្រុមជំនុំពីគ្រប់ទីកន្លែងទាំងអស់—ដែលប្រព្រឹត្តិចំពោះពួកគេបែបគួរ ដែលពួកគេស័ក្តិសមនឹងទទួល។ ពួកគេកំពុងសួរថា ហេតុអ្វីបានជាយេនឌ័រត្រូវពាក់ព័ន្ធទៅនឹងការចាត់តាំងការងារ តួនាទី ការិយាល័យ ទំនួលខុសត្រូវ និងឱកាសនានានៅក្នុងក្រុមជំនុំទៅវិញ»។[៤២]

ប្រាកដណាស់ យើងគិតថាយេនឌ័រ គឺពាក់ព័ន្ធនៅក្នុងការកំណត់យុត្តិធម៌នៃតួនាទី និងទំនួលខុសត្រូវ។ នេះប្រហែលជាវិធីល្អបំផុត ដើម្បីបង្ហាញពីមូលហេតុ៖ គឺការដកស្រង់អត្ថបទពីកាសែត មីនីអាប៉ូលីស ស្តារទ្រីបូន (Minneapolis Star-Tribune)។[៤៣] អ្នកនិពន្ធ ស្តូដាជ ប៊ី. ស្តដដាត (Thomas B. Stoddard) បានប្រាប់អំពីរឿងរ៉ាវរបស់ស្ត្រីដែលស្រឡាញ់ស្រីដូចគ្នាពីរនាក់ គឺនាង ឃែរិន ថមសិន (Karen Thompson) និងនាង ហ្សារ៉ន ខូវ៉ាល់ស្គី (Sharon Kowalski) នៅរដ្ឋមីនីសូតា (Minnesota)។ គាត់បានសរសេរថា «នាងឃែរិន និងនាង ហ្សារ៉ន គឺជាប្តី-ប្រពន្ធនៅក្នុងគ្រប់ទិដ្ឋភាពទាំងអស់» លើកលែងតែផ្លូវច្បាប់។ (នៅពេលនាង ឃែរិន បានសរសេរ គ្រប់ទាំងយុត្តាធិការនៅសហរដ្ឋអាមេរិកបានបដិសេធមិនអនុញ្ញាតឲ្យមនុស្សពីរ

---

៤២ លោក Nicholas Wolterstorff, "Hearing the Cry," in Women, Authority, and the Bible, កែសម្រួលដោយ៖ Alvera Mickelsen (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៦), ទំព័រ២៨៩។

៤៣ លោក Thomas B. Stoddard, "Gay Adults Should Not Be Denied the Benefits of Marriage," Minneapolis Star-Tribune, ថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៨៩ ១១A។



50 Crucial Questions.indd 95 7/4/26 2:18 in the afternoon

នាក់ដែលមានភេទដូចគ្នារៀបការនោះឡើយ)។ "ពួកគេបានសច្ចា និងបំពាក់ចិញ្ចៀនឲ្យគ្នា។ ពួកគេបានរស់នៅជាមួយគ្នារហូតដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៨៣ នៅពេលដែលនាង ហ្សារ៉ែន បានរងរបួសយ៉ាងធ្ងន់ធ្ងរ នៅពេលដែលអ្នកបើកបរក្នុងស្ថានភាពស្រវឹងម្នាក់បើកបុករថយន្តរបស់នាង។ នាងបាត់បង់សមត្ថភាពក្នុងការដើរ និងមិនអាចនិយាយច្រើនម៉ាត់បានក្នុងពេលតែមួយ ហើយត្រូវការការថែទាំជាប្រចាំ។ នាង ឃែរិន ចង់ឲ្យសិទ្ធិសម្រេចមើលថែទាំដល់ដៃគូរបស់នាងពីតុលាការ ប៉ុន្តែឪពុកម្តាយរបស់នាង ហ្សារ៉ែន បានជំទាស់នឹងការសម្រេចនេះ ហើយទទួលបានសិទ្ធិជាអាណាព្យាបាលតែម្នាក់ឯង។ ពួកគេបានផ្លាស់ប្តូរនាង ហ្សារ៉ែន ទៅកាន់មណ្ឌលថែទាំមានចម្ងាយជិត៥០០គ.ម ពីនាង ឃែរិន និងបានហាមឃាត់រាល់ការទៅសួរសុខទុក្ខទាំងអស់"។

លោក ស្ទូដាដ ប្រើរឿងនេះ ដើម្បីបង្ហាញពីផលប៉ះពាល់ដ៏ឈឺចាប់ដោយ "ភាពអយុត្តិធម៌ដ៏មហិមា" ស្តីពី "ការមិនអនុញ្ញាតឲ្យមនុស្សពេញវ័យស្រឡាញ់ភេទដូចគ្នារាប់លាននាក់នៅអាមេរិករៀបការតាមជម្រើសរបស់ពួកគេ" ។ អំណះអំណាងរបស់គាត់ គឺថាអាពាហ៍ពិពាហ៍ស្រឡាញ់ភេទដូចគ្នា "បង្កើតគ្រួសារ និងលើកកម្ពស់ស្ថេរភាពសង្គម។ នៅក្នុងពិភពលោកដែលពិបាកនឹងរកសេចក្តីស្រឡាញ់ អ្នកដែលប្រាថ្នាចង់តាំងខ្លួននៅក្នុងទំនាក់ទំនងដែលបង្កើតឡើងនៅលើការលះបង់ គួរតែត្រូវបានលើកទឹកចិត្ត មិនមែនមើលងាយឡើយនោះទេ។ រដ្ឋាភិបាលមិនមានចំណាប់អារម្មណ៍ស្របច្បាប់ចំពោះរបៀបដែលសេចក្តីស្រឡាញ់ត្រូវបានបង្ហាញចេញមកនោះទេ"។

រឿងនេះបានលើកឡើងនូវសំណួរជាមូលដ្ឋានសំខាន់មួយ៖ តើអត្តិភាពធម្មជាតិទាក់ទងនឹងកាតព្វកិច្ចសីលធម៌យ៉ាងដូចម្តេច? ឬអ្វីដែលជាឧបសគ្គខាងសីលធម៌ក្នុងការដែលកើតមកជាប្រុស ឬជាស្រីដាក់លើយើង? តើព្រះជាម្ចាស់មានបំណងឲ្យភាពជាបុរសគួរប្រឈមមុខនឹងបុរសជាមួយនឹងការទាមទារខាងសីលធម៌ ដែលខុសពីការទាមទារខាងសីលធម៌ដែលភាពជាស្ត្រី



50 Crucial Questions.indd 96 7/4/26 2:18 in the afternoon

ប្រឈមមុខនឹងមនុស្សស្រីដែរឬទេ?

ចម្លើយគឺមិនសាមញ្ញនោះទេ។ បើនិយាយមួយបែបទៀត យើងនឹងស្រែកថា ទេ! បញ្ញត្តិជប់ប្រការអនុវត្តស្មើៗគ្នាចំពោះបុរស និងស្ត្រីដោយគ្មានការបែងចែក។ ប៉ុន្តែ បើនិយាយមួយបែបទៀតវិញ ពួកយើងភាគច្រើនក៏នឹងស្រែកថា បាទ/ចាស ដែរ! វាជាអំពើបាបដែលបុរសរៀបការជាមួយបុរស ប៉ុន្តែមិនមែនជាអំពើបាបទេដែលស្ត្រីរៀបការជាមួយបុរស (រ៉ូម ១:២៦-២៧)។ បើសិនដូច្នេះមែន យើងមិនអាចនិយាយបានថា អ្វីដែលយើងមានពីធម្មជាតិ (យេនឌ័រ) មិនមានតួនាទីក្នុងការកំណត់កាតព្វកិច្ចសីលធម៌របស់យើងទាក់ទងនឹងមនុស្សដទៃបាននោះឡើយ។

នៅពេលដែលបុរសម្នាក់ឈរនៅចំពោះមុខស្ត្រីម្នាក់ កាតព្វកិច្ចសីលធម៌ដែលនៅខាងមុខគាត់ គឺមិនដូចគ្នាទៅនឹងកាតព្វកិច្ចរបស់គាត់នៅពេលគាត់ឈរនៅចំពោះមុខបុរសម្នាក់ទៀតនោះទេ។ ព្រះជាម្ចាស់បានកំណត់ថា ពិភពធម្មជាតិ និងសីលធម៌ប្រសព្វគ្នានៅក្នុងចំណោមកន្លែងផ្សេងទៀត ជាចំណុចនៃភេទរបស់យើង។

រហូតមកដល់ការលេចឡើងនៃមោទនភាពរបស់មនុស្សស្រឡាញ់ភេទដូចគ្នាថ្មីៗនេះ កម្រមាននរណាម្នាក់បានចោទប្រកាន់ព្រះជាម្ចាស់ថា បានរើសអើងស្ត្រី ដោយផ្តល់សិទ្ធិឲ្យតែបុរសអាចរៀបការជាមួយស្ត្រី។ តាមប្រវត្តិសាស្ត្រ វាហាក់បីដូចជាមិនយុត្តិធម៌ទេ ដែលមានតែលើមូលដ្ឋាននៃយេនឌ័រមួយមុខតែប៉ុណ្ណោះ ដែលព្រះអង្គមិនរាប់បញ្ចូលពាក់កណ្តាលនៃអំបូរមនុស្សជាតិថាជាប្តីប្រពន្ធស្របច្បាប់សម្រាប់ស្ត្រី។ វាហាក់ដូចជា “សម/ស័ក្តិសម” និង “សាមញ្ញ” និង “ត្រឹមត្រូវ” (យើងហ៊ាននិយាយថា “យុត្តិធម៌”) ដែលទិដ្ឋភាពដ៏ធំនៃអារម្មណ៍ និងសកម្មភាពអាពាហ៍ពិពាហ៍គួរតែត្រូវបានបដិសេធចំពោះស្ត្រី និងបុរសក្នុងទំនាក់ទំនងរបស់ពួកគេទៅនឹងពាក់កណ្តាលនៃពូជមនុស្ស។

មូលហេតុបណ្តាលឲ្យគ្មាន ការបះបោរប្រឆាំងទាស់ នឹងការកំណត់ដ៏ធំលើ



50 Crucial Questions.indd 97 7/4/26 2:18 in the afternoon

សេរីភាពនៅក្នុងមនុស្សជំនាន់មុនដូចនេះ គឺប្រហែលជាមនុស្សភាគច្រើនបាន គិតថា វាសមរម្យ ស័ក្តិសម ហើយត្រឹមត្រូវ។ ដោយសារព្រះគុណទ្រង់ ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យការដឹងខុសត្រូវពីកំណើតរបស់មនុស្សមានការភាន់ច្រឡំខ្លាំងឡើយ បើមិនដូច្នេះទេលោកីយ៍នឹងបាត់នូវសមត្ថភាពនៅក្នុងការដឹងថា អ្វីត្រឹមត្រូវតាមក្រមសីលធម៌នៅក្នុងស្ថានភាពបែបនេះជាមិនខាន។

អ្នកជឿបែបស្ត្រីនិយមមកពីនិកាយដំណឹងល្អអាចនឹងនិយាយថា យេនឌ័រជាប់ពាក់ព័ន្ធនៅក្នុងការកំណត់យុត្តិធម៌ទាក់ទងនឹងអាពាហ៍ពិពាហ៍ ពីព្រោះធម្មជាតិបង្រៀនដោយកាយវិភាគសាស្ត្រ និងសរីរវិទ្យារបស់បុរស និងស្ត្រីថា ជាអ្វីដែលសុក្រិត្យ និងត្រឹមត្រូវ។ ប៉ុន្តែ យើងសួរថា តើសេចក្តីនោះគឺមូលដ្ឋាននៃហេតុផលតែមួយសម្រាប់ការរៀបអាពាហ៍ពិពាហ៍មែនដែរឬទេ? តើការវិភាគខុសគ្នាជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍ភេទផ្ទុយគ្នាមែនឬទេ? ហេតុផលគោលក្នុងហេតុផលចម្បងមួយចំនួននៃសៀវភៅនេះគឺថា លក្ខណៈនៃភាពសមគ្នាពីកំណើតរបស់បុរស និងស្ត្រីនៅក្នុងអាពាហ៍ពិពាហ៍បានចាក់ឫសនៅក្នុងអ្វីដែលលើសពីគ្រាន់តែការវិភាគខាងរូបកាយ។ មានភាពជាបុរស និងភាពជាស្ត្រីយ៉ាងជ្រាលជ្រៅបានបង្ហាញមកនៅក្នុងរាងកាយដែលខុសគ្នារបស់យើង។ ដូចលោក អមីល ប្រូនន័រ (Emil Brunner) បានធ្លាប់លើកឡើងថា៖

> រឿងផ្លូវភេទរបស់យើងជ្រាបចូលទៅក្នុងមូលដ្ឋាននៃការពិតយ៉ាងជ្រាលជ្រៅបំផុតនៃបុគ្គលិកលក្ខណៈរបស់យើង។ ជាលទ្ធផល ភាពខុសប្លែកគ្នាខាងរូបកាយរវាងបុរស និងស្ត្រី គឺជារឿងប្រៀបប្រដូចនៃភាពខុសគ្នាខាងផ្លូវចិត្ត និងខាងវិញ្ញាណនៃធម្មជាតិដ៏អស្ចារ្យជាងនេះ។[៤៤]

ឬក៏លោកគ្រូ អតតូ ផាបភ័រ (Otto Piper) មានប្រសាសន៍ថា៖ "បើទោះ

៤៤ . លោក Thomas B. Stoddard, "Gay Adults Should Not Be Denied the Benefits of Marriage," Minneapolis Star-Tribune, ថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៨៩ ១១A។



50 Crucial Questions.indd 98 7/4/26 2:18 in the afternoon

បីជា [ភាពខុសគ្នារវាងភេទ] មានមូលដ្ឋានខាងផ្លូវភេទ តាមពិតទៅ វាគ្រប ដណ្ដប់រាល់ទិដ្ឋភាពទាំងអស់នៃជីវិតផ្ទាល់ខ្លួន»។[៤៥]

ប្រហែលបើអ្នកជឿបែបស្ត្រីនិយមនិកាយដំណឹងល្អដែលមិនគាំទ្រភាព យុត្តិធម៌នៃអាពាហ៍ពិពាហ៍ភេទដូចគ្នា យល់ស្របថាមូលដ្ឋាននៃតួនាទីរបស់ ពួកគេ នោះគឺមិនគ្រាន់តែខាងកាយវិភាគនោះទេ ប៉ុន្តែក៏មានភាពខុសគ្នាកាន់ តែជ្រាលជ្រៅចំពោះភាពជាបុរស និងភាពជាស្ត្រីទៀតផង ហើយយ៉ាងហោច ណាស់ពួកគេយល់ថា ហេតុអ្វីយើងមានការស្ទាក់ស្ទើរនៅក្នុងការបោះបង់ភាព ខុសគ្នាកាន់តែជ្រាលជ្រៅផ្សេងៗ នៅពេលយើងគិតអំពីលក្ខណៈយុត្តិធម៌នៅ ក្នុងបញ្ហាដែលជាប់ទាក់ទងផ្សេងៗ ក្រៅពីថានរណាអាចនឹងរៀបការជាមួយ នរណាបាននោះ។ ចំណុចសំខាន់របស់យើងគឺថា បទគម្ពីរ និងលក្ខណៈពី កំណើតបង្រៀនថា ភាពជាបុរស និងភាពជាស្ត្រីផ្ទាល់ខ្លួន តាមពិតទៅជាប់ ទាក់ទងគ្នានៅក្នុងការសម្រេចចិត្តថា គួរតែរៀបការជាមួយនរណា ហើយមិន គួររៀបការជាមួយនរណានោះទេ ប៉ុន្តែក៏ជាប់ទាក់ទងគ្នាផងដែរថា តើនរណា ជាអ្នកផ្ដល់តួនាទីជាអ្នកដឹកនាំចម្បងនៅក្នុងទំនាក់ទំនងនេះ។

## សំណួរទី៤៥
## តើវាមិនពិតទេមែនទេដែលថា គេហៅព្រះជាម្ចាស់ថា «អ្នកជំនួយ» របស់យើងជាច្រើនដងនៅក្នុងព្រះគម្ពីរជាមួយនឹងពាក្យដូចគ្នាដែល គេបានប្រើ ដើម្បីពណ៌នាអំពីនាង អេវ៉ា នៅពេលដែលនាងត្រូវបាន គេហៅថាជា «អ្នកជំនួយ» ដែលសមស្របសម្រាប់បុរសមែនឬ? តើ វាមិនច្រានចោលការយល់ឃើញណាមួយនៃតួនាទីចុះចូលពិសេស សម្រាប់នាង ឬសូម្បីតែធ្វើឲ្យនាងមានសិទ្ធិអំណាចជាងបុរសទេឬអី?

វាជាការពិតដែលព្រះជាម្ចាស់ ជាញឹកញាប់ត្រូវគេហៅថា "អ្នកជំនួយ" របស់ យើង ប៉ុន្តែពាក្យនោះផ្ទាល់មិនបានបង្ហាញន័យអ្វីផ្សេងក្រៅពីលំដាប់ថ្នាក់ ឬ

---

៤៥ . លោក Otto Piper, *Christian Ethics* (London: Thomas Nelson and Sons, ឆ្នាំ១៩៧០), ទំព័រ២៩៩។



50 Crucial Questions.indd 99 7/4/26 2:18 in the afternoon

សិទ្ធិអំណាចនោះទេ។ បរិបទត្រូវសន្មតថា តើនាង អេវ៉ា «ជួយ» ក្នុងនាមជាអ្នកខ្លាំងជួយអ្នកខ្សោយ ឬក៏ក្នុងនាមជាអ្នកជួយអ្នកដឹកនាំដ៏គួរឲ្យស្រឡាញ់។ បរិបទធ្វើឲ្យវាមិនសូវទំនង ដែល «អ្នកជំនួយ» គួរតែអានការប្រៀបធៀបនៃជំនួយរបស់ព្រះជាម្ចាស់ ពីព្រោះនៅកណ្ឌគម្ពីរ លោកុប្បត្តិ ២:១៩-២០ លោកអ័ដាម ដំបូងឡើយស្វែងរក «អ្នកជំនួយ» របស់គាត់នៅក្នុងចំណោមពពួកសត្វទាំងឡាយ។ ប៉ុន្តែ ពពួកសត្វទាំងនោះមិនអាចធ្វើដូច្នេះបាននោះទេ ពីព្រោះពួកវាមិន «ស័ក្តិសមនឹងគាត់»។ ដូច្នេះ ព្រះជាម្ចាស់បង្កើតស្ត្រី «ចេញពីបុរស» ដោយឲ្យមានលក្ខណៈជាមនុស្សរួមគ្នានឹងគាត់ ស្មើនឹងគាត់នៅក្នុងលក្ខណៈមនុស្សដូចជារូបអង្គនៃព្រះជាម្ចាស់។ ប្រាកដណាស់ នាងខុសពីសត្វ ហើយព្រះជាម្ចាស់បានគូសបញ្ជាក់អំពីគុណតម្លៃរបស់នាងទៅកាន់បុរស ដោយការបង្ហាញថា គ្មានសត្វណាមួយអាចបំពេញតួនាទីរបស់នាងបានឡើយ។ ប៉ុន្តែ នៅក្នុងការឆ្លងកាត់ការស្វែងរកពីសត្វដ៏មានប្រយោជន៍ទៅជាស្ត្រីដែលជាជំនួយវិញ ព្រះជាម្ចាស់បង្រៀនយើងថា ស្ត្រីគឺជា «អ្នកជំនួយ» របស់បុរសនៅក្នុងន័យស្មោះត្រង់ និងជាអ្នកជំនួយដ៏ស័ក្តិសមម្នាក់នៅក្នុងជីវិតនៃសួនអេដែន។

សំណួរបានសន្មតទាំងខុសឆ្គងថា ដោយសារតែពាក្យ «ដូចអ្នកជំនួយ» មានអត្ថន័យបង្កប់ជាក់លាក់ («ភាពដូចជាព្រះ») នៅកន្លែងខ្លះ នោះវាត្រូវតែមានការបង្កប់ន័យនៅគ្រប់ទីកន្លែងផងដែរ។ វាដូចជាការដែលនិយាយថា ដោយសារព្រះជាម្ចាស់ត្រូវបានពណ៌នាថាជាអ្នកដែល «ធ្វើការ» សម្រាប់យើង ដូច្នេះ គ្មានមនុស្សណាម្នាក់ដែល «ធ្វើការ» ត្រូវទទួលខុសត្រូវចំពោះចៅហ្វាយរបស់ខ្លួនទេ ពីព្រោះពាក្យនេះមិនអាចមានអត្ថន័យដូចគ្នានោះទេ ជាពិសេសនៅពេលដែលព្រះជាម្ចាស់បានប្រើប្រាស់ពាក្យនោះ។



50 Crucial Questions.indd 100 7/4/26 2:18 in the afternoon

## សំណួរទី៤៦

**នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ៧:៣-៥ បានចែងដោយត្រង់ៗថា «ត្រូវឲ្យប្ដីប្រព្រឹត្តនឹងប្រពន្ធដោយចិត្តសប្បុរស ហើយត្រូវឲ្យប្រពន្ធប្រព្រឹត្តនឹងប្ដីក៏ដូច្នោះដែរ ប្រពន្ធមិនមែនជាម្ចាស់លើរូបកាយខ្លួនឯងទេ គឺជាប្ដីវិញ ហើយប្ដីក៏មិនមែនជាម្ចាស់លើរូបកាយខ្លួនឯងដែរ គឺជាប្រពន្ធវិញ ដូច្នេះ កុំឲ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល ដើម្បីឲ្យបានជាទំនេរនឹងអធិស្ឋាន រួចត្រូវវិលមកនៅជាមួយវិញ ក្រែងអារក្សសាតាំងល្បួងលួងអ្នករាល់គ្នា ដោយមិនចេះអត់ទ្រាំ»។ តើការនេះមិនបង្ហាញថា សិទ្ធិអំណាចឯកតោភាគីពីប្ដីខុសទេឬ?**

ត្រូវហើយ ប៉ុន្តែចូរធ្វើឲ្យចម្លើយយើងកាន់តែទូលំទូលាយ ដើម្បីទទួលបានចម្លើយភាគច្រើនពីអត្ថបទនេះ និងការពារវាពីការប្រើប្រាស់ខុសឆ្គង។

អត្ថបទនេះអាចត្រូវបានប្រើប្រាស់ខុសឆ្គងយ៉ាងធ្ងន់ធ្ងរ ដោយបុរសដែលគ្មានក្ដីស្រឡាញ់ ដែលយកវាជាអាជ្ញាប័ណ្ណសម្រាប់ការទាមទាររឿងផ្លូវភេទដោយមិនចេះគិត ឬអាចសូម្បីតែសកម្មភាពផ្លូវភេទដ៏អាក្រក់ និងធ្វើឲ្យអាម៉ាស់មុខ។ មនុស្សម្នាក់អាចស្រមៃមើលការចំអកបញ្ឈឺចិត្តរបស់បុរសម្នាក់ថា "ព្រះគម្ពីរចែងថា អូនគ្មានអំណាចលើរូបកាយរបស់អូនទេ ប៉ុន្តែបងមាន។ ហើយបទគម្ពីរចែងថា អូនជំពាក់អ្វីដែលបងត្រូវការ"។ មូលហេតុដែលយើងនិយាយថានេះជាការប្រើប្រាស់ខុស គឺដោយសារអត្ថបទក៏ផ្ដល់សិទ្ធិអំណាចដល់ប្រពន្ធថា "ព្រះគម្ពីរចែងថា បងមិនមានអំណាចលើរូបកាយរបស់បងទេ ប៉ុន្តែអូនមាន ហើយអូនចង់ប្រាប់បងថា អូនមិនចង់ឲ្យបងប្រើរាងកាយរបស់បង ដើម្បីធ្វើដូច្នេះចំពោះអូនទេ"។ ហេតុផលមួយទៀតដែលយើងដឹងថានេះអាចជាការប្រើខុសគឺថា សាវ័ក ប៉ុល និយាយថាការសម្រេចចិត្តនៅក្នុងផ្នែកដ៏រសើបនេះគួរតែត្រូវបានធ្វើឡើងដោយ "ស្រុះចិត្តគ្នា" (ខ.៥)។

អត្ថបទនេះមិនមែនជាការផ្ដល់អាជ្ញាប័ណ្ណដល់ការកេងប្រវ័ញ្ចផ្លូវភេទនោះឡើយ។ វាគឺជាការអនុវត្តទៅនឹងសេចក្ដីបង្គាប់ខាងឯជីវិតផ្លូវភេទថា "នោះចូរមានចិត្តថ្នមគ្នាទៅវិញទៅមកចុះ" (រ៉ូម ១២:១០)។ ឬ "តែចូររាប់អានគេ



50 Crucial Questions.indd 101 7/4/26 2:18 in the afternoon

ឲ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ» (ភីលីព ២:៣)។ ឬ «តែកុំឲ្យប្រើសេរីនោះ ទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបម្រើគ្នាទៅវិញទៅមកដោយសេចក្ដីស្រឡាញ់វិញ» (កាឡាទី ៥:១៣)។ មិនត្រូវផ្ដោតទៅលើអ្វីដែលយើងមានសិទ្ធិទទួលនោះទេ ប៉ុន្ដែគឺលើបំណុលដែលយើងត្រូវសងដែរ។ សាវ័ក ប៉ុល មិនបាននិយាយថា «ចូរយកអ្វីដែលលោកអ្នកត្រូវការចុះ»។ គាត់និយាយថា «កុំបង្អត់គ្នាទៅវិញទៅមក» ទេតើ។ ម្យ៉ាងវិញទៀត នៅពេលដែលវាស្ថិតនៅក្នុងអំណាចរបស់លោកអ្នក ដើម្បីបំពេញតម្រូវការរបស់ប្ដីប្រពន្ធលោកអ្នកស្រាប់ហើយ ចូរធ្វើវាចុះ។

មានការរួបរួមគ្នានឹងគ្នាទៅវិញទៅមកដ៏អស្ចារ្យ ដែលដំណើរការតាមរយៈអត្ថបទកណ្ឌគម្ពីរ ១កូរិនថូស ៧:២-៥។ ទាំងប្ដី ឬប្រពន្ធមិនមាននរណាម្នាក់មានសិទ្ធិលើរាងកាយគ្នាលើសជាងនរណាម្នាក់ទៀតឡើយ។ ហើយនៅពេលដែលការផ្អាកសកម្មភាពផ្លូវភេទមួយចំនួនត្រូវបានពិចារណា នោះសាវ័ក ប៉ុលបានបដិសេធការសម្រេចចិត្តឯកតោភាគីដោយប្រពន្ធ ឬប្ដីថា «កុំឲ្យបង្អត់គ្នាឡើយ លើកតែស្រុះចិត្តគ្នាក្នុង១ពេល» (ខ៥)។

តើអត្ថបទនេះមានន័យយ៉ាងដូចម្ដេចចំពោះការដឹកនាំរបស់ស្វាមី? តើការអំពាវនាវឲ្យមានការយោគយល់គ្នាទៅវិញទៅមកចំពោះតម្រូវការផ្លូវភេទ និងការលះបង់ផែនការឯកតោភាគី ធ្វើឲ្យការទទួលខុសត្រូវរបស់ស្វាមីលែងមានទៀតចំពោះភាពជាអ្នកដឹកនាំទូទៅក្នុងអាពាហ៍ពិពាហ៍ដែរឬទេ? យើងមិនគិតដូច្នេះទេ។ ប៉ុន្ដែ អត្ថបទនេះច្បាស់ជាបង្ហាញពីភាពជាអ្នកដឹកនាំនោះ ហើយផ្ដល់ការណែនាំបន្ថែមពីព្រះគម្ពីរពីរបៀបដែលវាដំណើរការ។ វាបញ្ជាក់យ៉ាងច្បាស់ថា ការដឹកនាំរបស់គាត់នឹងមិនពាក់ព័ន្ធនឹងជម្រើសអាត្មានិយម និងឯកតោភាគីឡើយ។ គាត់នឹងខិតខំជានិច្ច ដើម្បីឧត្ដមគតិនៃការស្រុះស្រួលចិត្តគ្នា។ គាត់នឹងគិតគូរពីការពិតដែលថាតម្រូវការ និងចំណង់ផ្លូវភេទរបស់នាងមានរបៀបដូចគ្នានឹងគាត់ក្នុងការអភិវឌ្ឍន៍លំនាំនៃទំនាក់ទំនងស្និទ្ធស្នាលរបស់ពួកគេ។



50 Crucial Questions.indd 102 7/4/26 2:18 in the afternoon

អត្ថបទនេះបញ្ជាក់យ៉ាងច្បាស់ថា ភាពជាអ្នកដឹកនាំមិនមែនមានន័យថា អ្នកដឹកនាំត្រូវតែបានអ្វីមួយតាមចិត្តដែលខ្លួនគិតថាត្រូវនោះទេ។ អត្ថបទនេះក៏ជាហេតុផលចម្បងមួយផងដែរ ដែលយើងចូលចិត្តប្រើពាក្យថាភាពជាអ្នកដឹកនាំ ជាជាងសិទ្ធិអំណាចសម្រាប់ទំនួលខុសត្រូវពិសេសរបស់បុរសនោះ (សូមមើលសំណួរទី៣៦)។ អត្ថបទដូចជា កណ្ឌគម្ពីរ ១កូរិនថូស ជំពូកទី៧ បំប្លែងគំនិតនៃសិទ្ធិអំណាចយ៉ាងស៊ីជម្រៅ រហូតធ្វើឲ្យពាក្យនេះមានការយល់ច្រឡំយ៉ាងងាយ។ ភាពខុសគ្នារវាងយើង និងអ្នកជឿបែបស្រ្តីនិយមគឺពួកគាត់គិតថា គោលគំនិតនេះនឹងរលាយបាត់នៅពេលវាស្មើគ្នាទៅវិញទៅមក ខណៈពេលដែលយើងគិតថា គោលគំនិតត្រូវបានបង្រួបបង្រួមដោយការយោគយល់រវាងគ្នានឹងគ្នា។

## សំណួរទី៤៧

## ប្រសិនបើលោកគ្រូជឿថា ភាពខុសគ្នានៃតួនាទីរបស់បុរស និងស្រ្តីនៅក្នុងគ្រួសារ និងក្រុមជំនុំត្រូវបានចាក់ឫសទៅតាមលំដាប់លំដោយដែលព្រះបានបង្កើត ហេតុអ្វីបានជាលោកគ្រូមិនទទូចចង់ឲ្យមានការអនុវត្តច្បាប់នោះ នៅគ្រប់ទីកន្លែងក្នុងជីវិតលោកីយ៍ ដូចដែលអ្នកនៅក្នុងផ្ទះ និងព្រះវិហារដូច្នេះដែរ?

នៅពេលយើងចាកចេញឆ្ងាយពីក្រុមជំនុំ និងគ្រួសារ នោះយើងកាន់តែចាកឆ្ងាយពីអ្វីដែលបានបង្រៀនមកច្បាស់លាស់ និងដោយផ្ទាល់ ទៅជាគំនិតមិនច្បាស់លាស់ និងការបកស្រាយបន្ថែមទៀត។ យើងផ្លាស់ប្តូរពីតួនាទីដែលត្រូវបានពន្យល់យ៉ាងច្បាស់នៅក្នុងបទគម្ពីរទៅជាតួនាទីដែលព្រះគម្ពីរមិនផ្តល់ការណែនាំជាក់លាក់។ ដោយមូលហេតុនេះ នោះការផ្តោតអារម្មណ៍របស់យើងបានផ្លាស់ប្តូរពីការណែនាំអំពីតួនាទីលម្អិត (ដូចជាអ្វីដែលមាននៅក្នុងបទគម្ពីរ) ទៅជាការយល់ដឹងអំពីភាពជាមនុស្សរបស់បុរស និងស្រ្តី តាមរយៈទិដ្ឋភាពដែលមានទំនោរបែបយល់ឃើញតាមគំនិតខ្លួនឯងនៃទំនាក់ទំនងដូចជាអាកប្បកិរិយា ឥរិយាបថ កិរិយាមារយាទ សកម្មភាព និងការរំពឹងទុក



50 Crucial Questions.indd 103 7/4/26 2:18 in the afternoon

ជាច្រើនដែលបាននិយាយរួចហើយ ឬមិនបាននិយាយរួចហើយ។

យើងជឿជាក់ថា ព្រះគម្ពីរបង្រៀនយ៉ាងច្បាស់ថា បុរសគួរតែទទួលខុសត្រូវចម្បងសម្រាប់ការដឹកនាំនៅក្នុងផ្ទះ និងនៅក្នុងក្រុមជំនុំ ហើយតួនាទីនៃការបង្រៀនជាចម្បង និងការដឹកនាំសំខាន់ៗគួរតែធ្វើឡើងដោយបុរសដែលពេញដោយព្រះវិញ្ញាណ។ យើងមើលឃើញថានេះជាការបង្ហាញអំពីសេចក្តីសប្បុរស និងប្រាជ្ញារបស់ផងព្រះជាម្ចាស់ស្របតាមព្រះគម្ពីរទាក់ទងនឹងភាពជាអ្នកដឹកនាំនៅក្នុងផ្នែកទាំងនេះ និងលក្ខណៈនៃភាពជាបុរស និងភាពជាស្ត្រី។ ម្យ៉ាងវិញទៀត ព្រះជាម្ចាស់ទ្រង់ជ្រាបច្បាស់អំពីអ្វីដែលល្អបំផុតសម្រាប់យើង ដូច្នេះ យើងមិនចាំបាច់សម្រេចចិត្តដោយខ្លួនឯងថាតើជាបុរស ឬស្ត្រីគួរតែដឹកនាំក្នុងផ្នែកទាំងនេះទេ។ យ៉ាងណាមិញ នៅពេលនិយាយអំពីការងារ និងវិជ្ជាជីវៈផ្សេងៗគ្នាជាមួយនឹងរចនាសម្ព័ន្ធគ្រប់គ្រងខុសៗគ្នា នោះព្រះមិនបានផ្តល់ការណែនាំជាក់លាក់អំពីតួនាទីណា ក្នុងការបំពេញ សម្រាប់បុរស និងតួនាទីណាសម្រាប់ស្ត្រីនោះទេ។

ម្ល៉ោះហើយ យើងមិនប្រាកដថា នៅក្នុងវិស័យដ៏ធំទូលាយនេះ តើតួនាទីមួយណាអាចត្រូវបានធ្វើឡើងដោយបុរស ឬតួនាទីមួយណាអាចត្រូវបានធ្វើឡើងដោយបុរស/ស្ត្រីនោះ នៅក្នុងរបៀបដែលផ្តល់កិត្តិយសដល់តម្លៃពិសេសនៃភាពជាបុរស និងស្ត្រី។ យើងមិនចង់ដាក់កម្រិតដែលបទគម្ពីរមិនដាក់កម្រិតទេ។ ដោយសារហេតុផលនេះ យើងផ្តោតលើ (ដោយមានករណីលើកលែងមួយចំនួន) របៀបដែលតួនាទីទាំងនេះត្រូវបានអនុវត្ត ជាជាងថាតើមួយណាដែលសមស្របជាងនោះឡើយ។[៤៦]

៤៦ សូមមើលជំពូកទី១ក្នុង *Recovering Biblical Manhood and Womanhood*, ទំព័រ៤៤-៤៥, ៥០-៥២។



50 Crucial Questions.indd 104 7/4/26 2:18 in the afternoon

## សំណួរទី៤៨
## តើស្ត្រីដែលជាគ្រីស្ទបរិស័ទនៅលីវអាចចូលទៅក្នុងសេចក្ដីអាថ៌កំបាំងនៃព្រះគ្រីស្ទ និងក្រុមជំនុំដោយរបៀបណា បាន ប្រសិនបើនាងមិនធ្លាប់ឆ្លងកាត់អាពាហ៍ពិពាហ៍ផងនោះ?

លោកស្រី អេលីហ្សាបែត អ៊ីឡៀត (Elisabeth Elliot) ផ្ដល់ចម្លើយចំពោះសំណួរនេះ ដែលយើងចូលចិត្តដកស្រង់ជាជាងព្យាយាម (ឥតបានការ) ដើម្បីកែលម្អ៖

> អំណោយនៃភាពបរិសុទ្ធ ដែលផ្ដល់ឲ្យមនុស្សម្នាក់ៗដើម្បីថ្វាយដល់ព្រះសម្រាប់ការប្រើប្រាស់របស់ទ្រង់ គឺជាអំណោយដែលមិនអាចកាត់ថ្លៃបាន និងមិនអាចជំនួសបាន។ វាអាចត្រូវបានថ្វាយនៅក្នុងការលះបង់ដ៏បរិសុទ្ធនៃអាពាហ៍ពិពាហ៍ ឬវាអាចត្រូវបានផ្ដល់ជូននៅក្នុងការលះបង់នៃជីវិតដែលតាំងចិត្តនៅលីវ។ តើសេចក្ដីនេះស្ដាប់ទៅយុត្តិធម៌ដែរ ឬក៏ខ្ពស់ពេកហើយវិសុទ្ធពេកមែនដែរឬទេ? ប៉ុន្តែ សូមគិតមួយភ្លែតសិន—ដោយសារការដែលនៅព្រហ្មចារីមិនដែលស្គាល់បុរសនោះ នាងមានសេរីភាពក្នុងការថ្វាយខ្លួនទាំងស្រុងក្នុងកិច្ចការរបស់ព្រះអម្ចាស់ ដូចដែលសាវ័ក ប៉ុល បានមានប្រសាសន៍នៅក្នុងកណ្ឌគម្ពីរ ១កូរិនថូស ជំពូកទី៧ថា «ហើយគោលបំណងជីវិតរបស់នាងបានបរិសុទ្ធពេញទាំងខ្លួនប្រាណ និងព្រលឹងវិញ្ញាណផង»។ នាងរក្សាដួងចិត្តរបស់នាងជាកូនក្រមុំរបស់ព្រះគ្រីស្ទតាមរបៀបមួយដ៏ពិសេស ដោយថ្វាយដល់កូនកំលោះនៅស្ថានសួគ៌នូវអ្វីៗទាំងអស់របស់នាង និងអ្វីៗទាំងអស់ដែលនាងមាន។ នៅពេលនាងថ្វាយខ្លួននាងទៅទ្រង់ដោយក្ដីស្រឡាញ់ នាងមិនចាំបាច់បង្ហាញអំពីភាពត្រឹមត្រូវចំពោះលោកីយ៍ ឬចំពោះគ្រីស្ទបរិស័ទដែលសួរសំណួរនាង ឬផ្ដល់យោបល់ឲ្យនាងនោះទេ។ របៀបដែលស្ត្រីដែលរៀបការរួចមិនអាចធ្វើបាននោះគឺ៖ «ការលះបង់ជីវិត» ប្រចាំថ្ងៃរបស់នាង គឺជាទីបន្ទាល់ដ៏មានឥទ្ធិពល និងបន្ទាបខ្លួន ដែលបញ្ចេញពន្លឺនៃសេចក្ដីស្រឡាញ់។ ខ្ញុំជឿជាក់ថា នាងអាចនឹងចូលទៅក្នុងទី «អាថ៌កំបាំង» បាន



50 Crucial Questions.indd 105 7/4/26 2:18 in the afternoon

ជ្រាលជ្រៅជាងអ្នកដទៃទៅទៀត។[៤៧]

## សំណួរទី៤៩
## ដោយសារតែអ្នកប្រាជ្ញខាងឯដំណឹងល្អឈានមុខជាច្រើននាក់មិនយល់ស្របចំពោះសំណួរទាំងឡាយអំពីភាពជាបុរស និងភាពជាស្ត្រី នោះតើអ្នកជឿធម្មតាម្នាក់អាចសូម្បីតែសង្ឃឹមថានឹងមានការជឿជាក់យ៉ាងច្បាស់លាស់លើសំណួរទាំងនេះដោយរបៀបណាទៅ?

សេចក្តីកង្វល់ពីរយ៉ាងដែលជំរុញឲ្យយើងបង្កើតក្រុមប្រឹក្សាស្តីពីភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរឡើងគឺ៖ (១) «ការកើនឡើងនូវអត្រាការប្រើប្រាស់ និងការទទួលយកនូវការកាត់ស្រាយខុសពីប្រក្រតីដែលត្រូវបានរចនាឡើងដើម្បីបកស្រាយឡើងវិញនូវអត្ថន័យធម្មតានៃអត្ថបទព្រះគម្ពីរ» និង (២) «ការគម្រាមកំហែងជាបន្តបន្ទាប់ចំពោះព្រះគម្ពីរ។ សិទ្ធិអំណាច ដោយសារភាពច្បាស់លាស់នៃបទគម្ពីរគឺត្រូវបានបាត់បង់ ហើយលទ្ធភាពប្រើប្រាស់នៃអត្ថន័យរបស់វាសម្រាប់មនុស្សធម្មតាក្នុងការយល់ ដោយត្រូវបានកំណត់ចំពោះគំនិតដ៏ស្មុគស្មាញរបស់អ្នកជំនាញ»។[៤៨]

សិស្សដ៏មុតមាំរបស់ព្រះគម្ពីរត្រូវតែដើរក្នុងបន្ទាត់ដ៏ល្អដើម្បីជៀសវាងគ្រោះថ្នាក់ពីរ។ នៅផ្នែកម្ខាង គឺការធ្វើឲ្យសាមញ្ញជ្រុលនៃដំណើរការកាត់ស្រាយ ដែលធ្វេសប្រហែសចំពោះគោលការណ៍នៃការសិក្សាប្រវត្តិសាស្ត្រ និងវេយ្យាករណ៍។ ម្យ៉ាងទៀត គឺការល្បួងឲ្យដាក់ចំណាត់ថ្នាក់មកលើអ្នកជឿធម្មតា និងសង្កត់ធ្ងន់ទៅលើទិន្នន័យដែលមិនអាចចូលបាន និងបញ្ហាបរិបទស្មុគស្មាញ រហូតធ្វើឲ្យពួកគេអស់សង្ឃឹមក្នុងការយល់ដឹងប្រកបដោយទំនុកចិត្ត។ យើងដឹងថា «មានសេចក្តីខ្លះដែលពិបាកយល់ ហើយពួកអ្នកខ្លៅល្ងង់ និងពួកមិនខ្ជាប់ខ្ជួន គេបង្វែរន័យសេចក្តីទាំងនោះ ដូចជាគេបង្វែរបទគម្ពីរឯ

---

៤៧ លោកស្រី Elisabeth Elliot, “Virginity,” លោកស្រី Elisabeth Elliot Newsletter, ខែមីនា/មេសា ឆ្នាំ១៩៩០, ទំព័រ២-៣។

៤៨ សម្រង់សម្តីទាំងនេះដកស្រង់មកពី *Danvers Statement of the Council on Biblical Manhood and Womanhood.* សូមមើលឧបសម្ពន្ធ។



50 Crucial Questions.indd 106 7/4/26 2:18 in the afternoon

ទៀតដែរ [ក្នុងសំបុត្ររបស់សាវ័ក ប៉ុល]» (២ពេត្រុស ៣:១៦)។ ការទទួលស្គាល់នេះនឹងការពារយើងពីការធ្វើឲ្យព្រះគម្ពីរមានភាពសាមញ្ញហួសហេតុ។

ប៉ុន្តែ យើងជឿថា ការសង្កត់ធ្ងន់គួរតែធ្លាក់ទៅលើសារៈប្រយោជន៍នៃបទគម្ពីរទាំងអស់។ «គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត ដើម្បីឲ្យអ្នកសំណប់របស់ព្រះបានគ្រប់លក្ខណ៍ ហើយមានគ្រប់ទាំងចំណេះ សម្រាប់នឹងធ្វើការល្អគ្រប់មុខ» (២ធីម៉ូថេ ៣:១៦-១៧)។ យើងមិនចង់បំបាក់ទឹកចិត្តបុគ្គលមុតមាំណាមួយដោយគិតថា ប្រយោជន៍នៃបទគម្ពីរគឺហួសពីការឈោងចាប់នៃលទ្ធភាពរបស់គាត់។ យើងក៏ចង់សង្កត់ធ្ងន់ថា ក្រោមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ សាវ័ក ប៉ុល បានប្ដេជ្ញាចំពោះភាពច្បាស់លាស់ និងត្រង់ក្នុងការសរសេររបស់គាត់ថា «យើងខ្ញុំលះចោលអស់ទាំងការលាក់កំបាំងដែលគួរខ្មាស ឥតប្រព្រឹត្តដោយឧបាយកល ឬបំប្លែងព្រះបន្ទូលឡើយ គឺយើងខ្ញុំផ្ទុកផ្ដាក់ខ្លួន និងបញ្ញាចិត្តរបស់មនុស្សទាំងអស់ នៅចំពោះព្រះ ដោយសម្ដែងសេចក្ដីពិតវិញ» (២កូរិនថូស ៤:២)។

យើងក៏នឹងលើកទឹកចិត្តដល់មនុស្សទូទៅឲ្យមើលការចម្រូងចម្រាសលើបញ្ហាសំខាន់ៗ មិនត្រឹមតែជាភស្តុតាងនៃអំពើបាប និងភាពល្ងង់ខ្លៅរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាភស្តុតាងដែលបញ្ជាក់ថា ការពិតមានសារៈសំខាន់ ដែលសមនឹងឲ្យយើងប្រកាន់ខ្ជាប់ ហើយកំហុសដែលបង្គគ្រោះថ្នាក់នោះនឹងមិនកើតឡើងនៅថ្ងៃដែលមិនមានការប្រឆាំងនោះទេ។ សាវ័ក ប៉ុល បាននិយាយទៅកាន់ពួកកូរិនថូសថា «កាលណាអ្នករាល់គ្នាមូលមកក្នុងពួកជំនុំ នោះតែងមានការបែកខ្ញែកគ្នាទៅ ហើយខ្ញុំក៏បានជឿខ្លះដែរ ពីព្រោះត្រូវតែមានបក្សពួកក្នុងពួកអ្នករាល់គ្នា ដើម្បីឲ្យពួកខ្ជាប់ខ្ជួនបានសម្ដែងមកឲ្យស្គាល់ច្បាស់» (១កូរិនថូស ១១:១៨-១៩)។ យើងនៅឆ្ងាយពីការសង្ស័យអំពីជំហររបស់គ្រីស្ទបរិស័ទពិតប្រាកដរបស់ពួកអ្នកជឿបែបស្រ្តីនិយម។ ចំណុច



50 Crucial Questions.indd 107 7/4/26 2:18 in the afternoon

នៅទីនេះគឺថា ភាពចម្រូងចម្រាសគឺចាំបាច់ដែលការពិតសំខាន់ និងកំហុសធ្ងន់ធ្ងរកំពុងរីករាលដាល។ ដូច្នេះ អ្នកជឿទាំងឡាយត្រូវយល់ថាការតយុទ្ធសម្រាប់ប្រយោជន៍នៃសេចក្តីពិតតែងតែជៀសមិនផុតឡើយ។ ពួកគេគួរតែដឹងថា រឿងធម្មតាជាច្រើនដែលពួកគេស្ទើរតែទទួលយកដោយជំនឿរបស់ពួកគេនាពេលបច្ចុប្បន្ននេះ ធ្លាប់ជាជម្លោះយ៉ាងក្ដៅគគុក ហើយត្រូវបានរក្សាទុកសម្រាប់ពួកគេតាមរយៈភាពចម្រូងចម្រាសទាំងនោះ។

លើបញ្ហានៃភាពជាបុរស និងភាពជាស្ត្រីនេះ យើងលើកទឹកចិត្តអ្នកជឿទូទៅឲ្យពិចារណាអំពីអំណះអំណាងដែលមានសម្រាប់ពួកគេ គិតដោយខ្លួនឯង ផ្ចិតខ្លួនឯងនៅក្នុងបទគម្ពីរ ហើយអធិស្ឋានដោយអស់ពីចិត្តចំពោះអ្វីដែលសាវ័ក ប៉ុល បានសន្យានៅក្នុងកណ្ឌគម្ពីរ ភីលីព ៣:១៥ ថា “ដូច្នេះ យើងទាំងអស់គ្នាដែលគ្រប់លក្ខណ៍ហើយ យើងត្រូវមានគំនិតយ៉ាងនោះឯង តែបើអ្នករាល់គ្នាមានគំនិតណាផ្សេងក្នុងការអ្វី នោះព្រះទ្រង់នឹងសម្ដែងឲ្យអ្នករាល់គ្នាបានឃើញសេចក្ដីនេះដែរ”។ សម្រាប់ការណែនាំបន្ថែមនៅក្នុងដំណើរការនេះ យើងចង់ឲ្យលោកអ្នកមើលទៅកាន់អ្វីដែលបាននិយាយខាងលើនៅក្នុងសំណួរទី៤២ នៅក្នុងសៀវភៅ ការស្ដារឡើងវិញនូវភាពជាបុរស និងស្ត្រីស្របតាមព្រះគម្ពីរ ជំពូកទី២៦ ទំព័រ៤១៨-៤២០ ដែលជាកន្លែងដែលយើងពិភាក្សាអំពីការណែនាំរបស់ព្រះវិញ្ញាណនៅក្នុងបញ្ហានេះ។



50 Crucial Questions.indd 108 7/4/26 2:18 in the afternoon

## សំណួរទី៥០
## ប្រសិនបើអត្ថបទមួយក្រុមបង្កជម្លោះយ៉ាងក្តៅគគុក តើវាមិនមែនជាគោលការណ៍ដ៏ល្អទេឬនៅក្នុងការកាត់ស្រាយដែលមិនអនុញ្ញាតឲ្យពួកគេមានឥទ្ធិពលយ៉ាងសំខាន់លើទស្សនៈរបស់យើងចំពោះភាពជាបុរស និងស្ត្រី? ស្រដៀងគ្នានេះដែរ ដោយសារតែមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំងនៅក្នុងក្រុមជំនុំជុំវិញបញ្ហានៃតួនាទីបុរស និងស្ត្រី តើយើងមិនគួរចាត់ទុករឿងនេះថា វាមានសារៈសំខាន់តិចក្នុងការកំណត់ស្តង់ដារនៃជំនឿ និងការអនុវត្តរបស់ក្រុមនិកាយ ស្ថាប័ន និងក្រុមជំនុំទេឬ?

នៅពេលដែលដាក់អត្ថបទដែលមានជម្លោះទុកមួយឡែក វានឹងក្លាយជាគោលការណ៍មិនល្អក្នុងការកាត់ស្រាយនោះទេ។ ទីមួយ ស្ទើរតែគ្រប់អត្ថបទអំពីរឿងដែលមានតម្លៃ និងសំខាន់ទាំងអស់ត្រូវបានជំទាស់តាមមធ្យោបាយណាមួយ និងដោយពួកគ្រីស្ទបរិស័ទមួយចំនួន។ មិនដែលមានក្នុងប្រវត្តិសាស្ត្រទេ ដែលលទ្ធិពហុនិយមមានច្រើននៅក្រោមបដានៃព្រះគម្ពីរដូចសព្វថ្ងៃនេះ។ ទីពីរ សូមស្រមៃមើលថាតើវាមានន័យយ៉ាងដូចម្តេចប្រសិនបើយើងមិនប្រកាន់ជំហរលើរឿងទាំងនោះ ដោយសារតែវាមានជម្លោះ។ វានឹងធ្វើឲ្យគោលបំណងរបស់សាតាំងក្នុងការបំភាន់យើងកាន់តែងាយស្រួលឡើងហើយ។ សាតាំងមិនចាំបាច់ផ្តួលរំលំសេចក្តីពិតនៃអត្ថបទព្រះគម្ពីរទេ វាគ្រាន់តែបង្កើតការភាន់ច្រឡំល្មមដែលធ្វើឲ្យយើងនឹងទុករឿងសំខាន់នៅមួយឡែកសិន។ ទីបី ទុកសាតាំងចោលមួយភ្លែត យើងទាំងអស់គ្នាមានភាពលម្អៀង ហើយទំនងជានឹងប្រើគោលការណ៍នៃការកាត់ស្រាយនេះ ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃការធ្វេសប្រហែសទៅលើអត្ថបទដែលមិនសមស្របនឹងការលម្អៀងរបស់យើង ខណៈពេលដែលទទូចថា អ្វីដែលសមស្របនឹងភាពលម្អៀងរបស់យើងគឺច្បាស់លាស់ហើយ។

ការនេះ វាហាក់បីដូចជាពួកយើង គឺជាកែងជើងរបស់អាទិទេព អាឆីលស៍ (Achilles' heel) នៅក្នុងវិធីសាស្ត្រកាត់ស្រាយដែលធ្វើឡើងដោយលោក



50 Crucial Questions.indd 109 7/4/26 2:18 in the afternoon

ស្រី ហ្គ្រេតឆិន ហ្គេប៊ែលលេន ហ័ល (Gretchen Gaebelein Hull) នៅក្នុងសៀវភៅ «ស្មើភាពគ្នានៅក្នុងការបម្រើ» (Equal to Serve) របស់គាត់។ គាត់យកអត្ថបទមួយឈុតដែលមានលក្ខណៈច្បាស់លាស់ និងគ្មានជម្លោះ បន្ទាប់មកយកមួយឈុតទៀតមានលក្ខណៈមិនច្បាស់លាស់ និងមានការជជែកគ្នា រួចមានប្រសាសន៍ថា អត្ថបទដែលមិនច្បាស់លាស់មិនគួរមានការលើកឡើងសំខាន់ៗក្នុងការបង្កើតការយល់ដឹងរបស់យើងអំពីបញ្ហានោះទេ។ ជាពិសេស គាត់យកកណ្ឌគម្ពីរលោកុប្បត្តិ ជំពូក១-២ ជាឧទាហរណ៍នៃថ្នាក់ដឹកនាំស្ត្រី (ឧ. ដេបូរ៉ា, ហ៊ូលដា, ម៉ារាម, អប៊ីកែល ជាដើម) ការបម្រើរបស់ព្រះយេស៊ូវដល់ស្ត្រី គំរូនៃការបម្រើស្ត្រីក្នុងព្រះគម្ពីរសញ្ញាថ្មី បូកទាំងអត្ថបទនៅលើ ការប្រោសលោះសមភាពរបស់ស្ត្រី (ដូចជាកណ្ឌគម្ពីរ ២កូរិនថូស ៥:១៤-២១) ហើយគាត់ធ្វើការសន្និដ្ឋានថា កណ្ឌគម្ពីរទាំងនោះបង្រៀនយ៉ាងច្បាស់ថា ភាពជាអ្នកដឹកនាំរបស់បុរសនៅក្នុងទម្រង់ណាមួយប្លែកពីនេះមួយ គឺខុសហើយ។ ប៉ុន្តែ អត្ថបទទាំងអស់នៅក្នុងគម្ពីរសញ្ញាថ្មីដែលហាក់ដូចជាបង្រៀនពីភាពខុសគ្នានៃតួនាទីសំខាន់សម្រាប់ស្ត្រី និងបុរសដែលនាងនិយាយថា មានភាពស្រពេចស្រពិល នឹងមិនអាចរួមចំណែកដល់រូបរាងនៃទស្សនៈរបស់យើងអំពីភាពជាបុរស និងស្ត្រីបានទេ។ ក្នុងសម្ដីខាងក្រោមនេះ គាត់បានបង្ហាញពីវិធីសាស្ត្ររបស់គាត់ទាក់ទងនឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយបន្ទាប់មកយកវាមកអនុវត្តទៅលើបញ្ហាដែលមាននៅក្នុងដៃ៖

> អ្វីទាំងអស់ដែលខ្ញុំដឹងអំពីព្រះជាម្ចាស់បង្ហាញថា ទ្រង់ពិតជាសេចក្ដីស្រឡាញ់ ជាសេចក្ដីស្រឡាញ់ដែលទ្រង់បានយាងមកផ្ទាល់ ដើម្បីសុគតជំនួសខ្ញុំ។ ដូច្នេះ នៅពេលណាខ្ញុំអានព្រះគម្ពីរចំការជំនុំជម្រះក្នុងកណ្ឌគម្ពីរទំនុកតម្កើង ឬសង្គ្រាមជនជាតិកាណាន ខ្ញុំដាក់វាដោយឡែកនៅពេលនេះ។ ប៉ុន្តែ ខ្ញុំមិនបោះបង់ការពិតដែលគ្រប់គ្នាស្គាល់ថា «ព្រះជាតួនៃសេចក្ដីស្រឡាញ់» នោះទេ ដោយសារតែអត្ថបទខ្លះអំពីលក្ខណៈនៃព្រះបានធ្វើឲ្យខ្ញុំឆ្ងល់។ ដូច្នេះ យើងក៏គួរប្រព្រឹត្តទៅលើ «អត្ថបទព្រះគម្ពីរដ៏ពិបាក» ទាំងបីអំពីស្ត្រី [១កូរិនថូស ១១:២-១៦; ១៤:៣៣-៣៦;



50 Crucial Questions.indd 110 7/4/26 2:18 in the afternoon

> ១ធីម៉ូថេ ២:៨-១៥] ដែលយើងរកឃើញនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយដែលលេចចេញជាការដាក់កម្រិតជាក់លាក់ ចំពោះស្ត្រីតែប៉ុណ្ណោះ។ យើងអាចបន្ថែមនៅក្នុងកណ្ឌគម្ពីរ កូឡូស ៣:១៨; អេភេសូរ ៥:២២-២៤; ១ពេត្រុស ៣:១-៦....ដូច្នេះ យើងអាចដាក់ដោយស្របច្បាប់ផ្នែកខគម្ពីរមួយឡែកសម្រាប់ហេតុផលដែលថាពួកគេនៅតែជា “អត្ថបទព្រះគម្ពីរដ៏ពិបាកៗ”—ការពិនិត្យវិភាគដ៏ពិបាក ការកាត់ស្រាយអត្ថបទដ៏ពិបាក និងជាទេវសាស្ត្រដ៏ពិបាក។[៤៩]

តាមរបៀបនេះ អត្ថបទសំខាន់ៗត្រូវបានបំបិទដោយប្រធានបទគ្រប់គ្រងនៃ “ការខ្វាក់ចំពោះតួនាទីភេទ” ស្មើភាពគ្នា ដែលត្រូវបានបង្កើតឡើងដោយឯកឯងផ្ទាល់នៅលើអត្ថបទដែលមានជម្លោះ។ នេះបង្ហាញពីគ្រោះថ្នាក់នៃគោលការណ៍ដែលនិយាយថា ប្រសិនបើអត្ថបទនាំឲ្យមានជម្លោះ សូមកុំប្រើប្រាស់វា។ ផ្ទុយទៅវិញ នីតិវិធីរបស់យើងគួរតែធ្វើ ដើម្បីបន្តអានបទគម្ពីរដោយប្រុងប្រយ័ត្ន និងដោយការអធិស្ឋាន ដោយស្វែងរកកន្លែងដែលមិនច្រានចោលអត្ថបទ ប៉ុន្តែបកស្រាយអត្ថបទដែលពាក់ព័ន្ធទាំងអស់នៃបទគម្ពីរតាមរបៀបដែលស៊ីសង្វាក់គ្នា។ ហើយបន្ទាប់មក យើងត្រូវគោរពតាមការបង្រៀនដែលជាប់លាប់នោះ។

ឥឡូវនេះ ចំពោះបញ្ហានៃ “ការខ្វែងគំនិតគ្នាយ៉ាងសំខាន់នៅក្នុងក្រុមជំនុំលើបញ្ហានៃតួនាទីរបស់បុរស និងស្ត្រី” យើងត្រូវដឹងជាមុនថា ការខ្វែងគំនិតគ្នាដែលគួរឲ្យកត់សម្គាល់នេះនៅក្នុងក្រុមជំនុំមិនមានន័យថា បញ្ហានៅក្នុងក្រុមជំនុំមិនសំខាន់នោះទេ។ ប្រវត្តិនៃភាពចម្រូងចម្រាសខាងគោលលទ្ធិបង្រៀនយើងថា បញ្ហាសំខាន់ៗ (ក៏ដូចជារឿងដែលមិនសូវសំខាន់) គឺជាប្រធានបទនៃជម្លោះដ៏ធ្ងន់ធ្ងរ។ តាមពិតទៅ រយៈពេល និងភាពធ្ងន់ធ្ងរនៃជម្លោះអាចជាភស្តុតាងនៃសារៈសំខាន់នៃបញ្ហា មិនមែនភាពមិនសំខាន់របស់វានោះទេ។

ប្រសិនបើយើងពិនិត្យមើលបញ្ជីបទដ្ឋានដែលរំពឹងទុកសម្រាប់ការតែង

---

៤៩ លោក Gretchen Gaebelein Hull, *Equal to Serve: Men and Women in the Church and Home* (Old Tappan, NJ: Fleming H. Revell, ឆ្នាំ១៩៨៧), ទំព័រ១៨៨-៨៩។



50 Crucial Questions.indd 111 7/4/26 2:18 in the afternoon

តាំង ស្ថាប័ននានា និងក្រុមជំនុំភាគច្រើន យើងរកឃើញថាអត្ថបទមួយចំនួន (ប្រហែលជាភាគច្រើន) ត្រូវបានរួមបញ្ចូល ពីព្រោះភាពចម្រូងចម្រាសបានវិលជុំវិញការពិតនោះ ហើយជំហរចាំបាច់ត្រូវតែធ្វើឡើង ដើម្បីសុខភាពក្រុមជំនុំ និងបុព្វហេតុនៃក្រុមជំនុំរបស់ព្រះគ្រីស្ទ។ នេះមានន័យថា សេចក្តីពិតដ៏មានតម្លៃជាច្រើន ប្រហែលជាមិនត្រូវបានរាប់បញ្ចូលក្នុងបទដ្ឋានគោលលទ្ធិ និងសីលធម៌របស់យើង នៅចំណុចណាមួយក្នុងប្រវត្តិសាស្ត្រទេ ពីព្រោះពួកវាត្រូវបានទទួលយកដោយសាមញ្ញ ដោយគ្មានភាពចម្រូងចម្រាស។ ឧទាហរណ៍៖ រហូតមកដល់ពេលថ្មីៗនេះ បទដ្ឋានជាទូទៅមិនទាន់បានរួមបញ្ចូលសេចក្តីថ្លែងការណ៍ច្បាស់លាស់អំពីការអនុវត្តការស្រឡាញ់ភេទដូចគ្នា ឬប្រភេទមួយចំនួននៃការប្រើប្រាស់គ្រឿងញៀននៅឡើយទេ។

និកាយ ស្ថាប័ន និងក្រុមជំនុំគ្រីស្ទបរិស័ទភាគច្រើនបានទទួលយកការទទួលខុសត្រូវចម្បងរបស់ស្វាមីតាំងពីយូរយារណាស់មកហើយក្នុងការដឹកនាំគ្រួសាររបស់គាត់ និងការទទួលខុសត្រូវចម្បងរបស់បុរសខាងឯវិញ្ញាណក្នុងការដឹកនាំក្រុមជំនុំ។ ដូច្នេះ សេចក្តីពិតក្នុងព្រះគម្ពីរទាំងនេះមិនបានទទួលសេចក្តីថ្លែងការណ៍ច្បាស់លាស់នៅក្នុងស្តង់ដារជាផ្លូវការនោះទេ។ អវត្តមាននៃសេចក្តីពិតទាំងនោះគឺជាសញ្ញាមួយដែលថាវាមិនសូវជារឿងសំខាន់នោះទេ ប៉ុន្តែ (ស្ទើរតែផ្ទុយស្រឡះ) នៃតម្លៃដ៏ជ្រាលជ្រៅ រីករាលដាល និងយូរអង្វែងរបស់ពួកគេនៅក្នុងសហគមន៍គ្រីស្ទបរិស័ទ។ ដូច្នេះ យើងមានស្ថានភាពមិនប្រក្រតីនាពេលបច្ចុប្បន្ននេះ ដែលការអះអាងពីស្ថាប័ននៃជំនឿ និងការអនុវត្តរួមមានរឿងមួយចំនួនដែលមិនសូវសំខាន់ យើងជឿជាក់ជាងអ្វីដែលពាក់ព័ន្ធក្នុងបញ្ហានេះ។ ជាឧទាហរណ៍៖ យើងអាចនិយាយបានថាបញ្ហានៃការធ្វើពិធីបុណ្យជ្រមុជទឹកឲ្យទារកធៀបនឹងពិធីបុណ្យជ្រមុជទឹកឲ្យអ្នកជឿ បុរេសហស្សវត្សនិយម (premillennialism) និងគោលនយោបាយក្រុមជំនុំព្រេសប៊ីធើរាន (presbyterian) ឬក្រុមជំនុំគ្រួត្រួតត្រា (congregational) ឬក៏ក្រុមជំនុំអង់គ្លីខិន (episcopal) គឺមិនសូវមានការគម្រាម



50 Crucial Questions.indd 112 7/4/26 2:18 in the afternoon

កំហែងដល់សុខភាព និងបេសកកម្មរបស់ក្រុមជំនុំជាជាងសំណួរអំពីតួនាទីយេនឌ័រនោះទេ។

ជាងនេះទៅទៀត ការមិនប្រកាន់ជំហរលើបញ្ហានេះនៅក្នុងវប្បធម៌របស់យើង គឺត្រូវប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់បំផុត ដោយសារតែសម្ពាធមិនឈប់ឈរសម្រាប់ការផ្លាស់ប្តូរដែលស្រ្តីនិយមកំពុងអនុវត្តលើភាគីជាច្រើន។ ការតស៊ូមតិជាសាធារណៈលើបញ្ហានេះនាំឲ្យមានការរិះគន់យ៉ាងខ្លាំងដែលអ្នកដឹកនាំគ្រីស្ទបរិស័ទជាច្រើនព្យាយាមជៀសវាងវា។ ប៉ុន្តែ គ្មានផ្លូវណាអាចជៀសវាងវាបានឡើយ។ វាជាបញ្ហាដ៏ធំដែលឈានទៅដល់ជម្រៅដែលថាតើយើងជាមនុស្សបែបណា ដូច្នេះហើយបានជាវាប៉ះពាល់ដល់ជីវិតទាំងអស់គ្នា។ ដំបូន្មានរបស់យើងនៅទីនេះ គឺមិនមែនដើម្បីកំណត់យុទ្ធសាស្រ្តជាក់លាក់មួយ ដើម្បីរក្សាអំណោយទានរបស់ព្រះសម្រាប់ការបំពេញបន្ថែមគ្នា ខាងផ្លូវភេទនោះទេ។ ផ្ទុយទៅវិញ យើងគ្រាន់តែអង្វរដល់អ្នកដឹកនាំគ្រីស្ទបរិស័ទឲ្យភ្ញាក់ដឹងខ្លួនអំពីសារៈសំខាន់នៃអ្វីដែលកំពុងពិភាក្សា ហើយស្វែងរកប្រាជ្ញាស្ថានសួគ៌ពីរបៀបធ្វើសកម្មភាព ដើម្បីភាពល្អនៃក្រុមជំនុំ និងសិរីល្អរបស់ព្រះជាម្ចាស់។

50 Crucial Questions.indd 114 7/4/26 2:18 in the afternoon

# សេចក្ដីបន្ថែម

*សេចក្ដីថ្លែងការណ៍ទីក្រុងដែនវើរស័ស្ដីពីភាព*

*ជាស្ដ្រី និងភាពជាបុរសស្របតាមព្រះគម្ពីរ*

ខែធ្នូ ឆ្នាំ ១៩៨៧ ក្រុមប្រឹក្សា ដែលទើបបង្កើតថ្មីស្ដីពីភាពជាបុរស និងភាពជាស្ដ្រីស្របតាមព្រះគម្ពីរបាន ជួបប្រជុំគ្នានៅទីក្រុងដែនវើរស័ រដ្ឋម៉ាសាឈូសេត ហើយបានសរសេរសេចក្ដីថ្លែងការណ៍នៅទីក្រុងដែនវើរស័។ អត្ថបទទាំងស្រុងនៃសេចក្ដីថ្លែងការណ៍នោះមានដូចខាងក្រោម៖

## ១. ហេតុផល

យើងបានផ្លាស់ប្ដូរគោលបំណងរបស់យើងដោយការវិវត្តន៍សហសម័យដូចខាងក្រោម ដែលយើងសង្កេតឃើញដោយមានក្ដីបារម្ភយ៉ាងខ្លាំង៖

១. ការរីករាលដាលដែលមិនច្បាស់លាស់ និងច្របូកច្របល់ ដែលរីករាលដាលនៅក្នុងវប្បធម៌របស់យើងទាក់ទងនឹងភាពខុសគ្នានៃការបំពេញបន្ថែមឲ្យគ្នារវាងភាពជាបុរស និងភាពជាស្ដ្រី។

២. សោកនាដកម្មនៃការភាន់ច្រឡំក្នុងការស្រាយបំភ្លឺក្នុងអាពាហ៍ពិពាហ៍ដ៏ស្រស់ស្អាត និងភាពខុសគ្នានៃភាពជាបុរស និងភាពជាស្ដ្រីដែលព្រះជាម្ចាស់បានរៀបចំឡើង។



50 Crucial Questions.indd 115 7/4/26 2:18 in the afternoon

៣. ការកើនឡើងនៃការលើកកម្ពស់សមភាពនៃអ្នកស្រ្តីនិយម ជាមួយនឹងការបង្ខូច និងការធ្វេសប្រហែសចំពោះភាពសុខដុមរមនានៅក្នុងបទគម្ពីរ រវាងការដឹកនាំប្រកបដោយសេចក្ដីស្រឡាញ់ និងដោយបន្ទាបខ្លួនរបស់ប្ដីដែលជាអ្នកជឿ និងការដឹកនាំដ៏ឆ្លាតវៃ និងការគាំទ្រចេញពីឆន្ទៈរបស់ប្រពន្ធដែលជាអ្នកជឿនោះ។
៤. ការកើនឡើងនៃភាពមិនច្បាស់លាស់ទាក់ទងនឹងគុណតម្លៃនៃភាពជាម្ដាយ ការធ្វើការងារនៅផ្ទះ និងព័ន្ធកិច្ចជាច្រើនដែលស្ត្រីធ្វើនៅក្នុងប្រវត្តិសាស្ត្រ។
៥. ការអះអាងកាន់តែច្រើនឡើងអំពីភាពស្របច្បាប់សម្រាប់ទំនាក់ទំនងផ្លូវភេទដែលព្រះគម្ពីរ ហើយតាំងពីបុរាណរៀងមកចាត់ទុកថា មិនត្រឹមត្រូវ ឬទទួលយកមិនបាន និងការកើនឡើងនៃរូបភាពអាសអាភាសដែលបង្ហាញរូបភាពសកម្មភាពផ្លូវភេទរបស់មនុស្ស។
៦. ការកើនឡើងនៃការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្តនៅក្នុងក្រុមគ្រួសារ។
៧. ការផុសចេញនូវក្នុងដឹកនាំក្រុមជំនុំសម្រាប់បុរស និងស្ត្រី ដែលងាកចេញពីការបង្រៀនរបស់ព្រះគម្ពីរ ប៉ុន្តែមានប្រតិកម្មត្រឡប់មកវិញចំពោះការបាត់បង់ទីបន្ទាល់ដ៏ស្មោះត្រង់ស្របតាមព្រះគម្ពីរចេញ។
៨. ការកើនឡើងនូវទំនោរ និងការទទួលយកនូវការកាត់ស្រាយដ៏ចម្លែកដែលបានរៀបចំឡើង ដើម្បីកាត់ស្រាយឡើងវិញនូវអត្ថន័យធម្មតាជាក់ស្ដែងនៃអត្ថបទព្រះគម្ពីរ។
៩. លទ្ធផលគម្រាមកំហែងចំពោះសិទ្ធិអំណាចស្របតាមព្រះគម្ពីរ ដូចដែលភាពច្បាស់លាស់នៃបទគម្ពីរត្រូវបានបង្ខូច ហើយលទ្ធភាពប្រើប្រាស់នៃអត្ថន័យរបស់ព្រះបន្ទូលនោះចំពោះមនុស្សសាមញ្ញបានដកចេញទៅក្នុងស្ថានដែលមានការរឹតត្បិតនៃភាពប៉ិនប្រសប់ផ្នែកបច្ចេកទេស។
១០. ហើយនៅពីក្រោយការទាំងអស់នេះ ការស្នាក់នៅជាក់ស្ដែងរបស់មនុស្សមួយចំនួនជាមួយនឹងក្រុមជំនុំចំពោះវិញ្ញាណនៃយុគសម័យដោយចំណាយនៃភាពត្រឹមត្រូវនៃព្រះគម្ពីរដ៏វិសេសវិសាល និងការ



50 Crucial Questions.indd 116 7/4/26 2:18 in the afternoon

ផ្លាស់ប្តូរយ៉ាងទូលំទូលាយដ៏ពិតប្រាកដស្របតាមព្រះគម្ពីរ ដែលនៅក្នុងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធអាចធ្វើកំណែទម្រង់ជាជាងឆ្លុះបញ្ចាំងពីវប្បធម៌ទន់ខ្សោយរបស់យើង។

## ២. សេចក្តីបញ្ជាក់

យោងទៅតាមការយល់ដឹងស្តីពីការបង្រៀនស្របតាមព្រះគម្ពីរ យើងអាចបញ្ជាក់ដូចខាងក្រោម៖

១. ទាំងលោក អ័ដាម និងនាង អេវ៉ា បានបង្កើតមកនៅក្នុងរូបអង្គនៃព្រះជាម្ចាស់ជាមនុស្សដោយមានភាពស្មើគ្នា និងមានលក្ខណៈខុសពីគ្នាក្នុងភាពជាបុរស និងភាពជាស្ត្រីនៅចំពោះព្រះជាម្ចាស់ (លោកុប្បត្តិ ១:២-២៧; ២:១៨)។

២. ភាពខុសគ្នាក្នុងតួនាទីជាបុរស និងជាស្ត្រីត្រូវបានតែងតាំងដោយព្រះជាម្ចាស់ជាផ្នែកមួយនៃលំដាប់លំដោយនៃការបង្កើត ហើយគួរតែរកសំឡេងបន្ទរនៅគ្រប់ទាំងដួងចិត្តរបស់មនុស្សជាតិ (លោកុប្បត្តិ ២:១៨, ២១-២៤; ១កូរិនថូស ១១:៧-៩; ១ធីម៉ូថេ ២:១២-១៤)។

៣. ភាពជាអ្នកដឹកនាំរបស់លោក អ័ដាម នៅក្នុងអាពាហ៍ពិពាហ៍បានតាំងឡើងដោយព្រះជាម្ចាស់មុនការធ្លាក់ក្នុងអំពើបាបរបស់មនុស្សជាតិ ហើយមិនមែនកើតឡើងដោយសារអំពើបាបនោះទេ (លោកុប្បត្តិ ២:១៦-១៨, ២១-២៤; ៣:១-១៣; ១កូរិនថូស ១១:៧-៩)។

៤. ការធ្លាក់ក្នុងអំពើបាបបាននាំឲ្យមានការបំផ្លាញនៅក្នុងទំនាក់ទំនងរវាងបុរស និងស្ត្រី (លោកុប្បត្តិ ៣:១-៧, ១២, ១៦)។ នៅក្នុងផ្ទះសេចក្តីស្រឡាញ់ ការដឹកនាំដោយបន្ទាបខ្លួនរបស់ប្តីៗមាននិន្នាការជំនួសដោយការត្រួតត្រា ឬអសកម្ម ហើយប្រាជ្ញា និងការសុខចិត្តចុះចូលរបស់ប្រពន្ធមាននិន្នាការជំនួសដោយការកាន់កាប់ និងការបម្រើ។ អំពើបាបធ្វើឲ្យបុរសៗមានទំនោរស្រឡាញ់អំណាចដូចខាងលោកីយ៍ ឬការបោះបង់ទំនួលខុសត្រូវខាងឯវិញ្ញាណចោល ហើយជំរុញស្ត្រីឲ្យទប់ទល់នឹងដែនកំណត់នៃលើតួនាទីរបស់ពួកគេដែល



50 Crucial Questions.indd 117 7/4/26 2:19 in the afternoon

ព្រះគាប់ព្រះទ័យ ឬមិនអើពើនឹងការប្រើប្រាស់អំណោយទានរបស់ពួកគេនៅក្នុងការបម្រើព័ន្ធកិច្ចដែលសមស្របនៅក្នុងក្រុមជំនុំ។

៥. ទាំងព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីបានបង្ហាញពីតម្លៃ និងសេចក្តីថ្លៃថ្នូរដ៏ខ្ពង់ខ្ពស់ដូចគ្នា ដែលព្រះបានភ្ជាប់ជាមួយនឹងតួនាទីទាំងបុរស និងស្ត្រី (លោកុប្បត្តិ ១:២៦-២៧; ២:១៨; កាឡាទី ៣:២៨)។ ទាំងព្រះគម្ពីរសញ្ញាចាស់ និងព្រះគម្ពីរសញ្ញាថ្មីក៏បញ្ជាក់ពីគោលការណ៍នៃភាពជាបុរសនៅក្នុងគ្រួសារ និងនៅក្នុងសហគមន៍នៃសេចក្តីសញ្ញាផងដែរ (លោកុប្បត្តិ ២:១៨; អេភេសូរ ៥:២១-៣៣; កូឡូស ៣:១៨-១៩; ១ធីម៉ូថេ ២:១១-១៥)។

៦. ការប្រោសលោះនៅក្នុងព្រះគ្រីស្ទមានគោលបំណងលុបបំបាត់ការបំផ្លាញនាំមកដោយបណ្តាសា។ នៅក្នុងគ្រួសារ ពួកប្តីៗគួរតែលះចោលភាពគ្រោតគ្រាត ឬការដឹកនាំដោយអាត្មានិយមចោល រីកចម្រើនក្នុងសេចក្តីស្រឡាញ់ ហើយមើលថែពួកប្រពន្ធៗរបស់ពួកគេ ពួកប្រពន្ធៗគួរតែលះចោលការតតាំងនឹងអំណាចរបស់ប្តីៗរបស់ពួកគេ ហើយរីកចម្រើនក្នុងការស្ម័គ្រចិត្តចុះចូលដោយអំណរចំពោះការដឹកនាំរបស់ពួកប្តីៗរបស់ខ្លួន (អេភេសូរ ៥:២១; កូឡូស ៣:១៨-១៩; ទីតុស ២:៣-៥; ១ពេត្រុស ៣:១-៧)។ នៅក្នុងក្រុមជំនុំ ការប្រោសលោះក្នុងព្រះគ្រីស្ទផ្តល់ឲ្យបុរស និងស្ត្រីនូវចំណែកព្រះពរនៃការសង្គ្រោះស្មើៗគ្នា ទោះបីជាយ៉ាងណាតួនាទីក្នុងការគ្រប់គ្រង និងការបង្រៀនមួយចំនួននៅក្នុងក្រុមជំនុំត្រូវបានប្រគល់ទៅឲ្យពួកបុរសៗ (កាឡាទី ៣:២៨; ១កូរិនថូស ១១:២-១៦; ១ធីម៉ូថេ ២:១១-១៥)។

៧. គ្រប់ផ្នែកនៃជីវិតទាំងអស់ ព្រះគ្រីស្ទមានសិទ្ធិអំណាចខ្ពង់ខ្ពស់បំផុត និងជាមគ្គុទ្ទេសក៍សម្រាប់ទាំងបុរស និងស្ត្រី ដើម្បីកុំឲ្យមានសិទ្ធិអំណាចរបស់មនុស្សណាម្នាក់ ការចុះចូលតាមលោកីយ៍ទាំងក្នុងស្រុក សាសនា ឬស៊ីវិល ដែលមិនធ្លាប់មានចែងពីអាណត្តិ ដើម្បីធ្វើតាមអំណាចរបស់មនុស្សចូលទៅក្នុងអំពើបាប (ដានីយ៉ែល ៣:១០-១៨; កិច្ចការ ៤:១៩-២០; ៥:២៧-២៩; ១ពេត្រុស ៣:១-២)។



50 Crucial Questions.indd 118 7/4/26 2:19 in the afternoon

៨. យើងមិនគួរយកការត្រាស់ហៅឲ្យមនុស្សប្រុស និងស្ត្រីទៅបម្រើព័ន្ធកិច្ចជាគោលជំនួសលក្ខណៈវិនិច្ឆ័យស្របតាមព្រះគម្ពីរសម្រាប់ព័ន្ធកិច្ចជាក់លាក់ណាមួយឡើយ (១ធីម៉ូថេ ២:១១-១៥; ៣:១-១៣; ទីតុស ១:៥-៩)។ ផ្ទុយទៅវិញ ការបង្រៀនស្របតាមព្រះគម្ពីរគួរតែជាសិទ្ធិអំណាចសម្រាប់ការសាកល្បងការយល់ដឹងផ្ទាល់ខ្លួនអំពីព្រះហឫទ័យរបស់ព្រះ។

៩. ពាក់កណ្ដាលនៃចំនួនប្រជាជនពិភពលោក ដែលមិនទាន់បានឮដំណឹងល្អជាមួយមានមនុស្សរាប់មិនអស់ផ្សេងទៀតបានវង្វេងសូម្បីតែពួកគេបានឮដំណឹងល្អរួចហើយក្ដី ដោយភាពតានតឹង និងទុក្ខវេទនានៃជម្ងឺ កង្វះអាហារូបត្ថម្ភ ការគ្មានផ្ទះសម្បែង អក្ខរកម្ម ភាពល្ងង់ខ្លៅ ភាពចាស់ជរា ការញៀន ឧក្រិដ្ឋកម្ម ការជាប់ឃុំឃាំង ជម្ងឺសរសៃប្រសាទ និងភាពឯកោ គ្មានបុរស ឬស្ត្រីណាដែលមានអារម្មណ៍ទទួលបានចិត្តឆេះឆួលពីព្រះ ដើម្បីបង្ហាញព្រះគុណទ្រង់ឲ្យគេស្គាល់ដោយពាក្យសម្ដី ទង្វើ និងការរស់នៅដោយមិនបំពេញកិច្ចបម្រើ ដើម្បីថ្វាយសិរីល្អដល់ព្រះគ្រីស្ទ និងបានជាប្រយោជន៍ដល់លោកីយ៍ដែលធ្លាក់ក្នុងអំពើបាបនេះឡើយ (១កូរិនថូស ១២:៧-២១)។

១០. យើងជឿជាក់ថា ការបដិសេធ ឬការធ្វេសប្រហែសចំពោះគោលការណ៍ទាំងនេះនឹងនាំទៅរកការបំផ្លិចបំផ្លាញនៅក្នុងក្រុមគ្រួសារ ក្រុមជំនុំរបស់យើង និងវប្បធម៌ទាំងមូលយ៉ាងខ្លាំង។

យើងផ្ដល់ការអនុញ្ញាត និងលើកទឹកចិត្តដល់អ្នកចាប់អារម្មណ៍ឲ្យប្រើប្រាស់ និងចែកចាយសេចក្ដីថ្លែងការណ៍ទីក្រុងដែនវើរស៍ ដោយឥតគិតថ្លៃ។ សម្រាប់ច្បាប់ចម្លងនៃសេចក្ដីថ្លែងការណ៍ទីក្រុងដែនវើរស៍ សូមចូលទៅកាន់គេហទំព័រ៖ cbmw.org



50 Crucial Questions.indd 119 7/4/26 2:19 in the afternoon

# កំណត់ចំណាំ

## សេចក្តីផ្តើម៖ ការជួយបំពេញបន្ថែម

១. លោក Larry Crabb, *Men and Women, Enjoying the Difference* (Grand Rapids, MI: Zondervan, ឆ្នាំ១៩៩១), ទំព័រ១៧៤។

២. លោក Charles W. Colson, "What Can Gender Blending Render?" World ៥ (ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៩១)៖ ១១។

៣. សូមមើលបន្ថែមលោក Wayne Grudem, *Evangelical Feminism and Biblical Truth: An Analysis of Over 100 Disputed Questions* (Sisters, OR: Multnomah, ឆ្នាំ២០០៤; Wheaton, IL: Crossway, ឆ្នាំ២០១២); Wayne Grudem, *Evangelical Feminism: A New Path to Liberalism?* (Wheaton, IL: Crossway, ឆ្នាំ២០០៦); និងលោក John Piper, *What's the Difference? Manhood and Womanhood Defined According to the Bible* (Wheaton, IL: Crossway, ឆ្នាំ១៩៩០).

## សំណួរសំខាន់ៗ៥០

១. "Mission & Vision," *The Council on Biblical Manhood and Womanhood*, បានមើលនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥ http://cbmw.org/mission-vision/.



50 Crucial Questions.indd 121 7/4/26 2:19 in the afternoon

២. លោក John Piper និងលោក Wayne Grudem, បានកែសម្រួល, *Recovering Biblical Manhood and Womanhood: A Response to Evangelical Feminism* (Wheaton, IL: Cross- way, ឆ្នាំ១៩៩១)។ ចំណងជើងនេះក៏បានចេញផ្សាយនៅឆ្នាំ២០០៦ជាមួយនឹងបុព្វកថាថ្មីដោយ៖ លោក J. Ligon Duncan និង Randy Stinson.

៣. នេះរាប់បញ្ចូលទាំងគំរូដែលកើតចេញពីការព្រងើយកន្តើយ និងការបំពានដោយទាំងប្ដី និងប្រពន្ធ។ ដូចដែលសេចក្ដីថ្លែងការណ៍នៃទីក្រុងដែនវើរស៍បានថ្លែងថា៖ «នៅក្នុងផ្ទះ សេចក្ដីស្រឡាញ់ ការដឹកនាំដ៏បន្ទាបខ្លួនរបស់ប្ដីមានទំនោរជំនួសឲ្យការត្រួតត្រា ឬអសកម្ម។ ការចុះចូលដោយដ៏ឆ្លាតវៃ មានឆន្ទៈរបស់ប្រពន្ធមានទំនោរជំនួសឲ្យការដណ្ដើមយកអំណាច ឬបម្រើ»។ គោលបំណងរបស់យើង គឺធ្វើការចេញពីភាគីទាំងសងខាង ដើម្បីលើកកម្ពស់ទំនាក់ទំនងដែលព្រះគ្រីស្ទពិតជាគាប់ព្រះទ័យឲ្យយើងមានចំពោះក្រុមជំនុំ។

៤. ទស្សនៈពីរនៃកណ្ឌគម្ពីរ អេភេសូរ ៥:២១ គឺស៊ីគ្នានឹងទស្សនៈនៃសៀវភៅនេះ។ ទស្សនៈមួយគឺ ខគម្ពីរបង្រៀន «ការចុះចូលគ្នាទៅវិញទៅមក» របស់គ្រីស្ទបរិស័ទទាំងអស់ចំពោះគ្នាទៅវិញទៅមក ហើយ ២២-៣៣ បង្រៀនប្រភេទនៃការចុះចូលជាក់លាក់។ ការកាត់ស្រាយនេះ គឺស្របនឹងការបង្រៀនខាងក្រមសីលធម៌ទូទៅនៃបទគម្ពីរ ព្រោះវាត្រឹមត្រូវក្នុងការនិយាយថា យើងគួរតែ «ចុះចូលគ្នាទៅវិញទៅមក» ក្នុងន័យនៃការប្រព្រឹត្តដោយក្ដីស្រឡាញ់ ការគិតគូរ និងការលះបង់ចំពោះគ្នាទៅវិញទៅមក។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃកិច្ចព្រមព្រៀងក្នុងចំណោមអ្នកបំពេញគ្នាទៅវិញទៅមក (ដូចដែលបានលើកជាឧទាហរណ៍ នៅក្នុងភាគដែលបានកែសម្រួលដែលធំជាងនេះរបស់យើងនៅក្នុងសៀវភៅ ការស្ដារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ) មានកន្លែងសម្រាប់ការកាត់ស្រាយមួយផ្សេងទៀតនៃកណ្ឌគម្ពីរ អេភេសូរ ៥:២១ ខគម្ពីរនោះមិនបានបង្រៀនអំពី «ការចុះចូលគ្នាទៅវិញទៅមក» ទាល់តែសោះ ប៉ុន្តែ



50 Crucial Questions.indd 122 7/4/26 2:19 in the afternoon

បង្រៀនថា យើងទាំងអស់គ្នាគួរតែចុះចូលនឹងអ្នកដែលព្រះជាម្ចាស់បានដាក់ឲ្យមានអំណាចលើយើងដូចជាប្តី ឪពុកម្តាយ ឬនិយោជក (៥:២២; ៦:១, ៥)។ កណ្ឌគម្ពីរ អេភេសូរ ៥:២១ នឹងត្រូវបានកាត់ស្រាយថា៖ «ការចុះចូលនឹងគ្នាទៅវិញទៅមក (នោះគឺ អ្នកផ្សេងទៀត) ដោយការកោតខ្លាចដល់ព្រះគ្រីស្ទ»។ អំណះអំណាងចម្បងសម្រាប់ទិដ្ឋភាពជំនួសនេះ គឺពាក្យក្រិក អ៊ីប៉ូតាសូ (hypotasso «ចុះចូល»។ ទោះបីជាមនុស្សជាច្រើនបានអះអាងថា ពាក្យនេះអាចមានន័យថា «មានគំនិត និងចេះគិតគូរ ប្រព្រឹត្តដោយសេចក្តីស្រឡាញ់» (ចំពោះអ្នកដទៃ) វាជាការសង្ស័យដែលអ្នកនិយាយភាសាក្រិកនៅសតវត្សរ៍ទី១នឹងយល់វាតាមរបៀបនោះ ដ្បិតពាក្យនេះតែងតែបង្កប់ន័យទំនាក់ទំនងនៃការចុះចូលចំពោះសិទ្ធិអំណាច។ ពាក្យនេះត្រូវបានប្រើនៅកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីអំពីការចុះចូលរបស់ព្រះយេស៊ូវចំពោះសិទ្ធិអំណាចរបស់ឪពុកម្តាយខាងសាច់ឈាមរបស់ទ្រង់ (លូកា ២:៥១) អំពីពួកអារក្សដែលចុះចូលនឹងពួកសាវ័ក (លូកា ១០:១៧—ច្បាស់ណាស់ថា អត្ថន័យ «ចេះគិតគូរ និងប្រព្រឹត្តដោយសេចក្តីស្រឡាញ់» មិនសមនឹងនៅទីនេះទេ) អំពីប្រជារាស្ត្រដែលចុះចូលនឹងអំណាចរបស់រដ្ឋាភិបាល (រ៉ូម ១៣:១, ៥; ទីតុស ៣:១; ១ពេត្រុស ២:១៣) អំពីចក្រវាឡដែលចុះចូលនឹងព្រះគ្រីស្ទ (១កូរិនថូស ១៥:២៧; អេភេសូរ ១:២២) អំពីអំណាចខាងឯវិញ្ញាណដែលមើលមិនឃើញចុះចូលនៅក្រោមអំណាចរបស់ព្រះគ្រីស្ទ (១ពេត្រុស ៣:២២) អំពីព្រះគ្រីស្ទដែលចុះចូលនឹងព្រះវរបិតា (១កូរិនថូស ១៥:២៨) អំពីសមាជិកក្រុមជំនុំដែលចុះចូលនឹងថ្នាក់ដឹកនាំក្រុមជំនុំ (១កូរិនថូស ១៦:១៥-១៦ [ជាមួយ ១ក្លេមិន ៤២:៤ (1Clement 42:4)]; ១ពេត្រុស ៥:៥) អំពីប្រពន្ធដែលចុះចូលនឹងប្តី (កូឡុស ៣:១៨; ទីតុស ២:៥; ១ពេត្រុស. ៣:៥; អេភេសូរ ៥:២២, ២៤) អំពីក្រុមជំនុំចុះចូលនឹងព្រះគ្រីស្ទ (អេភេសូរ ៥:២៤) អំពីអ្នកបម្រើដែលចុះចូលនឹងចៅហ្វាយរបស់ពួកគេ (ទីតុស ២:៩; ១ពេត្រុស ២:១៨) និងអំពីគ្រីស្ទបរិស័ទដែលចុះចូលនឹងព្រះជា



50 Crucial Questions.indd 123 7/4/26 2:19 in the afternoon

ម្ចាស់ (ហេព្រើរ ១២:៩; យ៉ាកុប ៤:៧)។ គ្មានទំនាក់ទំនងណាមួយក្នុងចំណោមទំនាក់ទំនងទាំងនេះត្រូវបានបញ្ច្រាសត្រឡប់មកវិញឡើយ។ នោះគឺ ស្វាមីមិនដែលប្រាប់ឲ្យចុះចូលនឹងភរិយា រដ្ឋាភិបាលមិនដែលប្រាប់ឲ្យចុះចូលចំពោះប្រជាពលរដ្ឋ ចៅហ្វាយមិនដែលប្រាប់ឲ្យចុះចូលចំពោះបាវបម្រើ ពួកសាវ័កមិនដែលប្រាប់ឲ្យចុះចូលចំពោះពួកអារក្ស ។ល។ និងការស្ដាប់បង្គាប់របស់ទាហានក្នុងជួរកងទ័ពចំពោះអ្នកដែលមានឋានៈខ្ពង់ខ្ពស់ សូមមើល យ៉ូសែបផាស (Josephus) សង្គ្រាមជនជាតិយូដា (Jewish War) ២.៥៦៦, ៥៧៨; នៅក្នុងកណ្ឌ ១ក្លេមិន ៣៧:២ (1Clement 37:2) អំពីគុណកិរិយា និងលោក ហេនរី ចច លីដឌែល (Henry George Liddell) និងលោក រ៉ូប៊ឺត ស្កុត (Robert Scott), វចនានុក្រមក្រិក-អង់គ្លេស (A Greek-English Lexicon) លោកគ្រូ ហេនរី ស្ទើត ចូនស៍ (Henry Stuart Jones) និងលោក រូត័រិក ម៉ាកខិនហ្ស៊ី (Roderick McKenzie, suppl. E. A. Barber, et al. [Oxford: Clarendon, ឆ្នាំ១៩៦៨], ទំព័រ១៨៩៧, ដែលបានផ្ដល់អត្ថន័យទៅលើពាក្យ អ៊ីប៉ូតាសូ (hypotasso [កម្មវាចកៈ] ដែលមានន័យថា "ឲ្យស្ដាប់បង្គាប់")។ ន័យរបស់ពាក្យនេះមិនមានន័យ "ទៅវិញទៅមក" នោះទេ វាតែងតែមានទិសដៅតែមួយជាមួយភស្តុតាងនៃការចុះចូលចំពោះអ្នកមានសិទ្ធិអំណាច។ ដូច្នេះ យើងអាចនឹងសួរថា ហេតុអ្វីបានជាយើងគួរកំណត់អត្ថន័យមួយទៅលើពាក្យ អ៊ីប៉ូតាសសូ នៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ តែមិនមែនយកកន្លែងណាផ្សេងដូច្នេះ? ដូច្នេះហើយ វាហាក់ដូចជាការយល់ច្រឡំពីកណ្ឌគម្ពីរ អេភេសូរ៥:២១ ដើម្បីនិយាយថាវាបង្កប់ន័យចុះចូលទៅវិញទៅមក សូម្បីតែនៅកណ្ឌគម្ពីរ អេភេសូរ ៥:២២-២៤ ក៏យើងឃើញថា ប្រពន្ធមិនត្រូវចុះចូលចំពោះមនុស្សគ្រប់គ្នា ឬប្ដីទាំងអស់នោះឡើយ ប៉ុន្តែត្រូវចុះចូលចំពោះ "ប្ដីរបស់ខ្លួន"—"ការចុះចូល" ដែលសាវ័ក ប៉ុលមានក្នុងចិត្តមិនមែនជាការគិតទូទៅចំពោះអ្នកដទៃទេ ប៉ុន្តែជាការចុះចូលជាក់លាក់ចំពោះសិទ្ធិអំណាចខ្ពស់ជាង។ ប៉ុន្តែ តើកិរិយាសព្ទចុះចូលនៅក្នុងខ២២



50 Crucial Questions.indd 124 7/4/26 2:19 in the afternoon

(មិនថាដោយប្រយោល ឬច្បាស់លាស់) មិនគួរទទួលយកន័យដូច គ្នាដែលវាធ្វើនៅក្នុង៥:២១ ទេឬអី? ការបកស្រាយការចុះចូលចំពោះ គ្នាទៅវិញទៅមកគឺជារឿងធម្មតាណាស់ ពីព្រោះអ្នកបកប្រែសន្មតថា សព្វនាមក្រិក «អិលលាលូស៍» (allelous ដែលមានន័យថា «មួយ ផ្សេងទៀត») ត្រូវតែទៅវិញទៅមកទាំងស្រុង—ពោលគឺវាត្រូវតែមាន ន័យថា «មនុស្សគ្រប់គ្នាចំពោះមនុស្សគ្រប់គ្នា»។ មានអត្ថបទជាច្រើន ដែលពាក្យ អិលលាលូស៍ មានន័យថា «អ្នកគ្រប់គ្នាចំពោះមនុស្សគ្រប់ គ្នា» ប៉ុន្តែនោះមិនមែនជាករណីនៅក្នុងការប្រើប្រាស់របស់វាទាំងអស់ នោះទេ ហើយវាពិតជាមិនចាំបាច់ទទួលយកអត្ថន័យនោះដែរ។ ផ្ទុយ ទៅវិញ វាច្រើនតែមានន័យថា «ដល់អ្នកខ្លះទៀត»។ ជាឧទាហរណ៍ នៅក្នុងកណ្ឌគម្ពីរ វិវរណៈ ៦:៤ បានចែងថា «ដូច្នេះមនុស្សត្រូវសម្លាប់ គ្នា» មានន័យថា «ដូច្នេះអ្នកខ្លះនឹងសម្លាប់អ្នកដទៃ» (មិនមែន «ដូច្នេះ មនុស្សគ្រប់គ្នានឹងសម្លាប់មនុស្សគ្រប់គ្នា» ឬ «ដូច្នេះថាមនុស្សទាំង នោះ ការត្រូវបានសម្លាប់នឹងសម្លាប់គ្នាទៅវិញទៅមក អ្នកដែលកំពុង តែសម្លាប់ពួកគេ» ដែលមិនសមហេតុផល) នៅកណ្ឌគម្ពីរ កាឡាទី ៦:២ «ចូរយកអាសាគ្នាទៅវិញទៅមក» មានន័យថា មិនមែន «អ្នក រាល់គ្នាត្រូវដោះបន្ទុកជាមួយនឹងអ្នកដទៃ» ទេ។ ប៉ុន្តែ «អ្នកខ្លះដែល មានសមត្ថភាពច្រើនគួរជួយទទួលបន្ទុកអ្នកដទៃដែលមិនសូវមាន សមត្ថភាព»។ ហើយនៅក្នុងកណ្ឌគម្ពីរ១កូរិនថូស ១១:៣៣ «ដូច្នេះ បងប្អូនអើយ កាលណាប្រជុំគ្នា ដើម្បីនឹងបរិភោគនោះត្រូវបង្អង់ចាំគ្នា ផង» នេះមានន័យថា «អ្នកណាដែលត្រៀមខ្លួនពីព្រលឹម ត្រូវរង់ចាំ អ្នកឯទៀតដែលយឺត» (លូកា ២:១៥; ១២:១; ២៤:៣២—នៅមាន ឧទាហរណ៍ជាច្រើនដែលយើងមិនទាន់បានចំរាស់ពាក្យនេះទាំង ស្រុង)។ ដូចគ្នានេះដែរនៅក្នុងកណ្ឌគម្ពីរអេភេសូរ ៥:២១ ទាំងបរិបទ ខាងក្រោម និងអត្ថន័យនៃពាក្យអ៊ីប៉ូតាសសូ តម្រូវឲ្យពាក្យ អិលលា លូស៍ នៅទីនេះមានន័យថា «ខ្លះចំពោះអ្នកផ្សេងទៀត» ដូច្នេះ ខគម្ពីរ អាចត្រូវបានកាត់ស្រាយថា «អ្នកដែលស្ថិតនៅក្រោមអំណាចគួរតែ ចុះចូលនឹងអ្នកដទៃក្នុងចំណោមអ្នកដែលមានអំណាចលើពួកគេ»។



50 Crucial Questions.indd 125 7/4/26 2:19 in the afternoon

ដូច្នេះ យោងទៅតាមការបកស្រាយនេះ (ទីពីរ) វាហាក់ដូចជាល្អបំផុតក្នុងការនិយាយថានៅក្នុងកណ្ឌគម្ពីរ អេភេសូរ ៥:២១ សាវ័កប៉ុល កំពុងបញ្ជាមិនឲ្យត្រឹមតែ «ចុះចូលគ្នាទៅវិញទៅមក» ប៉ុន្តែក៏ត្រូវចុះចូលចំពោះសិទ្ធិអំណាចដែលសមស្របផងដែរ។

៥. លោក Wayne Grudem, *Evangelical Feminism and Biblical Truth*, *544-99*។

៦. សូមមើលការស្រាវជ្រាវដែលបានចុះនៅក្នុងកំណត់ចំណាំមុន។

៧. សាក្សីជនជាតិក្រិកដែលសំខាន់បំផុតសម្រាប់អត្ថន័យ «ក្បាល» នៅសម័យរបស់សាវ័កប៉ុលបានមកពីលោកហ្វីលឡូ នៅស្រុកអាឡិចសាន់ឌ្រា (Philo of Alexandria) ដែលពណ៌នាអំពីរូបភាពនៃក្បាលនៅលើដងខ្លួនថាមានតួនាទីជាអ្នកដឹកនាំ៖ «ដូចជាធម្មជាតិបានប្រគល់អធិបតេយ្យភាព [hegemonian] លើដងខ្លួនលើក្បាលនៅពេលធម្មជាតិបានប្រគល់ឲ្យ វាក៏កាន់កាប់បន្ទាយដែលស័ក្តិសមបំផុតសម្រាប់ឋានៈជាស្តេចផងដែរ ដឹកនាំពីទីនោះដើម្បីទទួលបញ្ជាហើយតាំងវាឲ្យខ្ពស់ដោយក្របខណ្ឌទាំងមូល តាំងពីកដល់ជើង តាំងនៅពីក្រោម ដូចជាជើងទម្រក្រោមរូបចម្លាក់ ដូច្នេះ ធម្មជាតិក៏បានប្រទាននូវ [ភាពជាចៅហ្វាយ kratos] ដល់ភ្នែកផង»។ ច្បាប់ពិសេស (Special Laws) ៣.១៨៤។

៨. លោកស្រី Mary Stewart Van Leeuwen, *Gender and Grace: Love, Work, and Parenting in a Changing World* (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៩០), ២៣៨។

៩. នៅពេលយើងសរសេរសំណេរនេះដំបូងសម្រាប់ការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ (*Recovering Biblical Manhood and Womanhood*) សំណេរជាភាសាអង់គ្លេសដកស្រង់មកច្រើនបំផុតចំពោះសំណួរនេះគឺនិក្ខេបបទដោយ៖ លោក J. E. Crouch, *The Origin and Intention of the Colossian Haustafel, Forschungen zur Religion und Literatur des Alten und Neuen Testaments 109* (Göttingen: Vandenhoeck und

Ruprecht, 1972)។ ឧទាហរណ៍នៃការបកប្រែជាក់ស្តែងដែលស្រប គ្នាទៅជាភាសាអង់គ្លេសអាចអាននៅក្នុងសំណេរនេះ។ សម្រាប់ការ ស្រាវជ្រាវបន្ថែមនាពេលថ្មីៗជាភាសាអង់គ្លេសលើប្រធានបទនេះ សូមមើលលោក James P. Hering, The Colossian and Ephesian Haustafeln in *Theological Context: An Analysis of Their Origins, Relationship, and Message*, American University Studies, ser. 7, Theology and Religion ២៦០ (New York: P. Lang, ឆ្នាំ២០០៧); លោក M. Y. McDonald, "Reading the New Testament Household Codes in Light of New Research on Children and Childhood in the Roman World," Studies in Religion ៤១, លេខ៣ (ឆ្នាំ២០១២)៖ ៣៧៦-៨៧។

១០. ពាក្យជាភាសាក្រិក «ប្រូសស្តេតធីស» (prostatis) មិនមែនមាន ន័យថា «អ្នកដឹកនាំ» នោះទេ ប៉ុន្តែមានន័យថា «អ្នកជំនួយ»។ នៅ ក្នុងព្រះគម្ពីរវាមាននៅទីនេះប៉ុណ្ណោះ។

១១. អ្នកចូលរួមខ្លះមិនគាំទ្រចំពោះទស្សនៈទំនាយនៃកណ្ឌសញ្ញាថ្មីទៅលើ ការស្តារឡើងវិញនូវភាពបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរ (*Recovering Biblical Manhood and Womanhood*)។ ពួកគាត់នឹង លើកឡើងថាអំណោយទាននៃការទាយនៅក្នុងព្រះគម្ពីរសញ្ញាថ្មី មិន មានការបន្តមកដល់សព្វថ្ងៃនេះទេ ពីព្រោះវាជាផ្នែកមួយដែលពិសេស ក្នុងអំឡុងពេលនៃការបើកសម្តែងនៅក្នុងប្រវត្តិសាស្ត្រ និងមានរួម ទាំងពាក្យពេចន៍ដែលមិនមានការខុសឆ្គងដោយសារពាក្យពេចន៍នោះ មានអំណាចពឹងអាងលើព្រះជាម្ចាស់ផ្ទាល់។ ពួកគាត់នឹងលើកឡើង ថា មនុស្សស្រីអាចថ្លែងទំនាយបាននៅក្នុងអត្ថន័យនេះ ប៉ុន្តែមិនអាច បង្រៀនបានទេដោយសារវាពាក់ព័ន្ធទៅនឹងសិទ្ធិអំណាច ដោយជាប់ ទៅនឹងពាក្យពេចន៍ច្បាស់លាស់ មិនមែនទៅនឹងបុគ្គល ឬក៏ការកាត់ ស្រាយក្នុងលក្ខណៈបែបជាការបង្រៀនឡើយ។



50 Crucial Questions.indd 127 7/4/26 2:19 in the afternoon

១២. ការយល់ដឹងចំពោះទំនាយនៅក្នុងកណ្ឌគម្ពីរសញ្ញាថ្មីនេះ គឺបានអភិវឌ្ឍ និងការពារនៅក្នុងសៀវភៅរបស់លោក វ៉េន ហ្គ្រូដឹម (Wayne Grudem), អំណោយទាននេះការទស្សន៍ទាយនៅក្នុងកណ្ឌគម្ពីរសញ្ញាថ្មី និងបច្ចុប្បន្ន *The Gift of Prophecy in the New Testament and Today* (Wheaton, IL: Crossway, ឆ្នាំ១៩៨៨); លោក Graham Houston, *Prophecy: A Gift for Today?* (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៩); លោក ឌី.អេ ខាសុន D. A. Carson, *Showing the Spirit: A Theological Exposition of* 1 *Corinthians* 12–14 (Grand Rapids, MI: Baker, ឆ្នាំ១៩៨៧) ទស្សនៈនៃទំនាយក្នុងព្រះគម្ពីរសញ្ញាថ្មីនេះ គឺជាទស្សនៈមួយដែលប្រកាន់យកដោយអ្នកនិពន្ធទាំងឡាយនៅក្នុងសៀវភៅនេះ (Recovering Biblical Manhood and Womanhood) ប៉ុន្តែអ្នកចូលរួមខ្លះនៅក្នុងសៀវភៅការស្តារឡើងវិញនូវភាពជាបុរស និងភាពជាស្ត្រីស្របតាមព្រះគម្ពីរប្រកាន់យកនូវទស្សនៈខុសគ្នា។

១៣. សូមមើលកំណត់ចំណាំ១១ និង១២។

១៤. សូមមើលលោក Wayne Grudem, "Prophecy, Yes, but Teaching, No: Paul's Consistent Affirmation of Women's Participation without Governing Authority," Journal of the Evangelical Theological Society ៣០, លេខ ១ (ខែមីនា ឆ្នាំ១៩៨៧): ១១-២៣។

១៥. លោកស្រី Ruth Tucker, *Guardians of the Great Commission: The Story of Women in Modern Missions* (Grand Rapids, MI: Zondervan, ឆ្នាំ១៩៨៨).

១៦. ក្នុងសៀវភៅដូចគ្នា, ៣៨។

១៧. ក្នុងសៀវភៅដូចគ្នា, ៤៧។

១៨. ក្នុងសៀវភៅដូចគ្នា, ៨៣។



50 Crucial Questions.indd 128 7/4/26 2:19 in the afternoon

១៩. លោក A. J. Gordon, "The Ministry of Women," Gordon Conwell Monograph ៦១ (South Hamilton, MA: Gordon Conwell Theological Seminary, n.d.), ១០។ បានបោះពុម្ពផ្សាយដំបូងនៅក្នុង Missionary Review of the World, n.s., ៨, លេខ ១២ (ខែធ្នូ ឆ្នាំ១៨៩៤)។
២០. លោកបណ្ឌិត និងលោកស្រី Howard Taylor, *Hudson Taylor and the China Inland Mission: The Growth of a Work of God* (London: The Religious Tract Society, ឆ្នាំ១៩៤០), ៣៩៧-៩៨។
២១. លោកស្រី Tucker, Guardians of the Great Commission, ១១៧។
២២. លោក John White, *When the Spirit Comes with Power: Signs and Wonders among God's People* (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៨), ១២៨។
២៣. *Thesaurus Linguae Graecae* (Irvine: University of California at Irvine, ឆ្នាំ១៩៨៧), Pilot CD-ROM #C.
២៤. លោក Plutarch's Lives of Illustrious Men, trans. លោក John Dryden (New York: John Wurtele Lovell, n.d.), ៣:៣៥៩។
២៥. Index discipulorum ១២៥។ ១៩-២០។
២៦. លោក John Chrysostom, *Homilies on the Epistle of St. Paul the Apostle to the Romans 31.7*, នៅក្នុង *A Select Library of the Nicene and Post-Nicene Fathers of the Christian Church*, កែសម្រួលដោយ៖ លោក Philip Schaff, ភាគទី១, លេខ១១ (Grand Rapids, MI: Eerdmans, ឆ្នាំ១៩៥៦), ៥៥៥។
២៧. យើងមានការងឿងឆ្ងល់អំពីការពិតដែលថានៅក្នុងបរិបទដែលជិតនៃការដកស្រង់របស់យូនាស ក្រុងអេភេសូរក៏កំណត់ថាព្រីស៊ីលឡា



50 Crucial Questions.indd 129 7/4/26 2:19 in the afternoon

(Prisca) ដែលត្រូវបានលើកឡើងនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១៦:៣ ជាបុរស ទោះជាយើងដឹងពីគម្ពីរសញ្ញាថ្មីថានាងជាស្ត្រីក៏ដោយ។

២៨. លោក Origen, *Commentaria in Epistolam B. Pauli ad Romanos, in Origenis: Opera Omnia*, លេខ១៤នៃ Patrologia Graeca, បានកែសម្រួលដោយ។ លោកJ. P. Migne, col. ១២៨៩។ សំណេរនេះត្រូវបានរក្សាទុកដោយការបកប្រែជាភាសាឡាតាំងដោយ៖ លោក Rufinus (ប្រហែលឆ្នាំ៣៤៥-៤១០ក្រោយគ.ស)។

២៩. លោក A. T. Robertson, *A Grammar of the Greek New Testament in the Light of Historical Research* (New York: Hodder and Stoughton, ឆ្នាំ១៩១៤), ១៧១-៧៣។

៣០. បើទោះបីជា យូនាស ជាឈ្មោះធម្មតារបស់ស្ត្រីជាភាសាឡាតាំង ហើយនោះត្រូវបានបញ្ចុះបញ្ចូលដោយការបកប្រែមួយចំនួនចំពោះការបកប្រែឈ្មោះថា យូនាស។

៣១. សំណង់ប្រយោគនៅក្នុងភាសាក្រិកប្រើគុណនាម episēmos (“មានកេរ្តិ៍ឈ្មោះ”) ជាមួយនឹងកន្សោមសម្រាប់ “ពួកសាវក” នៅក្នុងករណីកម្មបទមិនផ្ទាល់ ។ តាមរយៈការស្រាវជ្រាវយ៉ាងទូលំទូលាយនៅក្នុងការសរសេរជាភាសាក្រិកដ៏អស្ចារ្យលោក ម៉ៃខល ប្បូរី (Michael Burer) បានបង្ហាញថាការសង់ប្រយោគនេះស្ទើរតែតែងតែមានន័យថា “មានកេរ្តិ៍ឈ្មោះ” (នៅពេលដែលមនុស្សត្រូវបានគេដាក់ឈ្មោះនៅក្នុងករណីកម្មបទមិនផ្ទាល់) ចំណែកឯការនិយាយថានរណាម្នាក់ដែល “មានកេរ្តិ៍ឈ្មោះក្នុងចំណោម” ក្រុមមួយ (ជាកម្មសិទ្ធិនៅក្នុងក្រុម) អ្នកនិពន្ធជនជាតិក្រិកបានប្រើករណីជាប់ទំនាក់ទំនងជាប្រចាំ។ សូមមើលលោកម៉ៃខល ប្បូរី, “Ἐπίσημοι ἐν τοῖς ἀποστόλοις នៅក្នុងកណ្ឌគម្ពីររ៉ូម១៦:៧មានន័យថា៖ “ដែលមានកេរ្តិ៍ឈ្មោះក្នុងពួកសាវក៖ ការការពារបន្ថែម និងភស្តុតាងថ្មី” ទិនានុប្បវត្តិនៃសមាគមទេវសាស្ត្រផ្សាយដំណឹងល្អ (‘Well Known to the



50 Crucial Questions.indd 130 7/4/26 2:19 in the afternoon

Apostles': Further Defense and New Evidence," JETS ៥៨), លេខ៤ (ឆ្នាំ២០១៥): ៧៣១-៥៥ ។

៣២. លោក N. G. L. Hammond និងលោក H. H. Scullard, eds., Oxford Classical Dictionary, បានកែសម្រួលជាលើកទី២ (Oxford: Clarendon, ឆ្នាំ១៩៧០), ១១៣៩។

៣៣.លោក Gerald Sheppard, "A Response to Ray Anderson," TSF Bulletin៩, លេខ៤ (ខែមិនា–ឧសភា ឆ្នាំ១៩៨៦)៖ ២១។

៣៤. លោកស្រី Karen J. Torjesen, "Sexuality, Hierarchy and Evangelicalism," TSF Bulletin ១០, លេខ៤ (ខែមីនា-មេសា ឆ្នាំ១៩៨៧)៖ ២៦-២៧។

៣៥. "Gay Rights Resolution Divides Membership of Evangelical Woman's Caucus," Christianity Today (ថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៨៦)៖ ៤០-៤៣។

៣៦. លោក Paul Jewett, *Man as Male and Female: A Study in Sexual Relationships from a Theological Point of View* (Grand Rapids, MI: Eerdmans, ឆ្នាំ១៩៧៥), ១៧៨។

៣៧. លោក Paul Jewett, "An Overlooked Study: John Boswell on Homosexuality," Reformed Journal ៣៣ លេខ១ (ខែមករា ឆ្នាំ១៩៨៣)៖ ១៧។

៣៨. លោកស្រី Robin Scroggs, *The New Testament and Homosexuality: Contextual Backgrounds for Contemporary Debate* (Philadelphia: Fortress, ឆ្នាំ១៩៨៣), ១២៩។

៣៩. លោក Paul Jewett, review of *The New Testament and Homosexuality: Contextual Backgrounds for Contemporary Debate*, ដោយ៖ លោកស្រី Robin Scroggs, Interpretation ៣៩, លេខ២ (ខែមេសា ឆ្នាំ១៩៨៥)៖ ២១០។

៤០. សម្រាប់លោក Jim Wallis, សូមមើល Leigh Jones, "Jim Wallis Announces Support for Same-Sex Marriage,"



50 Crucial Questions.indd 131 7/4/26 2:19 in the afternoon

World, ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៣, http://www.worldmag.com/2013/04/jim_wallis_announces_support_for_same_sex_marriage. For Tony Cam- polo and David Neff, see Warren Cole Smith, "Jockeying for Position on Same-Sex Marriage," World, June 10, 2015, http://www.worldmag.com/2015/06/jockeying_for_position_on_same_sex_marriage.

៤១. លោក Nicholas Wolterstorff, "Hearing the Cry," in Women, Authority, and the Bible, កែសម្រួលដោយ៖ Alvera Mickelsen (Downers Grove, IL: InterVarsity Press, ឆ្នាំ១៩៨៦), ២៨៩។

៤២. លោក Thomas B. Stoddard, "Gay Adults Should Not Be Denied the Benefits of Marriage," Minneapolis Star-Tribune, ថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៨៩ ១១A។

៤៣. លោក Emil Brunner, *Das Gebot und die Ordnungen*: *Entwurf einer protestantisch- theologischen ethik* (Tübingen: J. C. B. Mohr/Paul Siebeck, ឆ្នាំ១៩៣៣), ៣៥៨។

៤៤. លោក Otto Piper, *Christian Ethics* (London: Thomas Nelson and Sons, ឆ្នាំ១៩៧០), ២៩៩។

៤៥. សូមមើលជំពូកទី១ក្នុង *Recovering Biblical Manhood and Womanhood*, ទំព័រ៤៤-៤៥, ៥០-៥២។

៤៦. លោកស្រី Elisabeth Elliot, "Virginity," លោកស្រី Elisabeth Elliot Newsletter, ខែមីនា/មេសា ឆ្នាំ១៩៩០, ២-៣។

៤៧. សម្រង់សម្ដីទាំងនេះដកស្រង់មកពី *Danvers Statement of the Council on Biblical Manhood and Womanhood.* សូមមើលឧបសម្ព័ន្ធ។



50 Crucial Questions.indd 132 7/4/26 2:19 in the afternoon

៤៨. លោក Gretchen Gaebelein Hull, *Equal to Serve: Men and Women in the Church and Home* (Old Tappan, NJ: Fleming H. Revell, ឆ្នាំ១៩៨៧), ១៨៨-៨៩។



50 Crucial Questions.indd 133 7/4/26 2:19 in the afternoon

# លិបិក្រមតាមព្រះគម្ពីរ


***លោកុប្បត្តិ***
១:២ ១១៧
១:២៦ ១១៨
២:១៦ ១១៧
២:១៨ ១១៧, ១១៨
២:១៩ ១០០
២:២៣ ២១
២:២៤ ៣៨, ៤១
៣:១ ១១៧
៣:៩ ៣៤

***និក្ខមនំ***
១៥:២០ ៥៧

***ពួកចៅហ្វាយ***
៤:៤ ៥៧
៤:៩ ៥៧
៥:២៤ ៥៧

***១សាំយូអែល***
១៩:២៣ ៥៨

***២ពង្សាវតារក្សត្រ***
២២:១៤ ៥៧

***ទំនុកតម្កើង***
៩៦:៣ ៧០

***សុភាសិត***
១៣:២៤ ៧៤
៣១:២៦ ៤៨

***យេរេមា***
២៣:៣២ ៧២

***ដានីយ៉ែល***
៣:១០ ១១៨

***ម៉ាថាយ***
៥:២៨ ៤៣
៥:៤១ ៣៩
៧:១២ ៤៣
៧:២២ ៥៨
៨:៩ ៧៣, ៧៤
១០:២ ៨០
១១:១៤ ៨០
១២:៣៦ ៤៣
១៥:៣ ៤៣
១៨:១៧ ៧៤, ៧៦
១៩:៨ ៣៦, ៤៣
១៩:២៨ ៨២
២០:២៥ ៧៤
២១:៣១ ៤៣
២៤:៣២ ៤៩

***ម៉ាកុស***
១:២៧ ៧៤

***លូកា***
១:៥ ៨០
២:១៥ ២៩, ១២៥
២:៣៦ ៥៧
២:៥១ ២៨, ១២៣
១០:១៧ ២៨, ១២៣





50 Crucial Questions.indd 135 7/4/26 2:19 in the afternoon

១៣:១៦ ៤២
១៦:២ ៧៤
២២:២៦ ៣៣, ៣៣, ៦

**យ៉ូហាន**
១:២៣ ៨០

**កិច្ចការ**
១:១៥ ៨២
២:១៧ ៥២, ៦៨, ៧
៤:១៣ ៨៥
៤:១៩ ១១៨
៥:២៩ ២៦
១៤:១៤ ៨២
១៥:២២ ៧៦, ៨០
១៨:២ ៨៥
១៨:១៨ ៨២, ៨៥
១៨:២៦ ៤៦, ៤៩, ៨៥, ៨៥, ៩៤, ៧
២០:២៧ ៨៦
២០:៣០ ២៦
២១:៤ ៥១

**រ៉ូម**
១:២៤ ៥៥
១:២៦ ៨៩, ៩៧
៨:១៧ ៣៥
១០:១៥ ៧២
១២:១ ៩២
១២:៦ ៥១
១២:១០ ១០១
១៣:១ ២៦, ២៨, ៧៣, ១២៣
១៣:៤ ៧៤
១៦:១ ៤៦, ៨៥
១៦:៣ ៤៦, ៦៩, ៧៩, ៨១, ៨៦, ១៣០
១៦:៧ ៧៧, ៧៨, ៧៨, ៧៨, ៧៩, ៨១, ៩
១៦:១២ ៨១

**១កូរិនថូស**
៤:៦ ៤៩
៥:១ ៧៤
៧:២ ១០២
៧:៣ ១០១, ១០
៧:៣៧ ៧៤
៩:១ ៨២
១១:២ ២២, ១១០, ១១៨
១១:៣ ៥៣
១១:៥ ៤៨, ៥១, ៥២, ៥៣, ៥៣, ៥៣, ៥៤, ៥៤, ៩៤, ៧
១១:៦ ៥៣
១១:៧ ៦៦, ១១៧, ១១៧
១១:១៣ ៦៤, ៦៥, ៨
១១:១៤ ៤៩
១១:១៨ ១០៧
១១:៣៣ ២៩, ១២៥
១២:៧ ១១៩
១២:២៨ ៥១
១៣:២ ៥៨
១៤:៣ ៥១
១៤:២៨ ៧១
១៤:២៩ ៥១
១៤:៣០ ៥១
១៤:៣១ ៤៨
១៤:៣៣ ៥៤
១៤:៣៤ ៥៣, ៥៣, ៥៣, ៨
១៤:៣៥ ៥៣, ៥៣
១៤:៣៦ ៥១
១៥:៧ ៨២
១៥:២៧ ២៨, ១២៣
១៥:២៨ ២៨, ១២៣
១៦:១៥ ២៨, ១២៣
១៦:១៩ ៤៦, ៨៦




50 Crucial Questions.indd 136 7/4/26 2:19 in the afternoon

**២កូរិនថូស**

| | |
|---|---|
| ៤:២ | ១០៧ |
| ៥:១៤ | ១១០ |
| ៨:២៣ | ៨២ |
| ១០:៨ | ៧៤, ៨៣ |

**កាឡាទី**

| | |
|---|---|
| ១:១ | ៨២ |
| ១:១៩ | ៨២ |
| ៣:២៨ | ៥៥, ៥៥, ៥៥, ៥៦, ៥៦, ១១៨, ១១៨, ៨ |
| ៥:១៣ | ១០២ |
| ៦:២ | ២៩, ១២៥ |

**អេភេសូរ**

| | |
|---|---|
| ១:២២ | ២៨, ១២៣ |
| ៤:១១ | ៥១, ៦៨ |
| ៥:១៨ | ៩៣ |
| ៥:២១ | ២៤, ២៥, ២៨, ២៨, ២៨, ២៨, ២៩, ២៩, ២៩, ១១៨, ១១៨, ១២២, ១២៣, ១២៣, ១២៤, ១២៥, ១២៦, ៦ |
| ៥:២២ | ២៨, ២៩, ៤០, ៧៣, ១១១, ១២៤, ១២៤ |
| ៥:២៣ | ៣០, ៣០, ៣១, ៣២, ៦ |
| ៥:២៤ | ២៨, ១២៤ |
| ៥:២៥ | ៧៥ |
| ៥:២៩ | ៧៥ |
| ៥:៣១ | ២១, ៣៨ |
| ៦:១ | ៧៣ |
| ៦:៩ | ៣៧ |

**ភីលីព**

| | |
|---|---|
| ១:១ | ៤៥ |
| ២:៣ | ១០២ |
| ២:២៥ | ៨២ |
| ៣:១៥ | ១០៨ |
| ៤:២ | ៤៥ |
| ៤:៣ | ៦៩ |

**កូឡុស**

| | |
|---|---|
| ៣:១៦ | ៤៩ |
| ៣:១៨ | ២៥, ២៨, ៤០, ៧៣, ១១១, ១១៨, ១១៨, ១២៤ |
| ៤:១ | ៣៧ |

**១ថែស្សាឡូនីច**

| | |
|---|---|
| ១:១ | ៨០ |
| ២:៦ | ៨២ |
| ៥:១២ | ៧៣ |
| ៥:២០ | ៥១ |

**២ថែស្សាឡូនីច**

| | |
|---|---|
| ២:១ | ៥២ |

**១ធីម៉ូថេ**

| | |
|---|---|
| ១:៣ | ៨៥ |
| ១:១០ | ៣៨ |
| ២:៨ | ៤៩, ១១១ |
| ២:៩ | ៦៣ |
| ២:១១ | ២២, ៨៥, ១១៨, ១១៨, ១១៩ |
| ២:១២ | ៤៥, ៤៦, ៤៧, ៤៨, ៤៩, ៥០, ៦៨, ៦៩, ៧៦, ៨៤, ៨៥, ៨៦, ៩៤, ១១៧ |
| ២:១៣ | ៦៤, ៨៣, ៨៤, ៨៤, ៩ |
| ២:១៤ | ៥៨, ៥៩, ៦០ |
| ៣:២ | ២៥, ៤៥, ៥១ |
| ៣:៥ | ៧៣ |




50 Crucial Questions.indd 137 7/4/26 2:19 in the afternoon

៥:១៧ ៥០
៥:២០ ២៦
៦:១ ៣៧, ៣៩

**២ធីម៉ូថេ**
១:៥ ៤៨
៣:១៦ ១០៧
៤:១៩ ៨៦

**ទីតុស**
១:៥ ១១៩
២:៣ ៤៨, ៨៥, ១១៨
២:៥ ២៥, ២៨, ១២៤
២:៩ ២៨, ១២៤
៣:១ ២៨, ៧៣, ១២៣

**ភីលេម៉ូន**
១:១៦ ៣៦, ៣៧

**ហេព្រើរ**
៥:៨ ៤៩
១២:៩ ២៨, ១២៤
១៣:៧ ៧៣
១៣:១៧ ២៦, ៣៣

**យ៉ាកុប**
៤:៧ ២៨, ១២៤

**១ពេត្រុស**
២:៩ ៧៦
២:១៣ ២៨, ៤០, ៧៣, ១២៣
២:១៨ ២៨, ៧៣, ១២៤
៣:១ ២៤, ២៥, ៤៩, ៥៦, ៧៣, ១១១, ១១៨, ១១៨
៣:៣ ៦៣
៣:៧ ២៧, ៤៧, ៧៥
៣:២២ ២៨, ១២៣
៥:៥ ២៨, ១២៣
៥:១២ ៨០

**២ពេត្រុស**
៣:១៦ ១០៧

**វិវរណៈ**
១:៦ ៧៦
៦:៤ ២៩, ១២៥
២១:១៤ ៨២


50 Crucial Questions.indd 138 7/4/26 2:19 in the afternoon